ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភូមិវិទ្យា

១២





គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# ភូមិវិទ្យា

## ថ្នាក់ទី ១២

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក អេង វ៉ាត់ | លោក ស៊ុន ណាត្រី |
| | លោក ប៉ុល ស៊ិទ្ធ | លោក ឌី ឆុំខឿន |
| **អ្នកខាយអត្ថបទ** | លោក សេង តុងបុត្តា | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក លឹម ហ៊ិន | |
| **អ្នករចនាទំព័រ** | លោក ហាក់ វណ្ណថា | |
| **គណៈកម្មការពិនិត្យ** | លោកស្រី ពន់ ជា | លោក ប្រាក់ សោភ័ណ |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១៤៩៣ អយក.ប្រក. ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-001-377

# អារម្ភកថា

សៀវភៅភូមិវិទ្យាថ្នាក់ទី 12 នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី 2009 របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាថ្មី មុខវិជ្ជា ភូមិវិទ្យា យើងបានរៀបចំតាក់តែងទៅតាមលំដាប់លំដោយនៃជំពូកនិងតាមមេរៀននីមួយៗ ។

ខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះនឹងជួយប្អូនៗឱ្យមានចំណេះដឹង និងបានស្វែងយល់ពីបម្រែបម្រួលប្រជាសាស្ត្រ ពីនគរូបនីយកម្មនិងស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា ហើយបានដឹងពីមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចសំខាន់ៗនៅលើពិភពលោកនិងរបៀបគ្រប់គ្រង ព្រមទាំងដឹងពីការរីកចំរើនរបស់ប្រទេសមហាអំណាចមួយចំនួននៅលើពិភពលោកដូចជា សហរដ្ឋអាមេរិក ប្រទេសជប៉ុន និងសហភាពអឺរ៉ុប ។

គ្រប់មេរៀនដែលមាននៅក្នុងសៀវភៅនេះគឺមានទម្រង់ដូចៗគ្នាទាំងអស់ ការកំណត់វត្ថុបំណងនៃមេរៀនសម្រាប់ឱ្យប្អូនៗដឹងពីអ្វីដែលត្រូវសិក្សានៅក្នុងមេរៀននីមួយៗ ពិសេសនៅចុងបញ្ចប់នៃជំពូកនីមួយៗមានតេស្តបញ្ចប់ជំពូកសម្រាប់វាយតម្លៃលើចំណេះដឹងនៅពេលរៀនចប់ជំពូកនីមួយៗ ។

តាមរយៈខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅនេះ ប្អូនៗនឹងទទួលបាននូវចំណេះដឹងបំណិន ឥរិយាបថតាមរយៈការសង្កេតរូបភាពដ្យាក្រាម តារាង អត្ថបទមេរៀន សំណួរ ការបញ្ចេញមតិយោបល់ ការពិភាក្សាជាដៃគូ ឬជាក្រុមនិងតាមការសិក្សាស្រាវជ្រាវជាដើម ។ ជាមួយនេះដែរ ការរៀបចំសៀវភៅនេះ ក៏មានការចូលរួមផ្តល់យោបល់កែលំអពីសំណាក់លោកគ្រូ អ្នកគ្រូនៅតាមបណ្តាខេត្ត ក្រុងមួយចំនួនផងដែរ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅភូមិវិទ្យាថ្នាក់ទី 12 នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាមិនខាន។ ទន្ទឹមគ្នានេះដែរ គណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលម្អពីសំណាក់លោកគ្រូ អ្នកគ្រូ និងប្រិយមិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ជំពូកទី 1 : លក្ខខណ្ឌសង្គមកម្ពុជា ........ 1
1. ទម្រង់ប្រជាសាស្ត្រកម្ពុជា ........ 2
2. បម្លាស់លំនៅនៃប្រជាជនកម្ពុជា ........ 12
ជំពូកទី 2 : អភិវឌ្ឍន៍ប្រជាជនមិនស្មើគ្នា ........ 19
1. វិសមភាពចំពោះសុខភាព ........ 20
2. វិសមភាពចំពោះការអប់រំ ........ 28
3. វិសមភាពនៃការប្រើប្រាស់សេវាមូលដ្ឋាន ........ 36
ជំពូកទី 3 : សេដ្ឋកិច្ចកម្ពុជា ........ 45
1. កសិកម្មកម្ពុជា ........ 46
2. ឧស្សាហកម្មកម្ពុជា ........ 54
3. គមនាគមន៍កម្ពុជា ........ 62
4. ពាណិជ្ជកម្មកម្ពុជា ........ 70
5. ទេសចរកម្ពុជា ........ 78
6. បញ្ហាមីននៅកម្ពុជា ........ 86
ជំពូកទី 4 : នគរូបនីយកម្មនៅកម្ពុជា ........ 95
1. លក្ខខណ្ឌប្រវត្តិសាស្ត្រនៃការអភិវឌ្ឍទីក្រុង ........ 96
2. សេដ្ឋកិច្ចតំបន់និងការបែងចែកប្រភេទខេត្តក្រុង ........ 102
3. កំណើននគរូបនីយកម្មនិងបញ្ហាបរិស្ថាន ........ 112
ជំពូកទី 5 : មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចពិភពលោក ........ 121
1. មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយ ........ 122
2. អំណាចសេដ្ឋកិច្ចពិភពលោក ........ 126
ជំពូកទី 6 : សហរដ្ឋអាមេរិក ........ 133
1. ប្រព័ន្ធសេដ្ឋកិច្ច រដ្ឋបាល និងនយោបាយសហរដ្ឋអាមេរិក ........ 134
2. សហរដ្ឋអាមេរិកគ្រប់គ្រងលំហ ........ 140
3. ប្រជាជនសហរដ្ឋអាមេរិក ........ 148
4. លំហសេដ្ឋកិច្ចសហរដ្ឋអាមេរិក ........ 156
ជំពូកទី 7 : ប្រទេសជប៉ុន ........ 165
1. គ្រឹះនៃមហាអំណាចជប៉ុន ........ 166
2. ជប៉ុនដណ្តើមទីផ្សារពិភពលោក ........ 174
ជំពូកទី 8 : សហភាពអឺរ៉ុប ........ 183
1. តំបន់រៀបចំតាមលំដាប់និងតំបន់កំពុងកសាង ........ 184
2. អានុភាពសេដ្ឋកិច្ចសហភាពអឺរ៉ុប ........ 190
3. នានាភាពនៃលំហសេដ្ឋកិច្ចសហភាពអឺរ៉ុប ........ 198

# ជំពូកទី 1 លក្ខណសង្គមកម្ពុជា




ប្រទេសកម្ពុជាស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ ចន្លោះខ្សែស្របទី 10° និងទី 15° នៃរយៈទទឹងខាងជើងនិងចន្លោះខ្សែបណ្ដោយទី 102° និងទី 108° នៃរយៈបណ្ដោយខាងកើត មានផ្ទៃដី 181 035km² គឺមានទំហំតូចជាងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសព្រុយណេ សិង្ហបុរី និងទីម័រខាងកើត ។

ប្រទេសកម្ពុជាមានរាជធានីចំនួន 1 គឺរាជធានីភ្នំពេញ មានខេត្តចំនួន 25 ស្រុកចំនួន 159 ខណ្ឌចំនួន 12 ក្រុងចំនួន 26 ឃុំចំនួន 1 417 សង្កាត់ចំនួន 204 និងភូមិចំនួន 14 073 (ចំនួនភូមិផ្លូវការរបស់ក្រសួងមហាផ្ទៃ 13 852 ភូមិ) ។ តាមលទ្ធផលជំរឿនចុងក្រោយនាខែមីនា ឆ្នាំ 2008 ប្រជាជនកម្ពុជាមានចំនួនសរុប 13 395 682 នាក់ បច្ចុប្បន្នមានប្រហែល 15 458 332 នាក់ (ឆ្នាំ 2014) ។ ចំនួននេះគឺតិចជាងច្រើន បើធៀបទៅនឹងចំនួនប្រជាជននៃបណ្ដា ប្រទេសនៅអាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសឡាវ ព្រុយណេ សិង្ហបុរី និងទីម័រខាងកើត ។

ចាប់តាំងពីទសវត្សរ៍ឆ្នាំ 1970 មក ស្ថានភាពប្រជាជនកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង ។ តើមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យស្ថានភាពប្រជាជនកម្ពុជាប្រែប្រួលខ្លាំងដូច្នេះ ?

# 1 ទម្រង់ប្រជាសាស្ត្រកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយពីទម្រង់ បម្រែបម្រួលប្រជាសាស្ត្រកម្ពុជា និងមូលហេតុដែលនាំឱ្យមានបម្រែបម្រួលនេះ ។

ទម្រង់ប្រជាសាស្ត្រកម្ពុជារួមមាន ដង់ស៊ីតេប្រជាជន អត្រាភេទ ទម្រង់តាមភេទនិងអាយុ ប្រជាជនទីប្រជុំជន ប្រជាជនជនបទ ប្រជាជនសកម្មនិងក្រុមទន់ខ្សោយ ។ ទម្រង់ប្រជាសាស្ត្រនេះតែងតែប្រែប្រួលខុសៗគ្នាតាមសម័យកាលនីមួយៗអាស្រ័យទៅតាមបម្រែបម្រួលនៃស្ថានភាពសង្គម សេដ្ឋកិច្ច នយោបាយ កម្រិតអភិវឌ្ឍន៍ផ្នែកវេជ្ជសាស្ត្រ និងវប្បធម៌របស់ប្រទេស ។

## 1. ដង់ស៊ីតេនិងលទ្ធភាពបង្កកំណើតនៃប្រជាជនកម្ពុជា

### 1.1. ប្រជាជនកម្ពុជា

យោងតាមការធ្វើជំរឿនរបស់ក្រសួងផែនការចាប់ពីម៉ោង 00 : 00 នាថ្ងៃទី 3 ដល់ថ្ងៃទី 13 ខែ មីនា ឆ្នាំ 2008 ប្រជាជនកម្ពុជាមានចំនួនសរុប 13 395 682 នាក់ ក្នុងនោះប្រុសមានចំនួន 6 516 054 នាក់ និងស្រីចំនួន 6 879 628 នាក់ (51.36%) ហើយអត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន 1.54% ។ ទិន្នន័យខាងលើនេះ បង្ហាញឱ្យឃើញពីកំណើនប្រជាជនកម្ពុជាគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងលទ្ធផលជំរឿនឆ្នាំ 1998 ប្រជាជនកម្ពុជាមានចំនួនសរុប 11 437 656 នាក់ ។ ជំរឿនឆ្នាំ 1962 ដែលជាជំរឿនចុងក្រោយនាសម័យសង្គមរាស្ត្រនិយម ប្រជាជនកម្ពុជាមានចំនួន 5 751 000 នាក់ ។ ជំរឿនឆ្នាំ 1931 មានចំនួន 2 803 000 នាក់ និងឆ្នាំ 1921 មានចំនួន 2 402 585 នាក់ ។ របាយប្រជាជននៅតាមតំបន់ធំៗទាំងបួន ក៏ដូចតាមបណ្តាខេត្តទាំង 23 និងរាជធានីដែរ គឺមិនស្មើគ្នាទេ ។

- **តំបន់វាលរាប** មានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង ត្បូងឃ្មុំ ព្រៃវែង និង តាកែវ ប្រមូលផ្តុំប្រជាជនចំនួន 6 547 953 នាក់ស្មើនឹង 48.88% ។
- **តំបន់ទន្លេសាប** មានខេត្តកំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ ឧត្តរមានជ័យ និងប៉ៃលិន ប្រមូលផ្តុំប្រជាជនចំនួន 4 356 705 នាក់ស្មើនឹង 32.52% ។

- **តំបន់ឆ្នេរសមុទ្រ** មានខេត្តព្រះសីហនុ កំពត កែប និងកោះកុង ប្រមូលផ្តុំប្រជាជនចំនួន 960 480 នាក់ ស្មើនឹង 7.17% ។
- **តំបន់ខ្ពង់រាបនិងតំបន់ភ្នំ** មានខេត្តកំពង់ស្ពឺ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ ប្រមូលផ្តុំប្រជាជនចំនួន 1 530 544 នាក់ស្មើនឹង 11.43% ។

តំបន់វាលរាបនិងតំបន់ទន្លេសាប មានប្រជាជនរស់នៅកុះករជាងតំបន់ឆ្នេរសមុទ្រនិងតំបន់ខ្ពង់រាបនិងភ្នំ ដោយសារតំបន់នេះមានលក្ខខណ្ឌប្រសើរដល់ការរស់នៅ ប៉ុន្តែបើធៀបនឹងឆ្នាំ 1998 ឃើញថាអត្រាភាគរយមានការថយចុះបន្តិចនៅតំបន់វាលរាប ហើយតំបន់ទន្លេសាបមានការកើនឡើងបន្តិច ។ រីឯតំបន់ភ្នំនិងខ្ពង់រាប ចំនួនប្រជាជនកើនឡើងពី 10.39% នៅឆ្នាំ 1998 ទៅ 11.43% នៅឆ្នាំ 2008 ។

កំពង់ចាម ជាខេត្តដែលមានប្រជាជនរស់នៅច្រើនជាងគេគឺមានចំនួន 1 679 992 នាក់ បច្ចុប្បន្នខេត្តនេះត្រូវបានបែងចែកជាពីរខេត្តគឺ ខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំ ។ បន្ទាប់ មកគឺរាជធានីភ្នំពេញដែលមានប្រជាជនរស់នៅចំនួន 1 327 615 នាក់ (កាលពីឆ្នាំ 1998 ចំណាត់ថ្នាក់ ទី 3 បន្ទាប់ពីកំពង់ចាមនិងកណ្តាល) ។ ឯខេត្តកណ្តាលដែលកាលពីឆ្នាំ 1998 មានចំណាត់ថ្នាក់លេខ 2 ខាងចំនួនប្រជាជនបានប្តូរមកចំណាត់ថ្នាក់លេខ 3 វិញ ក្នុងចំនួនប្រជាជន 1 265 280 នាក់ ។ ឯខេត្តដែលមានប្រជាជនរស់នៅតិចជាងគេ គឺខេត្តកែប( 35 753 នាក់) និងបន្ទាប់មកគឺខេត្តមណ្ឌលគិរីនិងខេត្តប៉ៃលិន ដែលកាលពីឆ្នាំ 1998 ជាក្រុងប៉ៃលិន ក្រុងកែប និងខេត្តមណ្ឌលគិរី ។




***ការបែងចែកប្រជាជនកម្ពុជាតាមតំបន់ឆ្នាំ 1998 និង 2008 (គិតជាភាគរយ)***

## 1.2. ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជន គឺជាចំនួនប្រជាជនក្នុងផ្ទៃដីមួយគីឡូម៉ែត្រការេ ។ ប្រសិនបើប្រជាជនកើនក្នុងអំឡុងពេលមួយ តែទំហំផ្ទៃដីនៅដដែល នោះដង់ស៊ីតេប្រជាជននឹងកើនជាសមាមាត្រ ។ ដង់ស៊ីតេប្រជាជនកម្ពុជាបានកើនពី 64 នាក់ / $km^2$ នៅឆ្នាំ 1998 ទៅ 75 នាក់ / $km^2$ នៅឆ្នាំ 2008 (មិនគិតផ្ទៃបឹងទន្លេសាប 3000$km^2$) គឺកើនឡើងចំនួន 11 នាក់ / $km^2$ តែក្នុងរយៈពេលមួយទសវត្សរ៍ប៉ុណ្ណោះ ។ ចំនួននេះតិចជាងនៅតំបន់អាស៊ីអាគ្នេយ៍ដែលមាន 126 នាក់ / $km^2$ ។ សិង្ហបុរី ជាប្រទេសដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍ 7 053 នាក់ / $km^2$ បន្ទាប់មកគឺប្រទេសហ្វីលីពីន 320 នាក់ / $km^2$ វៀតណាម 260 នាក់ / $km^2$ និងថៃ 127 នាក់ / $km^2$ ។ ប្រទេសឡាវមានដង់ស៊ីតេត្រឹមតែ 28 នាក់ / $km^2$ ប៉ុណ្ណោះ គឺទាបជាងដង់ស៊ីតេប្រជាជនកម្ពុជាជិតបីដង ។

តាមបណ្តាខេត្ត ដង់ស៊ីតេប្រជាជនប្រែប្រួលពីកម្រិតទាប 4 នាក់ / $km^2$ ក្នុងខេត្តមណ្ឌលគិរី ទៅ 4 516 នាក់ / $km^2$ នៅរាជធានីភ្នំពេញ ។ ខេត្តកណ្តាលនៅតែរក្សាលំដាប់ទីមួយក្នុងចំណោមខេត្តទាំង 23 ខាងដង់ស៊ីតេប្រជាជន 355 នាក់ / $km^2$ ។ បន្ទាប់មក គឺខេត្តតាកែវ 237 នាក់ / $km^2$ និងខេត្តព្រៃវែង 194 នាក់ / $km^2$ ។ ដង់ស៊ីតេនេះក៏មានការប្រែប្រួលរវាងពីស្រុកមួយទៅស្រុកមួយទៀតដែរ ទោះបីជានៅក្នុងខេត្តជាមួយគ្នាក៏ដោយ ។

ខេត្តចំនួនពីរដែលមានដង់ស៊ីតេប្រជាជនថេរក្នុងរយៈពេលមួយទសវត្សរ៍មកនេះគឺ ខេត្តព្រៃវែង (194 នាក់ / $km^2$) និងកោះកុង ( 12 នាក់ / $km^2$) ។

**ប្រជាជននិងដង់ស៊ីតេប្រជាជនតាមតំបន់ទាំង 4 (ឆ្នាំ 1998-2008)**

| កម្ពុជា/ តំបន់ | ផ្ទៃដី($km^2$) | ប្រជាជនឆ្នាំ 1998 (នាក់ ) | ប្រជាជនឆ្នាំ 2008 (នាក់) | ដង់ស៊ីតេប្រជាជន(នាក់ / $km^2$ ) | |
|---|---|---|---|---|---|
| | | | | 1998 | 2008 |
| កម្ពុជា | 181 035(1) | 11 437 656 | 13 395 682 | 64 | 75 |
| តំបន់វាលរាប | 25 069 | 5 898 305 | 6 547 953 | 235 | 261 |
| តំបន់ទន្លេសាប | 67 668 | 3 505 448 | 4 356 705 | 52 | 64 |
| តំបន់ឆ្នេរសមុទ្រ | 17 237 | 844 861 | 960 480 | 49 | 56 |
| តំបន់ខ្ពង់រាបនិងភ្នំ | 68 061 | 1 189 042 | 1 530 544 | 17 | 22 |

កំណត់សម្គាល់ : - (1) រួមបញ្ចូលទាំងផ្ទៃបឹងទន្លេសាប 3000$km^2$

- ប្រភពតួលេខផ្ទៃដី : ក្រសួងមហាផ្ទៃ

តំបន់ទំនាបកណ្ដាលមានដង់ស៊ីតេប្រជាជន 261 នាក់ / km² លើសពី ឆ្នាំ 1998 ដែលមានត្រឹមតែ 235 នាក់ / km² ។ បន្ទាប់មក គឺតំបន់ទន្លេសាប 64 នាក់ / km² និងតំបន់ឆ្នេរសមុទ្រ 56 នាក់ / km² ។ តំបន់ខ្ពង់រាបនិងភ្នំ មានដង់ស៊ីតេប្រជាជនត្រឹមតែ 22 នាក់ / km² ប៉ុណ្ណោះ ។




## 1.3. កម្រិតលទ្ធភាពបង្កកំណើត

អត្រាលទ្ធភាពបង្កកំណើត គឺជាចំនួនកូនមធ្យមដែលស្ត្រីម្នាក់អាចបង្កើតបាននៅក្នុងដំណាក់បន្តពូជ (15-44ឆ្នាំ) ។ តាមការធ្វើជំរឿនក្នុងឆ្នាំ 2008 អត្រាលទ្ធភាពបង្កកំណើតបានថយចុះពីចំនួនកូនគិតជាមធ្យម ដែលស្ត្រីម្នាក់មាន 5.2 នាក់នៅឆ្នាំ 1998 មកនៅត្រឹម 3.1 នាក់ (ចន្លោះពី 2.7 នាក់ ទៅ 3.4 នាក់) ។ ថ្វីត្បិតតែអត្រានេះថយចុះជាងពីឆ្នាំ 1998 ដែលមាន 5.2 នាក់ ក៏ដោយ តែបើធៀបទៅនឹងបណ្ដាប្រទេសក្នុងតំបន់ អត្រានេះនៅតែមានកម្រិតខ្ពស់ជាងគេនៅឡើយ ។ អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីប្រែប្រួលទៅតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ច ទំនៀមទម្លាប់ និងកម្រិតវប្បធម៌របស់ស្ត្រី ។ ស្ត្រីដែលមិនបានចូលរៀនមានកូនច្រើនជាងស្ត្រីដែលបានរៀនត្រឹមបញ្ចប់កម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ហើយស្ត្រីដែលបានរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិនិងខ្ពស់ជាងនេះ លទ្ធភាពបង្កកំណើតក៏ថយចុះជាងនេះដែរ ។

លទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅទីប្រជុំជននៅចន្លោះពី 1.8 ទៅ 2.4 ជាមធ្យម 2.1 មានកម្រិតទាបជាងលទ្ធភាពបង្កកំណើតរបស់ស្ត្រីនៅជនបទដែលមានចន្លោះពី 2.9 ទៅ 3.6 និងជាមធ្យម 3.3 នាក់ ។




ប្រភពនៃការប៉ាន់ស្មាន - ឆ្នាំ 1982.5 ដល់ 1997.5 អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ 2000 2002.5 2005 2005.8 ការប៉ាន់ស្មានពីជំរឿនឆ្នាំ2008 ។

- ឆ្នាំ 1982.5 មានន័យថាការអង្កេតប្រជាសាស្ត្រពាក់កណ្តាលឆ្នាំ 1982

លទ្ធភាពបង្កកំណើតរបស់ស្ត្រី គឺជាកត្តាកំណត់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ( IDH ) ។ ប្រសិនបើប្រទេសមួយ មានសន្ទស្សន៍អភិវឌ្ឍន៍មនុស្សទាប ( បញ្ហាចូលរៀនមានកម្រិត អាហារូបត្ថម្ភមិនគ្រប់គ្រាន់ សុខភាពមិនទាន់ល្អ) នោះលទ្ធភាពបង្កកំណើតរបស់ស្ត្រីមានកម្រិតខ្ពស់ ។ ផ្ទុយទៅវិញបើប្រទេសមួយមានសន្ទស្សន៍អភិវឌ្ឍន៍កម្រិតខ្ពស់ (អត្រាចូលរៀនខ្ពស់ អាហារូបត្ថម្ភគ្រប់គ្រាន់ សុខភាពប្រជាជនល្អប្រសើរនិងមានអាយុវែង) នោះលទ្ធភាពបង្កកំណើតរបស់ស្ត្រីមានកម្រិតទាបវិញ ។

**អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីកម្ពុជានិងអត្រាជាតិប្រមាណ ឆ្នាំ 2008**

| | អត្រាលទ្ធភាពបង្កកំណើត | អត្រាជាតិប្រមាណ(សម្រាប់ប្រជាជន 1000 នាក់) |
|---|---|---|
| **សរុប** | 3.1 | 26.9 |
| **ទីប្រជុំជន** | 2.1 | 23.9 |
| **ជនបទ** | 3.3 | 27.7 |

# 2. អត្រាភេទ ទម្រង់តាមភេទ និងអាយុប្រជាជនកម្ពុជា

## 2.1. អត្រាភេទនិងទម្រង់តាមភេទ

អត្រាភេទ គឺជាចំនួនមនុស្សប្រុសធៀបនឹងមនុស្សស្រី 100 នាក់ ដែលមានសារៈសំខាន់សម្រាប់ជារង្វាស់សាមញ្ញនៃសមាសភាពភេទ ។ អត្រាភេទប្រែប្រួលទៅតាមស្ថានភាពសង្គម តាមភូមិសាស្ត្រ តាមអាយុ និងចលនាបម្លាស់លំនៅរបស់ប្រជាជន ។

តាមប្រភពជំរឿនប្រជាជនកម្ពុជានៅឆ្នាំ 2008 អត្រាភេទមាន 94.2 ខ្ពស់ជាងកាលពីឆ្នាំ 1998 ដែលមានត្រឹមតែ 93.0 ប៉ុន្តែទាបជាងពីឆ្នាំ 1962 ដែលមាន 99.9 ។ អត្រាភេទដែលមានកម្រិតទាប 86.0 កើតមាននៅឆ្នាំ 1980 មូលហេតុដោយសារការស្លាប់របស់មនុស្សប្រុសក្នុងរបបខ្មែរក្រហម ប៉ុន្តែអត្រាភេទនេះបានកើនឡើងជារៀងរាល់ឆ្នាំ ។ ខេត្តចំនួន 16 ដែលមានអត្រាភេទខ្ពស់ជាងអត្រាភេទមធ្យមថ្នាក់ជាតិ ដូចជាខេត្តកោះកុងមាន 102.3 ខេត្តមណ្ឌលគិរីមាន 104.9 ខេត្តរតនគិរី 102.2 ខេត្តឧត្តរមានជ័យ 101.0 និងខេត្តប៉ៃលិន 105.5 ។

នៅឆ្នាំ 1998 អត្រាភេទនៅទីប្រជុំជនមាន 95.7 ខ្ពស់ជាងនៅជនបទ ដែលមានតែ 92.5 ប៉ុន្តែនៅឆ្នាំ 2008 មានលក្ខណៈផ្ទុយគ្នាវិញ គឺអត្រាភេទនៅទីប្រជុំជនមាន 91.7 ទាបជាងនៅជនបទ ដែលមាន 94.8 ។ ទាំងនេះដោយសារតែផ្នែកខ្លះនៃតំបន់ទីប្រជុំជននៅរាជធានីភ្នំពេញនិងនៅខេត្តកណ្ដាល មានអត្រាភេទទាបពេក ដោយមូលហេតុនៃការធ្វើបម្លាស់ទីរបស់នារីមកធ្វើការក្នុងវិស័យកាត់ដេរ ។

តាមជំរឿនឆ្នាំ 2008 គេសង្កេតឃើញថា នៅវ័យកុមារ ភេទប្រុសមានច្រើនជាងភេទស្រីក្នុងអត្រា 105.0 តែចាប់វ័យកណ្ដាលដល់វ័យចាស់ អត្រាភេទប្រុសធ្លាក់ចុះទាបជាបន្តបន្ទាប់ រហូតដល់អាយុ 70 ឆ្នាំឡើង អត្រាភេទប្រុសនៅក្រោម 70 ។




*ពីរ៉ាមីតអាយុប្រជាជនកម្ពុជា*
*គិតជាភាគរយឆ្នាំ 1998*




*ពីរ៉ាមីតអាយុប្រជាជនកម្ពុជា*
*គិតជាភាគរយឆ្នាំ 2008*

នៅក្នុងរូបពីរ៉ាមីតអាយុប្រជាជនកម្ពុជាឆ្នាំ 2008 គេសង្កេតឃើញថា ក្រុមអាយុ 30-34 ឆ្នាំដែលមានលក្ខណៈផតចូលក្នុង ទាំងនេះបញ្ជាក់ថា ប្រជាជននៅក្រុមអាយុនេះទាំងប្រុសនិងស្រីមានចំនួនតិចជាងគេ ដោយសារការថយចុះនៃលទ្ធភាពបង្កកំណើតរបស់ស្ត្រីនិងមរណភាពខ្ពស់របស់កុមារនៅសម័យខ្មែរក្រហម ។ ផ្ទុយទៅវិញ ក្នុងក្រុមវ័យចំណាស់(អាយុ 65 ឆ្នាំឡើង) ចំនួនស្ត្រីមានច្រើនជាងបុរស ។ ចំនួនស្ត្រីមានភាគច្រើនបំផុតប្រៀបធៀបនឹងចំនួនបុរសនៅត្រង់ក្រុមអាយុ 50-54 ឆ្នាំ ។ បញ្ហានេះដោយសារមនុស្សប្រុសក្នុងក្រុមអាយុនេះបានស្លាប់ច្រើនជាងមនុស្សស្រីនៅសម័យខ្មែរក្រហម (1975-1979) ដោយសារការកាប់សម្លាប់ ការបង្អត់អាហារ និងជំងឺផ្សេងៗ ជាពិសេសមនុស្សប្រុសជាមុខសញ្ញាក្នុងការសម្លាប់ ។ ដូចនេះ ក្រុមអាយុ 50-54 នៅឆ្នាំ 2008 ពួកគេមានអាយុ 21-25 នៅសម័យខ្មែរក្រហម ។

## 2.2. ទម្រង់តាមអាយុ

កុមារអាយុក្រោម 15 ឆ្នាំ មានចំនួន 33.7% គឺទាបជាងនៅឆ្នាំ 1998 ដែលមានដល់ទៅ 42.8% ។ បញ្ហានេះបណ្តាលមកពីការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូនចៅនៅទសវត្សរ៍ចុងក្រោយនេះ ។ សមាមាត្រកុមារក្នុងក្រុមអាយុ 0-4 ឆ្នាំ តិចជាងសមាមាត្រកុមារក្នុងក្រុមអាយុ 5-9 ឆ្នាំ ។ ក្រុមអាយុដែលស្ថិតក្នុងសកម្មភាពសេដ្ឋកិច្ចពី 15 ទៅ 64 ឆ្នាំ មាន 62.05% ខ្ពស់ជាងឆ្នាំ 2008 ដែលមានតែ 53.7% ហើយក្រុមវ័យចំណាស់អាយុចាប់ពី 65 ឆ្នាំឡើងទៅ ក៏មាននិន្នាការកើនឡើង ពី 3.5% នៅឆ្នាំ 1998 ទៅ 4.25% នៅឆ្នាំ 2008 ។ នេះបញ្ជាក់អំពីការថយចុះនៃមរណភាពរបស់មនុស្សពេញវ័យ ។

ពីរ៉ាមីតអាយុប្រជាជនឆ្នាំ 2008 បង្ហាញថា ក្រុមអាយុ 10-14 ឆ្នាំ តំណាងឱ្យក្រុមអាយុដែលធំជាងគេ (12.5%) និងក្រុមបន្ទាប់គឺ ក្រុមអាយុ 15-19 ឆ្នាំ(12.09%) ដែលបង្ហាញពីកម្រិតបង្កើតកូនខ្ពស់នៅដើមទសវត្សរ៍ឆ្នាំ 1990 ។ នៅអាយុក្រោម 10 ឆ្នាំ ពីរ៉ាមីតបង្ហាញអំពីនិន្នាការថយចុះបន្តិចម្តងៗនៃចំនួនកុមារ ។

# 3. ប្រជាជនសកម្ម

ប្រជាជនសកម្មលើវិស័យសេដ្ឋកិច្ច គឺបុរសនិងស្ត្រីដែលធ្វើការងារលើវិស័យការងារទាំងបី គឺកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ។ នៅកម្ពុជា ប្រជាជនដែលធ្វើការងារក្នុងវិស័យកសិកម្មភាគច្រើន ជាស្ត្រីនិងមាននិន្នាការថយចុះនៅទសវត្សរ៍ចុងក្រោយនេះ ។ ឯវិស័យឧស្សាហកម្មចំនួនប្រជាជនធ្វើ ការងារមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ គឺស្ត្រីមានចំនួនច្រើនជាងបុរស ។ ចំពោះវិស័យ សេវាកម្មវិញក៏មានចំនួនកើនឡើងដែរ ឯចំនួនស្ត្រីវិញថ្វីត្បិតមានចំនួនតិចជាងបុរសក៏ដោយ តែបើធៀបទៅនឹងឆ្នាំ 1998 មានសំទុះកើនឡើងខ្លាំងជាងបុរស ។

ភាគរយប្រជាជនមានការងារធ្វើក្នុងវិស័យនីមួយៗតាមភេទ

| ភេទ | វិស័យការងារ | | | | | |
|---|---|---|---|---|---|---|
| | កសិកម្ម | | ឧស្សាហកម្ម | | សេវាកម្ម | |
| | 1998 | 2008 | 1998 | 2008 | 1998 | 2008 |
| **ទាំងពីរភេទ** | 77.53 | 72.30 | 4.24 | 8.54 | 18.23 | 19.16 |
| ប្រុស | 71.65 | 69.37 | 5.03 | 8.06 | 23.32 | 22.57 |
| ស្រី | 83.12 | 75.11 | 3.48 | 9.00 | 13.40 | 15.89 |

## ៣.1. អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច (កម្លាំងពលកម្ម)

អត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច គឺជាភាគរយនៃប្រជាជនសកម្មធៀបនិងប្រជាជនសរុបចាប់ពីអាយុ 7ឆ្នាំឡើងទៅ ។ នៅកម្ពុជា មនុស្សចូលរួមសកម្មភាពសេដ្ឋកិច្ច(ប្រជាជនសកម្ម)សរុបមានចំនួន 7 053 398 នាក់ ក្នុងនោះស្ត្រីមានចំនួន 3 608 345 នាក់ ត្រូវជា 51.16% ។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅថ្នាក់ជាតិសម្រាប់មនុស្សអាយុ 7 ឆ្នាំឡើង (អន្តរជាតិគិត 15-64 ឆ្នាំ) បានកើនឡើងក្នុងទសវត្សរ៍ឆ្នាំ 1998-2008 ចាប់ពី 55.5% ទៅ 61.7% សម្រាប់មនុស្សទាំងពីរភេទ ចាប់ពី 56.5% ទៅ 62.5% សម្រាប់បុរស និងចាប់ពី 54.6% ទៅ 60.9% សម្រាប់ស្ត្រី ។

អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទខ្ពស់ជាងនៅទីប្រជុំជន អាស្រ័យដោយសារកត្តាសំខាន់ពីរយ៉ាងគឺ ទី 1 ការចូលរួមកម្លាំងពលកម្មក្នុងសកម្មភាពស្រែចំការនៅតំបន់ជនបទមានអត្រាខ្ពស់និង ទី 2 សមាមាត្រនៃការចូលរៀននៅតំបន់ជនបទមានអត្រាទាប ។ ប៉ុន្តែ បើគិតដល់សមាមាត្រភេទវិញឃើញថា អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅទីប្រជុំជនចំពោះបុរសគឺខ្ពស់ជាងស្ត្រី ហើយបញ្ហា នេះមានលក្ខណៈផ្ទុយគ្នានៅតំបន់ជនបទ ។

បើគិតតាមលក្ខណៈអន្តរជាតិ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចត្រូវបានគណនាចំពោះក្រុមមនុស្សអាយុចាប់ពី 15-64 ឆ្នាំ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចក្នុងចំណោមមនុស្សដែលស្ថិតនៅក្នុងក្រុមអាយុនេះរបស់ប្រទេសកម្ពុជា មានពី 79% ទៅ 80% ។ ចំនួនស្ត្រីដែលចូលរួមសកម្មភាពសេដ្ឋកិច្ចនៅក្រុមអាយុ 15-64ឆ្នាំ មាន 51.20% នៃចំនួនមនុស្សដែលមានសកម្មភាពសេដ្ឋកិច្ចសរុបនៅក្នុងក្រុមអាយុនេះ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៃស្ត្រីនៅប្រទេសកម្ពុជាមាន 78.5% គឺមានកម្រិតខ្ពស់បំផុតនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។

## 3.2. ការងារកុមារ

បញ្ហាមួយក្នុងចំណោមបញ្ហាចម្បងៗ ដែលប្រទេសកម្ពុជាត្រូវប្រឈមមុខ គឺមានចំនួនកុមារដ៏ច្រើនធ្វើការងារនិងការងារមួយចំនួនជាការងារធ្ងន់ធ្ងរ ហើយដែលកុមារត្រូវប្រឈមនិងគ្រោះថ្នាក់រហូតដល់អាយុជីវិតដូចជា ការងារនេសាទសមុទ្រ សិប្បកម្មឡឥដ្ឋ និងធ្វើជាស្ត្រីពេស្យាជាដើម ។ នៅឆ្នាំ 2008 កុមារអាយុក្រោម 15 ឆ្នាំចំនួន 1.35% បានការងារធ្វើក្នុងចំណោមអ្នកធ្វើការងារសរុប ។ ចំនួននេះថយចុះបន្តិចបន្តួចពីឆ្នាំ 1998 ដែលមាន 1.47% ។

# 4. ក្រុមងាយរងគ្រោះ

ផលវិបាកនៃសង្គ្រាមនិងវិបត្តិនយោបាយនៅប្រទេសកម្ពុជាតាំងពីទសវត្សរ៍ឆ្នាំ 1970 មក មិនត្រឹមនៅតែជាបញ្ហាចោទចំពោះប្រជាជនប៉ុណ្ណោះទេ ថែមទាំងកំពុងនិងបានបន្តបន្ថែមជាចំណោទជាបន្តបន្ទាប់ ។ ចំណោទបញ្ហាទាំងនោះ គឺការបន្សល់ទុកនូវស្ត្រីមេម៉ាយនិងជនពិការជាច្រើននាក់នៅក្នុងសង្គមកម្ពុជា ។

## 4.1. ស្ត្រីមេម៉ាយ

ក្នុងចំណោមមេគ្រួសារទូទាំងប្រទេសចំនួន 2 841 897 នាក់ ស្ត្រីដែលមាននាទីជាមេគ្រួសារមានចំនួន 721 119 នាក់ ។ មេគ្រួសារភាគច្រើនមានអាយុចាប់ពី 30 ឆ្នាំ ទៅ 59 ឆ្នាំ ។ ស្ត្រីដែលជាមេគ្រួសារនៅចន្លោះអាយុនេះមាន 64% គឺមានការថយចុះបន្តិចពីឆ្នាំ 1998 ដែលមាន 68% ។ ក្នុងចំណោមស្ត្រីជាមេគ្រួសារសរុប ស្ត្រីជាមេគ្រួសារដែលមានសមាជិកគ្រួសារចាប់ពី 3 នាក់ឡើងទៅ មានរហូតដល់ 72.359% 4 នាក់ឡើងទៅមាន 52.202% 5 នាក់ឡើងទៅ 33.757% 6 នាក់ឡើងទៅ 19.716% និង 7 នាក់ឡើងទៅ 10.685% ។ នេះជាទម្ងន់យ៉ាងធ្ងន់ធ្ងរចំពោះស្ត្រីក្នុងការធានារ៉ាប់រងនៅក្នុងគ្រួសារ ជាពិសេសចំពោះស្ត្រីដែលរស់នៅទីប្រជុំជន ពីព្រោះផលទុនដែលគេទទួលបានមានតិចតួចណាស់ ហើយមានលក្ខណៈលំបាកលំបិនទៀតផង រីឯស្ត្រីមេម៉ាយនៅជនបទវិញ ភាគច្រើនបានទទួលការគាំទ្រពីគ្រួសារធំ(គ្រួសារមានទំហំធំ ឬមានសមាជិកច្រើន) ដែលបុរសជាអ្នករកស៊ីចិញ្ចឹម(កូនប្រុស ឬកូនប្រសារប្រុស...) ។

## 4.2. ជនពិការ

សោកនាដកម្មមួយ ក្នុងចំណោមសោកនាដកម្មដ៏ច្រើន ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងជម្លោះប្រដាប់អាវុធ គឺការបំផ្លាញដែលបង្កឡើងដោយគ្រាប់មីនបង្កប់នៅក្នុងដី ។

ផលវិបាកនៃគ្រាប់មីនទាំងនោះ បានបន្សល់ទុកនូវជនពិការយ៉ាងច្រើន ហើយបច្ចុប្បន្នបញ្ហាមីននៅតែបន្តសម្លាប់មនុស្សគ្រប់វ័យ ។ តាមប្រភពជំរឿនឆ្នាំ 2008 ប្រទេសកម្ពុជាមានមនុស្សពិការចំនួន 192 538 នាក់ គឺស្មើនឹង 1.44% នៃប្រជាជនសរុបទូទាំងប្រទេស ក្នុងនោះមានជនពិការភេទប្រុសចំនួន 108 468 នាក់ ត្រូវជា 56.3% និងជនពិការភេទស្រីចំនួន 84 070 នាក់ ត្រូវនឹង 43.7% ។ បើធៀបទៅនឹងប្រជាជនសរុបតាមភេទនីមួយៗ ជនពិការប្រុសមាន 1.66% និងជនពិការស្រីមាន 1.22% ។

ជាទូទៅ ជនពិការនៅជនបទមានចំនួនច្រើនជាងជនពិការនៅទីប្រជុំជន ( ជនបទចំនួន 164 104 នាក់ និងទីប្រជុំជន 28 434 នាក់) ។ ជនពិការអវយវៈមានភាគរយខ្ពស់ជាងគេក្នុងអត្រា 40.83% ធៀបនឹងចំនួនជនពិការសរុប ។ ជនពិការពីកំណើតមានចំនួន 61 151 នាក់ ត្រូវនឹង 31.76% ។ ហេតុនេះ ជនពិការនៅកម្ពុជា ភាគច្រើនកើតឡើងក្រោយកំណើត ដែលរាប់បញ្ចូលទាំងជនរងគ្រោះដោយសារសង្គ្រាម មីនក្នុងដី និងគ្រោះថ្នាក់ផ្សេងទៀត ។ ជនពិការភ្នែកមានសមាមាត្រខ្ពស់ជាងគេបង្អស់ក្នុងចំណោមមនុស្សពិការតាំងពីកំណើតនៃកុមារពីអាយុ 0-14 ឆ្នាំ ឯជនពិការអវយវៈក៏មានច្រើនលើសលប់ ក្នុងចំណោមមនុស្សពិការក្រោយកំណើតផងដែរ ។ ជាទូទៅ ពិការភាពភាគច្រើនស្ថិតនៅក្នុងក្រុមអាយុ 15-29 ឆ្នាំ ដែលតាងមនុស្សកើតក្នុងអំឡុងឆ្នាំ 1979-1993 ក្រោយពីរបបខ្មែរក្រហម ។

បច្ចុប្បន្ន ជនពិការត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនិងអង្គការអន្តរជាតិនានាដោយបង្កឱ្យកុមារពិការបានចូលរៀន ដូចជាកុមារពិការភ្នែក គ ថ្លង់ ក៏ដូចជាពិការអវយវៈដែរ ។ ចំពោះជនពិការស្ថិតក្នុងវ័យប្រជាជនសកម្ម ត្រូវបានទទួលការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈផ្សេងៗដូចជាកាត់ដេរ ជាងឈើ ត្បាញហូល ផ្នែកព័ត៌មានវិទ្យា និងភាសាជាដើម ដើម្បីឱ្យពួកគេមានលទ្ធភាពរស់ក្នុងសង្គមដោយភាពថ្លៃថ្នូរនិងដោយក្តីសង្ឃឹម ។

## ? សំណួរ

1. តើក្នុងពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមានខេត្តចំនួនប៉ុន្មាន ? តើខេត្តណាខ្លះដែលមានក្រុងពីរ ?
2. ហេតុអ្វីបានជាតំបន់វាលរាបនិងតំបន់ទន្លេសាបមានប្រជាជនរស់នៅកុះករ ?
3. តើត្រូវធ្វើដូចម្តេចដើម្បីធ្វើឱ្យប្រជាជនចូលចិត្តទៅរស់នៅតំបន់ខ្ពង់រាបនិងតំបន់ភ្នំ ?
4. ចូររៀបរាប់ពីមូលហេតុនៃការកើនឡើងនៃប្រជាជននៅតំបន់ភ្នំនិងតំបន់ខ្ពង់រាប ។
5. ហេតុអ្វីបានជាលទ្ធភាពបង្កកំណើតរបស់ស្ត្រីគឺជាកត្តាកំណត់នៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ?
6. តាមពីរ៉ាមីតរបស់ប្រជាជនកម្ពុជាឆ្នាំ 2008 ហេតុអ្វីបានជាថ្នាក់អាយុ 30-34 ឆ្នាំមានភាពផត ? តើក្រុមអាយុនេះកើតនៅអំឡុងឆ្នាំណា ? តើក្រុមអាយុនេះមានអាយុប៉ុន្មានឆ្នាំនៅក្នុងសម័យខ្មែរក្រហមកាន់អំណាច (1975-1979) ?
7. ចូរប្រៀបធៀបចំនួនប្រជាជនសកម្មនៅកម្ពុជានៅឆ្នាំ 1998 និង 2008 ។
8. ហេតុអ្វីបានជាគេប្រើប្រាស់កុមារឱ្យធ្វើការងារ ?
9. តើមនុស្សប្រភេទណាខ្លះដែលចាត់ទុកថាជាក្រុមទន់ខ្សោយ ? ហេតុអ្វី ?

មេរៀនទី

# 2 បម្លាស់លំនៅនៃប្រជាជនកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

❑ រៀបរាប់ពីបម្លាស់លំនៅនៃប្រជាជនកម្ពុជានិងមូលហេតុនៃបម្លាស់លំនៅក្នុងស្រុក ។

បម្លាស់លំនៅ គឺជាការផ្លាស់ប្តូរកន្លែងរស់នៅពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រដទៃទៀត ។ បម្លាស់លំនៅ គឺជាបាតុភូតសកល ដែលកើតមាននៅគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក មិនថាប្រទេសអ្នកមាន ឬប្រទេសអ្នកក្រឡើយ ។ ដោយឡែកនៅប្រទេសកម្ពុជា ចាប់ពីអំឡុងឆ្នាំ 1970 មកនិងឆ្នាំបន្តមកទៀតរហូតមកដល់បច្ចុប្បន្ន មានចលនាបម្លាស់លំនៅទាំងក្នុងប្រទេសនិងក្រៅប្រទេសជាច្រើន ដែលបណ្តាលមកពីវិបត្តិនយោបាយ សេដ្ឋកិច្ច និងសង្គមរបស់ប្រទេស ។ បាតុភូតនេះធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំហំនិងសមាសភាពនៃប្រជាជន ហើយជនភៀសខ្លួនមួយចំនួនធំ បានទៅតាំងទីលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសទី 3 និងខ្លះទៀតបានតាំងទីលំនៅបណ្តោះអាសន្នក្នុងតំបន់ ឬប្រទេសជិតខាង ហើយក៏បានធ្វើមាតុភូមិនិវត្តន៍នៅពេលដែលស្ថានភាពនយោបាយមានសភាពល្អប្រសើរឡើងវិញ ។

ប្រធានបទខាងលើនេះ មានសារៈសំខាន់និងជាចំណាប់អារម្មណ៍មិនមែនសម្រាប់តែអ្នកប្រជាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកសេដ្ឋកិច្ច អ្នកសង្គមកិច្ច អ្នកមនុស្សសាស្ត្រ អ្នកវិទ្យាសាស្ត្រនយោបាយ អ្នកច្បាប់ អ្នកធ្វើគោលនយោបាយ អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងសាធារណៈផងដែរ ។

## 1. បម្លាស់លំនៅនៅកម្ពុជា

### 1.1. មុនឆ្នាំ 1975

មុនឆ្នាំ 1975 មានចលនាបម្លាស់លំនៅសំខាន់ៗ ដែលពាក់ព័ន្ធជាមួយនិងសហគមន៍វៀតណាម បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ដោយឧត្តមសេនីយ៍លន់ នល់ នាថ្ងៃទី 18 ខែមីនា ឆ្នាំ 1970 ។ ពេលនោះ ជនជាតិវៀតណាមប្រមាណ 200 000 នាក់ ត្រូវបានគេបង្ខំឱ្យចាកចេញពីប្រទេសកម្ពុជា ជាហេតុនាំឱ្យសហគមន៍វៀតណាមនៅសល់ប្រហែលពាក់កណ្តាលប៉ុណ្ណោះ ។

## 1.2. សម័យខ្មែរក្រហម ឬកម្ពុជាប្រជាធិបតេយ្យ (1975-1979)

ពេលឡើងកាន់អំណាច ខ្មែរក្រហមបានបង្កឱ្យមានចលនាបម្លាស់លំនៅមួយយ៉ាងធំ។ ពេលនោះប្រជាជនដែលរស់នៅតាមខេត្ត ក្រុង ពិសេសប្រជាជនទីក្រុងភ្នំពេញត្រូវគេជម្លៀសទាំងបង្ខំឱ្យទៅនៅជនបទ ហើយទន្ទឹមគ្នានេះ ក៏មានមនុស្សជាច្រើនបានសាកល្បងរត់គេចពីប្រទេសកម្ពុជាទៅប្រទេសជិតខាងមុនមានការបិទព្រំដែន(មនុស្ស 17 000 នាក់បានទៅជ្រកកោននៅប្រទេសថៃនាឆ្នាំ 1975)។ បន្ទាប់មកទៀត នៅចន្លោះឆ្នាំ 1975 និង 1978 ប្រជាជនកម្ពុជាប្រមាណ 35 000 នាក់ បានរត់ទៅជ្រកកោននៅប្រទេសថៃ។ ចំណែកប្រជាជនកម្ពុជាមួយចំនួន ដែលរស់នៅប៉ែកខាងកើតបានរត់ទៅជ្រកកោននៅវៀតណាមខាងត្បូងនាឆ្នាំ 1977។



*ជនភៀសខ្លួនកម្ពុជា ថ្ងៃ 17 មេសា 1975*

## 1.3. សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (1979-1990)

ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ មិនបានបញ្ឈប់ចលនាចំណាកស្រុកឡើយ។ ដោយសារមានការបើកទ្វារចំហនៃព្រំដែនប្រទេសថៃ នៅខែមករា ឆ្នាំ 1979 ប្រជាជនកម្ពុជាប្រមាណ 100 000 នាក់បានរត់គេចពីប្រទេសរបស់ខ្លួន ដើម្បីស្វែងរកជម្រកនិងចំណីអាហារ។ ក៏ប៉ុន្តែនៅខែ មិថុនា ឆ្នាំ 1979 ក្នុងបំណងបញ្ឈប់ចលនានេះ ប្រទេសថៃបានបិទព្រំដែន ហើយបញ្ជូនជនភៀសខ្លួនកម្ពុជាចំនួន 44 000 នាក់ មកមាតុប្រទេសវិញ។ នៅចុងឆ្នាំ 1979 ប្រជាជនកម្ពុជាប្រមាណ 500 000 នាក់ បានចាកចេញពីកម្ពុជា ចូលទៅប្រទេសថៃម្តងទៀត។ បម្លាស់លំនៅនេះ ធ្វើឡើងនៅពេលដែលកម្ពុជាកំពុង

ជួបប្រទះគ្រោះទុរភិក្ស ។ នៅដើមអំឡុងឆ្នាំ 1980 ពេលដែលស្ថានភាពនយោបាយនិងសេដ្ឋកិច្ចក្នុងប្រទេសកាន់តែប្រសើរឡើងនោះ ចលនាចំណាកស្រុកក៏បានបន្ថយល្បឿនផងដែរ ។ ថ្ងៃរំដោះ 7 មករា 1979 ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាម បានផ្តល់ឱកាសឱ្យប្រជាជនកម្ពុជាប្រមាណ 100 000 នាក់ ដែលរត់ទៅរស់នៅក្នុងប្រទេសវៀតណាមបានវិលត្រឡប់មកមាតុភូមិរបស់ខ្លួនវិញ ។

ក្រោយឆ្នាំ 1980 ជនជាតិវៀតណាម ដែលបានបញ្ជូនចេញពីប្រទេសកម្ពុជាកាលពីឆ្នាំ 1975 នោះក៏បានវិលត្រឡប់មកកម្ពុជាវិញដែរ និងនាំមកជាមួយនូវអ្នកចំណូលស្រុកជនជាតិវៀតណាមជាច្រើនទៀត ។

ក្នុងចន្លោះខែ មិថុនា ឆ្នាំ 1980 និង ខែ កក្កដា 1982 ប្រជាជនកម្ពុជាប្រមាណ 56 000 នាក់ បានចាកចេញពីជំរំប្រទេសថៃ វិលត្រឡប់មកប្រទេសកម្ពុជាវិញ ។

តាមការកត់ត្រារបស់អគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន ពីឆ្នាំ 1980 ដល់ដើមអំឡុងឆ្នាំ 1990 មានមនុស្សប្រមាណ 580 000 នាក់ បានឆ្លងកាត់ព្រំដែនថៃ គឺមានចំនួនស្មើនឹងមួយភាគដប់នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ 1980 ។ ចលនាបម្លាស់លំនៅនេះ បានបន្ថយល្បឿនកំណើនប្រជាជនយ៉ាងខ្លាំង ។

## 1.4. មាតុភូមិនិវត្តន៍នៃប្រជាជនកម្ពុជា (1991-1993)

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី 23 ខែ តុលា ឆ្នាំ 1991 ផ្តល់លទ្ធភាពដល់ការវិលត្រឡប់មកវិញដោយស្ម័គ្រចិត្តនៃជនភៀសខ្លួនប្រមាណ 375 000 នាក់ ពីជំរំគ្រប់គ្រងដោយអង្គការសហប្រជាជាតិក្នុងប្រទេសថៃ មុនការបោះឆ្នោតខែ ឧសភា ឆ្នាំ 1993 ។ កម្មវិធីមាតុភូមិនិវត្តន៍នេះ ជាកិច្ចចាប់ផ្តើមដ៏ធំមួយ ដែលកន្លងមកអគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួនមិនធ្លាប់បានរៀបចំឡើយ ។ នៅខែ មីនា ឆ្នាំ 1992 មានជនភៀសខ្លួនចំនួន 313 500 នាក់ បានសម្តែងឆន្ទៈរបស់ខ្លួនក្នុងបំណងចង់វិលត្រឡប់ចូលក្នុងមាតុប្រទេសរបស់ខ្លួនវិញ ។

ទន្ទឹមគ្នានេះ អគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន ដែលមានអក្សរកាត់ថា (UNHCR) ខិតខំរកដីសម្រាប់ធ្វើកសិកម្មបានប្រមាណ 240 000 ហិចតា ចែកជូនដល់ជនភៀសខ្លួនទាំងនោះផងដែរ ។ ជនភៀសខ្លួនភាគច្រើនមានបំណងប្រាថ្នាវិលត្រឡប់ទៅកាន់ស្រុកកំណើតរបស់ខ្លួនវិញដូចជាចង់រស់នៅខេត្តបាត់ដំបងចំនួន 57% ខេត្តបន្ទាយមានជ័យ 14% ខេត្តសៀមរាបនិងពោធិ៍សាត់ 6% ។ ប៉ុន្តែផ្ទៃដីមួយផ្នែកក្នុងខេត្តខាងលើត្រូវជួបការលំបាកដោយសារគ្រាប់មីនជាច្រើន ។ ពេលនោះក៏សង្កេតឃើញ មានការប្រជែងដីខ្លាំងមួយពីជនបំលាស់លំនៅក្នុងស្រុក ។ ពួកគេទាំងនេះ ចង់ដាំដុះលើដីកម្មសិទ្ធិចាស់របស់គេឡើងវិញ មុនការវិលត្រឡប់មកដល់នៃជនភៀសខ្លួន ។



*ជនភៀសខ្លួនកម្ពុជាក្នុងអំលុងឆ្នាំ 1990*

ដោយហេតុថា ផ្ទៃដីទំនេរសម្រាប់ជនភៀសខ្លួនមានចំនួនតិច ដូច្នេះដើម្បីដោះស្រាយបញ្ហា អគ្គស្នងការអង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួន បានផ្តល់លទ្ធភាពឱ្យជនភៀសខ្លួនទាំងនោះ ធ្វើការជ្រើសរើសយកដីដាំដុះ ឬមួយទទួលយកជាលុយ ។ នៅខែ កក្កដា ឆ្នាំ 1992 ក្នុងចំណោមជនភៀសខ្លួនចំនួន 90 000 នាក់ មានចំនួន 55% ដែលសម្រេចចិត្តជ្រើសរើសយកលុយ 25% ជ្រើសរើសយកដីដាំដុះ និង 20% ទៀតសុខចិត្តរង់ចាំដីដែលគេដោះមីនរួច ។

នៅខែ មេសា ឆ្នាំ 1993 ជនភៀសខ្លួន 360 000 នាក់ បានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ គឺទាន់ពេលដែលប្រទេសកម្ពុជារៀបចំបោះឆ្នោត ។ ដូច្នេះ ចាប់តាំងពីឆ្នាំ 1970 ដល់ឆ្នាំ 1990 មានមនុស្សជាងមួយលាននាក់បានភៀសខ្លួនចេញពីប្រទេសកម្ពុជា ហើយចន្លោះឆ្នាំ 1992 និង 1993 មានមនុស្សប្រមាណ 400 000 នាក់ ក៏បានវិលត្រឡប់មកមាតុភូមិវិញក្រោមការឧបត្ថម្ភពីអង្គការសហប្រជាជាតិ ។

## 2. បម្លាស់លំនៅក្នុងស្រុក

### 2.1. បម្លាស់លំនៅបណ្តាឆ្នាំ 1970

មានចរន្តពីរដែលផ្ទុយគ្នាស្រឡះនៃចលនាបម្លាស់លំនៅរបស់ប្រជាជនកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ 1970 ។ នៅដើមអំឡុងឆ្នាំ 1970 ចលនាបម្លាស់លំនៅមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងទៅនឹងប្រជាជនរស់នៅជនបទ ដែលមកជ្រកកោននិងរកការងារធ្វើនៅក្នុងទីក្រុង ។ ពេលនោះ មានមនុស្សប្រហែល 2 លាននាក់ ដែលរត់គេចចេញពីសង្គ្រាម ក៏ដូចជារត់គេចចេញពីការកៀរចូលក្នុងតំបន់រំដោះរបស់ពួកចលនាតស៊ូខ្មែរក្រហម មកតាំងលំនៅក្នុងទីក្រុង ។

នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាចថ្ងៃទី 17 ខែមេសា ឆ្នាំ 1975 ពួកគេបានជម្លៀសប្រជាជនទាំងអស់ដែលរស់នៅទីរួមខេត្តនិងទីក្រុង ឱ្យទៅរស់នៅជនបទ ។ នេះជានយោបាយតែមួយគត់ធ្វើឡើងដោយពួកខ្មែរក្រហម ហើយក៏មិនដែលមាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ពេលនោះប្រជាជនរាប់លាននាក់បានជម្លៀសបន្តឱ្យទៅកាន់តំបន់ផ្សេងៗទៀតនៃប្រទេស ពិសេសនៅតាមបណ្តាខេត្តនៅភាគខាងលិចនិងពាយ័ព្យ ។ ដូច្នេះ នៅចន្លោះឆ្នាំ 1975 និង 1979 គេប៉ាន់ស្មានថា ប្រជាជន $\frac{2}{3}$ បានត្រូវបង្ខំឱ្យជម្លៀសខ្លួនចេញ ។

## 2.2. បម្លាស់លំនៅបណ្តាឆ្នាំ (1979-1989)

ពេលដែលរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី 7 ខែ មករា ឆ្នាំ 1979 របបថ្មីមួយបានកើតឡើង គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រជាជនមានសេរីភាពក្នុងការធ្វើដំណើរ មិនមានបញ្ហាអ្វីរាំងស្ទះដូចកាលសម័យពីឆ្នាំ 1975 ដល់ 1979 ឡើយ ។ ប្រជាជនកម្ពុជាជាច្រើនលាននាក់បានធ្វើដំណើរឆ្លងកាត់ទូទាំងប្រទេសដើម្បីស្វែងរកក្រុមគ្រួសារដែលបានបែកគ្នាកាលពីជំនាន់ខ្មែរក្រហម ។ អ្នកខ្លះទៅនៅឯព្រំដែនថៃ ហើយអ្នកខ្លះទៀតទៅនៅទីក្រុង ជាពិសេសទីក្រុងភ្នំពេញ ។

នៅឆ្នាំ 1983 ជនស៊ីវិលកម្ពុជារាប់ម៉ឺន រាប់សែននាក់ ត្រូវបានគេបញ្ជូនឱ្យទៅបំពេញការងារការពារនៅតាមព្រំដែនថៃ ។ អ្នកខ្លះទៀត ត្រូវបានគេបញ្ជូនទៅខេត្តប៉ែកខាងកើត ដូចជានៅឆ្នាំ 1984 គេបានបញ្ជូនពលករចំនួន 14 000 នាក់ ទៅខេត្តរតនគិរី (J. Desbarat 1995 ) ។

## 2.3. បម្លាស់លំនៅនៅបណ្តាឆ្នាំ 1990

ពេលដែលកងទ័ពវៀតណាមដកចេញអស់ពីប្រទេសកម្ពុជានៅខែ កញ្ញា 1989 គេឃើញមានការរីកដុះដាលនៃការប្រយុទ្ធរវាងកងទ័ពរបស់រដ្ឋាភិបាលនិងកងទ័ពត្រីភាគី ។ ប្រជាជនជាច្រើននាក់បានចាកចេញពីតំបន់ប្រយុទ្ធទាំងនោះឆ្ពោះទៅទីកន្លែងផ្សេងទៀត ដោយខ្លះទៅនៅជំរំជនភៀសខ្លួននិងខ្លះទៀតទៅនៅទីក្រុង ។ នៅពាក់កណ្តាលឆ្នាំ 1990 មានមនុស្សប្រមាណ 150 000 នាក់ ដែលទៅជ្រកកោននៅទីក្រុង និងកើនដល់ 200 000 នាក់ នៅឆ្នាំ 1992 ។ អ្នកទាំងនោះមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ 47 000 នាក់ ខេត្តបាត់ដំបង 32 000 នាក់ ខេត្តកំពង់ស្ពឺ 31 000 នាក់ ខេត្តសៀមរាប 27 000 នាក់ ខេត្តកំពត 25 000 នាក់ និងខេត្តកំពង់ឆ្នាំង 30 000 នាក់ ។ នៅឆ្នាំ 1993 មនុស្សប្រមាណ 40 000 នាក់ ថ្មីទៀត បានរត់គេចចេញពីការប្រយុទ្ធគ្នានៅប៉ែកខាងលិចប្រទេស ។

## 2.4. បម្លាស់លំនៅក្នុងបរិបទបច្ចុប្បន្ន 2008

យោងតាមប្រភពជំរឿនប្រជាជនកម្ពុជាឆ្នាំ 2008 បង្ហាញថា ប្រជាជនធ្វើបម្លាស់លំនៅសរុបមានចំនួន 3 552 173 នាក់ ក្នុងនេះមានប្រុសចំនួន 1 792 519 នាក់ និងស្រី 1 759 654 នាក់ ។ ចំនួននេះថយចុះបន្តិចបើធៀបនឹងឆ្នាំ 1998 ដែលមានចំនួនសរុប 3 597 769 នាក់ ប្រុស 1 789 616 នាក់ និងស្រី 1 808 153 នាក់ ។ រូបភាពបម្លាស់លំនៅក្នុងស្រុក មានច្រើនលើសលប់ក្នុងចំនួន 3 457 228 នាក់ (97.33%) រីឯបម្លាស់លំនៅក្រៅស្រុកមានតិចតួចគឺត្រឹមតែ 2.67% ប៉ុណ្ណោះ (ឆ្នាំ 1998 មាន 5.85%) ។

មានមូលហេតុច្រើនដែលនាំទៅដល់ចលនាបម្លាស់លំនៅរបស់ប្រជាជន ទាំងក្នុងប្រទេសនិងក្រៅប្រទេសដូចជា ប្តូរកន្លែងធ្វើការងារ ស្វែងរកការងារធ្វើ ការសិក្សា រៀបអាពាហ៍ពិពាហ៍ គ្រួសារផ្លាស់លំនៅ មាតុភូមិនិវត្តន៍ គ្រោះធម្មជាតិ អសន្តិសុខ កូនកំព្រា ការបាត់បង់ដីធ្លីនិងលំនៅ និងមូលហេតុផ្សេងៗទៀត ។ ក្នុងចំណោមមូលហេតុទាំងអស់ មូលហេតុគ្រួសារបម្លាស់លំនៅមានចំនួនច្រើនជាងគេ (36.97%) បន្ទាប់មកមានមូលហេតុស្វែងរកការងារធ្វើ (21.52%) និងរៀបអាពាហ៍ពិពាហ៍ (14.62%) ។

ក្នុងចំណោមចរន្តបម្លាស់លំនៅក្នុងស្រុកទាំង 4 រូបភាព បម្លាស់លំនៅពីជនបទទៅជនបទមានចំនួនលើសគេ គឺជាងពាក់កណ្តាលនៃជនបម្លាស់លំនៅក្នុងស្រុកសរុបក្នុងអត្រា 50.88% បម្លាស់លំនៅពីជនបទទៅទីក្រុងដែលមានអត្រា 27.53% បម្លាស់លំនៅពីទីក្រុងទៅទីក្រុងមានអត្រា 15.11% និងបម្លាស់លំនៅពីទីក្រុងទៅជនបទមានចំនួនតិចជាងគេបំផុតគឺ 6.48% ប៉ុណ្ណោះ ។

បម្លាស់លំនៅពីជនបទទៅទីក្រុង មិនត្រឹមតែបង្កឡើងនូវបញ្ហានគរូបនីយកម្មប៉ុណ្ណោះទេ គឺថែមទាំងបង្កឱ្យមានចំណោទបញ្ហាលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ថែមទៀតផង ។

## ? សំណួរ

1. ហេតុអ្វីបានជាបម្លាស់ប្តូរទីលំនៅជាបាតុភូតសកល ?
2. តើមានព្រឹត្តិការណ៍អ្វីខ្លះកើតឡើងនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ?
3. ហេតុអ្វីបានជាមានចលនាចំណាកស្រុកនៅពេលរបបខ្មែរក្រហមដួលរលំ ?
4. តើចលនាមាតុភូមិនិវត្តន៍របស់ប្រជាជនកម្ពុជាធ្វើឡើងនៅក្នុងពេលណា ? ហេតុអ្វីបានជាមានចលនានេះ ? តើគេអនុវត្តគោលនយោបាយដូចម្តេចខ្លះចំពោះជនទាំងនោះ ?
5. ចូររៀបរាប់អំពីចលនាបម្លាស់លំនៅផ្ទុយគ្នារវាងដើមឆ្នាំ 1970 និងនៅឆ្នាំ 1975 ។
6. តើបម្លាស់លំនៅ នៅកម្ពុជាបច្ចុប្បន្នមានរូបភាពអ្វីខ្លះ ? តើរូបភាពណាមួយដែលមានទំហំធំជាងគេ ? ហេតុអ្វី ? តើរូបភាពណាមួយបណ្តាលឱ្យមានបញ្ហានគរូបនីយកម្ម ?

## ? សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ប្រទេសកម្ពុជាមានខេត្តចំនួន

☐ក. 22 ☐ខ. 23 ☐គ. 24 ☐ឃ. 25

2. ខេត្តដែលមានទីក្រុងចំនួន 2 មានចំនួន

☐ក. 2 ☐ខ. 3 ☐គ. 4 ☐ឃ. 5

3. ខេត្តដែលស្ថិតនៅតំបន់ទន្លេសាបមានចំនួន

☐ក. 5 ☐ខ. 6 ☐គ. 7 ☐ឃ. 8

4. ខេត្តដែលស្ថិតនៅជាប់សមុទ្រមានចំនួន

☐ក. 2 ☐ខ. 3 ☐គ. 4 ☐ឃ. 5

5. រូបភាពបំលាស់លំនៅនៅកម្ពុជាមានច្រើនជាងគេគឺ

☐ក. ជនបទ → ជនបទ ☐ខ. ជនបទ → ទីក្រុង

☐គ. ទីក្រុង → ជនបទ ☐ឃ. ទីក្រុង → ទីក្រុង

6. រូបភាពបំលាស់លំនៅដែលនាំឱ្យមានបញ្ហានគរូបនីយកម្មគឺ

☐ក. ជនបទ → ជនបទ ☐ខ. ជនបទ → ទីក្រុង

☐គ. ទីក្រុង → ជនបទ ☐ឃ. ទីក្រុង → ទីក្រុង

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ចំនួនមនុស្សប្រុសក្នុងចំណោមមនុស្សស្រី 100 នាក់ហៅថា.................................................. ។
2. វិស័យសេដ្ឋកិច្ចទាំងបីគឺ.................................................និង.......................................... ។
3. ចំពោះបញ្ហាសំខាន់បីដែលបណ្តាលមកពីចលនាបំលាស់លំនៅពីជនបទទៅទីក្រុងគឺ............. ។
4. អក្សរសរសេរកាត់ជាឡាតាំង "UNHCR" មានន័យពេញលេញគឺ................................ ។

III. សំណួរត្រិះរិះ

1. ហេតុអ្វីបានជានៅវ័យចាស់ប្រជាជនភេទស្រីនៅកម្ពុជាមានកាន់តែច្រើនឡើងជាងបុរស ?
2. កត្តាសំខាន់ទាំងពីរយ៉ាងដែលធ្វើឱ្យអត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅតំបន់ជនបទខ្ពស់ជាងទីប្រជុំជនមានអ្វីខ្លះ ?
3. ចូររៀបរាប់អំពីមូលហេតុដែលនាំឱ្យមានបម្លាស់លំនៅ ?
4. ចូររៀបរាប់អំពីបញ្ហានគរូបនីយកម្មដែលបណ្តាលមកពីបំលាស់លំនៅពីជនបទទៅនៅទីក្រុង ។

ជំពូកទី 2

# អភិវឌ្ឍន៍ប្រជាជនមិនស្មើគ្នា



សម្រាប់មនុស្សពាក្យថា "អភិវឌ្ឍន៍" មានន័យថា លទ្ធភាពអាចរស់នៅយូរអង្វែង ប្រកបដោយសុខភាពល្អ ទទួលបានការអប់រំ និងលទ្ធភាពទទួលបានធនធានចាំបាច់សម្រាប់ការរស់នៅសមរម្យ ។ ដើមឡើយគេកំណត់ពាក្យ "អភិវឌ្ឍន៍" សំដៅទៅលើវិសមភាពសេដ្ឋកិច្ចតែមួយមុខប៉ុណ្ណោះ ដោយផ្អែកលើលក្ខណវិនិច្ឆ័យជាច្រើនយកមកធ្វើជាមូលដ្ឋានគិត ក្នុងនោះមានមានផលិតផលក្នុងស្រុកសរុប និងផលិតផលជាតិសរុបជាដើម ។ ប៉ុន្តែសញ្ញាណនៃពាក្យ "អភិវឌ្ឍន៍" បែបសេដ្ឋកិច្ចនិយមនេះត្រូវគេជំទាស់ជាច្រើន ហើយលើកយករង្វាស់វិសមភាពថ្មីៗថែមទៀតសម្រាប់ធ្វើជាមូលដ្ឋាននៃការគិតលើការអភិវឌ្ឍប្រជាជននៃប្រទេសនីមួយៗ ។ ចាប់ពីឆ្នាំ 1990 មក កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានបង្កើតសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (IHD= Indiex of Human Development ឬ IDH= Indiex du dévelopement Humain) ដោយគិតលើសន្ទស្សន៍ធំៗបីជាមូលដ្ឋានគឺ សង្ឃឹមរស់ពីកំណើត អក្ខរភាពមនុស្សពេញវ័យ និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ ។ ចាប់ពីឆ្នាំ 1997 មក កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិបានរៀបចំឡើងនូវសន្ទស្សន៍មួយថ្មីទៀតសម្រាប់បំភ្លឺជ្រុងម្ខាងទៀតនៃការអភិវឌ្ឍមនុស្ស គឺសន្ទស្សន៍ភាពក្រីក្រ ។

មានការខុសគ្នាខ្លាំងរវាងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៃបណ្តាប្រទេសក្នុងពិភពលោក ក្នុងកម្រិតទាបបំផុត 0.273 (សៀរ៉ាឡេអូន) ខ្ពស់បំផុត 0.956 (ន័រវែស) ។ ក្នុងឆ្នាំ 2006 ប្រទេសកម្ពុជាមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស 0.575 ជាប់ចំណាត់ថ្នាក់ទី 116 លើ 177 ក្នុងចំណោមប្រទេសជាសមាជិកអង្គការសហប្រជាជាតិ (នៅឆ្នាំ 1997 ចំណាត់ថ្នាក់ 140 លើ 153) ។

# 1 វិសមភាពចំពោះសុខភាព

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីការចម្លងជំងឺផ្សេងៗ និងវិធីការពារខ្លួនជាមួយនឹងជំងឺឆ្លងនានា ។

សុខភាពប្រជាជន គឺជាផ្នែកមួយនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស និងជាកត្តាគន្លឹះនៃការអភិវឌ្ឍមនុស្ស ។ ភាពល្អប្រសើរនៃសុខភាពក៏ដូចជាជីវិត អាចវាស់វែងបានទៅតាមរបបម្ហូបអាហារដែលជាកត្តាសំខាន់សម្រាប់សុខុមាលភាពមនុស្សលោក ។

បច្ចុប្បន្ននៅប្រទេសកម្ពុជា ជំងឺឆ្លងត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង ពិសេសជំងឺគ្រុនចាញ់ ជំងឺអេដស៍ ដែលរីករាលដាលកាន់តែច្រើនឡើងៗ ។ បញ្ហាបន្ទាប់ដែលកំពុងចោទនៅកម្ពុជាដែរនោះ គឺកង្វះអាហាររូបត្ថម្ភរបស់កុមារ ។ កង្វះអាហារនេះ ជាកត្តានាំឱ្យមនុស្សមួយចំនួនក្នុងសង្គមងាយទទួលគ្រោះថ្នាក់ដោយជំងឺផ្សេងៗ ។

## 1. ជំងឺគ្រុនចាញ់

### 1.1. លក្ខណៈទូទៅ

ជំងឺគ្រុនចាញ់នៅតែជាជំងឺឆ្លង និងបង្កគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរបំផុត នៅក្នុងប្រទេសកំពុងអភិវឌ្ឍនៃពិភពលោក ។ មានប្រជាជនប្រមាណ 3 300 លាននាក់ រស់នៅក្នុងតំបន់ប្រឈមនឹងគ្រោះថ្នាក់ក្នុងប្រទេសចំនួន 109 លើពិភពលោក ។

យោងតាមរបាយការណ៍ស្ថិតិសុខាភិបាលឆ្នាំ 2006 បានបញ្ជាក់ឱ្យឃើញថា សព្វថ្ងៃនេះជំងឺគ្រុនចាញ់ គឺជាមូលហេតុលំដាប់ទី 6 នៃការចូលមកពិគ្រោះជំងឺ ជាលំដាប់ទី 5 នៃបញ្ហាសុខភាពចម្បងក្នុងចំណោមអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យនិងជាមូលហេតុទី 3 នៃអ្នកជំងឺស្លាប់ក្នុងមន្ទីរពេទ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គេបានប៉ាន់ប្រមាណឃើញមានប្រជាជនចំនួន 2 លាននាក់ ដែលរស់នៅក្នុងចម្ងាយ 2km ពីព្រៃ ត្រូវទទួលរងគ្រោះដោយជំងឺគ្រុនចាញ់និងប្រជាជនចំនួនប្រហែល 60 000 នាក់បានចូលមកទទួលសេវាព្យាបាលក្នុងមន្ទីរពេទ្យសាធារណៈក្នុងឆ្នាំ 2007 និងមានអ្នកស្លាប់ប្រមាណ 1 000 នាក់ក្នុងមួយឆ្នាំៗ ។ ភាពមេរោគស៊ាំនឹងថ្នាំព្យាបាល គឺជាបញ្ហាមួយដ៏ធំដែលធ្វើឱ្យរឹតតែមានភាពអាក្រក់បន្តិចម្តងៗ នៅក្នុងតំបន់ជាច្រើននៃប្រទេស ។

## 1.2. ភូមិសាស្ត្រនៃតំបន់ជំងឺគ្រុនចាញ់

បណ្ដាខេត្តទាំងអស់នៅប្រទេសកម្ពុជា ពុំមែនសុទ្ធតែបានទទួលគ្រោះថ្នាក់ដោយជំងឺគ្រុនចាញ់ដូចៗគ្នានោះទេ ។ ផ្ទៃដីទំហំ 62% គ្របដណ្ដប់ដោយព្រៃស្បាតដែលជាជម្រកនៃមូសដែកគោល ។ តំបន់ព្រៃស្បាតសុទ្ធសឹងជាតំបន់គ្រុនចាញ់កម្រិតមធ្យម(ភូមិភាគកណ្ដាល) និងគ្រុនចាញ់កម្រិតខ្ពស់(ភូមិភាគឦសាន ពាយ័ព្យ ឧត្តរនិងចម្ការកៅស៊ូ) ។ តំបន់ខ្ពង់រាបនិងភ្នំដែលសំបូរព្រៃឈើ ជាតំបន់គ្រោះថ្នាក់ដោយជំងឺគ្រុនចាញ់កម្រិតខ្ពស់ ពិសេសតំបន់ឦសាននៃខេត្តរតនគិរី តំបន់អាគ្នេយ៍នៃខេត្តក្រចេះ តំបន់តាមព្រំប្រទល់រវាងខេត្តព្រះវិហារនិងខេត្តឧត្តរមានជ័យ ព្រំប្រទល់ខេត្តបាត់ដំបង ពោធិ៍សាត់ ប៉ៃលិន និងតំបន់ចម្ការរកៅស៊ូ ។ មានប្រជាជនប្រមាណ 550 000 នាក់ ដែលភាគច្រើនជាជនជាតិភាគតិច បានរស់នៅតំបន់គ្រុនចាញ់កម្រិតខ្ពស់ ។ ប្រជាជនប្រមាណ 95% ទៀតរស់នៅតំបន់គ្រុនចាញ់កម្រិតមធ្យម និងតំបន់គ្មានគ្រុនចាញ់ ។ ដោយឡែកតំបន់ជុំវិញបឹងទន្លេសាប តំបន់ដីសណ្ដទន្លេមេគង្គ និងផ្នែកខាងក្រោមទន្លេបាសាក់ ពុំមានជំងឺគ្រុនចាញ់ទេ ។




បច្ចុប្បន្នកំណើននៃជំងឺគ្រុនចាញ់ផ្សារភ្ជាប់ទៅនឹងចលនាបំលាស់លំនៅរបស់ប្រជាជន ពិសេសបំលាស់លំនៅពីជនបទទៅជនបទក្នុងបំណងធ្វើអាជីវកម្ម រ៉ែត្បូង មាស កាប់អុស ធ្វើចម្ការជាដើម ។ ខេត្តដែលមានប្រជាជនស្លាប់ច្រើនជាងគេដោយជំងឺគ្រុនចាញ់មាន ខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ធំ ក្រចេះ និងកំពង់ចាម ។

## 1.3. ការចម្លងជំងឺគ្រុនចាញ់

គ្រុនចាញ់ជាជំងឺឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈមូសដែកគោលញីខាំ ។ ជំងឺនេះបង្កឡើងដោយមេរោគ អេម៉ាតូសូអ៊ែ (Hematozoaires) ជាពពួកមេរោគចូលចិត្តរស់នៅក្នុងគោលិកាឈាមក្រហម ។

ជំងឺគ្រុនចាញ់អាចកើតមានលើមនុស្សគ្រប់វ័យ បណ្ដាលមកពីមូសដែកគោលញីខាំ ពិសេសចន្លោះពេលពីរសៀលម៉ោង 4 រហូតដល់ម៉ោង 7 ព្រឹក ។ មូសដែកគោលញីខាំបឺតយកឈាមអ្នកផ្ទុកមេរោគគ្រុនចាញ់ហើយទៅខាំមនុស្សជាធម្មតា ។ ពេលនោះ មេរោគដែលនៅក្នុងទឹកមាត់មូសបានចូលទៅក្នុងឈាមអ្នកជាធ្វើឱ្យគេក្លាយខ្លួនទៅជាអ្នកជំងឺគ្រុនចាញ់បន្តទៀត ។ មេរោគគ្រុនចាញ់បានឆ្លងកាត់ជីវិតរស់នៅនិងវិវត្តនៅក្នុងខ្លួនមូសផងនិងក្នុងខ្លួនមនុស្សផង ។ ការវិវត្តនៃមេរោគនេះនៅក្នុងសត្វមូសក្នុងដំណាក់កាលបន្តពូជពី 10-14 ថ្ងៃ បន្ទាប់មក ពួកវាបង្កើតបានជាកូនចៅជាច្រើនក្នុងខ្លួនមូស ។ ប្រសិនបើមូសផ្ទុកមេរោគគ្រុនចាញ់បានខាំមនុស្សណាម្នាក់មានសុខភាពល្អ មេរោគនេះនឹងចូលទៅក្នុងខ្លួនអ្នកនោះភ្លាម តាមរយៈប្រព័ន្ធរបត់ឈាម ហើយអ្នកដែលត្រូវមូសខាំនឹងចាប់ផ្ដើមឈឺក្នុងរយៈពេល 1 ទៅ 3 សប្ដាហ៍បន្ទាប់មក ។

## 1.4. ផលវិបាកនៃជំងឺគ្រុនចាញ់

ជំងឺគ្រុនចាញ់បានធ្វើឱ្យអ្នកជំងឺទទួលរងនូវវិបាកផ្សេងៗដូចជា ថ្លើមរីក ធ្លាក់អណ្ដើក និងស្លេកស្លាំងដោយសារការបែកគ្រាប់ឈាមច្រើន ។ ការបែកគ្រាប់ឈាមច្រើននេះបណ្ដាលឱ្យខ្វះអុកស៊ីសែនចិញ្ចឹមកោសិកានិងអស់កម្លាំងល្ហិតល្ហៃ ដែលអាចឈានទៅបាត់បង់ស្មារតី ឬសន្លប់ក៏មាន ។

ចំពោះស្ត្រីមានផ្ទៃពោះមានគ្រោះថ្នាក់ពីរដងលើសមនុស្សធម្មតា ។ ជំងឺនេះធ្វើឱ្យកូនក្នុងផ្ទៃមានសភាពខ្សោយ ដោយសារម្ដាយខ្វះគ្រាប់ឈាមក្រហម ប្រឈមនឹងជំងឺស្លេកស្លាំងធ្ងន់ធ្ងរ និងមានការធ្លាក់ឈាមខ្លាំងនៅពេលសម្រាលកូន ។

ភាពស្លេកស្លាំងនេះបណ្ដាលឱ្យទារកស្លាប់ក្នុងផ្ទៃ ឬរលូត មានការលូតលាស់យឺតយ៉ាវក្នុងផ្ទៃកើតមិនគ្រប់ខែ កើតមកមានទម្ងន់មិនគ្រប់គ្រាន់ មានកម្លាំងខ្សោយ លូតលាស់មិនប្រក្រតី និងងាយទទួលយកជំងឺផ្សេងៗទៀតផង ។ អ្នកជំងឺមានសុខភាពចុះខ្សោយ មានសតិបញ្ញាអន់ មិនអាចរៀន ឬធ្វើការងារបានឡើយ ហើយនឹងឈានទៅស្លាប់ ប្រសិនបើការព្យាបាលយឺតយ៉ាវ ។

ជារួម គ្រួសារនិងសង្គមនឹងត្រូវបាត់បង់ធនធានមនុស្សសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចគ្រួសារនិងអភិវឌ្ឍប្រទេសជាតិ ។

# 2. ជំងឺអេដស៍

## 2.1. លក្ខណៈទូទៅ

អេដស៍ជាជំងឺរាតត្បាត កើតមានយ៉ាងពិតប្រាកដ ហើយបានឆ្លងរាលដាលពេញពិភពលោកទាំងមូល ។ ជំងឺនេះពុំមានឱសថណាអាចព្យាបាលឱ្យជាសះស្បើយបានឡើយ ។ មេរោគអេដស៍ (HIV) ជាមេរោគ(វីរុស) ដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់សារពាង្គកាយមនុស្សចុះខ្សោយ រីឯជំងឺអេដស៍ (AIDS) ជាប្រជុំរោគសញ្ញា ដែលកើតក្រោយពីប្រព័ន្ធភាពស៊ាំរបស់សារពាង្គកាយមនុស្សចុះខ្សោយ ។ ដូច្នេះជំងឺអេដស៍ គឺជាដំណាក់ចុងបញ្ចប់នៃការបង្កឡើងដោយមេរោគអេដស៍ (HIV) ។

អង្គការសុខភាពពិភពលោកឆ្នាំ 1991 បានប៉ាន់ស្មានថា មនុស្ស 8 ទៅ 10 លាននាក់ នៅលើពិភពលោក បានទទួលការបង្ករោគដោយវីរុស HIV ។ តាមការប៉ាន់ស្មានចំនួនកុមារនិងយុវវ័យ ដែលផ្ទុកមេរោគអេដស៍ ឬកើតជំងឺអេដស៍ រហូតមកដល់ចុងឆ្នាំ 2007 កើនឡើងរហូតដល់ 33.24 លាននាក់ (ថយចុះបន្តិចពីឆ្នាំ 2005 ដែលមាន 40.27 លាននាក់) ។

អាហ្វ្រិក ជាទ្វីបដែលមានអត្រាជំងឺអេដស៍ខ្ពស់ជាងគេក្នុងពិភពលោក បន្ទាប់មកគឺទ្វីបអាស៊ី ។ អាស៊ីខាងត្បូងនិងអាស៊ីអគ្នេយ៍ មានអត្រាជំងឺអេដស៍ខ្ពស់ជាងគេក្នុងចំណោមបណ្តាប្រទេសនៃទ្វីបអាស៊ី ដែលមានកម្ពុជានៅក្នុងនោះដែរ ។




## 2.2. ជំងឺអេដស៍នៅប្រទេសកម្ពុជា

តាមកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ 1997 ប្រទេសកម្ពុជាជួបប្រទះការចម្លងជំងឺអេដស៍ខ្លាំងក្លាជាងគេបំផុតនៅទ្វីបអាស៊ី ។ បច្ចុប្បន្ន ថ្វីត្បិតអ្នកកើតជំងឺនេះថយចុះបន្តិចក៏ដោយ ក៏អត្រានៅតែមានកម្រិតខ្ពស់នៅឡើយ បើធៀបនិងប្រទេសក្នុងតំបន់ក៏ដូចជានៅទ្វីបអាស៊ី ។

ចំនួនមនុស្សដែលកំពុងរស់នៅដោយផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍(កម្ពុជា)

| ឆ្នាំ 2006 | ឆ្នាំ 2007 | ឆ្នាំ 2009 |
|---|---|---|
| 150 000 នាក់ | 123 100 នាក់ | 57 900 នាក់ |

តាមការប៉ាន់ប្រមាណមនុស្សជាង 7 000 នាក់ ឆ្លងមេរោគអេដស៍ជារៀងរាល់ឆ្នាំ ហើយបើតាមការប្រមើលមើលឃើញថា មានមនុស្សចំនួន 20 000 នាក់ នឹងត្រូវស្លាប់ជារៀងរាល់ឆ្នាំ ដោយជំងឺនានាពាក់ព័ន្ធនឹងជំងឺអេដស៍ ។

នៅក្នុងចំនួន 123 100 នាក់ ដែលកំពុងរស់នៅដោយផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍នៅឆ្នាំ 2007 មានចំនួន 12 000 នាក់ ជាកុមារ ។ ថ្វីបើអត្រានៃការឆ្លងជំងឺអេដស៍បានថយចុះខ្លះក៏ដោយ ក៏ការចំណាយទៅលើការថែទាំមនុស្សដែលកំពុងរស់នៅដោយផ្ទុកមេរោគអេដស៍ / ជំងឺអេដស៍ នៅមានអត្រាខ្ពស់នៅឡើយ រហូតមកដល់ចុងទសវត្សរ៍នេះ ។

ការធ្វើតេសឈាមនិងផ្តល់ប្រឹក្សាដោយស្ម័គ្រចិត្ត គឺជាយុទ្ធវិធីមួយដែលរួមបញ្ចូលទាំងការផ្តល់ប្រឹក្សាមុននិងក្រោយការធ្វើតេសឈាម នៅក្នុងដំណើរការស្វែងរកស្ថានភាពមេរោគអេដស៍ ។ បុគ្គលម្នាក់ៗ ដែលដឹងអំពីស្ថានភាពមេរោគអេដស៍របស់ខ្លួន អាចរកវិធានការសមស្របដើម្បីការពារអ្នកដទៃនិង ថែរក្សាសុខភាពខ្លួនឯង ។

កុមារជាច្រើនបានឆ្លងមេរោគអេដស៍ពីម្តាយទៅកូន ។ ដើម្បីកាត់បន្ថយនូវការចម្លងមេរោគនេះឱ្យមានកម្រិតទាប ស្ត្រីមានផ្ទៃពោះនិងស្វាមី ឬដៃគូ គប្បីស្ម័គ្រចិត្តទៅធ្វើតេសឈាមដើម្បីពិនិត្យមេរោគអេដស៍ ។

## 2.3. របៀបឆ្លងនិងមិនឆ្លងនៃមេរោគអេដស៍

- **របៀបឆ្លង**




*ជំងឺអេដស៍គ្មានថ្នាំព្យាបាលទេ តែអាចបង្ការបាន (អត្រាឆ្លងដោយការរួមភេទខ្ពស់ជាងគេ 70%)*

- **របៀបមិនឆ្លង**

មេរោគអេដស៍មិនឆ្លងតាមទឹកមាត់ មូសខាំ តាមការដកដង្ហើម ទឹក ចំណីអាហារ ការប៉ះពាល់លើស្បែក ខោអាវ ប្រដាប់ប្រដាផ្ទះបាយ ហូបចុករួមគ្នា កំដរអ្នកជំងឺ និងគ្រប់សកម្មភាពរស់នៅប្រចាំថ្ងៃនោះទេ ។

## 2.4. ការវិវត្តនៃមេរោគអេដស៍

ក្រោយពីមេរោគអេដស៍ចូលក្នុងខ្លួនមនុស្ស វាយាយីប្រព័ន្ធភាពស៊ាំរបស់មនុស្ស ហើយវិវត្តជាច្រើនដំណាក់

- ដំណាក់ចំហ គឺជាការឆ្លងដំបូង ។ អ្នកផ្ទុកមេរោគអេដស៍មួយចំនួនតូចមានរោគសញ្ញាបន្តិចបន្តួចដូចជា ផ្តាសាយមិនគួរឱ្យចាប់អារម្មណ៍ ហើយមួយចំនួនធំមានសុខភាពល្អដូចជាធម្មតាពុំមានរោគសញ្ញាអ្វីទាំងអស់ ។
- ដំណាក់តែសឈាមវិជ្ជមាន : ក្នុងដំណាក់នេះ អ្នកផ្ទុកមេរោគអេដស៍ភាគច្រើនមានសុខភាពល្អ ។ មួយចំនួនតូចគេសង្កេតឃើញមានកូនកណ្តុរនៅក្លៀក នៅក... ។ ពេលនេះការធ្វើតែសឈាមផ្តល់លទ្ធផលវិជ្ជមាន ។
- ដំណាក់ជំងឺអេដស៍ : អ្នកផ្ទុកមេរោគអេដស៍ភាគច្រើនវិវត្តទៅជាអ្នកជំងឺអេដស៍ ក្នុងរយៈពេល 10ឆ្នាំ តែរយៈពេលនេះ អតិបរមារបស់វានៅតែមិនច្បាស់លាស់ ហើយប្រែប្រួលទៅតាមសុខភាពបុគ្គលម្នាក់ៗ ។ ក្នុងរយៈពេលនេះ អ្នកជំងឺទទួលការរាតត្បាតពីមេរោគឱកាសនិយមដូចជា របេង រាក ជំងឺសើស្បែក ហើយវិវត្តទៅរកសេចក្តីស្លាប់ក្នុងរយៈពេល 2ឆ្នាំបន្ទាប់ ។

# 3. ការបរិភោគមិនគ្រប់គ្រាន់

បញ្ហាចោទនៅលើពិភពលោកសព្វថ្ងៃ គឺកង្វះអាហារនិងការបរិភោគមិនគ្រប់គ្រាន់សម្រាប់មនុស្សលោកដែលចេះតែកើនឡើងយ៉ាងខ្លាំង ។ ការបរិភោគមិនគ្រប់គ្រាន់ចោទខ្លាំងនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ពីព្រោះចំនួនប្រជាជនមានច្រើនលើសលប់ ហើយមានកំណើនខ្ពស់ រីឯផលិតកម្ម (ពិសេសផលិតកម្មស្បៀង)មានកំណើនយឺត ។ កង្វះអាហារនិងការបរិភោគមិនគ្រប់គ្រាន់នាំឱ្យកើតជំងឺខ្វះជីវជាតិដែលធ្វើឱ្យមនុស្សស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់ ពិសេសចំពោះកុមារតូចៗ ។ កង្វះអាហារូបត្ថម្ភធ្វើឱ្យកុមារងាយរងគ្រោះ ឬស្លាប់ដោយសារជំងឺ ។ កុមារដែលខ្វះអាហារូបត្ថម្ភ មានការវិវត្តរាងកាយ និងសមត្ថភាពខាងប្រាជ្ញាមិនបានពេញលេញ ដែលនាំឱ្យការរៀនសូត្រធ្លាក់ក្រោមកម្រិតមធ្យម និងផលិតភាពការងារមានកម្រិតទាបក្នុងមួយជីវិតរបស់គេ ។ ដើម្បីដោះស្រាយបញ្ហានេះ គេត្រូវរកវិធីទប់ទល់នឹងកំណើនប្រជាជននិងត្រូវខិតខំលើកកម្ពស់កម្រិតជីវភាព ដោយបង្កើនផលិតផលកសិកម្ម ពិសេសផលិតផលអាហារឱ្យបានគ្រប់គ្រាន់ ។

## ១.1. ចំណីអាហាររបស់ប្រជាជនកម្ពុជា

អាហារមូលដ្ឋានរបស់ប្រជាជនកម្ពុជា គឺបាយដែលបានពីស្រូវ ។ បាយផ្តល់កាឡូរី $\frac{2}{3}$ សម្រាប់ប្រជាជនកម្ពុជាម្នាក់ៗ ។ ប៉ុន្តែបាយផ្តល់កាឡូរីពុំទាន់គ្រប់គ្រាន់ទេ ព្រោះបាយខ្វះសារធាតុចិញ្ចឹមទៀតជាច្រើនដូចជា ជាតិដែក ជីវជាតិអា... ។ ស្ត្រីនិងកុមារកម្ពុជាជាច្រើនរងជំងឺខ្វះជីវជាតិ ជំងឺខ្វះឈាមក្រហម(កង្វះជាតិដែក) ជំងឺស្លឹក(កង្វះជីវជាតិអា...) ។

មានវិសមភាពរវាងអ្នករស់នៅទីក្រុងនិងជនបទ ក្នុងការទទួលទានអាហារ ។ អ្នកជនបទទទួលទានអាហារមូលដ្ឋានមានកាឡូរីច្រើនជាងអ្នកទីក្រុង(2330 កាឡូរី ទល់នឹង 2153 កាឡូរី / ម្នាក់ / 1 ថ្ងៃ) ។ រីឯអ្នកក្រីក្រជាងគេរស់នៅទីក្រុង ទទួលបាន 2100 កាឡូរីសម្រាប់មនុស្សម្នាក់ក្នុង 1 ថ្ងៃ ។

ចំណីអាហារផ្សេងៗជាកត្តាសំខាន់ណាស់ ព្រោះវាផ្តល់សារធាតុផ្ទុកកាឡូរីចាំបាច់សម្រាប់ការលូតលាស់នៃសរីរាង្គ ។ អ្នកដែលមានជីវភាពធូរធារទទួលទានអាហារផ្សេងៗបានច្រើនដូចជា សាច់ជ្រូក សាច់គោ សាច់មាន់ សាច់ត្រី ផ្លែឈើ ... ។

## ១.2. ការផ្តល់អាហារមិនត្រឹមត្រូវដល់កុមារ

តាមប្រភពស្ថិតិឆ្នាំ 2008 អត្រាមរណទារកនៅកម្ពុជាមាន 58 លើទារកកើតរស់ 1000 នាក់(ទីក្រុងមាន 34 និងជនបទ 62) ។ អត្រាមរណប្រមាណកុមារអាយុ 5 ឆ្នាំ មាន 44 ភាគពាន់(ទីក្រុងមាន 22 និងជនបទ 48) ។ អត្រាមរណប្រមាណកុមារ មាន 6 ភាគពាន់(ទីក្រុងមាន 2 និងជនបទ 6) ។ អត្រាមរណប្រមាណមាតាមាន 461 ក្នុងកំណើតរស់ 100 000 នាក់(ទីក្រុងមាន 287 និងជនបទ 490) ។

កុមារកម្ពុជាអាយុពី 2 ឆ្នាំឡើងទៅទទួលការផ្គត់ផ្គង់អាហារូបត្ថម្ភមិនបានត្រឹមត្រូវ ។ កម្ពុជាជាប្រទេសមួយដែលមានអត្រាកង្វះខាតអាហារូបត្ថម្ភខ្ពស់បំផុតនៅក្នុងតំបន់និងនៅក្នុងពិភពលោក ។ កុមារកម្ពុជាជិតពាក់កណ្តាលអាយុក្រោម 5 ឆ្នាំ មានបញ្ហាកង្វះអាហារូបត្ថម្ភ(ឡាវមាន 42% វៀតណាមមាន 30% និងថៃមាន 12%) ។ កង្វះអាហារូបត្ថម្ភ ពុំមែនគ្រាន់តែបណ្តាលមកពីកង្វះចំណីអាហារប៉ុណ្ណោះទេ ប៉ុន្តែក៏អាចបណ្តាលមកពីកង្វះការថែទាំពីមាតាបិតា កង្វះសេវាសុខភាព កង្វះអនាម័យ កង្វះការប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យផងដែរ ។

មានទារកត្រឹមតែ 35% ប៉ុណ្ណោះដែលម្តាយបានបំបៅដោះនៅក្នុងអំឡុងម៉ោងដំបូងបន្ទាប់ពីសម្រាលរួច(ទឹកដោះដំបូង ឬទឹកដោះព្រៃ) និងមានទារកត្រឹមតែ 68% ប៉ុណ្ណោះដែលម្តាយចាប់បំបៅដោះចាប់ពីថ្ងៃទី 1 នៃជីវិតរបស់គេ ។ មានទារកចំនួនតែ 65.9% ប៉ុណ្ណោះដែលទទួលការបំបៅដោយទឹកដោះម្តាយតែមួយមុខគត់ ក្នុងរយៈពេល 6 ខែដំបូងនៃជីវិត ។ មានម្តាយជាច្រើននាក់បានអនុវត្តខុសឆ្គងដោយបានផ្តល់ ឬបញ្ចុកសារធាតុរាវផ្សេងៗបន្ថែមពីលើទឹកដោះដល់ទារកដែលមានអាយុក្រោម

6ខែ ។ ការផ្តល់ទឹក ឬសារធាតុរាវផ្សេងៗ ឬចំណីអាហារជាអាហារប្រចាំថ្ងៃបន្ថែមដល់ទារកក្នុងអំឡុងពេល 6ខែដំបូងនៃជីវិតរបស់គេ ធ្វើឱ្យទារកប្រឈមនឹងគ្រោះថ្នាក់ជាច្រើនដូចជា រាករូស រលាកផ្លូវដង្ហើមស្រួចស្រាវ ខ្វះអាហារូបត្ថម្ភ ឬលូតលាស់យឺតយ៉ាវ ។ ប៉ុន្តែនៅ ពេលដែលទារកមានអាយុចាប់ពី 6ខែឡើងទៅ ទឹកដោះម្តាយតែមួយមុខគត់មិនអាចគ្រប់គ្រាន់ សម្រាប់ការលូតលាស់ផ្នែករាងកាយ និងបញ្ញាបានទៀតឡើយ ដូច្នេះ ត្រូវផ្តល់អាហារបន្ថែមឱ្យបាន សមស្របប្រចាំថ្ងៃនិងបន្តបំបៅដោះរហូតដល់ទារកអាយុយ៉ាងតិច 2ឆ្នាំ ឬលើសពីនេះ ។

កង្វះសារជាតិចិញ្ចឹម ធ្វើឱ្យកុមារស្គម ស្បែកដណ្តប់ឆ្អឹង សាច់ដុំទន់ជ្រាយយារជ្រីវជ្រួញ ចុះទម្ងន់ ហើយរាករូសញឹកញាប់ ។ គេច្រើនហៅជំងឺទទួលទានអាហារមិនត្រឹមត្រូវនិងមិនគ្រប់គ្រាន់របស់កុមារនេះថាជាជំងឺពិសអាចម៍កុក ។ ជំងឺនេះអាចឱ្យកុមារស្លាប់បានយ៉ាងងាយដោយមានជំងឺផ្សេងៗ ទៀតម-ករាតត្បាតបន្ថែម ពិសេសជំងឺរាក ។

យុទ្ធវិធីសម្រាប់ទប់ទល់នឹងបញ្ហាខាងលើ ក្រសួងសុខាភិបាលត្រូវអប់រំមាតាបិតា ឬអាណាព្យាបាលឱ្យចេះថែទាំកុមារឱ្យបានត្រឹមត្រូវ ទាំងការបំបៅដោះកូន និងការបង្កើនគុណភាពចំណីអាហារដែលសំបូរជីវជាតិអាដូចជា បន្លែស្លឹកបៃតង បន្លែ ផ្លែឈើពណ៌លឿង សាច់ ស៊ុត ថ្លើមជាដើម ។

## ? សំណួរ

1. ហេតុអ្វីបានជាគេចាត់ទុកជំងឺគ្រុនចាញ់ជាជំងឺឆ្លង ?
2. ខេត្តណាខ្លះដែលឆ្លងជំងឺគ្រុនចាញ់ច្រើនជាងគេ ? ហេតុអ្វី ?
3. តើមេរោគអេដស៍និងជំងឺអេដស៍ខុសគ្នាដូចម្តេច ?
4. តើទ្វីបណាដែលមានអត្រាជំងឺអេដស៍ខ្ពស់ជាងគេ ? តើវ័យណាខ្លះដែលមានជំងឺអេដស៍ ? ហេតុអ្វីបានជាវ័យពី 15 ទៅ49 ឆ្នាំប្រឈមនឹងជំងឺអេដស៍ខ្ពស់ជាងគេ ?
5. តើអេដស៍ឆ្លងនិងមិនឆ្លងក្នុងករណីណាខ្លះ ?
6. ហេតុអ្វីបានជាប្រទេសកំពុងអភិវឌ្ឍមានបញ្ហាចោទអំពីការបរិភោគមិនគ្រប់គ្រាន់ ?
7. តើកង្វះអាហារូបត្ថម្ភបណ្តាលមកពីកង្វះចំណីអាហារតែមួយមុខ ឬដូចម្តេច ?
8. តើការបំបៅដោះកូនដោយទឹកដោះម្តាយមានផលប្រយោជន៍យ៉ាងណាខ្លះចំពោះទារក ?

មេរៀនទី

# 2 វិសមភាពចំពោះការអប់រំ

**ចប់មេរៀននេះ សិស្សអាច**

- យល់ពីស្ថានភាពអប់រំនៅកម្ពុជា
- ប្រៀបធៀបអក្ខរភាពមនុស្សពេញវ័យនៅកម្ពុជា ជាមួយប្រទេសមួយចំនួននៅអាស៊ី
- យល់ពីអត្ថប្រយោជន៍នៃអក្ខរភាពចំពោះការអភិវឌ្ឍសង្គមនិងទៅលើឥរិយាបថប្រជាសាស្ត្រ ។

ការអប់រំ គឺជាកម្លាំងសម្រាប់កែប្រែសង្គមនិងជាកត្តាដ៏សំខាន់បំផុតតែមួយគត់សម្រាប់ប្រយុទ្ធប្រឆាំងនិងភាពក្រីក្រ ផ្តល់សិទ្ធិអំណាចដល់ស្ត្រី ការពារកុមារពីការកេងប្រវ័ញ្ច លើកស្ទួយសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ការពារបរិស្ថាន និងសម្រាប់គ្រប់គ្រងការរីកចម្រើនរបស់ពលរដ្ឋ ។ លើសពីនេះទៀត ការអប់រំមានឥទ្ធិពលទៅលើឥរិយាបថប្រជាសាស្ត្រដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ លទ្ធភាពបង្កើតកូន មរណភាព បំលាស់លំនៅ ក៏ដូចជាការចូលរួមក្នុងកម្លាំងពលកម្មថែមទៀតផង ។ ដូច្នេះ កម្រិតអក្ខរកម្មនិងការសិក្សា ត្រូវបានចាត់ទុកជាសូចនាករមួយដ៏សំខាន់នៃការអភិវឌ្ឍសង្គម និងក៏ជាផ្នែកមួយសំខាន់ ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ប្រទេសនីមួយៗ ។ នៅក្នុងគោលដៅជាមូលដ្ឋានទាំង ៩ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់ព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ 2015 គោលដៅអប់រំជាគោលដៅមូលដ្ឋានទី 2 ដែលត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងខ្លឹមសារ " សម្រេចឱ្យបានជាទូទៅការអប់រំជាមូលដ្ឋានរយៈពេល ៩ ឆ្នាំ " ។

ប៉ុន្តែ បញ្ហាចំពោះមុខនៅក្នុងការអប់រំរបស់ប្រជាជនកម្ពុជានាបច្ចុប្បន្ន គឺវិសមភាពចំពោះការអប់រំដែលទាក់ទងទៅនឹងវិសមភាពទទួលការអប់រំតាមភេទ និងនៅតាមតំបន់ទីប្រជុំជននិងជនបទ ដែលបណ្តាលមកពីមូលហេតុសេដ្ឋកិច្ចគ្រួសារ ទំនៀមទម្លាប់ប្រពៃណី និងមធ្យោបាយទៅកាន់សាលារៀន ។

ដើម្បីអនុវត្តគោលនយោបាយអប់រំឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលនិងក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់កសាងគ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សាក្នុងទូទាំងប្រទេស និងខិតខំប្រមូលកុមារ យុវជន ប្រជាជនឱ្យបានចូលរៀនគ្រប់ៗគ្នា ។

# 1. សម្បទាខាងអំណាននិងសំណេររបស់ប្រជាជនកម្ពុជា

## 1.1. លក្ខណៈទូទៅ

ចំនួនប្រជាជនចេះអាននិងសរសេរ ចាប់ពីអាយុ 7ឆ្នាំឡើងទៅនៅក្នុងប្រទេសបានកើនឡើងខ្លាំង គឺពី 5.78 លាននាក់នៅឆ្នាំ 1998 ទៅ 8.96លាននាក់នៅឆ្នាំ 2008 ។ បើគិតជាអត្រាកំណើនក្នុងរយៈពេល 10ឆ្នាំនេះ គឺមានជិត 55%ទល់នឹងអត្រាកំណើនប្រជាជន ដែលមានតែ 17%ប៉ុណ្ណោះ ។ អត្រាអក្ខរកម្ម ទូទៅ ដែលជាភាគរយនៃប្រជាជនចេះអាននិងសរសេរធៀបនឹងប្រជាជនសរុបអាយុ 7ឆ្នាំឡើង បាន កើនឡើងពី 62.80%នៅឆ្នាំ 1998 ដល់ 78.35%នៅឆ្នាំ 2008 ។




*ចំនួនប្រជាជនចេះអក្សរនៅកម្ពុជាឆ្នាំ 1998 និង 2008*

## 1.2. វិសមភាពនៃអក្ខរភាព

ថ្វីត្បិតតែអត្រាអក្ខរភាពមានការកើនឡើងខ្ពស់ក្នុងរយៈពេលកន្លងមកនេះក៏ដោយ ប៉ុន្តែប្រជាជនកម្ពុជាទាំងអស់ពុំទាន់បានឆ្លងផុតពីអក្ខរភាពទាំងស្រុងនោះទេ ។ គេសង្កេតឃើញមានវិសមភាពនៃអក្ខរភាពតាមភេទ និងវិសមភាពនៃអក្ខរភាពរវាងប្រជាជនទីប្រជុំជននិងជនបទ ។

អត្រាអក្ខរភាពប្រជាជនភេទប្រុស ចាប់ពីអាយុ 7ឆ្នាំឡើងទៅ បានកើនពី 71.03%នៅឆ្នាំ 1998 ទៅ 83.99%នៅឆ្នាំ 2008 និងចំពោះប្រជាជនភេទស្រីវិញបានកើនពី 55.05%ទៅ 73.10% ។ ថ្វីត្បិតតែអត្រាអក្ខរភាពប្រជាជនភេទប្រុសនៅខ្ពស់ជាងប្រជាជនភេទស្រី ប៉ុន្តែកំណើនផ្នែកអក្ខរភាពរបស់ប្រជាជនភេទស្រីមានសន្ទុះខ្លាំងជាងប្រជាជនភេទប្រុសក្នុងអត្រា 18%ទល់នឹង 13% ។ អក្ខរភាពប្រជាជនអាយុ

ចាប់ពី 7ឆ្នាំឡើងទៅដែលរស់នៅទីក្រុង មានកម្រិតខ្ពស់ជាងជនបទទាំងភេទប្រុសនិងភេទស្រី ។ ប៉ុន្តែ អត្រាកំណើនអក្ខរភាពប្រជាជនជនបទ មានកម្រិតខ្ពស់ជាងប្រជាជនទីប្រជុំជន គឺកើនពីអត្រា 59.07% នៅឆ្នាំ 1998 ទៅ 75.33% នៅឆ្នាំ 2008 រីឯនៅទីប្រជុំជនកើនពី 78.51% ទៅ 90.17% ។

ក្នុងចំណោមអ្នកចេះអាននិងសរសេរសរុប មានប្រជាជនប្រមាណ 92% ដែលចេះអាននិងសរសេរតែភាសាខ្មែរ 5% ចេះភាសាខ្មែរនិងអង់គ្លេស 2% ចេះភាសាខ្មែរនិងភាសាដទៃទៀតលើកលែងតែអង់គ្លេស និង 1% ដែលចេះអាននិងសរសេរភាសាណាមួយក្រៅពីភាសាខ្មែរ ។




*ភាគរយនៃប្រជាជនកម្ពុជាអាយុ 7ឆ្នាំឡើងទៅដែលចេះអាននិងចេះសរសេរភាសាផ្សេងៗ*

## 1.៣. អក្ខរភាពមនុស្សពេញវ័យ

អក្ខរភាពមនុស្សពេញវ័យនៅកម្ពុជាពីឆ្នាំ 1998 ដល់ឆ្នាំ 2008 មានការកើនឡើងក្នុងទូទាំងប្រទេស ក្នុងនោះ ចំនួនស្ត្រីបានកើនខ្ពស់ជាងបុរស ទាំងនៅតំបន់ទីប្រជុំជននិងជនបទ ។ អត្រាកំណើនអក្ខរភាព នៅទីប្រជុំជនខ្ពស់ជាងនៅជនបទសម្រាប់ទាំងពីរភេទ ។

អត្រាអក្ខរភាពមនុស្សពេញវ័យពីឆ្នាំ 1998 ដល់ឆ្នាំ 2008 ចំពោះប្រជាជនសរុប បានកើន 10.25% (67.34% - 77.59%) ចំពោះបុរសកើន 5.6% (79.48% - 85.08%) និងចំពោះស្ត្រីកើន 13.87% (56.99% - 70.86%) ។ តួលេខនេះបានបង្ហាញនូវគម្លាតដ៏តូចនៃយេនឌ័រ ខាងការចេះអាននិងសរសេរ ក៏ដូចជាបង្ហាញឱ្យឃើញនូវតួនាទីរបស់ស្ត្រីក្នុងការចូលរួមក្នុងកិច្ចការសង្គមដែលមានចំនួនកាន់តែច្រើនឡើងៗ ។

**អក្ខរភាពមនុស្សពេញវ័យតាមភេទនិងទីកន្លែងរស់នៅ ពីឆ្នាំ 1998 ដល់ ឆ្នាំ 2008**

| សរុប/ទីប្រជុំជន/ជនបទ | 1998 | | | 2008 | | | កំណើនក្នុងអំឡុងឆ្នាំ 1998-2008 | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **សរុប** | 4 390 755 | 2 383 479 | 2 007 276 | 6 891 035 | 3 574 466 | 3 316 569 | 2 500 280 | 1 190 987 | 1 309 293 |
| | | | | | | | (56.94%) | (49.97%) | (65.23%) |
| ទីប្រជុំជន | 1 079 220 | 563 438 | 515 782 | 1 762 852 | 865 304 | 897 548 | 683 632 | 301 866 | 381 766 |
| | | | | | | | (63.35%) | (53.58%) | (74.02%) |
| ជនបទ | 3 311 535 | 1 820 041 | 1 491 494 | 5 128 183 | 1 709 162 | 2 419 021 | 1 816 648 | 889 121 | 927 527 |
| | | | | | | | (54.86%) | (48.85%) | (62.19%) |

*សម្គាល់*

- ភាគរយនៃអ្នកចេះអាននិងសរសេរ ត្រូវបានគណនាដោយមិនរាប់បញ្ចូលការចេះអាននិងសរសេរដែលមិនបានរាយការណ៍ ។
- កំណើនភាគរយក្នុងអំឡុងឆ្នាំ 1998-2008 ត្រូវបានបង្ហាញក្នុងវង់ក្រចក សម្រាប់ទាំងពីរភេទប្រុសនិងស្រី ។

ដោយមិនរាប់បញ្ចូលប្រទេសឡាវ អត្រាអក្ខរភាពរបស់មនុស្សពេញវ័យនៅកម្ពុជាទាបជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ថ្វីបើប្រទេសមួយចំនួនតូចនៅទ្វីបអាស៊ី មានកម្រិតអក្ខរភាពរបស់មនុស្សពេញវ័យតិចជាងកម្ពុជាក៏ដោយ ។

**អត្រាអក្ខរភាពរបស់មនុស្សពេញវ័យនៃប្រទេសមួយចំនួនឆ្នាំ 2008**

| ឈ្មោះប្រទេស | ភាគរយ | ឈ្មោះប្រទេស | ភាគរយ |
|---|---|---|---|
| បង់ក្លាដេស | 47.50 | ម៉ាឡេស៊ី | 88.70 |
| ប៊ូតង់ | 47.50 | វៀតណាម | 90.30 |
| នេប៉ាល់ | 48.60 | ឥណ្ឌូណេស៊ី | 90.40 |
| ប៉ាគីស្ថាន | 49.90 | សិង្ហបុរី | 92.50 |
| ឥណ្ឌា | 61.100 | ថៃ | 92.60 |
| ឡាវ | 68.70 | សាធារណរដ្ឋកូរ៉េ | 99.00 |
| កម្ពុជា | 77.59 | | |

## 2. ការចូលរៀនតាមកម្រិតសិក្សា

### 2.1. លក្ខណៈទូទៅ

ប្រព័ន្ធអប់រំចំណេះទូទៅនៅប្រទេសកម្ពុជាជាប្រព័ន្ធ 12ឆ្នាំ គឺ 6ឆ្នាំ នៅបឋមសិក្សា(អាយុពី 6ឆ្នាំ ដល់ 11ឆ្នាំ) 3ឆ្នាំនៅមធ្យមសិក្សាបឋមភូមិ (អាយុពី 12ឆ្នាំ ទៅ 14ឆ្នាំ) និង3ឆ្នាំនៅមធ្យមសិក្សាទុតិយភូមិ (អាយុពី 15ឆ្នាំ ដល់ 17ឆ្នាំ)។ ការចូលរៀននៅគ្រប់កម្រិតសិក្សា បើធៀបទៅនឹងឆ្នាំមុនៗឃើញមានការកើនឡើង ប៉ុន្តែបើធៀបទៅនឹងចំនួនសរុបវិញ (គិតជាអត្រា) ឃើញថានៅមានកម្រិតទាបនៅឡើយ ។ នៅឆ្នាំសិក្សា 2008-2009 មានកុមារអាយុពី 3 ទៅ 5ឆ្នាំត្រឹមតែ 10.24%ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យរដ្ឋ ។

ការស្រាវជ្រាវមួយបង្ហាញឱ្យឃើញថា កុមារដែលបានចូលរៀនថ្នាក់អប់រំកុមារតូចនៅអាយុ 5ឆ្នាំ ច្រើនត្រៀមខ្លួនបានល្អសម្រាប់ទទួលការអប់រំកម្រិតបឋមសិក្សា និងរៀនពូកែ ហើយការបោះបង់ការសិក្សាមានតិចជាងកុមារដែលមិនបានចូលរៀនថ្នាក់អប់រំកុមារតូច ។ បច្ចុប្បន្ន នៅប្រទេសកម្ពុជាមានថ្នាក់មត្តេយ្យចំនួន 75.25% ស្ថិតនៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលប្រជាពលរដ្ឋនៅជនបទមានដល់ 80.48% ។ ក្នុងចំណោមឃុំទាំង 1417 ទូទាំងប្រទេស មានឃុំចំនួនតែ 176ប៉ុណ្ណោះ ដែលបានផ្តួចផ្តើម ចាត់ចែងបង្កើតមណ្ឌលមត្តេយ្យសិក្សាសម្រាប់កុមារ 3-5ឆ្នាំ ។ ដូចនេះ ឃើញថាកម្រិតចូលរៀននៅមត្តេយ្យសិក្សារបស់កុមារកម្ពុជាមានកម្រិតទាបបើធៀបទៅនឹងប្រទេសនានាក្នុងតំបន់ ។

សម្រាប់កម្រិតបឋមសិក្សា ក្នុងឆ្នាំសិក្សា 2008-2009 មានកុមារ 91.9% នៃកុមារដល់វ័យសិក្សា (អាយុ 6ឆ្នាំ) បានចុះឈ្មោះចូលរៀនកម្រិតដំបូង(ថ្នាក់ទី 1)។ ការសិក្សាស្រាវជ្រាវបានបញ្ជាក់ថា កុមារជាពិសេសកុមារី ដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី 1 តាមអាយុត្រឹមត្រូវ (6ឆ្នាំ) បោះបង់ការសិក្សាតិច និងមានឱកាសអាចរៀនចប់ថ្នាក់អប់រំមូលដ្ឋានច្រើនជាង បើប្រៀបធៀបទៅនឹងកុមារ ដែលចាប់ផ្តើមចូលរៀនកម្រិតដំបូង(ថ្នាក់ទី 1) នៅពេលដែលគេមានអាយុលើសពី 6ឆ្នាំ ។ ក្នុងចំណោមកុមារសរុបដែលបានចុះឈ្មោះចូលរៀនថ្នាក់ដំបូង មានតែ 59.3%ប៉ុណ្ណោះ ដែលអាចរៀនដល់ថ្នាក់បញ្ចប់នៃអប់រំ កម្រិតបឋមសិក្សា(ថ្នាក់ទី 6)។ កុមារជាច្រើននាក់ដែលពុំបានរៀនចប់កម្រិតបឋមសិក្សា ក្លាយខ្លួនជាអនក្ខរជនវិញភ្លាមបន្ទាប់ពីគេឈប់រៀន ។

នៅឆ្នាំ 2008 ក្នុងចំណោមប្រជាជនដែលចេះអាននិងសរសេរនៅកម្ពុជា ប្រជាជនប្រមាណ 49% ដែលមិនបានបញ្ចប់កម្រិតបឋមសិក្សា 29%បានបញ្ចប់បឋមសិក្សា និង 17%ដែលបានបញ្ចប់ត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ ។ អ្នកដែលទទួលបានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិបច្ចេកទេស សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបច្ចេកទេសមាន 1.62% នៃប្រជាជនដែលចេះអាននិងសរសេរ ។ អ្នកមិនបានបញ្ចប់ថ្នាក់មហាវិទ្យាល័យនិងបានបញ្ចប់ថ្នាក់មហាវិទ្យាល័យ (មានសញ្ញាបត្រមហាវិទ្យាល័យ) រួមគ្នាទាំងអស់មានតែ 1.47%តែប៉ុណ្ណោះ ។

## 2.2. វិសមភាពនៃការចូលរៀន

ចំនួនសិស្ស និស្សិតដែលកំពុងរៀននៅតាមគ្រឹះស្ថានសិក្សានៅកម្ពុជា បានកើនពី 2 488 235 នាក់ ទៅ 3 390 690 នាក់(36.27%) ក្នុងអំឡុងឆ្នាំ 1998-2008 ពោលគឺក្នុងប្រជាជន 4 នាក់ មានម្នាក់នៅរៀន ។ នៅតំបន់ទីប្រជុំជនកើន 21.57% គឺកើនពី 573 941 នាក់ ទៅ 697 760 នាក់ និងនៅជនបទមានកម្រិតកំណើន 40.67% គឺកើនពី 1 914 264 នាក់ ទៅ 2 692 930 នាក់ ។

ជារួម សមាមាត្រប្រជាជនរៀននៅសាលាមានការកើនឡើងពី 25.95% នៅឆ្នាំ 1998 ទៅ 28.91% នៅឆ្នាំ 2008 ។ ប៉ុន្តែ វិសមភាពនៃការចូលរៀននៅតែកើតមាននៅឡើយរវាងទីប្រជុំជននិងជនបទ និងរវាងសិស្សប្រុសនិងសិស្សស្រី ពិសេសចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិឡើងទៅ ។ ការចូលរៀននៅបឋមសិក្សា សិស្សប្រុសមានប្រហាក់ប្រហែលនិងសិស្សស្រី ។ ប៉ុន្តែ គួរឱ្យកត់សម្គាល់ថា នៅជនបទសិស្សស្រីចូលរៀនមានអត្រាខ្ពស់ជាងសិស្សប្រុស គឺ 79.39% ទល់នឹង 78.84% ។ នេះបញ្ជាក់ឱ្យឃើញការរីកចម្រើននៃការយល់ដឹងរបស់ប្រជាជនកម្ពុជា ដែលកាន់តែយល់ច្បាស់ពីតម្លៃនៃការរៀនសូត្ររបស់កូនៗ ។ ប៉ុន្តែ វិសមភាពភេទបានកើតមានចាប់ពីកម្រិតមធ្យមសិក្សាបឋមភូមិឡើងទៅ ទាំងនៅទីប្រជុំជននិងជនបទ ។ នេះអាស្រ័យដោយការឆាប់ឱ្យកូនស្រីចាប់យកមុខរបរចិញ្ចឹមជីវិតដើម្បីជួយសម្រាលបន្ទុកជីវភាពក្នុងគ្រួសារ (ពិសេសធ្វើជាកម្មការិនីកាត់ដេរ) ក៏ដូចទំនៀមទម្លាប់ឆាប់ឱ្យកូនស្រីរៀបការជាដើម ។

សិស្សប្រុសពីអាយុ 15-19 ឆ្នាំ នៅទីប្រជុំជនមានអត្រា 67.41% ទល់នឹងសិស្សស្រី 42.95% និងនៅជនបទសិស្សប្រុសមានអត្រា 53.86% ទល់នឹងសិស្សស្រី 45.09% ។

ក្នុងអាយុពី 20-24 ឆ្នាំ និង 25 ឆ្នាំឡើងទៅ សមាមាត្ររៀននៅសាលាខ្ពស់ខ្លាំង ទាំងសិស្សប្រុសនិងសិស្សស្រី ។ នេះគឺបណ្ដាលមកពីការរីកចម្រើនរបស់សង្គមទាំងមូល ទាំងមធ្យោបាយធ្វើដំណើរ វិស័យ អប់រំ ស្ថិរភាពនយោបាយ និងចំណង់ចំណូលចិត្តរស់នៅទីក្រុង ដូចជាទីក្រុងភ្នំពេញជាដើម ដែលធ្វើឱ្យគេស្វែងរកការសិក្សាឱ្យបានខ្ពស់ ។ សិស្សប្រុសអាយុ 20-24 ឆ្នាំ នៅទីប្រជុំជនមាន 33.81% (1998=22.44%) ទល់នឹងសិស្សស្រី 20.21% (1998=9.78%) ។ នៅជនបទសិស្សប្រុសមាន 13.15% (1998=8.63%) ទល់នឹងសិស្សស្រី 6.57% (1998=4.20%) ។ សិស្សប្រុសចាប់ពីអាយុ 25 ឆ្នាំឡើងទៅ នៅទីប្រជុំជនមាន 3.77% (1998=2.96%) ទល់នឹងសិស្សស្រី 1.87% (1998=1.70%) ។ នៅជនបទសិស្សប្រុសមាន 0.95% (1998 =1.39%) ទល់នឹងសិស្សស្រី 0.65% (1998=0.98%) ។

អត្រាបោះបង់ការសិក្សានៅតែមានកម្រិតខ្ពស់នៅឡើយ គឺមាន 8.8% សម្រាប់បឋមសិក្សា 21.8% នៅមធ្យមសិក្សាបឋមភូមិ និង 14.4% នៅមធ្យមសិក្សាទុតិយភូមិ ។ ទាំងនេះបណ្ដាលមកពីភាពក្រីក្ររបស់ឪពុកម្ដាយដែលពុំមានលទ្ធភាពឱ្យកូនចូលរៀនបានវែងឆ្ងាយ ហើយម្យ៉ាងទៀតដោយសារបំលាស់លំនៅនិងការស្វែងរកការងារធ្វើបានធ្វើឱ្យកូនចៅមិនបានចូលរៀនបន្ត និងជួនកាលបណ្ដាលមកពីរស់ក្នុងតំបន់ដាច់ស្រយាល សាលារៀនស្ថិតនៅឆ្ងាយពីផ្ទះនិងខ្វះមធ្យោបាយធ្វើដំណើរ ។

## តារាងស្តីពីស្រុកដែលមិនទាន់មានវិទ្យាល័យនិងចំនួនឃុំដែលមិនទាន់មានអនុវិទ្យាល័យ (2010-2011)

| រាជធានី ខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | ក្រុង ស្រុក ខណ្ឌ មិនទាន់មានវិទ្យាល័យ | ចំនួនឃុំ សង្កាត់ | ចំនួនឃុំ សង្កាត់ មិនទាន់មាន អនុវិទ្យាល័យ |
|---|---|---|---|---|
| 1. បន្ទាយមានជ័យ | 9 | 0 | 64 | 0 |
| 2. បាត់ដំបង | 14 | 0 | 96 | 3 |
| 3. កំពង់ចាម | 17 | 0 | 173 | 6 |
| 4. កំពង់ឆ្នាំង | 8 | 0 | 69 | 3 |
| 5. កំពង់ស្ពឺ | 8 | 0 | 87 | 9 |
| 6. កំពង់ធំ | 8 | 0 | 81 | 1 |
| 7. កំពត | 8 | 0 | 92 | 2 |
| 8. កណ្តាល | 11 | 0 | 127 | 6 |
| 9. កែប | 2 | 0 | 5 | 0 |
| 10. កោះកុង | 7 | ស្រុកគិរីសាគរ<br>ស្រុកកោះកុង<br>ស្រុកថ្មបាំង | 29 | 8 |
| 11. ក្រចេះ | 6 | 0 | 46 | 3 |
| 12. មណ្ឌលគិរី | 5 | ស្រុកអូររាំង<br>ស្រុកពេជ្រាដា | 21 | 13 |
| 13. ឧត្តរមានជ័យ | 5 | 0 | 24 | 4 |
| 14. ប៉ៃលិន | 2 | 0 | 8 | 1 |
| 15. ភ្នំពេញ | 8 | 0 | 96 | 39 |
| 16. ព្រះសីហនុ | 4 | 0 | 26 | 1 |

| | | | | |
|---|---|---|---|---|
| 17. ព្រះវិហារ | 8 | ស្រុកត្បែងមានជ័យ | 49 | 9 |
| 18. ព្រៃវែង | 13 | ស្រុកកំពង់លាវ | 116 | 4 |
| 19. ពោធិ៍សាត់ | 6 | 0 | 49 | 7 |
| 20. រតនគិរី | 9 | ស្រុកលំផាត់<br>ស្រុកអូរជុំ<br>ស្រុកវើនសៃ<br>ស្រុកតាវែង<br>ស្រុកបកែវ<br>ស្រុកអូរយ៉ាដាវ<br>ស្រុកអណ្ដូងមាស | 49 | 36 |
| 21. សៀមរាប | 12 | 0 | 100 | 10 |
| 22. ស្ទឹងត្រែង | 5 | 0 | 38 | 12 |
| 23. ស្វាយរៀង | 8 | 0 | 80 | 8 |
| 24. តាកែវ | 10 | 0 | 100 | 2 |
| សរុបទូទាំងប្រទេស | 193 | 14 | 1621 | 187 |

## ? សំណួរ

1. ហេតុអ្វីបានជាគេចាត់ទុកកម្រិតអក្ខរកម្ម ជាសូចនាករដ៏សំខាន់សម្រាប់អភិវឌ្ឍសង្គមជាតិ ?
2. ចាប់ពីឆ្នាំ 1998 ដល់ 2008 តើកម្រិតអក្ខរកម្មនៅកម្ពុជាមានលក្ខណៈដូចម្ដេច ? ចូរពន្យល់អំពីមូលហេតុ ។
3. តើវិសមភាពនៃអក្ខរភាព មាននៅក្នុងរូបភាពណាខ្លះ ?
4. ហេតុអ្វីបានជាប្រជាជនដែលរស់នៅទីប្រជុំជនមានកម្រិតអក្ខរភាពខ្ពស់ជាងប្រជាជនជនបទ ?
5. តើអ្នកគិតថា ការចេះភាសាផ្សេងៗទៀតក្រៅពីភាសាជាតិខ្លួន ផ្ដល់ផលប្រយោជន៍យ៉ាងណាខ្លះចំពោះខ្លួនឯងនិងចំពោះសង្គមជាតិ ?
6. តើវិសមភាពនៃការចូលរៀនតាមភេទ កើតមានចាប់ពីវ័យណា ? ហេតុអ្វី ?
7. ការអប់រំមានឥទ្ធិពលដូចម្ដេចទៅលើអាពាហ៍ពិពាហ៍ លទ្ធភាពបង្កើតកូន និងមរណភាព ។ ចូរពន្យល់បកស្រាយ ។

មេរៀនទី

# 3 វិសមភាពនៃការប្រើប្រាស់សេវាមូលដ្ឋាន

**ចប់មេរៀននេះ សិស្សអាច**

❑ រៀបរាប់ពីរបៀបធ្វើអនាម័យមូលដ្ឋាននិងវិធីថែរក្សា ការពារសុខភាព ។

ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន លទ្ធភាពប្រើប្រាស់សេវាសង្គម (មន្ទីរពេទ្យ សាលារៀន...) និងសេវាមូលដ្ឋាន(ការស្នាក់នៅ ទឹក អនាម័យ វត្ថុធាតុសម្រាប់ដុត សម្ភារៈប្រើប្រាស់...) មានសារៈសំខាន់ណាស់ ព្រោះជាគ្រឹះនៃការអភិវឌ្ឍ។ បើសេវាទាំងអស់នេះស្ថិតនៅក្បែរប្រជាជន នោះពួកគេនឹងមានលទ្ធភាពទៅទទួលយកសេវាទាំងនោះក្នុងកម្រិតអតិបរមា និងប្រកបដោយគុណភាព ព្រោះពួកគេត្រូវចំណាយពេលតិចក្នុងការធ្វើដំណើរទៅមក ហើយចំណេញពេលវេលាក្នុងការធ្វើសកម្មភាពផ្សេងៗទៀត ជាពិសេសធ្វើឱ្យសុខភាពរបស់ប្រជាជនបានកាន់តែប្រសើរជាមួយនិងលទ្ធភាពប្រើប្រាស់សេវាសង្គម និងសេវាមូលដ្ឋានទាំងនោះ ។ ជាក់ស្តែង ការមានទឹកប្រើប្រាស់គ្រប់គ្រាន់មិនត្រឹមតែធ្វើឱ្យការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ មានភាពល្អប្រសើរប៉ុណ្ណោះទេ តែអាចកាត់បន្ថយរយៈពេលនៃការរាលដាលជំងឺផ្សេងៗថែមទៀតផង ។

## 1. លទ្ធភាពប្រើប្រាស់សេវាសង្គម

### 1.1. លក្ខណៈទូទៅ

លទ្ធភាពចូលរៀននៅសាលាបឋមសិក្សាពុំមានបញ្ហាចោទដូចមុនទៀតឡើយ ព្រោះសាលាបឋមសិក្សាមានការកើនឡើងពី 6 180 នៅឆ្នាំ 2004-2005 ទៅ 6 565 នៅឆ្នាំ 2008-2009 ហើយចម្ងាយឆ្ងាយបំផុតពីភូមិទៅកាន់សាលាបឋមសិក្សាមានត្រឹមតែ 2km ប៉ុណ្ណោះ ។ នៅឆ្នាំសិក្សា 2008-2009 កុមារដល់វ័យសិក្សា(អាយុ 6ឆ្នាំ) ចំនួន 3 390 690 នាក់ (91.9%) បានចុះឈ្មោះចូលរៀនថ្នាក់ទី 1 ចំនួន 91.9% ។

ចំពោះមជ្ឈមណ្ឌលថែទាំសុខភាពតាមមូលដ្ឋានមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដោយសារមានការធ្វើឱ្យប្រសើរឡើងនូវបញ្ហាបុគ្គលិកនិងបង្កើនបុគ្គលិកនៅតាមមណ្ឌលសុខភាពនានានៅតំបន់ដាច់ស្រយាល ពិសេសការធ្វើឱ្យមានផ្ទបជំនាញនៅបម្រើការងារទីនោះ ។ សមិទ្ធផលដែលបង្ហាញពី

ភាពចម្រើនរបស់វិស័យនេះមានជាអាទិ៍ ការថយចុះនៃអត្រាមរណភាពទារក ការឆ្លងជំងឺអេដស៍និងគ្រុនចាញ់ និងការកើនឡើងនៃការថែទាំស្ត្រីមុនពេលសម្រាលកូននិងការសម្រាលកូន។ សេវាព្យាបាលសាធារណៈត្រូវបានពង្រឹងតាំងពីមន្ទីរពេទ្យថ្នាក់ជាតិរហូតដល់មណ្ឌលសុខភាព ដែលធ្វើឱ្យប្រជាជនមានភាពកក់ក្ដៅជាបង្គួរ។ បន្ថែមលើនេះទៀត មានអង្គការក្រៅរដ្ឋាភិបាលចំនួនប្រហែល 130 បានរួមចំណែកក្នុងការទ្រទ្រង់វិស័យសុខាភិបាល ដែលភាគច្រើននៃអង្គការទាំងនោះកំពុងដំណើរមានការនៅតំបន់ដាច់ស្រយាល។

## 1.2. វិសមភាពនៃសេវាសង្គម

រាជធានី ខេត្តទាំងអស់នៅកម្ពុជាសុទ្ធតែមានមណ្ឌលសុខភាព គិលានដ្ឋាន និងមន្ទីរពេទ្យប្រចាំរាជធានី ខេត្តរបស់ខ្លួន។ ប៉ុន្តែ បើគិតពីផលធៀបចំនួនប្រជាជនទៅនឹងមណ្ឌលសុខភាពតាមខេត្តនីមួយៗ ឃើញថាមានមណ្ឌលសុខភាពមិនស្មើគ្នាឡើយ ដូច្នេះ ការទទួលបាននូវសេវាថែទាំសុខភាព ក៏នៅមានកម្រិតនៅឡើយ ពិសេសគម្លាតរវាងទីប្រជុំជននិងជនបទ។ សូចនាករមួយចំនួនដែលបង្ហាញអំពីវិសមភាពនេះដូចជា អត្រាមរណភាពទារកសរុបមាន 58 ភាគពាន់ ក្នុងនោះទីប្រជុំជនមាន 34 ភាគពាន់ និងជនបទមាន 62 ភាគពាន់។ អត្រាមរណប្រមាណមាតាសរុបគឺ 461 ក្នុងនោះទីប្រជុំជនមាន 287 និងជនបទមាន 490។ កុមារកម្ពុជាអាយុក្រោម 5 ឆ្នាំក្នុងគ្រួសារក្រីក្រ មានអត្រាស្លាប់បីដងច្រើនជាងកុមារក្នុងគ្រួសារអ្នកមាន។ កុមារអាយុក្រោម 5 ឆ្នាំក្នុងគ្រួសារក្រីក្រ បានទទួលការថែទាំសុខភាពសមស្រប 6 ដង តិចជាងកុមារក្នុងគ្រួសារអ្នកមាន។ ចំពោះស្ត្រីក្រីក្របានទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាល 10 ដង តិចជាងស្ត្រីគ្រួសារអ្នកមាន។

អស់រយៈពេលបីទសវត្សរ៍កន្លងទៅនេះ ការងារអប់រំមានការអភិវឌ្ឍជាលំដាប់ទាំងបរិមាណនិងគុណភាព ពិសេសនៅជនបទគេសង្កេតឃើញអត្រាកំណើននៃការចូលរៀនរបស់កុមារអាយុ 6 ឆ្នាំ ពីឆ្នាំ 1998-2008 មានការកើនឡើង 40.67% គឺខ្ពស់ជាងនៅទីប្រជុំជន ដែលមាន 21.57%។ ប៉ុន្តែការអប់រំកុមារតូចនៅមានកម្រិតទាបនៅឡើយបើធៀបទៅនឹងប្រទេសនានាក្នុងតំបន់ ដែលជាការលំបាកចំពោះមុខ ក៏ដូចជាកង្វល់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវដោះស្រាយ។ នៅឆ្នាំសិក្សា 2008-2009 មានកុមារអាយុពី 3 ទៅ 5 ឆ្នាំត្រឹមតែ 10.24% ប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យរដ្ឋ។ មានថ្នាក់មត្តេយ្យចំនួន 75.25% ដែលស្ថិតនៅតំបន់ជនបទនិងដាច់ស្រយាល ដែលប្រជាពលរដ្ឋនៅជនបទមានដល់ 80.48%។ នៅឆ្នាំ 2008 មានឃុំចំនួន 176 នៅទូទាំងប្រទេសបានផ្ដួចផ្ដើមចាត់ចែងបង្កើតមណ្ឌលមត្តេយ្យសិក្សាសម្រាប់កុមារអាយុ 3-5 ឆ្នាំ។ ឃុំបានបញ្ចូលតម្រូវការសេវាមត្តេយ្យសិក្សាទៅក្នុងផែនការឃុំនិងស្វែងរកការគាំទ្រពីក្រសួងនានាដែលពាក់ព័ន្ធ។ ឃុំបានផ្ដល់ដីជាកន្លែងសម្រាប់មណ្ឌល ជ្រើសរើសគ្រូ ផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូ និងពិនិត្យតាមដានការអភិវឌ្ឍនៃសកម្មភាពសិក្សា។

ការប្រើប្រាស់អ៊ិនធឺណែត (Internet) មានការលូតលាស់នាពេលបច្ចុប្បន្ន និងជាកត្តាមួយផ្នែកដែលគួសបញ្ជាក់អំពីផ្នែកព័ត៌មានវិទ្យានិងការសិក្សាស្រាវជ្រាវរបស់ប្រជាជនកម្ពុជា ។ ប៉ុន្តែ គេសង្កេតឃើញថា ការប្រើប្រាស់អ៊ិនធឺណែតនេះមានចំពោះតែអ្នករស់នៅទីប្រជុំជនប៉ុណ្ណោះ(4.5%) ហើយភាគច្រើនប្រើប្រាស់អ៊ិនធឺណែតសាធារណៈ (3.88%) ។ ការប្រើប្រាស់អ៊ិនធឺណែតតាមផ្ទះមានតិចតួចបំផុត ពិសេសមានចំពោះតែគ្រួសារអ្នកមានប៉ុណ្ណោះ ឯនៅជនបទវិញ ការប្រើប្រាស់អ៊ិនធឺណែតមិនមានអ្វីគួរឱ្យកត់សម្គាល់ឡើយ ។

# 2. លទ្ធភាពក្នុងការប្រើប្រាស់ទឹកស្អាត

នៅប្រទេសកម្ពុជា ជំងឺមួយចំនួនធំបណ្តាលមកពីការប្រើប្រាស់ទឹកមិនស្អាត(មានបាក់តេរីនៅក្នុងទឹក) ពិសេសកើតមានចំពោះប្រជាជនដែលរស់នៅជនបទ ។ ម្យ៉ាងទៀត ប្រជាជនកម្ពុជាមានលទ្ធភាពប្រើប្រាស់ទឹកស្អាតនៅមានចំនួនតិចនៅឡើយ មានតែប្រជាជនដែលរស់នៅទីក្រុងប៉ុណ្ណោះដែលប្រើប្រាស់ទឹកស្អាត ។

## 2.1. លក្ខណៈទូទៅ

យោងតាមជំរឿនប្រជាជនកម្ពុជាឆ្នាំ 2008 គ្រួសារចំនួន 25.87% ដែលនៅប្រើប្រាស់ទឹកអណ្តូងជីក(ទាំងគ្មានគម្របនិងមានគម្រប) ។ ចំនួននេះឃើញថា ថយច្រើនជាងឆ្នាំ 1998 ដែលមានដល់ទៅឆ្នាំ 40.2% ។ គ្រួសារប្រើប្រាស់ទឹកទន្លេ អូរ បឹង ត្រពាំងមាន 23.07% ថយចុះតិចតួច បើធៀបនឹងឆ្នាំ 1998 ដែលមាន 28.20% ។ ការប្រើប្រាស់ទឹកបែបនេះអាចបណ្តាលឱ្យមានគ្រោះថ្នាក់ពីការចម្លងមេរោគផ្សេងៗ ។ គ្រួសារ 48.83%មានទឹកស្អាតប្រើប្រាស់ ក្នុងនោះមានទឹកម៉ាស៊ីន 13.83% ទឹកអណ្តូងស្នប់ 26.83% និងទឹកទិញ 8.17% ។ ចំនួននេះលើសពីឆ្នាំ 1998 ដែលមានត្រឹមតែ 29.05% (ទឹកម៉ាស៊ីន 5.80% ទឹកអណ្តូងស្នប់ 14.95% និងទឹកទិញ 8.30%) ។

**ការបែងចែកភាគរយនៃគ្រួសារតាមប្រភពទឹកសម្រាប់ទទួលទាននៅកម្ពុជាឆ្នាំ 1998-2008**

| ប្រភពទឹកសំខាន់ៗ សម្រាប់ទទួលទាន | សរុប | | ទីប្រជុំជន | | ជនបទ | |
|---|---|---|---|---|---|---|
| | 1998 | 2008 | 1998 | 2008 | 1998 | 2008 |
| ចំនួនគ្រួសារ[១] | 2 162 086 | 2 817 637 | 364 581 | 506 579 | 1 797 505 | 2 311 058 |
| សរុប | 100 | 100 | 100 | 100 | 100 | 100 |
| ទឹកម៉ាស៊ីន | 5.80 | 13.83 | 26.78 | 56.75 | 1.54 | 4.43 |

| | | | | | | |
|---|---|---|---|---|---|---|
| អណ្តូងស្នប់ | 14.95 | 26.83 | 12.49 | 14.70 | 15.45 | 29.47 |
| អណ្តូងជីកមានគម្រប | - | 5.22 | - | 3.79 | - | 5.54 |
| អណ្តូងជីកគ្មានគម្រប | 40.28 | 20.65 | 16.73 | 4.53 | 45.07 | 24.19 |
| ទឹកភ្លៀង | - | 0.95 | - | 0.51 | - | 1.05 |
| ទឹកចេញក្រោមដី ខ្ទេ អូរ បឹង ត្រពាំង ។ល ។ | 28.20 | 23.07 | 13.32 | 6.22 | 31.22 | 26.76 |
| ទឹកទិញ | 8.30 | 8.17 | 29.18 | 12.96 | 4.06 | 7.12 |
| ប្រភពទឹកផ្សេងៗ | 2.47 | 1.28 | 1.50 | 0.54 | 2.66 | 1.44 |

សម្គាល់ : (១) ចំនួនគ្រួសារធម្មតា ឬគ្រួសារប្រក្រតី ។

## 2.2. វិសមភាពនៃការប្រើប្រាស់ទឹក

ថ្វីត្បិតតែការផ្គត់ទឹកសម្រាប់ប្រើប្រាស់មានការរីកចម្រើន ប៉ុន្តែក៏នៅមានភាពខុសគ្នាខ្លាំងនៅឡើយរវាងទីប្រជុំជននិងជនបទ ។ ខេត្តចំនួនពីរដែលពុំទាន់មានរដ្ឋាករទឹកនៅឡើយគឺ ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ ។ ខេត្តកែប ទើបតែមានដំណើរការសាងសង់ ។ ប៉ុន្តែដើម្បីចូលរួមលើកស្ទួយកម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល គិតត្រឹមដំណាច់ឆ្នាំ 2009 បានរៀបចំបែបបទចេញអាជ្ញាប័ណ្ណ គោលការណ៍ច្បាប់និងពិនិត្យលើគោលការណ៍បច្ចេកទេសសម្រាប់ចេញប្រកាស និងបន្តប្រកាសដល់អាជីវករក្រុមហ៊ុនឯកជនដែលកំពុងធ្វើអាជីវកម្មផ្គត់ទឹកស្អាតសរុបបានចំនួន 35 កន្លែង ។ លើសពីនេះទៅទៀត ក្រសួងបានទទួលជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីធ្វើការសិក្សារៀបចំគម្រោងទឹកស្អាតនិងអនាម័យនៅខេត្តក្រចេះនិងស្ទឹងត្រែង ។ រាជរដ្ឋាភិបាលជប៉ុនក៏បានផ្តល់ជំនួយតាមរយៈ JICA (ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន) សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋាករទឹកសាធារណៈតាមខេត្តចំនួន ៨ គឺខេត្តសៀមរាប ពោធិ៍សាត់ បាត់ដំបង កំពង់ចាម កំពង់ធំ ស្វាយរៀង កំពត និងខេត្តព្រះសីហនុ និងក៏បានផ្តល់ជំនួយឥតសំណង ដើម្បីអនុវត្តគម្រោងទឹកស្អាតក្នុងក្របខ័ណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ។ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង កំពង់ចាម កំពង់ធំ ក្រចេះ និងកណ្តាល ក៏បានទទួល ជំនួយពីអង្គការ USAID (ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ) សម្រាប់រៀបចំគម្រោងអភិវឌ្ឍន៍ទឹកស្អាតខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមនៅក្នុងខេត្តរបស់ខ្លួនផងដែរ ។ នៅឆ្នាំ 2009 ការងារតបណ្តាញទឹកស្អាតនៅរាជធានីភ្នំពេញបាន 97.69% នៃផែនការនិងការពង្រីកបណ្តាញដាក់បំពង់មេនៅរាជធានីភ្នំពេញ នៅក្រុងតាខ្មៅ និងស្រុកអង្គស្នួល(ខេត្តកណ្តាល) បានចំនួន 83.36% នៃផែនការ ។

នៅឆ្នាំ 2008 ការប្រើប្រាស់ទឹកស្អាតនៅទីប្រជុំជនមាន 84.41% ច្រើនជាងឆ្នាំ 1998 ដែលមានតែ 68.45% និងនៅជនបទមានតែ 41.02% (ឆ្នាំ 1998 មាន 21.05%)។ ប្រជាជនទីប្រជុំជនដែលមានទឹកម៉ាស៊ីនប្រើប្រាស់មាន 56.75% ខ្ពស់ជាងជនបទខ្លាំង ដែលមានតែ 4.43%។ នៅទីប្រជុំជន គ្រួសារដែលមានប្រភពទឹកប្រើប្រាស់នៅក្នុងបរិវេណផ្ទះមាន 67.44% ខ្ពស់ជាងជនបទដែលមានតែ 29.35% ដូច្នេះ គេប្រើប្រាស់ប្រភពទឹកផ្សេងៗដែលនៅជិតបរិវេណផ្ទះ( 34.42%) និងនៅឆ្ងាយពីផ្ទះ (36.23%) ដូចជា ទឹកអណ្តូង ទឹកត្រពាំង ទឹកបឹង ស្ទឹង ទន្លេជាដើម ដែលជាហេតុធ្វើឱ្យសុខភាពរបស់គេត្រូវប្រឈមនឹងការទទួលឆ្លងមេរោគផ្សេងៗ។ ពិនិត្យជារួមឃើញថា លទ្ធភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនកម្ពុជានៅទីប្រជុំជន ថ្វីត្បិតមិនទាន់មានកម្រិតខ្ពស់ខ្លាំងក៏ដោយក៏ឃើញមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែរ បើធៀបទៅនឹងទសវត្សរ៍មុន។ តែចំពោះប្រជាជននៅជនបទវិញ លទ្ធភាពប្រើប្រាស់ទឹកស្អាតស្ថិតនៅទាបនៅឡើយ ពិសេសការប្រើប្រាស់ទឹកម៉ាស៊ីន។ គេឃើញមានការរីកចម្រើនលើផ្នែកទឹកអណ្តូងស្នប់ (29.47%)ដែលមួយភាគធំមិនទាន់បានទទួលការវិភាគទឹកឱ្យបានត្រឹមត្រូវនៅឡើយ។

ដោយឡែក កង្វះទឹកស្អាតនៅតាមសាលារៀនក៏ជាបញ្ហាមួយសំខាន់ផងដែរដែលជះឥទ្ធិពលដល់សុខុមាលភាពសិស្សានុសិស្ស។ នៅឆ្នាំសិក្សា 2008-2009 សាលារៀនដែលគ្មានទឹកស្អាត ផ្នែកបឋមសិក្សាមាន 34.8% ផ្នែកមធ្យមសិក្សាបឋមភូមិមាន 40.8% និងមធ្យមសិក្សាទុតិយភូមិមាន 22.3%។

**ការបែងចែកភាគរយនៃគ្រួសារ តាមទីតាំងប្រភពទឹកសម្រាប់ទទួលទាននៅកម្ពុជាឆ្នាំ 2008**

| ទីតាំងប្រភពទឹក | គ្រួសារ | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| ចំនួន | 2 817 637 | 506 579 | 2 311 058 |
| សរុប | 100 | 100 | 100 |
| ក្នុងបរិវេណផ្ទះ | 36.20 | 67.44 | 29.35 |
| នៅជិតបរិវេណផ្ទះ | 31.50 | 18.20 | 34.42 |
| នៅឆ្ងាយពីបរិវេណផ្ទះ | 32.30 | 14.36 | 36.23 |

# 3. អនាម័យមូលដ្ឋាន

## 3.1. ស្ថានភាពទូទៅនៅកម្ពុជា

ការងារអប់រំសុខភាព អនាម័យមូលដ្ឋាន ជាគន្លឹះមួយក្នុងការបង្កើនកម្រិតយល់ដឹងនិងសកម្មភាពចូលរួមរបស់ប្រជាជនគ្រប់រូបដើម្បីអនុវត្តវិធានការនានាដូចជា អនាម័យបុគ្គល និងបរិស្ថានរស់

នៅក្នុងសហគមន៍របស់ខ្លួន ។ ការពង្រឹងសកម្មភាពប្រយុទ្ធជំងឺឆ្លង ជាកត្តាមួយសំខាន់បំផុតដើម្បីរួមចំណែកកាត់បន្ថយអត្រាឈឺនិងអត្រាស្លាប់របស់ប្រជាជន ។ ប៉ុន្តែ ការយល់ដឹងរបស់ប្រជាជនកម្ពុជាក្នុងការងារនេះមានកម្រិតទាបនៅឡើយ ។ ជាទូទៅ ប្រជាជនកម្ពុជាចំនួន 66.29% (2008) គ្មានបង្គន់ប្រើប្រាស់ ពោលគឺក្នុងចំណោមប្រជាជនបីនាក់ មានប្រជាជនពីរនាក់ដែលបានបន្ទោបង់ពាសវាលពាសកាល ។ ការបន្ទោបង់ពាសវាលពាសកាលមានន័យថា ការបន្ទោបង់លើដី ក្នុងព្រៃ ក្នុងគុម្ពោតព្រៃ ក្នុងប្រភពទឹក នៅទីវាល ឬការបោះចោលលាមកមនុស្សពាសវាលពាសកាល ។ ការបន្ទោបង់ពាសវាលពាសកាល គឺជាការដោះទ័លរបស់អ្នកដែលគ្មានបង្គន់ប្រើប្រាស់ និងជាក្រុម មនុស្សមានស្មារតីអនុវត្តអនាម័យទាបបំផុត គ្មានសេចក្តីថ្លៃថ្នូរ គ្មានសេចក្តីខ្មាសអៀន ចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តជារៀងរាល់ថ្ងៃ ដែលជាញឹកញយគេឃើញនៅតាមទីសាធារណៈ ។

ការលុបបំបាត់ការបន្ទោបង់ពាសវាលពាសកាល ជាប្រការសំខាន់ណាស់ ព្រោះការបន្ទោបង់បែបនេះធ្វើឱ្យប៉ះពាល់ដល់សុខភាពនិងក៏អាចបង្កជាបញ្ហាដល់អ្នករស់នៅជិតខាងផងដែរ ។ ប្រសិនបើសមាជិកមួយចំនួននៅក្នុងសហគមន៍មួយនៅតែបន្តការបន្ទោបង់ពាសវាលពាសកាល សហគមន៍នោះទាំងមូលនិងប្រឈមមុខទៅនិងជំងឺរាករូស ព្រូន រលាកថ្លើម ជាងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដែលគ្មានការបន្ទោបង់ពាសវាលពាសកាល ។ ការលុបបំបាត់ភាពអវិជ្ជមាននេះ ជាការលំបាកស្មុគស្មាញដ៏ធំមួយ ព្រោះជាទម្លាប់បន្តពីជំនាន់មួយទៅជំនាន់មួយជាយូរមកហើយ ប៉ុន្តែមិនមែនមានន័យថាមិនអាចធ្វើបាននោះទេ ។ តាមរយៈកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងរបស់ក្រសួងអភិវឌ្ឍជនបទ មានភូមិប្រមាណ 300 ក្នុងទូទាំងប្រទេសកម្ពុជាបានបញ្ឈប់ទាំងស្រុងនូវការបន្ទោបង់ពាសវាលពាសកាល ។

## 3.2. វិសមភាពនៃអនាម័យមូលដ្ឋាន

មានភាពខុសគ្នាខ្លាំងផ្នែកអនាម័យមូលដ្ឋានរវាងប្រជាជនទីប្រជុំជននិងជនបទ ។ នៅឆ្នាំ 2008 អ្នកជនបទ 76.76% ដែលគ្មានបង្គន់អនាម័យប្រើប្រាស់ បានថយចុះជាងកាលពីឆ្នាំ 1998 ដែលមានរហូតដល់ 93.97% ។ រីឯប្រជាជននៅទីប្រជុំជន ដែលគ្មានបង្គន់អនាម័យប្រើប្រាស់មាន 18.54% ថយចុះខ្លាំងជាងឆ្នាំ 1998 ដែលមាន 43.87% ។ ភាគច្រើននៃគ្រួសារមានបង្គន់អនាម័យជាអ្នករស់នៅតំបន់ទីប្រជុំជន ដែលប្រើប្រាស់បង្គន់ចាក់ទឹកភ្ជាប់ទៅបំពង់លូ(56.13%) ។ ឯនៅជនបទប្រជាជនប្រមាណ 45% មានបង្គន់អនាម័យ ប្រើប្រាស់ដោយចាក់ទឹកមានអាងស្តុក និង 28% ប្រើប្រាស់បង្គន់ចាក់ទឹកភ្ជាប់ទៅបំពង់លូ ។ ប្រជាជនរស់នៅជនបទដែលមានទឹកស្អាត អគ្គិសនី និងបង្គន់ នៅក្នុងបរិវេណផ្ទះនៅឆ្នាំ 2008 មានតែ 5.34% គឺតិចជាងឆ្ងាយពីទីប្រជុំជនដែលមានរហូតដល់ 72.49% (ឆ្នាំ 1998 មាន 0.92% និង 42.92%) ។

នៅតាមគ្រឹះស្ថានសិក្សា បញ្ហាកង្វះបង្គន់អនាម័យប្រើប្រាស់កើតមាននៅគ្រប់ភូមិសិក្សា ដែលជះឥទ្ធិពលសំខាន់ដល់សុខភាពនិងលទ្ធផលនៃការសិក្សារបស់សិស្សផងដែរ ។ សាលារៀនដែលគ្មានបង្គន់អនាម័យប្រើប្រាស់នៅកម្រិតបឋមសិក្សាមាន 22.40% អនុវិទ្យាល័យមាន 21.20% និងនៅវិទ្យាល័យមាន 5.20% ។ នៅតាមសាលារៀនមួយចំនួនគេសង្កេតឃើញថា មានបង្គន់អនាម័យដែរ តែមិនអាចប្រើប្រាស់បាន ដោយសារកង្វះការថែទាំក៏ដូចជាកង្វះទឹកប្រើប្រាស់ ។

# 4. ចម្រើបម្រាស់ថាមពល

## 4.1. គ្រឿងបរិក្ខារសម្រាប់បំភ្លឺគេហដ្ឋាន

នៅឆ្នាំ 2008 ប្រជាជនកម្ពុជាប្រើអគ្គិសនីបណ្តាញ 22.47% សម្រាប់បំភ្លឺគេហដ្ឋាន គឺច្រើនជាងកាលពីឆ្នាំ 1998 ដែលមានត្រឹមតែ 12.50%ប៉ុណ្ណោះ ។ ក្រៅពីនេះ ប្រជាជនបានប្រើប្រាស់ប្រេងកាត 38.61% និងអាគុយ ថ្មពិល 34.06% ។ ការប្រើប្រាស់គ្រឿងបរិក្ខារសម្រាប់បំភ្លឺគេហដ្ឋាន មានវិសមភាពធំធេងណាស់រវាងអ្នកទីក្រុង និងអ្នកជនបទ ។ នៅទីប្រជុំជន 82.53%មានអគ្គិសនីប្រើប្រាស់ និងនៅជនបទមាន 9.31% បើធៀបទៅនឹងឆ្នាំ 1998 (56.9% និង 3.56%) មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

ដោយសារស្ថានភាពផលិតកម្មថាមពលអគ្គិសនីនៅក្នុងប្រទេសពុំទាន់បានគ្រប់គ្រាន់នៅឡើយ (ឆ្នាំ 2009 ផលិតបាន 13 739 661 kWh) ការនាំចូលថាមពលអគ្គិសនីពីប្រទេសជិតខាងមានច្រើនលើសលប់ គឺនៅឆ្នាំ 2009 នាំចូលពីប្រទេសថៃ 226 756 095 kWh និងពីប្រទេសវៀតណាមចំនួន 500 742 495 kWh ។

ក្នុងការអភិវឌ្ឍវិស័យអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយថាមពល ដែលមានភាពប្រាកដប្រជាដូចខាងក្រោម

- ផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យបានគ្រប់គ្រាន់នៅក្នុងទូទាំងប្រទេស តាមតម្លៃសមរម្យនិងអាចទទួលយកបាន ក្នុងនោះនៅឆ្នាំ 2020 គ្រប់ភូមិទាំងអស់នឹងទទួលបានការផ្គត់ផ្គង់អគ្គិសនី និងនៅឆ្នាំ 2030គ្រួសារយ៉ាងហោចណាស់ 70%នៃចំនួនគ្រួសារសរុប នឹងទទួលបានការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញដែលមានគុណភាព ។
- ធានាឱ្យមានការទុកចិត្ត និងស្ថិរភាពក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីដើម្បីសម្រួលដល់ការធ្វើវិនិយោគនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។
- លើកទឹកចិត្តដល់ការប្រើប្រាស់ថាមពលដោយប្រសិទ្ធភាព និងកាត់បន្ថយការប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់និងការផ្គត់ផ្គង់ថាមពល ។

- បន្តជំរុញឱ្យមានការចូលរួមវិនិយោគក្នុងវិស័យថាមពលពីផ្នែកឯកជន ។
- បន្តជំរុញឱ្យមានការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ ។

ដើម្បីធ្វើឱ្យសម្រេចបាននូវគោលនយោបាយខាងលើ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល បាននិងកំពុងជំរុញក្រុមវិនិយោគទាំងអស់ឱ្យខិតខំអនុវត្តបន្តការសាងសង់ប្រភពផ្គត់ផ្គង់អគ្គិសនី រោងចក្រអគ្គិសនីធ្យូងថ្ម និងជាពិសេសប្រភពវារីអគ្គិសនី ដែលជាសក្ដានុពលថាមពលធម្មជាតិនិងថាមពលកើតឡើងវិញរបស់ប្រទេស ។ គម្រោងវារីអគ្គិសនីកំចាយនៅខេត្តកំពត មានអានុភាព 193.25 MW បាននិងកំពុងសាងសង់ ក្នុងនោះរោងចក្រវារីអគ្គិសនីទី 2 ដែលមានអានុភាព 10MW បានធ្វើពិធីសម្ពោធដាក់ឱ្យដំណើរការនៅថ្ងៃទី 07 ខែធ្នូ ឆ្នាំ 2009 កន្លងទៅនេះ ។ គម្រោងវារីអគ្គិសនីគីរីរម្យទី 3 អានុភាព 18MW កំពុងតែមានដំណើរការសាងសង់បន្តពីវារីអគ្គិសនីទី 1 ដែលមានអានុភាព 12MW និងដែលបានសម្ពោធបើកការប្រើប្រាស់តាំងពីថ្ងៃទី 09 ខែឧសភា ឆ្នាំ 2002 ។ នៅមានគម្រោងអគ្គិសនីជាច្រើនទៀត នៅតាមខេត្តមួយចំនួនដូចជា ខេត្តក្រចេះ កោះកុង ស្ទឹងត្រែង រតនគីរី បាត់ដំបង ពោធិ៍សាត់ កំពង់ធំ និងប៉ៃលិន ដែលមានអានុភាពជាច្រើនមេហ្គាវ៉ាត់ ។

## 4.2. វត្ថុធាតុសម្រាប់ចម្អិនអាហារ

ប្រជាជនកម្ពុជា 83.61% ប្រើអុសសម្រាប់ចម្អិនអាហារ 7.47% ប្រើធ្យូង ហើយ 7.90% ទៀតប្រើឧស្ម័ន(ហ្គាស) ។ ចំនួននេះឃើញថានៅមានកម្រិតខ្ពស់នៅឡើយ បើធៀបទៅនឹងឆ្នាំ 1998 ដែលមាន 90.04% ។ អ្នករស់នៅទីក្រុងប្រើអុស 34.74% ធ្យូង 25.56% ឧស្ម័ន 37.28% រីឯប្រជាជនជនបទវិញប្រើអុសកម្រិតខ្ពស់រហូតដល់ 94.32% ប្រើធ្យូង 3.51% និងប្រើឧស្ម័នមានតិចតួចត្រឹមតែ 1.46% ប៉ុណ្ណោះ ។ ការប្រើប្រាស់អុសច្រើនបែបនេះ នាំឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ពីព្រោះព្រៃរបស់ភូមិមិនអាចបម្រើសេចក្ដីត្រូវការធ្វើអុស-ធ្យូងបានឡើយ ដូច្នេះហើយគេនាំគ្នាលួចកាប់ព្រៃឈើសម្រាប់ធ្វើអុស-ធ្យូង ។ ប្រជាជនខ្មែរមួយចំនួនច្រើនបង្គួរ ដែលរស់នៅក្នុងតំបន់ដែលគ្មានព្រៃទាល់តែសោះ ដូច្នេះគេប្រើអុសសន្សំសំចៃបំផុតដូចជាគេប្រើ សំបកដូង ធាងដូង ធាងត្នោត ចំបើង អង្កាម លាមកគោហាល ឬមែកឈើតូចតាចនៅក្បែរៗភូមិ ។

## សំណួរ

1. តើលទ្ធភាពប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនកម្ពុជា នាំមកនូវផលប្រយោជន៍អ្វីខ្លះ ?
2. តើកង្វះបង្គន់អនាម័យប្រើប្រាស់នៅទីក្រុង ឬនៅជនបទ ដែលមានកម្រិតខ្ពស់ជាង ? ហេតុអ្វី ?
3. តើអ្វីខ្លះជាសក្ដានុពលក្នុងការផលិតវារីអគ្គិសនីនៅកម្ពុជា ?
4. តើត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីចៀសវាងបាននូវការកាប់ព្រៃឈើសម្រាប់ធ្វើអុស-ធ្យូង ?

## ? សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ជំងឺគ្រុនចាញ់អាចកើតមានលើមនុស្ស

☐ក. ចាស់ ☐ខ. ក្មេង ☐គ. ស្រី ☐ឃ. គ្រប់វ័យ

2. បច្ចុប្បន្នប្រព័ន្ធអប់រំចំណេះទូទៅនៅកម្ពុជាមានរយៈពេល

☐ក. 9ឆ្នាំ ☐ខ. 10ឆ្នាំ ☐គ. 11ឆ្នាំ ☐ឃ. 12ឆ្នាំ

3. ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីការអភិវឌ្ឍអន្តរជាតិមានអក្សរកាត់ជា

☐ក. USAID ☐ខ. IDH ☐គ. UNTAC ☐ឃ. Fa

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. គ្រុនចាញ់ជាជំងឺរស់នៅក្នុងគោលិកាឈាមក្រហម បង្កឡើងដោយមេរោគម្យ៉ាងឈ្មោះថា ....... ....................................... ។

2. អក្ខរភាពមនុស្សពេញវ័យគឺ អ្នកដែលចេះអាន ចេះសរសេរមានអាយុចាប់ពី .................... ឡើងទៅ ។

3. ចំនួនស្ត្រីស្លាប់ក្នុងមូលហេតុមានគភ៌ក្នុងកំណើតរស់ 100 000 នាក់ ហៅថា ........................ ។

III. សំណួរត្រិះរិះ

1. តើជំងឺគ្រុនចាញ់ឆ្លងមកមនុស្សដោយសារអ្វី ? តើជំងឺនេះមានកម្រិតខ្ពស់នៅតំបន់ណាខ្លះនៃប្រទេសកម្ពុជា ?
2. ហេតុអ្វីបានជាការបរិភោគមិនគ្រប់គ្រាន់ ជាបញ្ហាចោទខ្លាំងចំពោះបណ្ដាប្រទេសកំពុងអភិវឌ្ឍ ?
3. តើកត្តាសំខាន់ៗអ្វីខ្លះ ដែលធ្វើឱ្យអត្រាស្លាប់របស់កុមារនៅកម្ពុជាមានកម្រិតខ្ពស់នៅឡើយ ?
4. តើវិសមភាពនៃការចូលរៀនមានទំនាក់ទំនងទៅនឹងបញ្ហាអ្វីខ្លះ ?
5. តើកូនអ្នកនៅទីប្រជុំជន ឬជនបទដែលមានលទ្ធភាពទទួលការរៀនសូត្របានវែងឆ្ងាយជាង ? ព្រោះអ្វី ?
6. តើកំណើនអក្ខរភាពនៃប្រជាជនកម្ពុជា កើតឡើងដោយសារមូលហេតុអ្វីខ្លះ ?
7. តើកង្វះបង្គន់អនាម័យប្រើប្រាស់នៅតាមសាលារៀន ផ្ដល់ផលប៉ះពាល់យ៉ាងណាខ្លះចំពោះសិស្សានុសិស្ស ?
8. ការប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ នាំឱ្យមានផលប៉ះពាល់ដូចម្ដេចខ្លះចំពោះបរិស្ថាននិងសុខភាពរបស់មនុស្ស ?

# ជំពូកទី 3 សេដ្ឋកិច្ចកម្ពុជា



ប្រទេសកម្ពុជាបានទទួលយកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីជាផ្លូវការចាប់តាំងពីឆ្នាំ 1993 មកម្ល៉េះ ។ ការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចនេះ បានធ្វើឱ្យប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយបរទេសតាមរយៈការធ្វើពាណិជ្ជកម្មក្រៅប្រទេសនិងតាមរយៈការវិនិយោគទុន ។ ក៏ប៉ុន្តែ នៅក្នុងសេដ្ឋកិច្ចជាតិ កសិកម្មជាគ្រឹះមួយយ៉ាងសំខាន់បំផុត ព្រោះកសិករមានរហូតដល់ 72.30% នៃប្រជាជនទាំងអស់( 80.5% នៃប្រជាជនរស់នៅជនបទ) ហើយកសិកម្មផ្តល់ 34.4% នៃផលិតផលក្នុងស្រុកសរុប(ឆ្នាំ 2008 ) ។

ថ្វីត្បិតតែទទួលរងនូវបច្ច័យអាក្រក់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកដែលបានកើតមានឡើងនៅពាក់កណ្តាលឆ្នាំ 2008 ក៏ពិតមែន ប៉ុន្តែគេសង្កេតឃើញថា វិស័យនានានៅតែមានដំណើរការល្អ ហើយបានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តទិសដៅស្តារនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

មិនក៏នៅតែជាបញ្ហានិងជាឧបសគ្គមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រោះសេដ្ឋកិច្ចប្រទេសពឹងផ្អែកលើកសិកម្ម ផ្ទុយទៅវិញ បើដឹកសិកម្មជាចំការមីននោះ សេដ្ឋកិច្ចប្រទេសក៏ពុំអាចលូតលាស់បានដែរ ។

# 1 កសិកម្មកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

❑ យល់ដឹងអំពីប្រព័ន្ធផលិតកម្មនៅកម្ពុជា អំពីសារៈសំខាន់របស់វិស័យនេះចំពោះសេដ្ឋកិច្ចជាតិ និងសង្គមកម្ពុជា និងមានគំនិតការពារបរិស្ថានធម្មជាតិ និងអភិវឌ្ឍប្រព័ន្ធផលិតកម្មកសិកម្មឱ្យរីកចម្រើនដូចប្រទេសជឿនលឿនទាំងឡាយ ។

កម្ពុជា ជាប្រទេសមួយដែលពឹងផ្អែកលើកសិកម្មជាសំខាន់ ។ កសិកម្មជាវិស័យមួយដែលមានសារៈសំខាន់បំផុតក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រោះវិស័យនេះអាចផ្ដល់នូវប្រភពស្បៀងអាហារសម្រាប់ជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ជាប្រភពផ្គត់ផ្គង់វត្ថុធាតុដើមចម្បងសម្រាប់ការអភិវឌ្ឍផ្នែកកសិ-ឧស្សាហកម្ម និងជាប្រភពចំណូលជាតិសំខាន់ ដែលទទួលបានពីការធ្វើផលិតកម្មនិងការនាំចេញផលិតផលកសិកម្មចូលទៅក្នុងទីផ្សារអន្តរជាតិ ។

វិស័យកសិកម្មបានរួមចំណែកយ៉ាងសំខាន់ផងដែរក្នុងកិច្ចការសង្គម ក៏ដូចជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ព្រោះវិស័យនេះអាចដោះស្រាយបាននូវការងាររបស់ប្រជាជនបានរហូតដល់ប្រមាណ 70% តាមរយៈការធ្វើផលិតកម្មនៅក្នុងសមាសភាពនៃអនុវិស័យ ក្នុងវិស័យកសិកម្ម ។ ផលិតផលកសិកម្មរួមមាន ដំណាំស្រូវនិងដំណាំរួមផ្សំ 52.7% ការនេសាទ 25% ការចិញ្ចឹមសត្វ 15.5% ព្រៃឈើនិងអាជីវកម្ម 6.8% ។

## 1. វិស័យកសិកម្ម




*សមាសភាព GDP នៃវិស័យកសិកម្មឆ្នាំ 2008*

គួរកត់សម្គាល់ថា អត្រាភាគរយនៃ GDP ផ្នែកកសិកម្មជារួម មាននិន្នាការថយចុះពី 41.5% នៅឆ្នាំ 1999 មកត្រឹម 29.6% នៅឆ្នាំ 2006 និងមានការកើនឡើង 29.7% នៅឆ្នាំ 2007 និង 34.4% នៅឆ្នាំ 2008 ។ ការណ៍នេះ បង្ហាញពីភាពប្រកួតប្រជែង ភាពរីកចម្រើនរួមនៃវិស័យសេដ្ឋកិច្ចទាំងបីរបស់កម្ពុជា ហើយនៅក្នុងនោះវិស័យកសិកម្មនៅតែបន្តរីកចម្រើនទាំងបរិមាណនិងគុណភាព ។ ឆ្នាំ 2008 កន្លងទៅ ការចូលរួមចំណែករបស់កសិកម្មក្នុង GDP បានកើនឡើងពី 29.7% ដល់ 34.4% ដោយសារការធ្លាក់ចុះនៃវិស័យសេដ្ឋកិច្ចពីរផ្សេងទៀត ។




*សរុប (%) GDP ផ្នែកកសិកម្មពីឆ្នាំ 1999-2008*

## 2. ប្រភេទកសិករ

ប្រជាជនកម្ពុជាភាគច្រើនរស់នៅជនបទ (80.5%) ហើយប្រកបរបរកសិកម្ម (72.3%) ។ ទោះបីប្រទេសកម្ពុជាមានផ្ទៃដីសម្រាប់ដំណាំស្រូវពី 85% ទៅ 90% ក៏ដោយ ក៏គ្រួសារមួយចំនួនផលិតស្រូវពុំបានគ្រប់គ្រាន់តាមតម្រូវការនៅឡើយ ។ គេចែកកសិករទាំងនោះជាប្រភេទធំៗដូចតទៅ

- **កសិករផលិតស្រូវ ឬអ្នកស្រែ** មានចំនួនច្រើនជាងគេ ។ ពួកគេនិយមធ្វើស្រូវវស្សានៅលើផ្ទៃដីទំនាប ។ ក្រៅពីនេះ គេមានការងារផ្សេងៗទៀតដូចជា ចិញ្ចឹមសត្វ ឡើងត្នោត ឯកសិករមួយចំនួនទៀត ធ្វើស្រូវប្រដេញទឹកនិងស្រូវប្រាំងនៅចុងរដូវវស្សា ពេលទឹកស្រក តាមដងទន្លេ មាត់បឹង និងមាត់ព្រែកនានា ។ កសិករទាំងនោះអាចរកប្រាក់បំពេញតម្រូវការរបស់ពួកគេ ដោយធ្វើចំណាកស្រុកតាមរដូវទៅកាន់ទីក្រុង ឬទីប្រជុំជន ដើម្បីរកការងារធ្វើ ។
- **កសិករនៅតំបន់ដីខ្ពស់** ដាំដំណាំអចិន្ត្រៃយ៍ ឬតាមរដូវដូចជា ពោត ដំឡូង សណ្ដែក ល្ង... ។ កសិករខ្លះទៀតចិញ្ចឹមសត្វនិងធ្វើស្រូវប្រដេញទឹក ។
- **កសិករធ្វើចំការ ឬកសិករមិនដាំស្រូវ** ដាំដំណាំផ្សេងៗនៅតាមបណ្ដោយមាត់ទន្លេ មាត់ស្ទឹង និងដីទួលនានាដូចជា ថ្នាំជក់ បន្លែ ផ្កា ... ។

កសិករទាំងនោះមានការងារបន្ទាប់បន្សំទៀតដូចជា ចិញ្ចឹមសត្វ ដាំឈើហូបផ្លែ និងនេសាទ ។ កសិករភូមិភាគឦសាន (រតនគិរី មណ្ឌលគិរី) និងតំបន់ព្រៃភ្នំនានាច្រើនធ្វើដំណាំព្រៃដុតមាន ស្រូវ

ពោត ដំឡូង និងរុក្ខជាតិ ផ្តល់មើមផ្សេងៗទៀត។ ក្រៅពីនេះ ពួកគេស្វែងរកអនុផលព្រៃឈើនិងបរបាញ់សត្វ។ កសិករតំបន់ទំនាបកណ្តាលនិងអ្នកបរិស្ថានមួយចំនួនយល់ថា ប្រព័ន្ធកសិកម្មបែបពនេចរ (កសិកម្មព្រៃដុត) នេះមានលក្ខណៈបំផ្លាញបរិស្ថានខ្ពស់បំផុតដូចជា ធ្វើឱ្យមានសំណឹកដីបាត់បង់សារធាតុចិញ្ចឹមសម្រាប់រុក្ខជាតិ ទឹកជំនន់ ភាពរាំងស្ងួត បាត់បង់ជម្រកសត្វព្រៃ និងការថយចុះនូវផលិតភាពកសិកម្ម។ ប៉ុន្តែ ការស្រាវជ្រាវបច្ចុប្បន្នបានបង្ហាញយ៉ាងច្បាស់ថា នៅតំបន់ដែលមានដង់ស៊ីតេប្រជាជនទាបនិងមានផ្ទៃដីធំទូលាយសំរាប់ឱ្យព្រៃដុះឡើងវិញ កសិកម្មពនេចរអាចរួមចំណែកយ៉ាងពិតប្រាកដក្នុងការការពារទីជម្រាល គម្របព្រៃឈើ និងជីវៈចម្រុះ។

នៅក្នុងវិស័យកសិកម្មកម្ពុជា ស្ត្រីបានដើរតួនាទីសំខាន់ណាស់ បន្ថែមលើការងារផ្ទះសំបែង (ដាំបាយ បុកស្រូវ កិនស្រូវ ដងទឹក រកអុស និងថែទាំកូនចៅ)។ ស្ត្រីត្រូវដាំដំណាំ ប្រមូលផល មើលថែទាំសត្វពាហនៈ និងត្រូវទៅលក់ផលិតផលនៅឯទីផ្សារទៀតផង។

# 3. ប្រព័ន្ធផលិតកម្ម

## 3.1. ដំណាំស្រូវ

ស្រូវជាដំណាំសំខាន់ជាងគេបំផុតនៅប្រទេសកម្ពុជា ព្រោះដំណាំស្រូវដាំដុះលើផ្ទៃដីប្រមាណ 90% នៃផ្ទៃដីដាំដុះសរុប។ ក្នុងឆ្នាំ 2008 ផ្ទៃដីដាំស្រូវមាន 2 615 741 ហិចតា តែផ្ទៃដីប្រមូលផលមានតែ 2 613 363 ហិចតាប៉ុណ្ណោះ និងទិន្នផលជាមធ្យម 2.746 ត/ហិចតា លើសពីឆ្នាំ 2007 ដែលមាន 2.621 ត/ហិចតា។ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេសរយៈពេល 10 ឆ្នាំ មានការកើនឡើងចាប់ពីឆ្នាំ 1999 រហូតមកដល់ឆ្នាំ 2008 លើកលែងតែឆ្នាំ 2002 ដែលផ្ទៃដីដាំដុះបានធ្លាក់ចុះ ដោយសារជួបនឹងភាពរាំងស្ងួតនិងទឹកជំនន់។ កសិករប្រមាណ 50% មានដីស្រែតូចជាង 1 ហិចតា ហើយក្នុងចំណោមកសិករទាំងអស់ មានតែកសិករ 20% ប៉ុណ្ណោះ ដែលផលិតស្រូវបានច្រើនលើសពីតម្រូវការហូបចុក។ ប្រព័ន្ធផលិតស្រូវអាចមានលក្ខណៈខុសប្លែកគ្នាទៅតាមទីតាំងភូមិសាស្ត្រ របប ទឹក រដូវដាំដុះ និងកម្រិតត្រួតពិនិត្យផ្សេងៗ។ ដូច្នេះ គេអាចចែកប្រព័ន្ធផលិតស្រូវដូចតទៅ៖

- ស្រូវវស្សា ត្រូវបានគេដាំនៅទូទាំងប្រទេស ចាប់ពីខែឧសភា ដល់ខែតុលា។ ផ្ទៃដីសម្រាប់ស្រូវវស្សាមាន 2 255 104 ហិចតា ទិន្នផលមធ្យម 2.54 ត/ហិចតា(2008) ខ្ពស់ជាងឆ្នាំ 2007 ដែលមាន 2.413 ត/ហិចតា និងកាលពីឆ្នាំ 1999 ដែលមានតែ 1.805 ត/ហិចតាប៉ុណ្ណោះ។ ខេត្តដែលផ្តល់ស្រូវបានច្រើនជាងគេគឺ ខេត្តព្រៃវែង តាកែវ បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ កំពង់ចាម កំពង់ឆ្នាំង និងស្វាយរៀង។ ខេត្តដែលផលិតស្រូវមិនគ្រប់គ្រាន់នឹងតម្រូវការមាន ខេត្តព្រះសីហនុ កោះកុង ប៉ៃលិន និងកែប។

- ស្រូវប្រាំង គេធ្វើនៅតំបន់ក្បែរមាត់បឹង ទន្លេ ស្ទឹង ព្រែក ដោយវិធីស្ទូងនិងបាចទឹកបញ្ចូលនៅរដូវទឹកស្រក ។ ផ្ទៃដីស្រែប្រាំងមាន 360 637 ហិចតា(2008) កើនលើសឆ្នាំ 1999 ដែលមានតែ 242 000 ហិចតា និងឆ្នាំ 2007 មាន 344 791 ហិចតា ។ ទិន្នផលជាមធ្យម 4.03 ត/ហិចតា លើសពីឆ្នាំ 1999 ដែលមាន 3.039 ត/ហិចតា និងឆ្នាំ 2007 មាន 3.959 ត/ហិចតា ។ ខេត្តដែលធ្វើស្រូវប្រាំងសំខាន់ៗមាន ខេត្តព្រៃវែង តាកែវ កណ្តាល កំពង់ចាម និងកំពង់ឆ្នាំង ។
- ស្រូវឡើងទឹក ជាប្រភេទស្រូវធ្ងន់ ដែលមានរយៈពេលដាំដុះពី ៨ ទៅ ៩ ខែ ទើបអាចប្រមូលផលបាន ។ ស្រូវឡើងទឹកអាចធន់នឹងកម្ពស់ទឹកពី 2m ទៅ 5m ។ តំបន់ស្រូវឡើងទឹកសំខាន់ៗស្ថិតនៅជុំវិញបឹងទន្លេសាបនិងកំហូងនានាតាមបណ្តោយទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម ព្រៃវែង និងតាកែវ ។

ប្រជាជនខ្មែរម្នាក់ត្រូវការស្បៀងជាមធ្យមចំនួន 143kg ក្នុងមួយឆ្នាំ ក្នុងនោះអង្ករមាន 64% ។




*ផែនទីតំបន់ដំណាំស្រូវសំខាន់ៗនៅកម្ពុជា*

## ៣.២. ដំណាំកៅស៊ូ

កៅស៊ូមានប្រភពនៅប្រទេសប្រេស៊ីល ហើយនាំចូលមកដាំនៅកម្ពុជាដោយក្រុមហ៊ុនបារាំងកាលពីឆ្នាំ 1920 ។ គេដាំកៅស៊ូនៅតំបន់ដីក្រហមក្នុងខេត្ត កំពង់ចាម ក្រចេះ រតនគិរី និងព្រះសីហនុ និងបច្ចុប្បន្នតាមរយៈការវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងការដាំជាលក្ខណៈគ្រួសារមាននៅខេត្តស្ទឹងត្រែង មណ្ឌលគិរី សៀមរាប កំពង់ធំ ព្រះវិហារ ពោធិ៍សាត់ បាត់ដំបង និងប៉ៃលិន ។ មុនឆ្នាំ 1970 ចំការកៅស៊ូកម្ពុជាមាន 67 000 ហិចតា ឱ្យផល 52 000 តោនក្នុងមួយឆ្នាំ ។ ដើមកៅស៊ូចាស់ៗដែលលែងផ្តល់ជ័រ ត្រូវបានគេកាប់ធ្វើជាអុសនិងបញ្ចូលក្នុងរោងចក្រ សិប្បកម្មអារ-កែច្នៃឈើ ហើយដាំ ថ្មីជំនួសវិញ ។ ក្នុងឆ្នាំ 2008 ផ្ទៃដីដាំកៅស៊ូសរុបមាន 107 901 ហិចតា គឺស្មើនឹង 74% នៃផែនការយុទ្ធ សាស្រ្តឆ្នាំ 2015 ក្នុងនោះជាចំការកៅស៊ូរដ្ឋនិងក្រុមហ៊ុនឯកជនមាន 53 674 ហិចតា និងចំការកៅស៊ូគ្រួសារមាន 54 227 ហិចតា ដែលផ្តល់ជ័រស្ងួតសំរាប់ធ្វើនីហរណកម្មបានចំនួន 10 825 តោន ប្រាក់ចំណូល 24 903 378 ដុល្លារអាមេរិក(តម្លៃលក់ជាមធ្យម 2 300$ ក្នុង1 តោន) ។ ផ្ទៃដីកៅស៊ូកម្ពុជាចែកជាបីប្រភេទគឺ កៅស៊ូកសិ-ឧស្សាហកម្មមានស្រាប់ (Estates) កៅស៊ូក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច (New Investments) និងកៅស៊ូគ្រួសារ (Small holders) ។ សន្ទុះនៃការដាំដុះកៅស៊ូមានការកើនឡើងជាលំដាប់ ជាពិសេសផ្នែកកៅស៊ូគ្រួសារនិងការវិនិយោគលើដីសម្បទានសេដ្ឋកិច្ច ។ កៅស៊ូ ជា ដំណាំសេដ្ឋកិច្ចរយៈពេលវែងដែលមានតួនាទីយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ដល់សេដ្ឋកិច្ចសង្គម ដែលក្នុងនោះ កៅស៊ូបានរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិនិងសង្គមគ្រួសារ បង្កើតការងារនៅមូលដ្ឋានជនបទ និងទប់ស្កាត់ការធ្វើចំណាកស្រុក រួមចំណែកការពារបរិស្ថាន ទប់ទល់នឹងភាពក្តៅខ្លាំងនៃអាកាសធាតុ ការហូរច្រោះដី និងបង្កើតជាគម្របបៃតងជំនួសព្រៃឈើដែលរេចរិល និងផ្តល់ឈើសម្រាប់ប្រើប្រាស់និងធ្វើអុសដុត ដែលអាចកាត់បន្ថយការកាប់ព្រៃឈើបាន ។

## ៣.៣. ដំណាំផ្សេងៗទៀត

ក្រៅពីដំណាំស្រូវនិងកៅស៊ូ នៅមានដំណាំផ្សេងៗជាច្រើនមុខទៀតដូចជា

- **ដំណាំរួមផ្សំ** ដាំដុះលើដីសរុប 444 683 ហិចតា ក្នុងនោះមាន ពោត 163 106 ហិចតា ទិន្នផល 3.73 ត/ហិចតា(ពោតក្រហម 4.94 ត/ហិចតា) ដំឡូងឈើ 179 945 ហិចតា ទិន្នផល 20.43 ត/ហិចតា ដំឡូងជ្វា 8 246 ហិចតា ទិន្នផល 4.88 ត/ហិចតា បន្លែ 47 781 ហិចតា ទិន្នផល 5.43 ត/ហិចតា និង សណ្តែកបាយ 45 605 ហិចតា ទិន្នផល 0.84 ត/ហិចតា ។
- **ដំណាំឧស្សាហកម្ម** ដាំដុះលើដីសរុប 151 611 ហិចតា ក្នុងនោះមាន សណ្តែកដី 18 183 ហិចតា ទិន្នផល 1.96 ត/ហិចតា សណ្តែកសៀង 74 413 ហិចតា ទិន្នផល 1.45 ត/ហិចតា ល្ង 35 874 ហិចតា ទិន្នផល 0.76 ត/ហិចតា ក្រចៅ 397 ហិចតា ទិន្នផល 0.74 ត/ហិចតា អំពៅ 13 297 ហិចតា ទិន្នផល 29.11 ត/ហិចតា និងថ្នាំជក់ 9 447 ហិចតា ទិន្នផល 1.84 ត/ហិចតា ។

## 3.4. ការចិញ្ចឹមសត្វ

នៅប្រទេសកម្ពុជា ការចិញ្ចឹមសត្វទទួលបានផលទាបនៅឡើយ ហើយមានលក្ខណៈតូចតាចនៅតែក្នុងរង្វង់គ្រួសារនិងខ្វះបច្ចេកទេស ។ ការចិញ្ចឹមសត្វមិនបម្រើឧស្សាហកម្ម ឬជំនួញទេ គឺបម្រើតែការងារកសិកម្មប៉ុណ្ណោះ ពិសេសសម្រាប់ធ្វើជាកម្លាំងអូសទាញ ។ ជារួម ផលិតកម្មសត្វនៅកម្ពុជាមានការប្រែប្រួលកំណើនយឺត ។

- តាមស្ថិតិឆ្នាំ 2008 សត្វគោមានចំនួនសរុប 3 457 787 ក្បាល (មេ 989 790 ក្បាល និងកម្លាំងអូសទាញ 1 360 986 ក្បាល) ។ ខេត្តដែលចិញ្ចឹមច្រើនជាងគេគឺខេត្ត កំពង់ចាម កំពង់ស្ពឺ តាកែវ ព្រៃវែង កំពង់ធំ សៀមរាប និងកំពត ។ ផលិតកម្មសត្វគោមានការកើនឡើង 13% បើធៀបទៅឆ្នាំ 2004 ។
- សត្វក្របីមានចំនួនសរុប 746 207 ក្បាល(មេ 259 667 ក្បាលនិងកម្លាំងអូសទាញ375 532 ក្បាល) ។ ខេត្តដែលចិញ្ចឹមច្រើនជាងគេមានខេត្ត ស្វាយរៀង ពោធិ៍សាត់ ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង និងក្រចេះ ។ បើប្រៀបធៀបនឹងឆ្នាំ 2007 មានការថយចុះចំនួន 26 573 ក្បាល ។
- សត្វជ្រូកមានចំនួនសរុប 2 215 641 ក្បាល (មេ 220 072 ក្បា) ។ បើធៀបនឹងឆ្នាំ 2007 ថយចុះ 173 748 ក្បាល (អត្រាថយចុះ 7.84%) ។ ការថយចុះនេះ បណ្ដាលមកពីការហូរចូលផលិតផលសត្វជ្រូកពីបណ្ដាប្រទេសជិតខាង ។
- សត្វស្លាប (មាន់ ទា...) មាន 16 928 075 ក្បាល កើនលើសពីឆ្នាំ 2007 ចំនួន 1 102 761 ក្បាល ដែលជាមោទនភាពដ៏ល្អដោយសារកម្ពុជាមានវិធានការល្អប្រសើរក្នុងការការពារមិនឱ្យមានការផ្ទុះឡើងជំងឺផ្ដាសាយបក្សី ។

  ក្រៅពីនេះ នៅមានការចិញ្ចឹមសត្វសេះ ចៀម និងពពែមួយចំនួនទៀត ។

## 3.5. ការនេសាទ

ប្រទេសកម្ពុជា កាលពីមុនសង្គ្រាមសំបូរត្រីណាស់ ដោយសារសំបូរព្រៃលិចទឹក អាកាសធាតុអនុគ្រោះ របបទឹកឡើងនិងស្រកមានភាពទៀងទាត់ ឯបទល្មើសនេសាទក៏មានតិចតួចដែរ ។ ប៉ុន្តែសព្វថ្ងៃបរិមាណត្រីថយចុះយ៉ាងខ្លាំង ពូជត្រីមួយចំនួនត្រូវបាត់បង់និងពូជត្រីមួយចំនួនទៀតកំពុងឈានទៅរកការបាត់បង់ទាំងស្រុង ។ ទាំងនេះដោយសារការកាប់បំផ្លាញព្រៃលិចទឹកស្ទើរអស់ កំណើនមោកនៅបាតបឹង ទន្លេ ស្ទឹង ការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ថ្នាំនិងជីគីមីក្នុងកសិកម្ម ពិសេសបទល្មើសក្នុងការនេសាទនិងការនេសាទដោយឧបករណ៍ទំនើប ។ ការនេសាទទឹកសាបប្រព្រឹត្តទៅនៅរដូវទឹកស្រកតាមបឹងនិងផ្លូវទឹកនានា ពិសេសបឹងទន្លេសាប (មុនឆ្នាំ 1970=10 ត/ $km^2$) ។ តាមស្ថិតិផលនេសាទទឹកសាបឆ្នាំ 2008 មាន 356 000 តោនថយចុះពីជាងពីឆ្នាំ 2007 ដែលមាន 395 000 តោន ដោយសារកត្តាធម្មជាតិធ្វើឱ្យកម្រិតទឹកទន្លេទាបជាងឆ្នាំមុន ។

អាជីវកម្មនេសាទសមុទ្រ អនុវត្តបាន 66 000 តោន (2008) មានកំណើន 18% ក្នុងរយៈពេល 5 ឆ្នាំ ។ ខេត្តនេសាទសមុទ្រសំខាន់ៗមាន ខេត្តព្រះសីហនុ កោះកុង កំពតនិងកែបក្នុងនោះខេត្តកោះកុងនេសាទបានច្រើនជាងគេ គឺ 32 580 តោននិងខេត្តព្រះសីហនុ 27 030 តោន ។

ការអភិវឌ្ឍវារីវប្បកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ គឺកើនពី 20 535 តោននៅឆ្នាំ 2004 ទៅ 40 000 តោននៅឆ្នាំ 2008 ក្នុងអត្រាកំណើន 94% ។ ការចិញ្ចឹមត្រីនិងបង្គាបានចំនួន 40 000 តោនក្នុងនោះបង្គា 75 តោន អន្ទង់ 79 តោន កង្កែប 11 តោន ក្ដាមថ្ម 15 តោន ខ្យង 800 តោន ក្រែងឈាម 495 តោន និងត្រីសមុទ្រ 265 តោន ។ ចិញ្ចឹមក្រពើបាន 156 500 ក្បាលដែលច្រើនមាននៅក្នុងខេត្តសៀមរាប បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ បន្ទាយមានជ័យ និងកណ្ដាល ។ ការភ្ញាស់កូនត្រីពូជបាន 37 193 ពាន់ក្បាល ។

ថ្វីបើមានការថយចុះក្ដី ក៏ប្រទេសកម្ពុជានៅតែមានលទ្ធភាពនាំចេញផលនេសាទមួយចំនួននៅឡើយ ដូចជាផលនេសាទស្រស់ចំនួន 17 000 តោននិងផលកែច្នៃចំនួន 8 000 តោនក្នុងឆ្នាំ 2008 បាននាំចេញលើសផែនការកំណត់ទុកត្រឹមតែ 15 000 តោននិង 5 000 តោន ។

## 3.6. ព្រៃឈើ

ព្រៃឈើជាប្រភពភោគទ្រព្យធម្មជាតិដែលកើតឡើងវិញ ។ ភោគទ្រព្យនេះត្រូវតែទទួលការគ្រប់គ្រងប្រកបដោយគតិបណ្ឌិត ដើម្បីជាប្រយោជន៍សម្រាប់មនុស្សជំនាន់ក្រោយនិងអនាគតនៃប្រជាជនកម្ពុជា ។ ប្រសិនបើមានគ្រប់គ្រងប្រកបដោយគតិបណ្ឌិត ព្រៃឈើអាចបន្តផ្គត់ផ្គង់តម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ក៏ដូចជាតម្រូវការរបស់ប្រទេសក្នុងការទទួលបានប្រាក់ចំណូលសម្រាប់ការអភិវឌ្ឍ ។ ប្រសិនបើការគ្រប់គ្រងមិនបានល្អវិញនោះ ភោគទ្រព្យនេះនឹងត្រូវបាត់បង់ ហើយកាលានុវត្តភាព ឬឱកាសសម្រាប់មនុស្សជំនាន់ក្រោយនឹងត្រូវបាត់បង់ ។ ក្នុងករណីអាក្រក់ខ្លាំង ការគ្រប់គ្រងមិនបានល្អអាចនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រព័ន្ធធនធានផ្សេងៗ ដូចជាផលិតផលស្បៀងនិងផលស្តុកត្រីជាដើម ។

ប្រទេសកម្ពុជាសំបូរព្រៃឈើដោយសារអាកាសធាតុអនុគ្រោះ ។ ប៉ុន្តែ ក្នុងមួយសតវត្សកន្លងមក ព្រៃឈើត្រូវបាត់បង់ជាបន្តបន្ទាប់គួរឱ្យព្រួយបារម្ភ ។ រហូតមកដល់ឆ្នាំ 1900 ផ្ទៃដីព្រៃឈើស្មើនឹង 75% នៃផ្ទៃប្រទេស នៅឆ្នាំ 1960 នៅសល់ 73% នៅឆ្នាំ 1980 នៅសល់ 50% (តាមតារាងណបឥណ្ឌថតពីលើអាកាស) ឆ្នាំ 1989 នៅសល់តែ 7 548 000 ហិចតាស្មើនឹង 41.7% (យោងតាមទីភ្នាក់ងារសារព័ត៌មាន For Eastern Economic Review ចុះថ្ងៃទី 12 ខែ មករា ឆ្នាំ 1989) ហើយបច្ចុប្បន្ននៅតិចជាង 40% និងបន្តចុះថយជាលំដាប់ ។ មូលហេតុនៃការថយចុះព្រៃឈើនេះ បណ្ដាលមកពីកត្តាជាច្រើន ដូចជាកំណើនប្រជាជនដែលនាំមកនូវកំណើនតម្រូវការដីកសិកម្ម លំនៅឋាន ឈើសំណង់ គ្រឿងសង្ហារិម អុស ធ្យូង (មនុស្សម្នាក់ប្រើប្រាស់អុសធ្យូងប្រមាណ 207 kg ក្នុងមួយឆ្នាំ "Wood Energy Flow Study 1997") ភ្លើងឆេះព្រៃនិងការធ្វើអាជីវកម្មបែបទ្រង់ទ្រាយធំនិងអនាធិបតេយ្យ ។

ការកាប់បំផ្លាញព្រៃឈើពុំផ្តល់ផលអាក្រក់តែនៅកន្លែងកាប់បំផ្លាញប៉ុណ្ណោះទេ តែប៉ះពាល់ជាទូទៅដល់បរិស្ថាន កសិកម្ម សេដ្ឋកិច្ចនិងសង្គម ដូចជាទឹកជំនន់ ភាពរាំងស្ងួត កំណើនកម្តៅ ផលស្រូវថយចុះ វិនាសហិនហោចសត្វនិងមច្ឆជាតិដោយសារការបាត់បង់ជម្រកនិងធ្វើឱ្យបាត់បង់ប្រភពទឹកសម្រាប់ប្រើប្រាស់ផងដែរ ។ រដ្ឋាភិបាលសហការជាមួយស្ថាប័នជាតិនិងស្ថាប័នអភិវឌ្ឍន៍អន្តរជាតិនានាដើម្បីគ្រប់គ្រងព្រៃឈើឱ្យបានល្អ បង្កើនផ្ទៃដីគម្របព្រៃឈើឈានឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាដែលបានកំណត់រក្សាគម្របព្រៃឈើ 60% នៅឆ្នាំ 2015 ។ ការអនុវត្តមានដូចជាការបង្កើនតំបន់ការពារធម្មជាតិ(ឧទ្យានជាតិ) ការបង្កើតសហគមន៍ព្រៃឈើ (ឆ្នាំ 2008 មាន 360 សហគមន៍គ្របដណ្តប់លើផ្ទៃដី 325 130 ហិចតា) ការបោះបង្គោលព្រំដែនព្រៃឈើ ការស្រាវជ្រាវនិងអភិរក្សសត្វព្រៃ និងការដាំដើមឈើឡើងវិញ (ប្រារព្ធរុក្ខទិវាថ្ងៃទី 09 ខែកក្កដារៀងរាល់ឆ្នាំ) ។

## 4. ទំនាក់ទំនងរវាងការដាំដុះ អាជីវកម្មព្រៃឈើ និងនេសាទ

ការដាំដុះព្រៃឈើ និងនេសាទជាភោគទ្រព្យយ៉ាងសំខាន់សម្រាប់ប្រជាជនកម្ពុជាក្នុងការទ្រទ្រង់ជីវភាពរស់នៅនិងការអភិវឌ្ឍប្រទេសជាតិ ។ ធាតុគន្លឹះទាំងបីនេះ មានអន្តរអំពើលើគ្នាទៅវិញទៅមក ។ ប្រសិនបើការពង្រីកប្រព័ន្ធផលិតកម្មមិនបានយកចិត្តទុកដាក់ដល់ទំនាក់ទំនងនៃធាតុគន្លឹះទាំងបីនេះទេ នោះនឹងឈានទៅដល់ការបំផ្លិចបំផ្លាញបរិស្ថានកាន់តែធ្ងន់ឡើងថែមទៀត មានន័យថា "មនុស្សជាអ្នកបំផ្លាញជីវិតខ្លួនឯង" ។

ដើម្បីបំពេញតម្រូវការក្នុងផលិតកម្មនិងតម្រូវការផ្សេងៗទៀត មនុស្សនាំគ្នាកាប់ព្រៃឈើដែលជាហេតុធ្វើឱ្យមានការប្រែប្រួលអាកាសធាតុ ប៉ះពាល់ដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ។ អតិផលនៃប្រព័ន្ធផលិតកម្មនាំឱ្យមានកំណើនការប្រែប្រួលថ្នាំសម្លាប់សត្វល្អិត និងជីគីមី ។ ថ្នាំសម្លាប់សត្វល្អិតនិងជីគីមីទាំងនោះហូរទៅផ្តុំគ្នានៅទន្លេនិងបឹងហើយបំផ្លាញជីវិតនិងពូជមច្ឆជាតិ ។

## ? សំណួរ

1. តើគេចែកប្រភេទកសិករនៅកម្ពុជាជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើនៅកម្ពុជាស្ត្រីមានតួនាទីអ្វីខ្លះក្នុងវិស័យកសិកម្ម ?
3. តើនៅកម្ពុជាគេដាំស្រូវអ្វីច្រើនជាងគេ ? ព្រោះអ្វី ?
4. តើដំណាំកៅស៊ូផ្តល់សារៈសំខាន់អ្វីខ្លះដល់សេដ្ឋកិច្ច បរិស្ថាន និងសង្គម ?
5. តើការចិញ្ចឹមសត្វនៅកម្ពុជា មានភាពជឿនលឿនហើយ ឬនៅ ? ហេតុអ្វី ?
6. ចូររៀបរាប់អំពីមូលហេតុដែលនាំឱ្យបរិមាណត្រីចុះថយ ។
7. តើព្រៃឈើមានសារប្រយោជន៍អ្វីខ្លះ ? កន្លងមកនេះ តើព្រៃឈើនៅកម្ពុជាមានលក្ខណៈដូចម្តេច? តើរដ្ឋាភិបាលមានគោលការណ៍យ៉ាងណាខ្លះ ក្នុងការការពារព្រៃឈើ ?
8. ចូររៀបរាប់អំពីទំនាក់ទំនងរវាងការដាំដុះ អាជីវកម្មព្រៃឈើ និងនេសាទ ។

មេរៀនទី

# 2 ឧស្សាហកម្មកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- ពិពណ៌នាពីបម្រែបម្រួលឧស្សាហកម្មនិងតួនាទីឧស្សាហកម្មនៅកម្ពុជាក្នុងវិស័យសេដ្ឋកិច្ចជាតិ ។ មានគំនិតអភិវឌ្ឍវិស័យឧស្សាហកម្មដើម្បីជំរុញជីវភាពរស់នៅរបស់ប្រជាជនឱ្យបានកាន់តែប្រសើរឡើង ។

ប្រទេសកម្ពុជាបានអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីចាប់ពីឆ្នាំ 1993 មក ។ ដូច្នេះ សហគ្រាសនានាត្រូវបានកែទម្រង់ហើយក្លាយជារបស់ឯកជនជាបន្តបន្ទាប់ ។ វិស័យឧស្សាហកម្មបានរួមចំណែក 23.8% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ 2008 បើធៀបនឹងឆ្នាំ 2007 មានការធ្លាក់ចុះ (30.2%) ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោកនិងការចូលរួមរបស់វិស័យកសិកម្មមានការកើនឡើង ។ នៅក្នុងចតុកោណទី 3 នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានលើកឡើងអំពី "ការអភិវឌ្ឍវិស័យឯកជននិងការងារ" ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់និងយល់ស្របលើចំណុចមួយដ៏សំខាន់ដែលថា ផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចក្នុងប្រទេស ។ កាលណាផ្នែកឯកជនមានកំណើនរឹងមាំ អាចបំពេញបន្ថែមវិនិយោគសាធារណៈក្នុងវិស័យសង្គមកិច្ច ដោយស្រូបយកកម្លាំងពលកម្មធ្វើការងារកាន់តែកើនឡើងនិងបង្កើតជំនាញផ្សេងៗជាច្រើន ។ មុំទាំង 4 នៃចតុកោណទី 3 នេះគឺ ការពង្រឹងវិស័យឯកជននិងការទាក់ទាញការវិនិយោគ (រួមមានវិស័យកាត់ដេរសម្លៀកបំពាក់ និងទេសចរ) ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករនិងនិយោជិក ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់មន្ត្រី បុគ្គលិក កម្មករ ។




*តម្លៃផលិតផលសរុបក្នុងស្រុក (GDP) នៃកម្ពុជាតាមវិស័យក្នុងឆ្នាំ 2008*

# 1. រចនាសម្ព័ន្ធសហគ្រាស

## 1.1. ការអភិវឌ្ឍសហគ្រាសឯកជន

ចាប់ពីឆ្នាំ 1993 រដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី ។ សហគ្រាសនានាត្រូវបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅហើយក្លាយជាកម្មសិទ្ធិរបស់ឯកជនជាបន្តបន្ទាប់ ។ មកដល់ឆ្នាំ 1995 សហគ្រាសរដ្ឋចំនួន 50 បានលក់ទៅឱ្យក្រុមហ៊ុនឯកជន ក្នុងចំណោមសហគ្រាសរដ្ឋសរុបចំនួន 152 ។ អាស្រ័យដោយការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ការវិនិយោគក្នុងវិស័យឯកជននិងផ្នែកពាក់ព័ន្ធកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស ។ នេះបញ្ជាក់ថាការជឿជាក់និងភាពកក់ក្តៅរបស់វិស័យឯកជនកំពុងមានការកើនឡើងនៅកម្ពុជា ដោយសារការធានាឱ្យមានសន្តិភាព ស្ថិរភាពនយោបាយ ច្បាប់និងសណ្តាប់ធ្នាប់ ការគ្រប់គ្រងដោយច្បាប់ កំណើនម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយរូបិយវត្ថុរួមទាំងការកាត់បន្ថយជាបណ្តើរៗនូវអំពើពុករលួយ ។ ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោកបានបន្តប៉ះពាល់មកលើឧស្សាហកម្មកម្ពុជានៅឆ្នាំ 2009 រោងចក្រកាត់ដេរចំនួន 40 ត្រូវបិទទ្វារ ប៉ុន្តែក្នុងខែធ្នូឆ្នាំ 2009 មានរោងចក្រកាត់ដេរចំនួន 11 មានដំណើរការឡើងវិញ ។ នៅឆ្នាំ 2009 មានរោងចក្រកើតថ្មីចំនួន 43 ។ ចំនួនរោងចក្រដែលបានចុះក្នុងបញ្ជីសរុបឆ្នាំ 2009 មានចំនួន 556 និងប្រើប្រាស់ពលកម្មសរុបចំនួន 392 373 នាក់ ។

## 1.2. សហគ្រាសធុនតូចនិងសិប្បកម្ម

ឧស្សាហកម្មនៅកម្ពុជាស្ទើរតែទាំងអស់ជាសហគ្រាសធុនតូចនិងសិប្បកម្ម (ឧស្សាហកម្មស្រាល) ។ កាលពីឆ្នាំ 1999 ប្រទេសកម្ពុជា មានសហគ្រាសខ្នាតតូចនិងសិប្បកម្មប្រមាណ 24 740 មូលដ្ឋាន និងកម្មករចំនួន 66 181 នាក់ប៉ុណ្ណោះ ។ មកដល់ឆ្នាំ 2009 នេះ ឧស្សាហកម្មធុនតូចនិងសិប្បកម្មមានចំនួនសរុប 35 560 មូលដ្ឋានបើប្រៀបធៀបនឹងឆ្នាំ 2008 ដែលមានចំនួន 32 800 មូលដ្ឋាន ឃើញថាមានការកើនឡើងចំនួន 8.41% ។ ការអនុវត្តតម្លៃបរិមាណផលិតផលសរុបក្នុងឆ្នាំ 2009 មានចំនួន 2 950 361 លានរៀលបើប្រៀបធៀបនឹងឆ្នាំ 2008 ដែលមានចំនួន 2 699 667 លានរៀលឃើញថាមានការកើនឡើង 9.29% ។ ចំនួនពលកម្មសរុបមានចំនួន 125 332 នាក់ គឺកើនឡើង 29.23% បើប្រៀបធៀបទៅនឹងឆ្នាំ 2008 ដែលមានចំនួន 96 983 នាក់ ។ ទំនិញចេញពីរោងចក្រច្រើនជាផលិតផលអាហារ ភេសជ្ជៈនិងថ្នាំជក់ដែលមានមូលដ្ឋានឧស្សាហកម្មចំនួន 29 987 និងប្រើប្រាស់កម្លាំងពលកម្ម 90 148 នាក់ (ឆ្នាំ 2009) ។ បន្ទាប់មក មានផលិតផលតម្បាញ កាត់ដេរសម្លៀកបំពាក់និងផលិតផលពីស្បែក ឧស្សាហកម្មរ៉ែមិនមែនលោហៈ ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃលោហៈនិងឧស្សាហកម្មផ្សេងៗទៀត ។

## 1.3. ឧស្សាហកម្មកាត់ដេរ



*ឧស្សាហកម្មកាត់ដេរ*

ឧស្សាហកម្មកាត់ដេរ ដែលកន្លងមកមានតួនាទីនាំមុខគេក្នុងកំណើនសេដ្ឋកិច្ចជាតិ បាននិងកំពុងបង្ហាញនូវសញ្ញាចុះថយដោយសារតម្រូវការទីផ្សារមុខទំនិញផ្នែកនេះបានថយចុះរួមផ្សំនិងការប្រកួតប្រជែងទីផ្សារដូចគ្នានៃបណ្ដាប្រទេសជិតខាងនិងថ្លៃដឹកជញ្ជូនកើនខ្ពស់ជាងមុនដោយសារមានការកើនឡើងនៃតម្លៃប្រេង ។ វិស័យនេះបានផ្ដល់ការងារដល់កម្មករប្រមាណ 350 000 នាក់ ដែលភាគច្រើនជាស្ត្រីវ័យក្មេងបម្រើការងារនៅក្នុងរោងចក្រកាត់ដេរចំនួន 422 (ឆ្នាំ 2009) ។ ការបិទទ្វាររោងចក្រកាត់ដេរមួយចំនួនដោយសារការទទួលរងឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចពិភពលោក បានធ្វើឱ្យកម្មករត្រូវបាត់បង់ការងារអស់ចំនួន 19 812 នាក់ក្នុងឆ្នាំ 2009 ។

## 1.4. ការផ្គត់ផ្គង់ទឹកស្អាត

ក្នុងឆ្នាំ 2009 ប្រជាជននៅរាជធានីភ្នំពេញចំនួន 90% ទទួលបានទឹកស្អាតប្រើប្រាស់ 24 ម៉ោងលើ 24 ម៉ោង ។ រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញផលិតបាន 91 132 000 $m^3$ គឺមានការកើនឡើង 5.9% បើធៀបនិងឆ្នាំ 2008 ដែលផលិតបាន 86 048 000 $m^3$ ។

ក្នុងឆ្នាំ 2009 នេះដែរ ប្រជាជនរស់នៅតាមបណ្ដាក្រុង ទីប្រជុំជនខេត្តទូទាំងប្រទេសចំនួន 54.43% បានទទួលទឹកស្អាតប្រើប្រាស់ ដែលកាលពីឆ្នាំ 2007 មានត្រឹមតែ 40% ប៉ុណ្ណោះ ។

## 1.5. ការផ្គត់ផ្គង់អគ្គិសនី



ខ្សែបណ្តាញអគ្គិសនីបញ្ជូនតង់ស្យុង 115kV ពីប្រទេសថៃ

ក្នុងការអភិវឌ្ឍវិស័យអគ្គិសនីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយថាមពលដើម្បីផ្គត់ផ្គង់ថាមពលឱ្យបានគ្រប់គ្រាន់នៅក្នុងទូទាំងប្រទេសដោយតម្លៃសមរម្យនៅក្នុងនោះឆ្នាំ 2020 គ្រប់ភូមិទាំងអស់នឹងទទួលបានការផ្គត់ផ្គង់អគ្គិសនីនិងនៅឆ្នាំ 2030 ប្រជាជនយ៉ាងហោចចំនួន 70% នៃគ្រួសារនឹងទទួលបានការផ្គត់ផ្គង់បណ្តាញអគ្គិសនីដែលមានគុណភាព ។ ដើម្បីសម្រេចបានគោលដៅខាងលើ រដ្ឋាភិបាលបានផ្តល់អាទិភាពខ្ពស់លើការពង្រីកនិងការថែទាំយ៉ាងត្រឹមត្រូវនូវហេដ្ឋារចនាសម្ព័ន្ធទូទាំងប្រទេស ដោយធ្វើការលើកទឹកចិត្តនិងទាក់ទាញការវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជននៅគ្រប់ទិដ្ឋភាពទាំងអស់ ដូចជាការផលិត ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី ការនាំចូលអគ្គិសនីដោយមានកិច្ចព្រមព្រៀងច្បាស់លាស់ពីប្រទេសថៃ ឡាវ និងវៀតណាម ។

ជាមួយនេះដែរ គោលនយោបាយថាមពលបានជំរុញឱ្យមានការអភិវឌ្ឍវិស័យថាមពលកើនឡើងវិញ ដោយបានសហការជាមួយអង្គការអន្តរជាតិនានា និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដូចជាប្រព័ន្ធថាមពលអគ្គិសនី ជីវឧស្ម័នសម្រាប់ទីជនបទ ជាពិសេសថាមពលវារីអគ្គិសនី ។

នៅឆ្នាំ 2009 ផលិតកម្មអគ្គិសនីនៅទូទាំងប្រទេសមានចំនួន 1 817 899 008 គីឡូវ៉ាត់ម៉ោង (kWh) លើសពីឆ្នាំ 2008 ដែលមាន 1 620 206 380 kWh ។ ដោយឡែកនៅឆ្នាំនេះដែរ ការនាំចូលថាមពលអគ្គិសនីពីប្រទេសថៃមានចំនួនសរុប 226 756 095 kWh និងពីប្រទេសវៀតណាម 500 742 495 kWh ។

បច្ចុប្បន្ននេះ ប្រជាជនប្រមាណ 25% នៃគ្រួសារទាំងអស់ទទួលបានអគ្គិសនីប្រើប្រាស់ពីគ្រប់ប្រភពទាំងអស់ ។

## 1.6. ការសិក្សាស្រាវជ្រាវនិងការធ្វើអាជីវកម្មរ៉ែ

ក្នុងវិស័យធនធានរ៉ែ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល បានចុះកិច្ចព្រមព្រៀងស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែដល់ក្រុមហ៊ុនរ៉ែជាច្រើនដែលមកវិនិយោគនិងសិក្សាស្រាវជ្រាវធនធានរ៉ែមួយចំនួន ដូចជា រ៉ែមាស (នៅខេត្តឧត្តរមានជ័យ ស្រុកបន្ទាយអំពិល ខេត្តកំពង់ធំ ស្រុកសន្ទុក និងខេត្ត

ក្រចេះ ស្រុកព្រែកប្រសព្វ) រ៉ែត្បូងថ្មមានតម្លៃ (ខេត្តរតនគិរី ប៉ៃលិន) រ៉ែលោហៈ (ខេត្តក្រចេះ រតនគិរី មណ្ឌលគិរី និងព្រះវិហារ) រ៉ែច្បូងថ្ម (ខេត្តឧត្តរមានជ័យ ស្រុកត្រពាំងប្រាសាទ) រ៉ែដែក (ស្រុកបរកែវ ខេត្តរតនគិរី ខេត្តកំពង់ធំ និងព្រះវិហារ) រ៉ែបុកស៊ីត (នៅខេត្តមណ្ឌលគិរីនិងរតនគិរី) ថ្មកំបោរ ផូស្វាត (ខេត្តកំពតនិងបាត់ដំបង) ខ្សាច់សនិងថ្មសំណង់ ។ ប៉ុន្តែបច្ចុប្បន្ននេះ បញ្ហាសំខាន់ដែលកំពុងប្រឈមចំពោះវិស័យធនធានរ៉ែ គឺកង្វះខាតធនធានមនុស្ស ជាពិសេសមន្ត្រីជំនាញរ៉ែសម្រាប់ប្រតិបត្តិការនៅទូទាំងប្រទេស ដោយហេតុថា បច្ចុប្បន្ននេះយើងពុំមានមហាវិទ្យាល័យធ្វើការបណ្តុះបណ្តាលជំនាញផ្នែកភូគព្ភសាស្ត្រ- រ៉ែនៅឡើយ ។




*ផែនទីឧស្សាហកម្មកម្ពុជា*

# 2. តួនាទីនៃឧស្សាហកម្មនៅក្នុងសេដ្ឋកិច្ចជាតិ

## 2.1. ការរួមចំណែកនៃឧស្សាហកម្មក្នុងសកម្មភាពសេដ្ឋកិច្ច

យោងតាមរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ 2008 ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2006-2010 អត្រាកំណើនផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2008 ស្មើនឹង 7% គឺមានការថយចុះជាងឆ្នាំ 2005 ដែលមាន 13.3% ឆ្នាំ 2006 មាន 10.8% និងឆ្នាំ 2007 មាន 10.2% ។ នៅឆ្នាំនេះដែរផលិតផលក្នុងស្រុកសម្រាប់ប្រជាជនកម្ពុជាម្នាក់ស្មើនឹង 716 ដុល្លារអាមេរិក ហើយនឹងកើនដល់ 842 ដុល្លារនៅឆ្នាំ 2010 ។ ដោយឡែកវិស័យឧស្សាហកម្មរួមចំណែកបាន 23,8% នៃផលិតផលក្នុងស្រុកសរុប គឺមានកម្រិតទាបជាងវិស័យកសិកម្មដែលមាន 34.4% និងវិស័យសេវាកម្មដែលមាន 41.8% ។ ប៉ុន្តែ បើប្រៀបធៀបនឹងមួយទសវត្សរ៍កន្លងទៅនេះ (ឆ្នាំ 1999 មាន 14%) ឃើញថាមានការកើនឡើងជិតពីរដង ដែលអាស្រ័យដោយសារភាពរីកចម្រើនខ្លាំងនៃវិស័យកាត់ដេរ ទោះបីជាមានការទទួលរងវិបត្តិហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ 2008-2009 ក៏ដោយ ។

**តម្លៃសរុបបរិមាណផលិតផលប្រចាំឆ្នាំ 2009**

| ល.រ | តម្លៃសរុបបរិមាណផលិតផល (ពាន់លានរៀល) | 2008 | 2009 | |
|---|---|---|---|---|
| | | ចំនួន | ចំនួន | កំណើន % |
| 1 | តម្លៃសរុបបរិមាណផលិតផល | 14 530 | 13 253 | -8.8 |
| 2 | តម្លៃសរុបបរិមាណផលិតផលផ្នែកកាត់ដេរ | 12 147 | 10 711 | -11.8 |
| 3 | តម្លៃសរុបបរិមាណផលិតផលផ្នែកដទៃទៀត | 2 383 | 2 542 | 6.7 |

## 2.2. ឧស្សាហកម្មបង្កើតការងារ

តាមឯកសារជំរឿនប្រជាជនឆ្នាំ 2008 មនុស្សមានអាយុលើសពី 5 ឆ្នាំធ្វើការក្នុងវិស័យផ្សេងៗមានចំនួន 7 053 398 នាក់ ក្នុងនោះនៅក្នុងវិស័យកសិកម្មមាន 72.30% វិស័យឧស្សាហកម្ម 8.54% និងវិស័យសេវាកម្ម 19.16% ។ ផ្នែកកាត់ដេរសម្លៀកបំពាក់ប្រើប្រាស់ពលករប្រមាណ 4.90% នៃប្រជាជនសកម្ម គឺស្មើនឹង 345 860 នាក់ ។

តាមរបាយការណ៍ស្ដីពីលទ្ធផលការងាររបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្នុងឆ្នាំ 2009 សហគ្រាសតូចនិងសិប្បកម្មផ្ដល់ការងារជូនប្រជាពលរដ្ឋបានចំនួន 125 332 នាក់ក្នុងនោះបម្រើការក្នុងផ្នែកឧស្សាហកម្មអាហារ ភេសជ្ជៈ និងថ្នាំជក់មាន 90 148 នាក់ ។

ភាគរយប្រជាជនមានការងារធ្វើអាយុ ១៥ឆ្នាំឡើងនៅកម្ពុជាតាមវិស័យនិងភេទ

ឆ្នាំ 1998-2008 គិតជាភាគរយ

| ភេទ | វិស័យការងារ | | | | | |
|---|---|---|---|---|---|---|
| | កសិកម្ម | | ឧស្សាហកម្ម | | សេវាកម្ម | |
| | 1998 | 2008 | 1998 | 2008 | 1998 | 2008 |
| ទាំងពីរភេទ | 77.53 | 72.30 | 4.24 | 8.54 | 18.23 | 19.16 |
| ប្រុស | 71.65 | 69.37 | 5.03 | 8.06 | 23.32 | 22.57 |
| ស្រី | 83.12 | 75.11 | 3.48 | 9.00 | 13.40 | 15.89 |

ចំនួនកម្មករ

| ចំនួនពលកម្មសរុប (នាក់) | ដើមឆ្នាំ 2009 | ចំនួនពលកម្មបាត់បង់ការងារឆ្នាំ 2009 | ចំនួនពលកម្មកើតថ្មីសរុបឆ្នាំ 2009 | ចំនួនពលកម្មសរុបខែធ្នូឆ្នាំ 2009 |
|---|---|---|---|---|
| ផ្នែកកាត់ដេរ | 325 868 | 19 812 | 39 804 | 345 860 |
| ផ្នែកផ្សេងៗ | 44 417 | | 2 096 | 46 513 |
| សរុប | 370 285 | 19 812 | 41 900 | 392 373 |

# ៣. ការងារបច្ចេកទេសរបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

## ៣.១. ការងារត្រួតពិនិត្យគុណភាពផលិតផល

ដើម្បីរក្សានូវសុខុមាលភាពរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ផលិតផលឧស្សាហកម្ម ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល បានចុះត្រួតពិនិត្យនិងវាយតម្លៃទិដ្ឋភាពបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្មសិប្បកម្មព្រមទាំងពិនិត្យលក្ខណៈបច្ចេកទេសផលិតកម្មដើម្បីកែលម្អនៅតាមបណ្តាមូលដ្ឋានឧស្សាហកម្មសិប្បកម្មមួយចំនួន ដូចជាផលិតកម្មស្រាកែច្នៃ នំប៉័ង នំគ្រប់មុខ ការលីងកាហ្វេនិងតែ ទឹកផ្លែឈើ និងការ៉េម ទឹកបរិសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ គុយទាវ មីសរសៃតូច-ធំ ទឹកកកអនាម័យ គ្រឿងគ្រប់ប្រភេទ កែច្នៃលោហៈគ្រប់ប្រភេទ ផលិតគ្រឿង ឥដ្ឋការ៉ូ យានដ្ឋានជួសជុលរថយន្ត ម៉ូតូ ។ល ។

- បានចុះស្រង់ព័ត៌មានអំពីសកម្មភាពការងារបច្ចេកទេសដើម្បីណែនាំធ្វើការកែលម្អឱ្យស្របតាមគោលការណ៍ផលិតកម្មនៅរោងចក្រធុនតូចផលិតទឹកបរិសុទ្ធ ទឹកកកអនាម័យ ទឹកកកដើម និងផលិតប្រហិតត្រីនៅរាជធានីភ្នំពេញបាន 28 រោងចក្រ រោងចក្រធុនតូចនិងសិប្បកម្មផលិតសម្ភារៈ

ប្រើប្រាស់នៅរាជធានីភ្នំពេញបានចំនួន 169មូលដ្ឋាននិងរោងចក្រធុនតូចផលិតចំណីអាហារបាន 106មូលដ្ឋាន ។

- បានវិភាគគុណភាពផលិតផលចំណីអាហារបានចំនួន 10 44 ផលិតផល (ពិសោធមីក្រូជីវសាស្ត្រចំណីអាហារ) ។
- បានវិភាគគុណភាពផលិតផលចំណីអាហារ មិនមែនចំណីអាហារនិងទឹកបានចំនួន 1 176 ផលិតផល (ពិសោធលើផ្នែកគីមីសាស្ត្រ) ។
- បាននិងកំពុងធ្វើការជ្រើសរើសសិប្បកម្មផលិតទឹកស៊ីអ៊ីវគម្រូ ដើម្បីអនុវត្តបច្ចេកវិទ្យាថ្មីក្នុងការផលិត ដើម្បីកាត់បន្ថយសារធាតុបង្កឱ្យកើតជំងឺមហារីក ។

ក្រៅពីនេះ នៅបានធ្វើការត្រួតពិនិត្យលើផ្នែកវេចខ្ចប់ផលិតផលឧស្សាហកម្មដោយបានកែតម្រូវបរិមាណចំណុះ ទម្ងន់ឱ្យបានសមស្របនិងកែតម្រូវទំហំតួលេខនិងតួអក្សរលើសំបកវេចខ្ចប់ឱ្យបានត្រឹមត្រូវតាមការកំណត់ ។

## 3.2. ការងារត្រួតពិនិត្យបរិស្ថាននិងសុវត្ថិភាព

ក្រសួងបានពិនិត្យឬង់និងបញ្ជាក់ជូនរោងចក្រចំនួន 10 បានពិនិត្យណែនាំសុវត្ថិភាពប្រើប្រាស់ឡចំហាយ ម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមខ្យល់ និងឧបករណ៍យោងបានចំនួន 46 រោងចក្រ និងបានចុះពិនិត្យស្ថានភាពបរិស្ថាននិងបាតុភាពផ្សេងៗដែលកើតមានឡើងនៅតាមបណ្តារោងចក្រមួយចំនួនដោយផ្តល់មតិណែនាំកែលម្អទៅលើការបង្ហូរកាកសំណល់រាវនិងកខ្វក់ដោយឱ្យតម្លើងប្រព័ន្ធសម្អាត ឬសម្លាប់មេរោគមុននឹងបង្ហូរចូលទៅក្នុងទន្លេ ឬបឹង ។ ចំពោះរោងចក្រ សិប្បកម្មដែលមានការបញ្ចេញក្លិនមិនល្អ តម្រូវឱ្យមានវិធានការកែលម្អឡើងវិញ ដើម្បីកុំឱ្យប៉ះពាល់ដល់សុខភាពប្រជាជននៅជុំវិញ ។

## ? សំណួរ

1. ហេតុអ្វីបានជាផ្នែកឯកជនជាកម្លាំងដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចក្នុងប្រទេស ?
2. ហេតុអ្វីបានជារដ្ឋាភិបាលលើកស្ទួយសហគ្រាសធុនតូចនិងសិប្បកម្ម ?
3. តើឧស្សាហកម្មអ្វីដែលមានតួនាទីនាំមុខគេក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន ? តើឧស្សាហកម្មនេះមានភាពរឹងមាំដែរ ឬទេ ? ហេតុអ្វី ?
4. តើការផ្គត់ផ្គង់ទឹកស្អាតមានសារប្រយោជន៍យ៉ាងណាខ្លះចំពោះប្រជាជន ?
5. តើការផ្គត់ផ្គង់អគ្គិសនីមានអត្ថប្រយោជន៍យ៉ាងណាខ្លះចំពោះសេដ្ឋកិច្ចនិងសង្គម ?
6. តើអាជីវកម្មរ៉ែនៅកម្ពុជាមានសកម្មភាពខ្លាំងក្លាហើយ ឬនៅ ? ព្រោះអ្វី ?
7. តើឧស្សាហកម្មមានតួនាទីចំពោះសេដ្ឋកិច្ចជាតិយ៉ាងណាខ្លះ ?
8. ចូររៀបរាប់ពីការត្រួតពិនិត្យគុណភាពផលិតផលឧស្សាហកម្ម ។

មេរៀនទី

# 3 គមនាគមន៍កម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់បានពីប្រភេទគមនាគមន៍កម្ពុជានិងសារៈសំខាន់ចំពោះវិស័យសេដ្ឋកិច្ចជាតិ។ មានគំនិតអភិវឌ្ឍនិងរក្សាការពារគមនាគមន៍គ្រប់ប្រភេទ ។

រាជរដ្ឋាភិបាលបានកំណត់ថា ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បណ្តាញគមនាគមន៍នៅតែមានតួនាទីជា "ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច" និងជាសរសៃឈាមសម្រាប់ភ្ជាប់ទៅគ្រប់ច្រកល្ហកនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយទៅជាសរីរាង្គសេដ្ឋកិច្ចមួយ ក្នុងគោលដៅធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់និងពិភពលោក និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយសម្រាប់កាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់ជីវភាពប្រជាជន ព្រមទាំងបម្រើដល់កិច្ចការពារជាតិទៀតផង ។

ហេតុដូច្នេះហើយ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ ផ្លូវជាតិ ស្ពាន កំពង់ផែ និងព្រលានយន្តហោះសំខាន់ៗ និងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារនិងកសាងប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទ ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស និងតភ្ជាប់ជាមួយបណ្តាប្រទេសជិតខាងឱ្យទៅជាប្រព័ន្ធ ឬបណ្តាញគមនាគមន៍មានភាពងាយស្រួល មានស្ថិរភាព សុវត្ថិភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាប សម្រួលដល់ការធ្វើពាណិជ្ជកម្ម ជំរុញវិស័យទេសចរ ការអភិវឌ្ឍជនបទ និងជួយសម្រួលការដឹកជញ្ជូនកសិផលរបស់ប្រជាជនទៅកាន់ទីផ្សារបានទាន់រហ័សទាន់ពេល ។

បណ្តាញគមនាមន៍នៅក្នុងប្រទេសកម្ពុជាមាន ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសសម្រាប់ធ្វើដំណើរនិងដឹកជញ្ជូនទំនិញផ្សេងៗនៅក្នុងប្រទេសនិងក្រៅប្រទេស ។

## 1. ផ្លូវគោក

ផ្លូវគោកមានពីរប្រភេទគឺ ផ្លូវថ្នល់និងផ្លូវដែក ក្នុងនោះផ្លូវថ្នល់មានសារៈសំខាន់ជាងគេ ទាំងប្រវែងនិងសកម្មភាព ។

## 1.1. ផ្លូវថ្នល់

ផ្លូវថ្នល់ចែកចេញជា ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវលំ និងផ្លូវរុក្ខបាល ។

- ផ្លូវជាតិ : ផ្លូវដែលស្ថាបនានិងថែរក្សាដោយថវិកាជាតិ ហើយជាផ្លូវដែលចេញពីរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ខេត្តនានា ។
- ផ្លូវខេត្ត : ផ្លូវទាំងឡាយណាដែលកាត់ផ្លូវជាតិ ឬជាផ្លូវដែលចេញពីទីប្រជុំជន ក្រុង(ក្នុងខេត្ត) ទៅទីប្រជុំជនមួយទៀត(ផ្លូវទៅតាមបណ្តាស្រុក) ហើយផ្លូវនេះកសាងសង់និងថែរក្សាដោយថវិកាខេត្ត ។
- ផ្លូវលំ : ផ្លូវតូចៗគ្មានក្រាលថ្ម ក្រាលគ្រួសក្រហម មាននៅតំបនជនបទ ។ ផ្លូវនេះកសាងដោយរដ្ឋអំណាចមូលដ្ឋាន សហការជាមួយអង្គការក្រៅរដ្ឋាភិបាល សប្បុរសជន និងប្រជាជនក្នុងតំបន់ ។
- ផ្លូវរុក្ខបាល : ផ្លូវដែលធ្វើនិងថែរក្សាដោយក្រសួងរុក្ខាប្រមាញ់ សម្រាប់ដឹកផលិតផលព្រៃឈើ សម្រួលដល់ការថែទាំព្រៃឈើ និងធ្វើចរាចរធម្មតាផងដែរ ។



រហូតមកដល់បច្ចុប្បន្ន ប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែង 39 618 km ក្នុងនោះរួមមាន

- ផ្លូវជាតិមួយលេខប្រវែង 2 119 km
- ផ្លូវជាតិពីរលេខប្រវែង 3 086 km
- ផ្លូវខេត្តប្រវែង 6 413 km
- ផ្លូវជនបទ(ផ្លូវលំ)ប្រវែង 28 000 km ។

ផ្លូវជាតិសំខាន់ៗមាន

- ផ្លូវជាតិលេខ 1 ពីភ្នំពេញទៅព្រំប្រទល់វៀតណាម កាត់តាមអ្នកលឿងនិងស្វាយរៀង មានប្រវែង 167 km ។
- ផ្លូវជាតិលេខ 2 ពីភ្នំពេញទៅភ្នំដិន(ព្រំប្រទល់វៀតណាម) កាត់តាមតាខ្មៅនិងតាកែវ មានប្រវែង 137 km ។
- ផ្លូវជាតិលេខ 3 ពីភ្នំពេញទៅក្រុងព្រះសីហនុ កាត់តាមកំពតនិងព្រៃនប់ មានប្រវែង 260 km ។
- ផ្លូវជាតិលេខ 4 ពីភ្នំពេញទៅក្រុងព្រះសីហនុ កាត់តាមកំពង់ស្ពឺ មានប្រវែង 226 km ។
- ផ្លូវជាតិលេខ 5 ពីភ្នំពេញទៅអូរជ្រៅ(ព្រំប្រទល់ថៃ) កាត់តាមកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ មានប្រវែង 408 km ។
- ផ្លូវជាតិលេខ 6 ពីភ្នំពេញទៅសិរីសោភ័ណ កាត់តាមកំពង់ធំនិងសៀមរាប មានប្រវែង 386 km (គិតពីព្រែកក្ដាមទៅសិរីសោភ័ណ) ។
- ផ្លូវជាតិលេខ 7 ពីស្គន់ទៅស្នួល កាត់តាមកំពង់ចាម មានប្រវែង 180 km ។
- ផ្លូវជាតិលេខ 8 ពីព្រែកតាមាក់(កណ្ដាល)ទៅអន្លង់ជ្រៃ (កំពង់ចាម)មានប្រវែង 109 km ។
- ផ្លូវជាតិលេខ 13 ពីស្នួលទៅព្រំដែនឡាវ កាត់តាមក្រចេះនិងស្ទឹងត្រែង មានប្រវែង 292 km ។
- ផ្លូវជាតិលេខ 15 ពីអ្នកលឿងទៅជប់ កាត់តាមព្រៃវែង មានប្រវែង 90 km ។
- ពីអូរពងមាន់(ស្ទឹងត្រែង)ទៅបរកែវ កាត់តាមឡាបានសៀក(រតនគិរី) មានប្រវែង 203 km ។
- ផ្លូវជាតិលេខ 21 ពីតាខ្មៅ(កណ្ដាល) ទៅជ្រៃធំ(ព្រំប្រទល់វៀតណាម)មានប្រវែង 67 km ។
- ផ្លូវជាតិលេខ 48 ពីស្រែអំបិលទៅកោះកុង មានប្រវែង 138 km ។
- ផ្លូវជាតិលេខ 57 ពីបាត់ដំបងទៅប៉ៃលិន មានប្រវែង 103.6 km ។
- ផ្លូវជាតិលេខ 62 ពីកំពង់ធំទៅត្បែងមានជ័យ មានប្រវែង 128 km និងពីត្បែងមានជ័យទៅប្រាសាទព្រះវិហារ មានប្រវែង 115 km ។
- ផ្លូវជាតិលេខ 68 ពីក្រឡាញ់(សៀមរាប) ទៅអូរស្មាច់(ឧត្ដរមានជ័យ)មានប្រវែង 117 km ។
- ផ្លូវជាតិលេខ 76 ពីស្នួល(ក្រចេះ) ទៅសែនមនោរម្យ(មណ្ឌលគិរី) មានប្រវែង 127 km ។
- ផ្លូវជាតិលេខ 78 ពីអូរពងមាន់(ស្ទឹងត្រែង) ទៅបានលុង(រតនគិរី) មានប្រវែង 121.1 km ។

**ចម្ងាយផ្លូវពីរាជធានីភ្នំពេញ ទៅខេត្ត-រមណីយដ្ឋាននានា**

| គោលដៅ | ចម្ងាយផ្លូវ ( km) | គោលដៅ | ចម្ងាយផ្លូវ ( km) |
|---|---|---|---|
| ភ្នំពេញ - កំពង់ឆ្នាំង | 95 | ភ្នំពេញ - រតនគិរី | 588 |
| ភ្នំពេញ - ពោធិ៍សាត់ | 189 | ភ្នំពេញ - មណ្ឌលគិរី | 521 |
| ភ្នំពេញ - បាត់ដំបង | 291 | ភ្នំពេញ - កណ្ដាល | 11 |
| ភ្នំពេញ - ប៉ៃលិន | 371 | ភ្នំពេញ - តាកែវ | 78 |
| ភ្នំពេញ - បន្ទាយមានជ័យ | 359 | ភ្នំពេញ - កែប | 174 |
| ភ្នំពេញ - ឧត្ដរមានជ័យ | 469 | ភ្នំពេញ - កំពត | 148 |
| ភ្នំពេញ - សៀមរាប | 314 | ភ្នំពេញ - កំពង់ស្ពឺ | 48 |
| ភ្នំពេញ - កំពង់ធំ | 168 | ភ្នំពេញ - ខេត្តព្រះសីហនុ | 226 |
| ភ្នំពេញ - ព្រះវិហារ | 294 | ភ្នំពេញ - កោះកុង | 271 |
| ភ្នំពេញ - កំពង់ចាម | 124 | ភ្នំពេញ - អង្គរវត្ត | 321 |
| ភ្នំពេញ - ក្រចេះ | 315 | ភ្នំពេញ - បូកគោ | 189 |
| ភ្នំពេញ - ស្ទឹងត្រែង | 455 | ភ្នំពេញ - គិរីរម្យ | 117 |
| ភ្នំពេញ - ស្វាយរៀង | 122 | ភ្នំពេញ - ព្រៃវែង | 90 |

ក្រោមពាក្យស្លោក "អភិវឌ្ឍស្ពាន-ផ្ដល់គឺកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន" ស្ពានមានប្រវែងវែងជាច្រើនត្រូវបានស្ថាបនាឡើង ដើម្បីជួយសម្រួលដល់ចរាចរគ្រប់ផ្នែកបានកាន់តែឆាប់រហ័ស ទាន់ពេល វេលា។ ស្ពានទាំងនោះមាន ស្ពានមិត្តភាពកម្ពុជា-ជប៉ុន "ជ្រោយចង្វា" នៅភ្នំពេញ (913 m) ស្ពានគីសូណា នៅខេត្តកំពង់ចាម(1430 m) ស្ពានកោះកុង(1900 m) ស្ពានសេកុង នៅខេត្តស្ទឹងត្រែង ស្ពានព្រះមុនីវង្សថ្មី ស្ពានព្រែកព្នៅ(1543 m) ស្ពានព្រែកក្ដាម(981 m) ស្ពានព្រែកតាមាក់... ។ល។ និងនៅមានគម្រោងសាងសង់ស្ពានអ្នកលឿង (ប្រភពជំនួយឥតសំណងរបស់ជប៉ុន) ស្ពានភ្នំពេញ-អរិយក្សត្រ និងស្ពានខ្លះទៀតដែលឆ្លងកាត់ទន្លេបាសាក់(តាខ្មៅ) និងស្ពានជ្រោយចង្វាថ្មី ។

## ក. ផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍

ដើម្បីកាត់បន្ថយចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍និងដើម្បីចូលរួមអនុវត្តតាមផែនការសុវត្ថិភាពចរាចរណ៍របស់អាស៊ាន គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកសហការជាមួយស្ថាប័នពាក់ព័ន្ធបាននិងកំពុងបន្តធ្វើការងារសកម្មភាពជាច្រើនដូចជា

- ធ្វើការអប់រំ ផ្សព្វផ្សាយដល់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសយុវវ័យ ឱ្យបានយល់ច្បាស់អំពីអត្ថប្រយោជន៍ក្នុងការគោរពច្បាប់ចរាចរណ៍ ។
- ខិតខំពង្រឹងច្បាប់ចរាចរណ៍ ឱ្យអ្នកជិះម៉ូតូពាក់មួកសុវត្ថិភាពទាំងយប់ ទាំងថ្ងៃឱ្យបានគ្រប់គ្នា ដោយសង្កត់ធ្ងន់លើយុវជន(ឆ្នាំ 2009 អនុវត្តបាន : ពាក់មួកសុវត្ថិភាពនៅពេលថ្ងៃ 80% និងពេលយប់ 40%) ។

ផែនការសកម្មភាពសុវត្ថិភាពចរាចរណ៍អាស៊ាន(ក្នុងយានយន្ត 10 000 គ្រឿង)

| ដល់ឆ្នាំ | ស្លាប់មិនឱ្យលើស |
|---|---|
| 2004 | 7 នាក់ |
| 2010 | 5 នាក់ |
| 2015 | 5 នាក់ |
| 2020 | 2 នាក់ |

- បន្តការរឹតបណ្តឹងការអនុវត្តច្បាប់ ចំពោះការបើកបរល្បឿនលើសច្បាប់កំណត់ បើកបរមានជាតិស្រវឹង ជិះរថយន្តមិនពាក់ខ្សែក្រវាត់សុវត្ថិភាព និងបទប្បញ្ញត្តិផ្សេងៗទៀត ។
- ពង្រឹងគុណភាពសាលាបង្រៀនបើកបរនិងការប្រឡងយកប័ណ្ណបើកបរយានយន្ត ។
- ធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឱ្យបានគ្រប់យានយន្ត 100% ។
- សវនកម្មសុវត្ថិភាពចរាចរណ៍នៅតំបន់ដែលកើតមានគ្រោះថ្នាក់ចរាចរណ៍ញឹកញាប់ ដោយធ្វើការកែលម្អផ្លូវ បំពាក់បន្ថែមស្លាកសញ្ញាចរាចរណ៍ ។ល ។
- កែលម្អមជ្ឈមណ្ឌលព្យាបាលនិងប្រព័ន្ធសេវាសង្គ្រោះបន្ទាន់នៅទូទាំងប្រទេសឱ្យមានប្រសិទ្ធភាព ។

## 1.2. ផ្លូវដែក

ប្រទេសកម្ពុជាមានផ្លូវដែកចំនួនពីរខ្សែ ខ្សែទីមួយចេញពីភ្នំពេញទៅអូរជ្រៅមានប្រវែង 385 km និងខ្សែទីពីរចេញពីភ្នំពេញទៅខេត្តព្រះសីហនុ មានប្រវែង 266 km ។ ចាប់ពីឆ្នាំ 1979 មកទល់បច្ចុប្បន្ន សកម្មភាពតាមផ្លូវដែកនៅមានកម្រិតនៅឡើយ ដោយសារការទ្រុឌទ្រោម ដោយសង្គ្រាម អស្ថិរភាពផ្នែកសន្តិសុខ នយោបាយ និងការរីកចម្រើនខ្ពស់ផ្នែកផ្លូវថ្នល់ ។ ដោយឡែកនៅឆ្នាំ 2009 ការដឹកជញ្ជូនអ្នកដំណើរត្រូវបានបញ្ឈប់ ដោយសារចំនួនអតិថិជនធ្លាក់ចុះ (ឆ្នាំ 2005 ដឹកជញ្ជូនអ្នកដំណើរបាន 47 779 នាក់ ឆ្នាំ 2006 បានត្រឹមតែ 14 003 នាក់ ឆ្នាំ 2007 ធ្លាក់ដល់ 10 628 នាក់ និងឆ្នាំ 2008 នៅសល់តែ 4 924 នាក់ប៉ុណ្ណោះ) ។ ការដឹកជញ្ជូនទំនិញក៏មានការធ្លាក់ចុះខ្លាំងដែរ គឺនៅឆ្នាំ 2009 ដឹកជញ្ជូនបានតែ 151 152 តោន ដែលកាលពីឆ្នាំ 2008 បាន 233 294 តោន និងឆ្នាំ 2007 បាន 315 367 តោន ។

ដើម្បីស្តារនិងអភិវឌ្ឍបណ្តាញផ្លូវដែក រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចផ្តល់សម្បទានដល់វិស័យឯកជនក្នុងការធ្វើអាជីវកម្មលើផ្លូវដែកដែលតភ្ជាប់ពីរាជធានីភ្នំពេញទៅបណ្តាខេត្តមួយចំនួន និងតភ្ជាប់ទៅបណ្តាញផ្លូវដែកនៃប្រទេសជិតខាង ដែលជាផ្នែកមួយនៃបណ្តាញផ្លូវដែកអាស៊ី ។ គណៈកម្មាធិការកំណែទម្រង់ការស្តារផ្លូវដែកឡើងវិញនិងគណៈកម្មការគ្រប់គ្រងការធ្វើសម្បទានផ្លូវដែកត្រូវបានបង្កើតឡើង ។ កិច្ចព្រមព្រៀងសម្បទានរយៈពេល 30ឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជានិងក្រុមហ៊ុនឯកជនរបស់អូស្ត្រាលី (Toll Cambodia Ltd) ត្រូវបានចុះហត្ថលេខានាថ្ងៃទី 12 ខែ មិថុនា ឆ្នាំ 2009 ។

គម្រោងស្តារផ្លូវដែកដែលមានទឹកប្រាក់សរុបចំនួន 73 លានដុល្លារអាមេរិក ត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នា ដោយធនាគារអភិវឌ្ឍន៍អាស៊ីនិងម៉ាឡេស៊ី រួមគ្នាជាមួយថវិកាបដិភាគរបស់រាជរដ្ឋាភិបាល កំពុងធ្វើដំណើរការអនុវត្ត ។ គម្រោងនេះនឹងធ្វើការស្តារផ្លូវដែកឡើងវិញ ក្នុងនោះរួមមាន

- កំណាត់ផ្លូវដែកដែលបាត់មិនទាន់មាន តភ្ជាប់ពីក្រុងសិរីសោភ័ណទៅក្រុងប៉ោយប៉ែត(តភ្ជាប់ផ្លូវដែកប្រទេសថៃ) ប្រវែង 48 km ។
- កំណាត់ផ្លូវដែកតភ្ជាប់ពីរាជធានីភ្នំពេញ ទៅក្រុងព្រះសីហនុ ប្រវែង 266 km ។
- និងកំណាត់ផ្លូវដែកតភ្ជាប់ពីរាជធានីភ្នំពេញ ទៅក្រុងសិរីសោភ័ណ ប្រវែង 338 km ។

គម្រោងមួយផ្នែកផ្សេងទៀត ដែលមានទឹកប្រាក់សរុបចំនួន 68.6 លានដុល្លារអាមេរិក ត្រូវបានផ្តល់ហិរញ្ញប្បទានរួមគ្នា ដោយឥណទានកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ីនិងជំនួយឥតសំណងពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី សម្រាប់ការសាងសង់ឃ្លាំងនិងស្ថានីយ៍រថភ្លើងថ្មីមួយនៅសំរោង ដែលមានចម្ងាយ 9 km ពីរាជធានីភ្នំពេញនិងសម្រាប់កែលម្អបន្ថែមនូវបណ្តាញផ្លូវដែកទៅកាន់ឃ្លាំងនានានិងខ្សែផ្លូវដែកផ្នែកខាងជើង ។

គម្រោងស្តារឡើងវិញនិងលើកកម្ពស់សមត្ថភាពល្បឿន 50 km ក្នុងមួយម៉ោងនៅលើផ្លូវដែកទាំងពីរទិសតាមផែនការនិងត្រូវបញ្ចប់នៅចុងឆ្នាំ 2013 ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងស្វែងរកការ វិនិយោគតាមរយៈដៃគូអភិវឌ្ឍន៍និងផ្នែកឯកជន ដើម្បីសាងសង់កំណាត់ផ្លូវដែកដែលមិនទាន់មាន មានប្រវែងសរុប 255 km ដើម្បីតភ្ជាប់ពីបាត់ដឹង(ខេត្តកំពង់ស្ពឺ) ទៅត្រពាំងស្រែ(ចំណុចតភ្ជាប់រវាងកម្ពុជាជាមួយព្រំប្រទល់វៀតណាម) ដែលជាផ្នែកមួយនៃគម្រោងផ្លូវដែកអាស៊ី សម្រាប់អាស៊ី-ប៉ាស៊ីហ្វិក និងផ្លូវដែកតំបន់សម្រាប់អាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ ។

## 2. ផ្លូវទឹក

នៅកម្ពុជាមានផ្លូវទឹកសរុបប្រវែងប្រមាណ 1750 km ដែលអាចធ្វើនាវាចរណ៍បាន ។ ប៉ុន្តែ នៅរដូវប្រាំងអាចធ្វើនាវាចរណ៍បានតែប្រវែង 850 km ប៉ុណ្ណោះ ។ ផ្លូវទឹកសំខាន់ៗមាន ទន្លេមេគង្គ (ពីក្រចេះ ដល់សមុទ្រ) ទន្លេសាប បឹងទន្លេសាប ទន្លេបាសាក់ និងដៃនានា ។ នៅរាជធានីភ្នំពេញមាន

កំពង់ផែស្វយ័តភ្នំពេញ ជាកំពង់ផែអន្តរជាតិដែលអាចឱ្យនាវាចូលចតបានសឹងគ្រប់រដូវ ។ ក្រសួងសាធារណការនិងដឹកជញ្ជូនបានបង្កើនគ្រឿងចក្រសម្រាប់លើកស្ទូចកុងតឺន័រដែលមានសមត្ថភាពលើកដាក់បាន 45 តោន ចំនួន 2 គ្រឿង និងឧបករណ៍សម្រាប់លើកដាក់សំបកកុងតឺន័រ 40 ហ្វីត (1 ហ្វីត= 30.48 cm) មួយគ្រឿង ។ ក្រៅពីកំពង់ផែភ្នំពេញ មានកំពង់ផែកំពង់ចាម ក្រចេះ កំពង់ឆ្នាំង សៀមរាប ... ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាកំពង់ផែថ្នាក់អន្តរជាតិ អាចទទួលឱ្យនាវាសមុទ្រធំៗចូលចតបានគ្រប់រដូវ ។ តាមរយៈយុទ្ធសាស្ត្រ "បើកចំហជើងសមុទ្រ" របស់រាជរដ្ឋាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុបានសាងសង់ចំណតផែកុងតឺន័របន្ថែមប្រវែង 400m មានជម្រៅទឹក 9m ដែលអាចទទួលបរិមាណនាវាបាន 135 គ្រឿងក្នុងមួយខែ ។ ចំណតផែកុងតឺន័រនេះ មានសមត្ថភាពអាចស្តុកកុងតឺន័រក្នុងចំនួនអតិបរមាបាន 7 900 ក្នុងមួយពេល ឬ 340 000 ក្នុងមួយឆ្នាំ ហើយមានសមត្ថភាពលើកដាក់ទំនិញជាមធ្យមបានប្រមាណ 25 កុងតឺន័រក្នុងមួយម៉ោង សម្រាប់ដងយោងមួយ ។

ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យលទ្ធផលអាជីវកម្មរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅឆ្នាំ 2009 មានការថយចុះ ។ បរិមាណនាវាសរុបចូលចតមាន 847 គ្រឿង ថយចុះ 11% ធៀបនឹងឆ្នាំ 2008 ដែលមានចំនួន 954 គ្រឿង ។ បរិមាណទំនិញឆ្លងកាត់មាន 1 874 095 តោន ថយចុះ 9% បើធៀបនឹងឆ្នាំ 2008 ដែលមាន 2 057 966 តោន និងកុងតឺន័រឆ្លងកាត់មាន 207 861 ថយចុះប្រមាណ 20% ធៀបនឹងឆ្នាំ 2008 ដែលមាន 258 775 តោន ។ ប៉ុន្តែជារួម ចាប់ពីឆ្នាំ 2006 ដល់ ឆ្នាំ 2008 លទ្ធផលអាជីវកម្មមានការរីកចម្រើនជាលំដាប់ ។

ក្រសួងសាធារណការនិងដឹកជញ្ជូនមានគម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសលើផ្ទៃដី របស់កំពង់ផែទំហំ 70 ហិចតា ក្នុងដំណាក់កាលទី 2 (2008-2012) និងមានគម្រោងអភិវឌ្ឍន៍ផែថ្មីបន្ថែមដែលមានឈ្មោះថា "ចំណតផែពហុចំណត" មានជម្រៅទឹក 13.50 ម៉ែត្រ សម្រាប់បម្រើសេវាកម្មរុករកប្រេងនៅតាមសមុទ្រនិងជាផែសម្រាប់ប្រភេទទំនិញមិនវេចខ្ចប់ សម្រាប់បូមគ្រាប់ធញ្ញជាតិ ។

ក្រៅពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ នៅមានកំពង់ផែរាមដែលប្រើប្រាស់សម្រាប់ជាមូលដ្ឋាននាវាចរណ៍កងទ័ពខេមរភូមិន្ទ ។ កំពង់ផែកោះកុង សម្រាប់ទូកយន្តនិងនាវាតូចៗចូលចត ។

## 3. ផ្លូវអាកាស

ការដឹកជញ្ជូនតាមផ្លូវអាកាស មានសកម្មភាពខ្លាំងក្លាជាលំដាប់ ។ អាកាសយានដ្ឋានសំខាន់ៗនៃព្រះរាជាណាចក្រកម្ពុជា មានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ(ពោធិ៍ចិនតុង) សៀមរាប និងខេត្តព្រះសីហនុ ។ ក្រៅពីនេះ នៅមានអាកាសយានដ្ឋាននៅតាមខេត្តនិងក្រុងជាច្រើនទៀត ដូចជាបាត់ដំបង រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង កោះកុង និងព្រះវិហារ ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានផ្លូវចុះប្រវែង 3 200m យន្តហោះធុនធ្ងន់ស្ទើរតែគ្រប់ប្រភេទអាចចុះចតបាន ។

អាកាសយានដ្ឋាននៅតាមបណ្តាខេត្តមួយចំនួន ត្រូវបានរៀបចំគម្រោងផែនការស្តារនិងជួសជុលឡើងវិញដូចជា អាកាសយានដ្ឋាននៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងព្រះវិហារ ។ នៅមានគម្រោងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិថ្មីៗបន្ថែមទៀតមានដូចជា អាកាសយានដ្ឋានថ្មីនៅខេត្តសៀមរាប អាកាសយានដ្ឋានចាស់នៅខេត្តកំពង់ឆ្នាំង និងអាកាសយានដ្ឋានស្ថិតនៅឃុំប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ។ ខេត្តកំពត កែប ពោធិ៍សាត់ កំពង់ធំ មណ្ឌលគិរី ប៉ៃលិន និងឧត្តរមានជ័យ (មាននៅស្រុកសំរោងនិងស្រុកបន្ទាយអំពិល) ក៏ត្រូវបានគម្រោងចុះធ្វើការស្រាវជ្រាវ ប៉ាន់តម្លៃ ដើម្បីធ្វើប្លង់គ្រប់គ្រងនិងរៀបចំការពារទីតាំងអាកាសយានដ្ឋាន កុំឱ្យមានការរំលោភយកដីផងដែរ ។

## ? សំណួរ

1. តើប្រទេសកម្ពុជា មានផ្លូវគមនាគមន៍ប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. តើផ្លូវគោកមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
3. តើប្រទេសកម្ពុជាមានផ្លូវថ្នល់សរុបប្រវែងប៉ុន្មាន ? ក្នុងនោះមានផ្លូវអ្វីខ្លះ ?
4. តើផ្លូវជាតិណាដែលវែងជាងគេ ? កាត់ខេត្តណាខ្លះ ?
5. ហេតុអ្វីបានជាគេចាត់ទុកគ្រោះថ្នាក់ចរាចរណ៍ ជាគ្រោះមហន្តរាយដ៏ធំបន្ទាប់ពីជំងឺអេដស៍ ?
6. តើបច្ចុប្បន្នចរាចរណ៍តាមផ្លូវដែកមានសកម្មភាពខ្លាំងក្លាហើយ ឬនៅ ? ព្រោះអ្វី ?
7. តើផ្នែកមួយណាដែលមានសកម្មភាពប្រសើរជាង រវាងសកម្មភាពនាវាចរណ៍តាមប្រព័ន្ធទន្លេមេគង្គ និងកំពង់ផែសមុទ្រ ? ព្រោះអ្វី ?
8. តើអាកាសយានដ្ឋានអន្តរជាតិសំខាន់ៗរបស់ប្រទេសកម្ពុជា ស្ថិតនៅឯណាខ្លះ ? តើគម្រោងសាងសង់អាកាសយានដ្ឋានអន្តរជាតិថ្មីៗ មាននៅក្នុងខេត្តណាខ្លះ ?

1 ហ្វូត (foot) = 30.48 cm ; 40 ហ្វីត (feet) = 30.48 x 40 = 12.192 m ។

# 4 ពាណិជ្ជកម្មកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់បានពីលក្ខណៈពាណិជ្ជកម្មនៅកម្ពុជានិងសារៈសំខាន់របស់វិស័យនេះចំពោះសេដ្ឋកិច្ចជាតិ ។ មានគំនិតឱ្យតម្លៃនិងការពារផលិតផលក្នុងស្រុក ។

ចាប់ពីឆ្នាំ 1979 មកទល់ឆ្នាំ 1993 សេដ្ឋកិច្ចកម្ពុជាស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋ ដោយរដ្ឋជាអ្នកក្តោបក្តាប់ផ្តាច់មុខលើរាល់សកម្មភាពពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។ ក្រោយពីបានអនុវត្តនយោបាយសេដ្ឋកិច្ចទីផ្សារសេរីនៅឆ្នាំ 1993 មក ក្រុមហ៊ុនឯកជននានាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រកបរបរអាហរ័ណនីហរ័ណ ។ នយោបាយបែបនេះ ធ្វើឱ្យវិស័យពាណិជ្ជកម្មមានសំទុះរីកចម្រើនជាបន្តបន្ទាប់ ។ ការអនុវត្តនយោបាយចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងចតុកោណទី 3 ស្តីពី " ការអភិវឌ្ឍវិស័យឯកជននិងការងារ " បាននិងកំពុងជួយជំរុញវិស័យពាណិជ្ជកម្មឱ្យក្លាយទៅជាប្រភពដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចជាតិ ដែលជាកត្តាសំខាន់មួយសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងសម្រាប់កាត់បន្ថយភាពក្រីក្រ ។ ជាក់ស្តែងការនាំចេញសម្លៀកបំពាក់មានការកើនឡើងក្នុងឆ្នាំ 2006 និង 2007 គឺជាង 2.6 ពាន់លានដុល្លារក្នុងឆ្នាំ 2006 និងជាង 2.9 ពាន់លានដុល្លារក្នុងឆ្នាំ 2007 ។ អង្ករ 1.5 លានតោនត្រូវបាននាំចេញក្នុងឆ្នាំ 2006 ដែលមានចំនួនពីរដងនៃកម្រិតឆ្នាំ 2005 ។ នៅឆ្នាំ 2009 កន្លងទៅនេះវិស័យពាណិជ្ជកម្មបានរួមចំណែកក្នុងថវិការដ្ឋបានចំនួន 129 949 196 696 រៀល លើផែនការដែលមាន 116 448 400 000 រៀល ស្មើនឹង 111.59% នៃផែនការចំណូលប្រចាំឆ្នាំ ។

ប្រទេសកម្ពុជាមានការប្រែប្រួលនិងការវិវត្តយ៉ាងលឿនក្នុងវិស័យនយោបាយក្នុងប្រទេស ពិសេសនយោបាយយោធា សន្តិសុខ នយោបាយក្រៅប្រទេស និងនយោបាយសមាហរណកម្មសេដ្ឋកិច្ចទាំងក្នុងតំបន់និងទាំងក្នុងពិភពលោក ។ ចាប់តាំងពីពេលដែលកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី 28-30 ខែ កញ្ញា ឆ្នាំ 2009 មក មុខមាត់កម្ពុជាកាន់តែត្រូវបានលើកតម្កើងលើឆាកអន្តរជាតិ គឺធ្វើឱ្យកម្ពុជាអាចបោះជំហានចូលទៅកាន់ទីផ្សារពិភពលោកយ៉ាងស្វាហាប់និងបង្កើនទំនាក់ទំនងទ្វេភាគី ពហុភាគីដ៏ខ្ជាប់ខ្ជួនជាមួយបណ្តាប្រទេសនានា ផ្តល់ឱកាសមាសសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគលើគ្រប់វិស័យនៅកម្ពុជា ។

# 1. ការនាំចេញ

ក្នុងឆ្នាំ 2009 មានក្រុមហ៊ុនឯកជនសរុបចំនួន 2045 ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនសញ្ជាតិខ្មែរចំនួន 1231 ក្រុមហ៊ុននិងសញ្ជាតិបរទេសចំនួន 814 ក្រុមហ៊ុន(ក្នុងនោះដែរមានក្រុមហ៊ុនវិនិយោគចំនួន 53 ក្រុមហ៊ុន) ដែលបានបោះទុនរកស៊ីនៅក្នុងប្រទេសកម្ពុជា ។

ក្រុមហ៊ុនដែលផ្តល់ផលិតផលសម្រាប់ការនាំចេញបានជារូបិយប័ណ្ណច្រើនជាងគេមាន ក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់និងក្រុមហ៊ុនស្បែកជើង ។ នៅឆ្នាំ 2009 មានរោងចក្រកាត់ដេរចំនួន 243 និងរោងចក្រស្បែកជើងចំនួន 26 ប្រើប្រាស់កម្លាំងការងារសរុបចំនួន 320 734 នាក់(កម្មការិនីចំនួន 293 664 នាក់) ដែលអាចស្រូបយកកម្លាំងពលកម្មក្នុងសង្គមមួយភាគធំនិងជាលទ្ធភាពដល់ការផ្គត់ផ្គង់សាច់ប្រាក់ជាមធ្យម 27 លានដុល្លារក្នុងមួយខែៗ និងជួយទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលករ ពលការិនី និងក្រុមគ្រួសាររបស់ពួកគេ ។

ទំនិញនាំចេញមានទឹកប្រាក់សរុបប្រមាណ 1 751 346 929 ដុល្លារអាមេរិក ថយចុះជាងឆ្នាំ 2008 ក្នុងទឹកប្រាក់ 487 297 170 ដុល្លារអាមេរិក ស្មើនឹង 21.77% ។ ដោយឡែកសម្លៀកបំពាក់និងវាយនភ័ណ្ឌមានទឹកប្រាក់ប្រមាណ 1 731 221 540 ដុល្លារអាមេរិក ថយចុះជាងឆ្នាំ 2008 អស់ទឹកប្រាក់ប្រមាណ 498 893 139 ដុល្លារអាមេរិក ស្មើនឹង 22.37% ។ ទីផ្សារសំខាន់ៗមាន ទ្វីបអាមេរិកទាំងមូល ទ្វីបអឺរ៉ុប អាហ្វ្រិក អាស៊ី អូសេអានី និងសាធារណរដ្ឋសង្គមនិយមវៀតណាម ។

## 1.1. ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក

បរិមាណទឹកប្រាក់សរុបនាំចេញក្នុងឆ្នាំ 2009 ប្រមាណ 1 518 748 890 ដុល្លារអាមេរិក ថយចុះពីឆ្នាំ 2008 អស់ 471 492 240 ដុល្លារអាមេរិក ស្មើនឹង 23.9% ។ ក្នុងនោះមានមុខទំនិញ

| មុខទំនិញ | ទឹកប្រាក់ (ដុល្លារអាមេរិក) | មុខទំនិញ | ទឹកប្រាក់ (ដុល្លារអាមេរិក) |
|---|---|---|---|
| សម្លៀកបំពាក់ | 1 489 008 769 | វាយនភ័ណ្ឌ | 18 538 693 |
| ស្បែកជើង | 6 932 255 | ទោចក្រយាន | 1 697 952 |
| ផលិតផលសិប្បកម្ម | 960 646 | ចំណីឆ្កែ | 792 206 |
| ប្រដាប់ក្មេងលេង | 588 457 | ផ្សេងៗ | 229 910 |

## 1.2. ការនាំចេញទៅកាន់ទីផ្សារកាណាដា

ទឹកប្រាក់សរុបនាំចេញក្នុងឆ្នាំ 2009 មានប្រមាណ 198 009 020 ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ 2008 ទឹកប្រាក់នាំចេញថយចុះប្រមាណ 4 907 745 ដុល្លារអាមេរិក ស្មើនឹង 2.42% ។

| មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) | មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|---|---|
| សម្លៀកបំពាក់ | 192 616 251 | ទោចក្រយាន | 1 683 470 |
| វាយនភ័ណ្ឌ | 2 440 763 | អង្ករ | 19 344 |
| ស្បែកជើង | 1 249 191 | | |

## 1.3. ការនាំចេញទៅកាន់ទីផ្សារផ្សេងៗនៃទ្វីបអាមេរិក(ក្រៅពីស.រ.អានិងកាណាដា)

ទឹកប្រាក់សរុបនាំចេញក្នុងឆ្នាំ 2009 មានប្រមាណ 34 589 017 ដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ 2008 ទឹកប្រាក់នាំចេញថយចុះប្រមាណ 10 897 184 ដុល្លារអាមេរិក ស្មើនឹង 23.96% ។

| មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) | មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|---|---|
| សម្លៀកបំពាក់ | 28 569 893 | ស្បែកជើង | 5 951 450 |
| វាយនភ័ណ្ឌ | 47 171 | ទោចក្រយាន | 20 468 |

## 1.4. ការនាំចេញទៅសហគមន៍អឺរ៉ុប

ការធ្វើអាជីវកម្មនាំចេញទំនិញទៅកាន់រដ្ឋជាសមាជិករបស់សហគមន៍អឺរ៉ុបទាំង 27 រដ្ឋមានទឹកប្រាក់សរុប 655 458 595 ដុល្លារអាមេរិក (ឆ្នាំ 2008 មានទឹកប្រាក់សរុប 797 256 677 ដុល្លារអាមេរិក គឺថយចុះ 17.78%) ។

| មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) | មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|---|---|
| សម្លៀកបំពាក់ | 567 814 397 | ផលិតផលសិប្បកម្ម | 680 776 |
| ស្បែកជើង | 63 829 602 | ផលិតផលផ្សេងៗ | 14 058 080 |
| អង្ករ | 9 075 738 | | |

## 1.5. ការនាំចេញទៅទ្វីបអាហ្វ្រិក

ទឹកប្រាក់សរុបនាំចេញក្នុងឆ្នាំ 2009 មានចំនួន 4 087 676 ដុល្លារអាមេរិក តិចជាង ឆ្នាំ 2008 ដែលមានទឹកប្រាក់ចំនួន 4 409 109 ដុល្លារអាមេរិក គឺថយចុះ 7.29% ។

| មុខទំនិញ | ទឹកប្រាក់(ដុល្លារអាមេរិក) |
|---|---|
| សម្លៀកបំពាក់ | 3 051 946 |
| ស្បែកជើង | 1 035 730 |

## 1.6. ការនាំចេញទៅទ្វីបអាស៊ីនិងអូសេអានី

ការនាំទំនិញចេញទៅទ្វីបអាស៊ី និងអូសេអានី មានទឹកប្រាក់សរុប 131 731 933 ដុល្លារអាមេរិក (ឆ្នាំ 2009) ។

## 1.7. ការនាំចេញទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម

យោងតាមកិច្ចសម្របសម្រួលដែលបានចុះហត្ថលេខានៅថ្ងៃទី 05 ខែ វិច្ឆិកា ឆ្នាំ 2007 រវាងក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មនៃសាធារណរដ្ឋសង្គមនិយមវៀតណាម កម្ពុជាទទួលបានភាពអនុគ្រោះពន្ធសូន្យភាគរយ(0%) លើទំនិញកសិផលចំនួន 25 មុខ ដែលទទួលការអនុញ្ញាតឱ្យធ្វើការនាំចេញទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម លើកលែងតែសន្លឹកថ្នាំជក់ និងស្រូវអង្ករចេញ ។ ក្នុងឆ្នាំ 2009 ការនាំចេញទំនិញ មានទឹកប្រាក់សរុបចំនួន 23 023 250 ដុល្លារអាមេរិក បើធៀបទៅនឹងឆ្នាំ 2008 មានទឹកប្រាក់សរុបចំនួន 14 450 159 គឺកើនឡើង 59.33% ។ មុខទំនិញសំខាន់ៗមាន សន្លឹកថ្នាំជក់និងគ្រាប់ស្វាយចន្ទី ។

# 2. ការនាំចូល

ក្នុងគោលបំណងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោកឱ្យសម្រេចបានជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងពាណិជ្ជកម្មបានរៀបចំយុទ្ធសាស្ត្រសំខាន់ៗគ្របដណ្តប់ទូទៅលើវិស័យពាណិជ្ជកម្មដោយបានធ្វើការថែរក្សានិងអភិវឌ្ឍទីផ្សារ ។ តាមរយៈការសម្របសម្រួលពាណិជ្ជកម្ម ការបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសអភិវឌ្ឍនានា និងការបើកផ្លូវឱ្យមានការចូលរួមពីផ្នែកឯកជននៅក្នុងសកម្មភាពពាណិជ្ជកម្ម ។

ដោយសារប្រទេសយើងនៅមិនទាន់មានការរីកចម្រើនខាងផ្នែកឧស្សាហកម្មនិងកសិ-ឧស្សាហកម្ម ដើម្បីបំពេញតម្រូវការចាំបាច់របស់ប្រជាជនកម្ពុជា ជាមួយនិងការរីកចម្រើនកើនឡើងផ្នែកជីវភាពរស់នៅនិងតម្រូវការប្រើប្រាស់ ការនាំចូលផលិតផលពីប្រទេសក្រៅនៅតែជាកត្តាសំខាន់នៅឡើយ ។ ទំនិញនាំចូលសំខាន់ៗ ដែលឆ្លងកាត់ការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានកាំកុងត្រូលនៅឆ្នាំ 2009មានថ្លៃដើមសរុបចំនួន 3 739 863 818 ដុល្លារអាមេរិក ។ ទំនិញទាំងនោះភាគច្រើននាំចូលពីប្រទេសថៃ វៀតណាម សិង្ហបុរី ចិន ឥណ្ឌា កូរ៉េ ហុងកុង ម៉ាឡេស៊ី ឥណ្ឌូណេស៊ី បារាំង សហរដ្ឋអាមេរិក អាល្លឺម៉ង់ តៃវ៉ាន់ ជប៉ុន អង់គ្លេស ... ។ ទំនិញទាំងនេះ មានម្ហូបអាហារ ភេសជ្ជៈ សារធាតុគីមី ប្រេងឥន្ធនៈ ឱសថនិងបរិក្ខារពេទ្យ គ្រឿងសំអាង វត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរ សម្ភារៈសំណង់ និងយាន ជំនិះគ្រប់ប្រភេទ ។

## 3. ជញ្ជីងពាណិជ្ជកម្ម

យើងមានមោទនភាពចំពោះណាស់ ចំពោះសមិទ្ធផលនៃការរីកចម្រើនខាងការនាំចេញនូវផលិតផល សិប្បកម្ម និងឧស្សាហកម្ម និងទំនិញជាច្រើនមុខថែមទៀត ទៅកាន់ទីផ្សារនៃប្រទេសពិភពលោក ។ ជាពិសេស ប្រទេសកម្ពុជាទទួលបាននូវភាពអនុគ្រោះពន្ធ (GSP) ជាបន្តបន្ទាប់ លើមុខទំនិញថ្មីបន្ថែមទៀតពីបណ្ដាប្រទេសអភិវឌ្ឍនិងការទទួលបានជាគោលការណ៍នូវការអនុគ្រោះពន្ធកម្រិតសូន្យលើមុខទំនិញចំនួន 177មុខថែមទៀត ជាពិសេសសិប្បកម្មសូត្រ អង្ករ ត្រី ទឹកឃ្មុំ ចម្លាក់ថ្ម និងឈើជាដើម ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ដែលធ្វើឱ្យទឹកប្រាក់ដែលបានមកពីការនាំចេញកើនឡើងជាបន្តបន្ទាប់ ។

ប៉ុន្តែ ដោយសារប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសកំពុងស្ដារនិងកសាងសេដ្ឋកិច្ចឡើងវិញលើគ្រប់វិស័យ ដូចនេះហើយបានជាជញ្ជីងពាណិជ្ជកម្មកម្ពុជានៅមានឱនភាពនៅឡើយ ព្រោះការនាំចូលនៅគ្របដណ្ដប់លើការនាំចេញ ដោយសារតែផលិតកម្មគ្រប់ផ្នែកនៃសេដ្ឋកិច្ច មិនទាន់បំពេញតម្រូវការគ្រប់គ្រាន់សម្រាប់ប្រជាជន ។ ម្យ៉ាងទៀត ផលិតផលមួយចំនួនពុំទាន់អាចផលិតបាននៅក្នុងប្រទេសនៅឡើយ ។

**តារាងប្រៀបធៀបការនាំចូលនិងការនាំចេញ ឆ្នាំ 2008 និង 2009 (គិតជាដុល្លារអាមេរិក)**

| | ឆ្នាំ 2008 | ឆ្នាំ 2009 | ប្រៀបធៀប | |
|---|---|---|---|---|
| | | | ប្រាក់លម្អៀង | គិតជាភាគរយ |
| ការនាំចូល | 4 421 753 656 | 3 739 863 818 | -681 889 838 | 15.42% |
| ការនាំចេញ | 3 356 219 813 | 2 790 747 980 | -565 471 833 | 16.84% |
| សរុប | 7 777 973 469 | 6 530 611 798 | -1 247 361 671 | 16.04% |

# 4. សេវាពន្ធ័ទសុវត្ថិភាព គុណភាពទំនិញ និងការការពារអ្នកប្រើប្រាស់

ការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលទំនិញ និងសេវា ជាចំណុចសំខាន់ក្នុងគោលដៅនៃការពង្រាយសេវាសាធារណៈនិងពង្រឹងគុណភាពសេវាបម្រើសំណូមពរដ៏ទទូចរបស់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ។

## 4.1. ការត្រួតពិនិត្យទំនិញនាំចូល

តាមរយៈការត្រួតពិនិត្យទំនិញនាំចូលឆ្នាំ 2009 របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ និហរ័ណ- អាហរ័ណនិងការបង្ក្រាបការក្លែងក្លាយបន្លំ(កាំកុងត្រូល) គេបានរកឃើញនូវទំនិញនាំចូលមួយចំនួនដែលពុំមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិបច្ចេកទេស ឬគោលការណ៍ច្បាប់និងទំនិញស្អុកយូរខូចគុណភាព ។ ទំនិញទាំងនោះមាន ស៊ុត មាន់ ទា គ្រួច សាច់មាន់ ឆ្អឹងមាន់ សាច់ជ្រូក ប្រហិតសាច់មាន់ កំទេចនំ កំទេចមី ស្ករគ្រាប់ គ្រាប់សណ្តែក ចាហួយ កំទេចមឹកគ្រៀម ដំណាប់ផ្លែឈើ ប្រេងសណ្តែក ខ្លាញ់ ត្រីខកំប៉ុង កាពី ទឹកដោះគោខាប់ ទឹកខ្មេះ ភេសជ្ជៈ ទឹកអាស៊ីត អំបិលគ្មានអ៊ីយ៉ូដ ។ល ។ នីតិវិធីដែលបានអនុវត្តយោលទៅតាមករណីនីមួយៗមាន ការបំផ្លាញចោល ឬរុញត្រឡប់ទៅប្រទេសដើមវិញ ហើយករណីខ្លះទៀត ត្រូវបានកសាងសំណុំបែបបទបញ្ជូនទៅតុលាការដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

## 4.2. ការត្រួតពិនិត្យទំនិញនាំចេញ

កម្លាំងសមត្ថកិច្ចអគ្គនាយកដ្ឋានកាំកុងត្រូលបានចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ឃាត់ខ្លួនជនសង្ស័យដែលប៉ុនប៉ងនាំយកម្សៅគ្រឿងញៀនប្រភេទហេរ៉ូអ៊ីនបានចំនួន ៥ករណី មានទម្ងន់សរុប 3 102.3g ដែលមានបំណងនាំចេញទៅបរទេសតាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ លទ្ធផលនេះ បង្ហាញពីភាពទទួលខុសត្រូវនិងសមត្ថភាពរបស់មន្ត្រីជំនាញ រួមទាំងកិច្ចសហការល្អពីស្ថាប័នអនុវត្តច្បាប់ក្នុងការរួមចំណែកការពារមុខមាត់របស់ជាតិយើងលើឆាកអន្តរជាតិ ។

## 4.3. ការត្រួតពិនិត្យទំនិញតាមទីផ្សារនិងសិប្បកម្ម

បញ្ហាគុណភាពនិងសុវត្ថិភាពផលិតផលទំនិញ កំពុងតែត្រូវបានប្រជាពលរដ្ឋទូទៅចាប់អារម្មណ៍ ហើយតម្រូវឱ្យសមត្ថកិច្ចជំនាញចុះធ្វើការត្រួតពិនិត្យទៅតាមបណ្តាទីផ្សារលក់ដុំ- រាយនៅតាមមូលដ្ឋាន រាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ ដើម្បីទប់ស្កាត់ភាពពុំសមស្របតាមបញ្ញត្តិលើផលិតផលនិងសកម្មភាពពាណិជ្ជកម្មផ្សេងៗ ។ ការត្រួតពិនិត្យបានតម្រង់ឆ្ពោះទៅលើគោលដៅសំខាន់ៗមួយចំនួនដូចជា

- ការត្រួតពិនិត្យលើគ្រោះថ្នាក់ផ្នែកគីមីដែលដាក់នៅក្នុងម្ហូបអាហារ ការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់នៅក្នុងផលិតផលកែច្នៃម្ហូបអាហារ ។ ផលិតផលដែលចាត់ទុកថាគ្មានគុណភាពនិងសុវត្ថិភាពសមស្របតាមបទបញ្ញត្តិត្រូវបានរឹបអូសយកទៅកម្ទេចចោល ដោយបង្គាប់ឱ្យម្ចាស់សិប្បកម្មធ្វើកិច្ចសន្យាបញ្ឈប់ការប្រើប្រាស់សារធាតុគីមីដែលហាមឃាត់ក្នុងផលិតផលរបស់ខ្លួនជាបន្តទៀត ។
- ការត្រួតពិនិត្យលើផ្នែកអនាម័យ ដោយធ្វើការវាយតម្លៃអំពីកម្រិតវត្តមាននៃពពួកមេរោគបង្កជំងឺ ដែលបណ្តាលមកពីការផលិតខ្វះអនាម័យ ឬជាការចម្លងពីបរិស្ថានជុំវិញ តាមការទុកដាក់នៅកន្លែងមិនស្អាត ។
- ការត្រួតពិនិត្យលើការក្លែងបន្លំ គឺជាការត្រួតពិនិត្យទៅលើស្លាកសញ្ញាមានដូចជា ឈ្មោះផលិតផល អាស័យដ្ឋានផលិត ប្រទេសផលិត អាស័យដ្ឋានអ្នកនាំចូល សារធាតុផ្សំ របៀបប្រើការប្រុងប្រយ័ត្ន បរិមាណ ទម្ងន់ ថ្ងៃខែឆ្នាំផលិត ថ្ងៃខែឆ្នាំផុតកំណត់ប្រើប្រាស់ ។ល ។ ជារួមស្លាកសញ្ញាត្រូវធានាឱ្យប្រាកដថា អ្នកប្រើប្រាស់អាចទទួលបាននូវព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់តាមតែគេចង់បានសម្រាប់ធ្វើការជ្រើសរើស ។
- ក្រៅពីនេះគេនៅបានធ្វើការត្រួតពិនិត្យទៅលើប្រភេទទំនិញដទៃទៀតដូចជា ប្រេងឥន្ធនៈនិងផលិតផលគីមីកសិកម្មជាដើម ។

## 5. សកម្មភាពជំរុញពាណិជ្ជកម្ម

ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មឱ្យមានសំទុះទៅមុខ រួមចំណែកអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិក្រសួងពាណិជ្ជកម្មបានខិតខំអនុវត្តនូវការងារមួយចំនួនដូចជា

- ការរៀបចំនិងចូលរួមពិព័រណ៍ក្នុងនិងក្រៅប្រទេស សំដៅលើកកម្ពស់កិត្យានុភាពជាតិដើម្បីធ្វើឱ្យសាធារណជនទទួលស្គាល់ផលិតផលប្រើប្រាស់ក្នុងស្រុក ជំរុញឱ្យមានការកែលម្អគុណភាពនិងម៉ូតផលិតផល រុញច្រានផលិតផលខ្មែរជ្រៀតចូលទៅក្នុងទីផ្សារបរទេស ទទួលបានការបញ្ជាទិញច្រើនមុខ ។
- ការតាមដានទីផ្សារនិងស្ថិរភាពតម្លៃ ដោយចុះណែនាំការបិតស្លាកតម្លៃលើមុខទំនិញនិងសេវាកម្ម គ្រប់ប្រភេទ និងតាមដានជាប្រចាំនូវតម្លៃទំនិញសំខាន់ៗ នៅលើទីផ្សារអន្តរជាតិដូចជាអង្ករ សណ្តែក កៅស៊ូ កាផេ ដែក ប្រេងឥន្ធនៈ មាស និងអត្រាប្តូរប្រាក់នៃរូបិយវត្ថុអន្តរជាតិមានតម្លៃនានាដូចជា ប្រាក់ដុល្លារ ប្រាក់ដោន ប្រាក់អឺរ៉ូ ប្រាក់យ៉េនជប៉ុន និងលុយបាតថៃ

ជាដើម ដើម្បីចងក្រងការវិវត្តនិងធ្វើការវិភាគតម្លៃទំនិញទាំងនេះ ជាគុណប្រយោជន៍ដល់អ្នកនាំចេញ ។ កម្ពុជាធ្វើការស្វែងយល់ ហើយតម្រង់ទិសអាជីវកម្មរបស់ស្មៀស្របទៅនឹងនិន្នាការក្នុងស្រុកនិងក្រៅស្រុក ។

- ការងារអភិវឌ្ឍផលិផលនិងស្វែងរកទីផ្សារជូនពាណិជ្ជករនិងកសិករ ដោយបានបង្កើតជាសមាគមផលិត សមាគមអាជីវកម្ម ហើយធ្វើការបណ្ដុះបណ្ដាលអំពីបច្ចេកវិទ្យាថ្មីៗសំដៅជំរុញការនាំចេញមុខទំនិញរបស់ពួកគេដោយផ្ទាល់ ឬតាមរយៈដៃគូពាណិជ្ជករនាំចេញធំៗនៅ ក្នុងប្រទេស ឧទាហរណ៍ដូចជា ការអភិវឌ្ឍផលិផលដំឡូងមីនិងគ្រាប់ស្វាយចន្ទីជាដើម ។
- ការងារអភិវឌ្ឍពាណិជ្ជកម្មនិងសកម្មភាពពង្រឹងដៃគូពាណិជ្ជកម្ម ដោយធ្វើការជ្រើសរើសផលិតផល វិភាគទីផ្សារនាំចូល និងតម្រូវការទីផ្សារពិភពលោក ។ ធ្វើការសិក្សាស្រាវជ្រាវជាមួយកសិករ អ្នកប្រមូលទិញ និងរោងចក្រកែច្នៃ ។ ក្រៅពីនេះ នៅបានរួមសហការជាមួយដៃគូពាណិជ្ជកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍ដើម្បីជំរុញពាណិជ្ជកម្មនិងអ្នកវិនិយោគពីបរទេសមកកម្ពុជាដើម្បីជំរុញការនាំចេញផលិផលនិងសេវាកម្មផ្សេងៗ ។

## ? សំណួរ

1. តើកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក នៅថ្ងៃ ខែ ឆ្នាំណា ? តើការបានចូលនេះ មានផលប្រយោជន៍យ៉ាងណាខ្លះ ?
2. តើក្រុមហ៊ុនណាខ្លះដែលផ្តល់ផលិតផលសម្រាប់ការនាំចេញបានច្រើនជាងគេ ?
3. ចូររៀបរាប់អំពីទីផ្សារសំខាន់ៗរបស់កម្ពុជា ។ តើទីផ្សារណាដែលមានបរិមាណទឹកប្រាក់ច្រើនជាងគេ ? ហេតុអ្វី ?
4. តើប្រភេទទំនិញសំខាន់ៗអ្វីខ្លះ នៅក្នុងការនាំចូលរបស់កម្ពុជា ?
5. ហេតុអ្វីបានជាការនាំចូល មានកម្រិតខ្ពស់ជាងការនាំចេញ ? តើត្រូវធ្វើដូចម្ដេច ដើម្បីកាត់បន្ថយកម្រិតនាំចូលឱ្យបានជាអតិបរមា ?
6. តើជញ្ជីងពាណិជ្ជកម្មនៅកម្ពុជា មានលក្ខណៈដូចម្ដេច ? ហេតុអ្វី ?
7. តើការត្រួតពិនិត្យទំនិញនៅតាមទីផ្សារ តម្រង់ឆ្ពោះទៅរកគោលដៅសំខាន់ៗអ្វីខ្លះ ?
8. តើការរៀបចំពិព័រណ៍ក្នុងនិងក្រៅប្រទេស មានសារប្រយោជន៍យ៉ាងណាខ្លះចំពោះវិស័យពាណិជ្ជកម្ម?
9. តើកិច្ចការសំខាន់ៗអ្វីខ្លះ ដែលត្រូវអនុវត្តដើម្បីជំរុញវិស័យពាណិជ្ជកម្មឱ្យមានសំទុះទៅមុខ ?

មេរៀនទី

# 5 ទេសចរណ៍កម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីតំបន់ទេសចរណ៍និងសារៈសំខាន់នៃវិស័យនេះនៅក្នុងខឿនសេដ្ឋកិច្ចជាតិ ។ មានគំនិតការពារ និងច្នៃប្រឌិត អភិវឌ្ឍរមណីយដ្ឋានបេតិកភណ្ឌពិភពលោក រមណីយដ្ឋានទេសចរណ៍ក្នុងប្រទេស ។

វិស័យទេសចរណ៍ គឺជាវិស័យមួយដែលមានលក្ខណៈជាប្រព័ន្ធនិងជាអាទិភាពមួយក្នុងចំណោមអាទិភាពសេដ្ឋកិច្ចសំខាន់ៗ ក្នុងការរួមចំណែកកសាងសេដ្ឋកិច្ចសង្គម ការបង្កើតឱកាសការងារ ការបង្កើនប្រាក់ចំណូល ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការកាត់បន្ថយភាពក្រីក្រ ។ ចំណូលដែលបានមកពីទេសចរណ៍ត្រូវបានបញ្ចូលភ្លាមៗទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ រួមចំណែកជំរុញកំណើនផលិតផលក្នុងស្រុកសរុបនិងធ្វើឱ្យមានលំនឹងផ្នែកជញ្ជីងពាណិជ្ជកម្ម ។ ហេតុនេះហើយបានជារដ្ឋាភិបាលប្រទេសនានានៅលើពិភពលោកខិតខំអភិវឌ្ឍវិស័យនេះយ៉ាងខ្លាំងក្លា ។ ក្នុងន័យនេះហើយបានជាគេហៅ វិស័យទេសចរណ៍ថា "ឧស្សាហកម្មគ្មានផ្សែង" ។

## 1. ទេសចរណ៍កម្ពុជា

ទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌និងធម្មជាតិ មានការរីកលូតលាស់ជាលំដាប់ ហើយបានប្រែក្លាយកម្ពុជាទៅជាគោលដៅទេសចរណ៍ដ៏សំខាន់មួយក្នុងតំបន់ ពិសេសភាពទាក់ទាញនៃប្រាសាទអង្គរ(ដាក់ជាបេតិកភណ្ឌពិភពលោកនៅឆ្នាំ 1992)ដែលជាបេតិកភណ្ឌរបស់មនុស្សជាតិនិងជាអច្ឆរិយៈពិភពលោក ។ ប្រាសាទព្រះវិហារដែលមានតម្លៃជាសកល (ដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោកនៅថ្ងៃទី 07 ខែកក្កដា ឆ្នាំ 2008) ប្រាង្គប្រាសាទដទៃទៀត ឆ្នេរសមុទ្រនិងធនធានធម្មជាតិដ៏សំបូរបែប សត្វផ្សោតទន្លេមេគង្គ និងតំបន់អេកូទេសចរណ៍នានា ។

យុទ្ធនាការឃោសនាផ្សព្វផ្សាយ "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" និងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" បាននិងកំពុងជ្រួតជ្រាបក្នុងគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ និងជួយជំរុញវិស័យទេសចរណ៍កម្ពុជាឱ្យមានសំទុះរីកចម្រើន ។ ក្នុងឆ្នាំ 2008 និង 2009 ទោះបីជាវិស័យទេសចរណ៍បាននិងកំពុងទទួលរងនូវឥទ្ធិពលវិបត្តិសេដ្ឋកិច្ចពិភពលោក វិបត្តិនយោបាយក្នុងប្រទេសជិតខាងនិងការគំរាមកំហែងពីការរីករាលដាលនៃជំងឺគ្រុនផ្តាសាយ $A(H_1N_1)$ ក៏ទេសចរណ៍កម្ពុជានៅតែស្ថិតក្នុងស្ថានភាពល្អគួរជាទីមោទនៈ ។

# 2. តួនាទីនៃវិស័យទេសចរណ៍នៅក្នុងសេដ្ឋកិច្ចជាតិ

## 2.1. ទេសចរអន្តរជាតិ

តាមរបាយការណ៍ឆ្នាំ 2008 កម្ពុជាទទួលបានទេសចរអន្តរជាតិចំនួន 2 125 465 នាក់ មកពីគ្រប់ទិសទីនៃពិភពលោក ដោយមានការកើនឡើង 5.5% បើប្រៀបធៀបទៅនឹងឆ្នាំ 2007 ។ នៅក្នុងនោះទេសចរមកតាមផ្លូវអាកាសមានចំនួនច្រើនជាងគេ គឺមានចំនួន 1 239 407 នាក់ ស្មើនឹង 58.31% បន្ទាប់មកតាមផ្លូវគោកចំនួន 690 138 នាក់ ស្មើនឹង 32.47% តាមផ្លូវទឹកចំនួន 71 889 នាក់ ស្មើនឹង 3.38% និងទេសចរវិលល្ងាចចំនួន 124 031 នាក់ ស្មើនឹង 5.84% ។

ទីផ្សារទេសចរណ៍សំខាន់ជាងគេ គឺទេសចរកូរ៉េ បន្ទាប់មកមានវៀតណាម ជប៉ុន អាមេរិក ចិន ថៃ អង់គ្លេស បារាំង អូស្ត្រាលី និងតៃវ៉ាន់។ ក្រៅពីនេះមានទេសចរមកពីម៉ាឡេស៊ី ឡាវ អាល្លឺម៉ង់ សិង្ហបុរី ហ្វីលីពីន កាណាដា ហូឡង់ ស៊ុយអែត អ៊ីតាលី និងអេស្ប៉ាញ ។

**ទីផ្សារទេសចរណ៍សំខាន់ៗទាំង 10 ឆ្នាំ 2008**

| ល.រ | មកពីប្រទេស | ចំនួនទេសចរ ( នាក់ ) | កើនឡើង ឬធ្លាក់ចុះ (ជាភាគរយ) |
|---|---|---|---|
| 1 | កូរ៉េ | 266 525 | ធ្លាក់ចុះ 19.2 |
| 2 | វៀតណាម | 209 516 | កើនឡើង 67 |
| 3 | ជប៉ុន | 163 806 | កើនឡើង 1.1 |
| 4 | អាមេរិក | 145 079 | កើនឡើង 5.5 |
| 5 | ចិន | 129 626 | កើនឡើង 9.5 |
| 6 | ថៃ | 109 020 | កើនឡើង 7.3 |
| 7 | អង់គ្លេស | 98 093 | កើនឡើង 8.8 |
| 8 | បារាំង | 97 517 | កើនឡើង 15.9 |
| 9 | អូស្ត្រាលី | 84 957 | កើនឡើង 18.6 |
| 10 | តៃវ៉ាន់ | 83 000 | ធ្លាក់ចុះ 29.8 |

ទេសចរអន្តរជាតិចូលមកប្រទេសកម្ពុជាតាមច្រកទ្វារអន្តរជាតិសំខាន់ៗចំនួន 3 (2008) ។

- តាមច្រកប្រទេសវៀតណាម(ទាំងផ្លូវគោក ទឹក និងអាកាស) មានចំនួន 709 074 នាក់ ស្មើនឹង 33.4% នៃចំនួនទេសចរសរុប កើនឡើង 27.6% ធៀបទៅនឹងឆ្នាំ 2007 ក្នុងនោះច្រកអន្តរជាតិបាវិតក៏ជាច្រកសំខាន់មួយ ដែលមានទេសចរ 221 668 នាក់ កើនឡើង 24.1% ។

- តាមច្រកប្រទេសថៃ(ទាំងផ្លូវគោក ទឹក និងអាកាស) មានចំនួន 736 430 នាក់ ស្មើនឹង 34.7% នៃចំនួនទេសចរសរុបកើនឡើង 5.5% ធៀបទៅនឹងឆ្នាំ 2007 ក្នុងនោះ ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតមានទេសចរ 268 795 នាក់ កើនឡើង 12.4% ។
- តាមច្រកប្រទេសឡាវមានទេសចរចំនួន 58 760 នាក់ ស្មើនឹង 2.8% នៃចំនួនទេសចរសរុប កើនឡើង 41.6% ។
- ក្រៅពីនេះភ្ញៀវទេសចរចូលមកប្រទេសកម្ពុជាតាមច្រកផ្សេងៗទៀតដូចជា ច្រកម៉ាឡេស៊ី សិង្ហបុរី ចិន ជប៉ុន កូរ៉េ តៃវ៉ាន់ ។ល ។

## 2.2. ទេសចរក្នុងស្រុក

បច្ចុប្បន្ន គេសង្កេតឃើញសកម្មភាពទេសចរក្នុងស្រុកមានការរីកចម្រើនគួរកត់សម្គាល់ ។ បាតុភូតនេះកើតឡើងដោយសារការរីកចម្រើនផ្នែកមធ្យោបាយដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ស្ពានថ្នល់ ការរីកចម្រើនខាងជីវភាពរស់នៅ ការរីកចម្រើនផ្នែកកម្សាន្តសប្បាយ និងកម្រិតលូតលាស់ខាងការយល់ដឹងរបស់ប្រជាជនអំពីសុខុមាលភាពក្នុងការរស់នៅ ។

នៅឆ្នាំ 2008 ទេសចរក្នុងស្រុកមានចំនួនរហូតដល់ 6.73 លាននាក់ បានធ្វើដំណើរកម្សាន្តទៅកាន់គោលដៅទេសចរណ៍នានា ដោយមានអត្រាកំណើន 15.5% ។ តំបន់ភ្នំពេញទទួលទេសចរបាន 1.79 លាននាក់ កើនឡើង 2.2% តំបន់សៀមរាបទទួលទេសចរបាន 1.19 លាននាក់ កើនឡើង 34% តំបន់ឆ្នេរទទួលទេសចរបាន 0.4 លាននាក់កើនឡើង 38% តំបន់អេកូទេសចរណ៍ភូមិភាគឦសាន ទទួលទេសចរបាន 0.27 លាននាក់ កើនឡើង 19.1% និងតំបន់ផ្សេងៗទៀតទទួលទេសចរបាន 2.62 លាននាក់ កើនឡើង 19.2% ។

## 2.3. ទេសចរកម្ពុជាទៅក្រៅប្រទេស

ទន្ទឹមនឹងចំណូលចិត្តធ្វើទេសចរណ៍ក្នុងស្រុក ប្រជាជនកម្ពុជាក៏បានធ្វើដំណើរទៅក្រៅប្រទេសក្នុងបំណងទស្សនាកម្សាន្តនិងពិនិត្យសុខភាព ដែលក្នុងឆ្នាំ 2008 មានទេសចរកម្ពុជាចេញទៅក្រៅប្រទេសចំនួន 785 896 នាក់ មានការធ្លាក់ចុះ 21% ។ ការធ្លាក់ចុះនៃទេសចរកម្ពុជាទៅក្រៅប្រទេសបណ្តាលមកពីឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច ការគិតគូរឡើងវិញអំពីចំណូលនិងការចំណាយ សន្សំសំចៃ និងភាពប្រសើរឡើងនៃស្ថានភាពទេសចរណ៍ក្នុងស្រុក ដែលមានកន្លែងច្រើនសម្រាប់ទស្សនាកម្សាន្តផងដែរ ។

## 2.4. តួនាទីនៃវិស័យទេសចរណ៍នៅក្នុងសេដ្ឋកិច្ចជាតិ

ក្នុងឆ្នាំ 2008 វិស័យទេសចរណ៍កម្ពុជាបាននាំមកនូវចំណូលប្រមាណ 1 595 លានដុល្លាអាមេរិករួមចំណែក 12.5% នៃផលិតផលក្នុងស្រុកសរុប ដែលកាលពីឆ្នាំ 1995 មានតែ 5.5% ប៉ុណ្ណោះ ។

ក្នុងដំណាក់កាលវិបត្តិសេដ្ឋកិច្ច ទោះបីមានការធ្លាក់ចុះនិងការកើនឡើងនៅតំបន់ទេសចរណ៍មួយចំនួនក្តី ក៏កម្លាំងពលកម្មនៅក្នុងឧស្សាហកម្មទេសចរណ៍នេះពុំទាន់ត្រូវបានកាត់បន្ថយច្រើនទេ ។ នៅតំបន់ភ្នំពេញនិងខេត្តព្រះសីហនុកម្លាំងពលកម្មនៅរក្សាបាន រីឯនៅខេត្តសៀមរាបទោះបីទេសចរមានការធ្លាក់ចុះខ្លះ តែកម្លាំងពលកម្មនៅរក្សាបានច្រើន ។ សណ្ឋាគារមួយចំនួនបានកាត់បន្ថយបុគ្គលិកប្រមាណ 30-50% និងសណ្ឋាគារខ្លះទៀត គ្រាន់តែបានកាត់បន្ថយប្រាក់ខែចំនួន 30-50% តាមរបៀបកាត់បន្ថយម៉ោងធ្វើការនិងប្តូរវេនគ្នា ។ ក្នុងដំណាក់កាលនៃវិបត្តិសេដ្ឋកិច្ចជាសកល ការហូរចូលនៃទេសចរប្រទេសជិតខាងតាមផ្លូវគោកបានដើរតួនាទីយ៉ាងសំខាន់ ជាក់ស្តែងទេសចរមកពីប្រទេស វៀតណាមកើនឡើងក្នុងលំដាប់ទីមួយ ។ ការសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនឆ្លងកាត់ព្រំដែនកាន់តែមានភាពប្រសើរឡើង តាមរយៈការលើកលែងទិដ្ឋាការ ។ នៅក្នុងក្របខ័ណ្ឌអាស៊ាន 10 ប្រទេស រាជរដ្ឋាភិបាលបានព្រមព្រៀងក្នុងការលើកលែងទិដ្ឋាការចំពោះអ្នកដំណើរនៃប្រទេសចំនួន 5 គឺ សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ និងវៀតណាម ។ ទន្ទឹមនឹងនេះ ក៏នៅមានការជំរុញឃោសនា ផ្សព្វផ្សាយ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើឱ្យកាន់តែប្រសើរឡើងផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ ធ្នាប់សង្គម ។ ក្រៅពីសារប្រយោជន៍សេដ្ឋកិច្ច វិស័យទេសចរណ៍បានធ្វើឱ្យសាធារណជនស្គាល់តម្លៃនានាភាពនៃវប្បធម៌ របៀបរបបរស់នៅ បរិស្ថានធម្មជាតិ និងផ្តល់ដល់យុវជននូវការប្តូរអន្តរវប្បធម៌ដ៏មានប្រយោជន៍ ។

## 2.5. វិស័យទេសចរណ៍បង្កើតការងារ

នៅឆ្នាំ 2008 វិស័យទេសចរណ៍បានផ្តល់ការងារដល់ប្រជាជនកម្ពុជាប្រមាណ 30 ម៉ឺននាក់ក្នុងនោះកម្លាំងពលកម្មជានារីមានប្រមាណ 55% ។

ការងារទាំងនោះមាននៅក្នុងហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យវិស័យទេសចរណ៍រួមមាន

- សណ្ឋាគារដែលមាននៅគ្រប់ខេត្តក្រុងទាំងអស់ ពិសេសនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ។ នៅឆ្នាំ 2008 សណ្ឋាគារទូទាំងប្រទេសមានបន្ទប់ចំនួន 40 200 ដោយឡែកខេត្តសៀមរាបមាន 11 960 បន្ទប់ និងនៅមានផ្ទះសំណាក់ជាច្រើនទៀតសម្រាប់បម្រើភ្ញៀវទេសចរ ។ សណ្ឋាគារនិងផ្ទះសំណាក់ប្រមាណ 95% មានអាជ្ញាបណ្ណអាជីវកម្ម ។
- ការរៀបចំផ្ទះសំបែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានសម្រាប់ឱ្យទេសចរស្នាក់នៅ (Home Stay) គួបផ្សំជាមួយនិងការផ្គត់ផ្គង់សេវាម្ហូបអាហារ សេវាដឹកជញ្ជូនតាមមធ្យោបាយសាមញ្ញ(ដូចជារទេះគោ រទេះសេះ ជិះ កង់ ...) បានក្លាយទៅជាផ្នែកសំខាន់មួយនៃវិស័យទេសចរណ៍ ធ្វើឱ្យប្រជាពលរដ្ឋអាចរកប្រាក់ចំណូលបានដោយងាយស្រួល ។

- ភោជនីយដ្ឋាន មានការកើនឡើងនិងធានាបាននូវអនាម័យស្អាត មានសណ្តាប់ធ្នាប់ល្អ និងមានសេវាកម្មទេសចរណ៍ប្រកបដោយគុណភាព ។ ភោជនីយដ្ឋានទេសចរណ៍ប្រមាណ 85%មានអាជ្ញាប័ណ្ណអាជីវកម្ម ប៉ុន្តែមិនទាន់បានបង្កើតជាសមាគមភោជនីយដ្ឋាននៅឡើយ ។
- ទីភ្នាក់ងារទេសចរណ៍ដែលមានអាជ្ញាប័ណ្ណអាជីវកម្មមាន 96.5% ដែលភាគច្រើនមានទីតាំងនៅរាជធានីភ្នំពេញនិងខេត្តសៀមរាប ។
- មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានទទួលការបណ្តុះបណ្តាល រៀបចំដោយក្រសួងទេសចរណ៍និងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការជាតិ-អន្តរជាតិនានា ។ នៅឆ្នាំ 2008 និងឆមាសទី 1 ឆ្នាំ 2009 បានបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរតាមខេត្តនានាបានចំនួន 1 362 នាក់ ។ ដើម្បីជំរុញផ្នែកនេះឱ្យបានខ្លាំងក្លា ដោយមានកិច្ចសហការជាមួយស្ថានទូតនានា ក្រសួងទេសចរណ៍បានរៀបចំប្រឡងជ្រើសរើសមគ្គុទ្ទេសក៍ទេសចរណ៍ឆ្នើមប្រចាំឆ្នាំដែលចេះនិយាយភាសា ជប៉ុន កូរ៉េ និងចិន និងរៀបចំផែនការពង្រីកការជ្រើសរើសមគ្គុទេសក៏ទេសចរណ៍ឆ្នើមនិយាយភាសាផ្សេងៗទៀត ។ មកដល់បច្ចុប្បន្ននេះ មានមហាវិទ្យាល័យទេសចរណ៍ឯកជនចំនួន 25 និងមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ចំនួន 5 ។
- តារយៈយន្តការនិងចលនា "ភូមិមួយ ផលិតផលមួយ" បានធ្វើឱ្យចលនាផលិតនូវផលិតផលកសិកម្មមានសកម្មភាពផុលផុស ។ ផលិតផលដាំដុះ បន្លែបង្ការ ផ្លែឈើដែលមិនប្រើជីគីមីសាច់ និងស៊ុតសម្រាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មទេសចរណ៍មានដូចជា ប៉េងប៉ោះ ត្រសក់ក្រូចថ្លុង ត្រសក់ស្រូវ ស្រកានាគ សារ៉ាវ មង្ឃុត ទុរេន ស្វាយ ផ្កាអ័រគីដេ ស៊ុតមាន់ ការផលិតស្រាសំប៉ាញ ទឹកត្នោត ។ល ។ បានចាប់ផ្តើមជំនួសឱ្យការនាំចូលមួយចំនួនធំ ។ សណ្ឋាគារភោជនីយដ្ឋានភាគច្រើនប្រើប្រាស់ផលិតផលក្នុងស្រុក ។ ផលិតផលសិប្បកម្មជាច្រើនបានឈានដល់ការវេចខ្ចប់យ៉ាងល្អ ក្នុងនោះក៏មានវត្ថុអនុស្សាវរីយ៍ដែលផលិតចេញពីវត្ថុធាតុដើម ជាផលិតផលធម្មជាតិក្នុងស្រុក ។ ទាំងនេះ អាចធ្វើឱ្យប្រជាជនមានការងារធ្វើនិងទទួលផលចំណេញដោយប្រយោលពីវិស័យទេសចរណ៍ ។

## 2.៦. បំណែងចែកមិនស្មើគ្នានៃប្រយោជន៍ដែលបានមកពីវិស័យទេសចរណ៍

សព្វថ្ងៃ ផលប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីវិស័យទេសចរណ៍ ភាគច្រើនប្រមូលផ្តុំនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តកែប ។ គេសង្កេតឃើញមានការកើនឡើងគួរឱ្យកត់សម្គាល់នូវទេសចរដែលចូលចិត្តទៅកម្សាន្តតំបន់អេកូទេសចរណ៍ភូមិភាគឦសាន ( ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី) ។

**តំបន់ទទួលទេសចរសំខាន់ៗ (ឆមាសទី 1 ឆ្នាំ 2009)**

| តំបន់ទេសចរណ៍ | ទេសចរបរទេស | ទេសចរក្នុងស្រុក |
|---|---|---|
| តំបន់សៀមរាប | 503 028 នាក់ | 0.69 លាននាក់ |
| ភ្នំពេញ | 463 250 នាក់ | 0.9 លាននាក់ |
| តំបន់ឆ្នេរ | 94 685 នាក់ | 0.26 លាននាក់ |
| តំបន់ភូមិភាគឦសាន | 25 323 នាក់ | 0.22 លាននាក់ |
| តំបន់ផ្សេងៗ | 119 460 នាក់ | 1.57 លាននាក់ |

## 3. គោលទ្រព្យទេសចរណ៍នៅកម្ពុជា




*ផែនទីទេសចរណ៍ព្រះរាជាណាចក្រកម្ពុជា*

## ៣.១. ភោគទ្រព្យទេសចរណ៍ធម្មជាតិនៅកម្ពុជា

ដើម្បីការពារសត្វព្រៃនិងរុក្ខជាតិនានា ការពារទេសភាព រក្សាកន្លែងសម្រាប់ទេសចរណ៍ រាជរដ្ឋាភិបាលបានបង្កើតតំបន់ការពារធម្មជាតិជាច្រើនកន្លែង ។ នៅកម្ពុជាមានឧទ្យានជាតិចំនួន 7កន្លែងគឺ ខ្លង់រាប គិរីរម្យ ភ្នំបូកគោ កែប រាម បុទុមសាគរ ភ្នំគូលែន និងវីរជ័យ ។ លើសពីនេះទៀត មានដែនជម្រកសត្វព្រៃចំនួន 10កន្លែងនិងតំបន់ការពារធម្មជាតិផ្សេងៗចំនួន 6កន្លែងទៀត ។ តំបន់អេកូទេចរណ៍ភូមិភាគឦសាន្ត ត្រូវបានជំរុញការអភិវឌ្ឍដូចជា តំបន់សត្វផ្សោតទន្លេមេគង្គ តំបន់ទឹកជ្រោះសុភក្ត័មិត្តនៅខេត្តស្ទឹងត្រែង ។ តំបន់ទេសចរណ៍គេទឹកពុះនៅខេត្តកំពង់ស្ពឺ ក៏ត្រូវបានបង្កើតឡើងតាមរយៈគម្រោងវិនិយោគ ព្រោះជាតំបន់ទាក់ទាញទេសចរជប៉ុនយ៉ាងធំ ។ តំបន់ទន្លេសាបក៏ត្រូវបានអភិរក្សដោយរក្សានូវបរិស្ថានធម្មជាតិសម្រាប់ដំណើរកម្សាន្តភ្ញៀវទេសចរណ៍តាមផ្លូវទឹក ។

## ៣.២. ភោគទ្រព្យទេសចរណ៍ប្រវត្តិសាស្ត្រនិងវប្បធម៌

មណ្ឌលអង្គរ មានប្រាសាទអង្គរវត្ត អង្គរធំ និងប្រាសាទដទៃទៀត ជាតំបន់ទាក់ទាញទេសចរយ៉ាងសំខាន់ជាងគេនៅកម្ពុជា ។ ប្រាសាទទាំងនេះកំពុងទទួលការថែរក្សាជួសជុលក្រោមកិច្ចសហការជាមួយអាជ្ញាធរខេត្ត អាជ្ញាធរអប្សរា និងអង្គការយូណេស្កូ ។ ប្រាសាទនិងកន្លែងដទៃទៀត ក៏ត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលទាក់ទាញទេសចរផងដែរដូចជា វត្តភ្នំ សារមន្ទីរ ប្រាសាទព្រះវិហារ អង្គរបុរី ភ្នំជីសូរ ប្រាសាទនៅទន្លេបាទី ភ្នំបាសិត... ។ រមណីយដ្ឋានទេសចរណ៍មួយចំនួនបាន និងកំពុងអភិវឌ្ឍ ដូចជាប្រាសាទសំបូរព្រៃគុហ៍ តំបន់ហ្លួងព្រះស្ដេចកន ស្ពានបុរាណកំពង់ក្ដីប្រាសាទកោះកេរ្តិ៍ បឹងមាលា និងការអនុវត្តផែនការតភ្ជាប់ផ្លូវពីប្រាសាទព្រះវិហារទៅប្រាសាទវត្តភូ ប្រទេសឡាវ ។

សារមន្ទីរជាតិ គុកទួលស្លែង និងជើងឯក តំបន់អន្លង់វែង ជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនិងវប្បធម៌នៃប្រទេសកម្ពុជា ។ វត្តព្រះពុទ្ធសាសនា ក៏អាចទាក់ទាញភ្ញៀវទេសចរផងដែរ ហេតុនេះហើយបានជាគេបានរៀបចំវត្តព្រះពុទ្ធសាសនាចំនួនពីរនៅខេត្តសៀមរាប និងមួយនៅរាជធានីភ្នំពេញសាកល្បងធ្វើជាវត្តគំរូដើម្បីទទួលភ្ញៀវទេសចរ ។ មរតកក្បាច់ចម្លាក់នៅភ្នំពេញនិងនៅតាមខេត្តដទៃទៀតក៏ជាចំណុចល្អសម្រាប់ទាក់ទាញទេសចរផងដែរ ប្រសិនបើមានការថែរក្សាឱ្យបានត្រឹមត្រូវ នោះនឹងក្លាយទៅជាកន្លែងទេសចរណ៍មួយយ៉ាងពិតប្រាកដទៅថ្ងៃអនាគត ។

## ៣.៣. ផលិតផលទេសចរណ៍ថ្មី

បន្ថែមលើការបង្កើតមជ្ឈមណ្ឌលទេសចរណ៍ថ្មីៗនៅតំបន់ឆ្នេរនិងកោះនិងតំបន់អេកូទេសចរណ៍នៅភូមិភាគឦសាននិងនិរតី ក្រសួងទេសចរណ៍បានរៀបចំព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ដើម្បីឱ្យក្លាយជាព្រឹត្តិការណ៍ទេសចរណ៍វប្បធម៌ ឬកីឡាទេសចរណ៍ដ៏សំខាន់ ដើម្បីផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរឱ្យបានច្រើន ដែលជាអាទិ៍ព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ ពិធីបុណ្យច្រត់ព្រះនង្គ័ល ការរត់ប្រណាំងអន្តរជាតិពាក់កណ្ដាលម៉ារ៉ាតុង ការប្រកួតកីឡាវាយកូនគោល ។ល ។

ការងារអាស៊ានបូក 3(ចិន ជប៉ុន និងសាធារណរដ្ឋកូរ៉េ)និងអាស៊ានបូក 1(ឥណ្ឌា) ក៏បានផ្ដោតសំខាន់ទៅលើទីផ្សារទេសចរណ៍នៃកម្ពុជាផងដែរដូចជា ការហោះហើរត្រង់អាស៊ាន-កម្ពុជា ជាដើម ។

## 4. ទេសចរណ៍និងសង្គម

ចំនួនភ្ញៀវទេសចរអាចមានភាពវិជ្ជមាន ដរាបណាមរតកប្រវត្តិសាស្ត្រ វប្បធម៌ និងទេសភាពធម្មជាតិ មានកិច្ចការពារបានត្រឹមត្រូវ ព្រមទាំងធានាសន្តិសុខគ្រប់បែបយ៉ាងក្នុងការធ្វើដំណើរកម្សាន្ត។ សណ្តាប់ធ្នាប់ អនាម័យ និងសេវាល្អ ក៏ជាកត្តាសំខាន់រួមចំណែកទាក់ទាញភ្ញៀវទេសចរផងដែរ។ ហេតុនេះ ហើយបានជាបង្កើតឡើងនូវការផ្សព្វផ្សាយ "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" និងចលនាប្រឡង ប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ" តាមគ្រប់រូបភាពនិងគ្រប់មធ្យោបាយទៅកាន់ទីផ្សារអន្តរជាតិសំខាន់ៗក្នុងតំបន់អំពីគោលដៅទេសចរណ៍ថ្មីៗនៅតាមតំបន់អាទិភាពទាំងបួន។ ជាទូទៅ កំណើននៃប្រាក់ចំណូលដែលបានមកពីវិស័យទេសចរណ៍ អាចយកទៅប្រើប្រាស់សម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកដូចជា មន្ទីរពេទ្យ សាលារៀន ផ្លូវថ្នល់...។ ទន្ទឹមនឹងការនាំមកនូវផលប្រយោជន៍វិជ្ជមាន ទេសចរណ៍ក៏ផ្តល់ផលប៉ះពាល់ជាអវិជ្ជមានមួយចំនួនដូចជា ឧក្រិដ្ឋកម្មឆ្លងដែន ពេស្យាចារ ការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ការជួញដូរគ្រឿងញៀន...។ ដើម្បីទប់ស្កាត់ផលប៉ះពាល់ទាំងនេះ ក្រសួងទេសចរណ៍បានសហការជិតស្និទ្ធជាមួយ ក្រសួងពាក់ព័ន្ធ ពិសេសក្រសួងមហាផ្ទៃ អង្គការអន្តរជាតិ និងផ្នែកឯកជន ធ្វើការបណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយជូនដល់ក្រុមគោលដៅរួមមានមន្ត្រីមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី-ខេត្ត ក្រុង-ខណ្ឌ-ស្រុក សាលាឃុំ-សង្កាត់ និងអង្គការពាក់ព័ន្ធ សិស្ស និស្សិត ព្រមទាំងនិយោជក និយោជិកជាដើមឱ្យមានការយល់ដឹងអំពីផលអវិជ្ជមានក្នុងវិស័យទេសចរណ៍។

### សំណួរ

1. ហេតុអ្វីបានជាគេថាវិស័យទេសចរណ៍ ជាឧស្សាហកម្មគ្មានផ្សែង ?
2. ចូររាប់ទីផ្សារទេសចរណ៍ទាំង 10 ប្រទេសរបស់កម្ពុជា។ តើទេសចរប្រទេសណាដែលមកកម្ពុជាមានកំណើនខ្ពស់ជាងគេ ? ហេតុអ្វី ?
3. តើការងារអ្វីខ្លះ ដែលប្រជាជនកម្ពុជាទទួលបានពីវិស័យទេសចរណ៍ ?
4. តើផលិតកម្មក្នុងវិស័យកសិកម្ម អាចបម្រើឱ្យផលប្រយោជន៍វិស័យទេសចរណ៍ដែរ ឬទេ ? ហេតុអ្វី ?
5. តើភោគទ្រព្យទេសចរណ៍នៅកម្ពុជាមានអ្វីខ្លះ ? ចូររៀបរាប់។
6. ចូររៀបរាប់អំពីផលិតផលទេសចរណ៍ថ្មី។
7. ហេតុអ្វីបានជាប្រជាជនកម្ពុជានិយមធ្វើទេសចរណ៍ក្នុងស្រុក ?
8. តើអ្វីខ្លះជាផលអវិជ្ជមាន ដែលបណ្តាលមកពីវិស័យទេសចរណ៍ ?

មេរៀនទី

# 6 បញ្ហាមីននៅកម្ពុជា

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់បានពីប្រភេទមីនដែលមាននៅក្នុងប្រទេសកម្ពុជានិងមាន មធ្យោបាយការពារខ្លួនពីគ្រោះថ្នាក់ដោយសារមីន
- ❑ បង្ហាញបានច្បាស់លាស់ពីឥទ្ធិពលនៃមីន ចំពោះសេដ្ឋកិច្ចជាតិនិងមានគំនិតស្អប់ខ្ពើមសកម្មភាពផ្សេងៗដែលបណ្ដាលឱ្យមានមីន ។

ព្រះរាជាណាចក្រកម្ពុជា មានធនធានធម្មជាតិសំបូរបែបដូចជា ដីធ្វើស្រែចំការ ព្រៃឈើ ត្រី សត្វព្រៃ រ៉ែមាស រ៉ែត្បូង ដែលសុទ្ធសឹងតែជាវត្ថុដែលមានតម្លៃ ។ ជាងនេះទៅទៀត កម្ពុជាសំបូរទៅដោយវត្ថុបុរាណ ប្រាង្គប្រាសាទប្រកបដោយក្បូរក្បាច់រចនាដ៏អស្ចារ្យ ដែលជាកេរតំណែលវប្បធម៌ដ៏រុងរឿងរបស់ខ្មែរកសាងឡើងក្នុងសម័យមហានគរ ។ ប៉ុន្តែចាប់តាំងពីទសវត្សរ៍ឆ្នាំទី 70 រហូតមកដល់ចុងទសវត្សរ៍ឆ្នាំទី 90 នៃសតវត្សទី 20 ដែនដីសុវណ្ណភូមិរបស់យើងបានទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយបន្សល់ទុកនូវវិនាសកម្មរហូតមកដល់បច្ចុប្បន្ន ដោយដីស្រែ ដីចំការ ដីព្រៃ ភូមិដ្ឋាន ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ទីវត្តអារាម និងប្រាង្គប្រាសាទមួយចំនួនបានក្លាយជាតំបន់ ដែលមានគ្រាប់មីនឬជាចំការមីន ។

## 1. គោលបំណងនៃការប្រើប្រាស់មីន

មីនជាគ្រឿងផ្ទុះម្យ៉ាងដែលគេច្រើនយកទៅប្រើក្នុងពេលសង្គ្រាមដើម្បីកម្ទេចវត្ថុផ្សេងៗ ដូចជាយានយន្តតូចធំ ស្ពាន សំណង់ផ្សេងៗ និងសម្លាប់ជីវិតមនុស្ស សត្វ ។ មីនត្រូវបានគេដាក់នៅលើដីនិងក្នុងដី ហើយអាចផ្ទុះបាននៅពេលណាដែលមានអ្វីទៅប៉ះពាល់វា ។ មីនគ្រប់ប្រភេទត្រូវបានគេយកមកប្រើប្រាស់ក្នុងសង្គ្រាមនៅកម្ពុជា ។ សង្គ្រាមមិនត្រឹមតែបន្សល់ទុកនូវគ្រាប់មីនប៉ុណ្ណោះទេ ថែមទាំងមានគ្រឿងផ្ទុះដែលមិនទាន់ផ្ទុះជាច្រើនទៀតដូចជា គ្រាប់រ៉ុកកែត គ្រាប់បែកដៃ និងគ្រាប់កាំភ្លើងតូចធំ ។ ឧបករណ៍ទាំងនេះចោទជាបញ្ហាធំមួយ ចំពោះជីវិតប្រជាជនកម្ពុជានិងសត្វពាហនៈផងដែរ ។

ក្នុងពេលធ្វើសង្គ្រាម គូវិវាទទាំងសងខាងប្រើគ្រប់វិធីសាស្ត្រ និងល្បិចកលគ្រប់បែបយ៉ាងដើម្បីយកឈ្នះគូសត្រូវរបស់ខ្លួន ក្នុងនោះមីនគឺជាឧបករណ៍ដែលគេនិយមយកមកប្រើប្រាស់ក្នុងការប្រយុទ្ធមិនផ្ទាល់ ។ ក្នុងកងទ័ពមួយដែលមានការហ្វឹកហាត់និងវិន័យល្អ ការប្រើប្រាស់មីនត្រូវមានការត្រួត

ពិនិត្យមិត់ចត់ កត់ត្រាលើផែនទី និងមានតម្រុយផ្សេងៗ ។ ប៉ុន្តែនៅក្នុងប្រទេសយើង មិនត្រូវបានគេដាក់ពង្រាយដោយគ្មានផែនទី គ្មានកំណត់ត្រាច្បាស់លាស់ និងគ្មានតម្រុយចំណាំផ្សេងៗ ។

## 2. តំបន់មានមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានបញ្ហាមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះច្រើនជាងគេក្នុងចំណោមប្រទេសដែលមានបញ្ហាមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅលើពិភពលោក ។ នៅឆ្នាំ 1994 អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) បានប្រមាណថា 40% នៃផ្ទៃដីដាំដំណាំក្នុងប្រទេសកម្ពុជាមានគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ។ ផ្ទៃដីទាំងនោះមាននៅស្ទើរពាសពេញផ្ទៃប្រទេស ពិសេសនៅតាមបណ្តាខេត្តនៃតំបន់ពាយ័ព្យរួមមាន ខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ សៀមរាប និងព្រះវិហារ ។ តាមការស្រាវជ្រាវថ្នាក់ជាតិកម្រិត 1 នៅខែមេសា ឆ្នាំ 2002 បានរាយការណ៍ថា ផ្ទៃដីទំហំ 4 544 km$^2$ ពោរពេញទៅដោយបញ្ហាមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ព្រមទាំងគ្រាប់បែកចង្កោម ។

ទីតាំងមានកប់មីននិងយុទ្ធភណ្ឌគ្រប់ប្រភេទ ច្រើនតែជាសមរភូមិមានការប្រយុទ្ធគ្នាក្នុងសម័យសង្គ្រាម ទីតាំងឈរជើង ឬបន្ទាយចាស់ការពារសន្តិសុខរបស់ទាហាន ស្ពានចាស់បាក់បែក ឬផ្លូវគ្មានអ្នកដំណើរឆ្លងកាត់ និងភូមិចាស់បោះបង់ចោលដោយភ័យខ្លាចការប្រយុទ្ធគ្នារវាងគូបដិបក្ខ ។




*ផែនទីតំបន់មីននៅកម្ពុជា*

ដូច្នេះ នៅពេលយើងនៅក្នុងតំបន់មានមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ យើងត្រូវប្រុងប្រយ័ត្ន ហើយត្រូវចៀសវាងនូវប្រការមួយចំនួនដូចជា មិនចូលទៅក្នុងបន្ទាយចាស់ មិនចូលក្រោមស្ពានបែកបាក់ មិនចូលទៅក្នុងភូមិចាស់ដែលគេបោះបង់ចោល មិនចូលក្នុងតំបន់ដែលមានសញ្ញាសម្គាល់មីន មិនប៉ះពាល់គ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងត្រូវរាយការណ៍ជាបន្ទាន់ជូនប្រធានភូមិ សមត្ថកិច្ច ឬអ្នកដោះមីន នៅពេលដែលប្រទះឃើញមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ។ មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ បង្កគ្រោះថ្នាក់គ្រប់ពេលវេលាដល់អ្នកដែលប៉ះពាល់ ចាប់កាន់ ទាត់ ជាន់ គប់ ចោល បោះលេង ដំលេង ដុតលេង យកទៅកែច្នៃជារបស់ផ្សេងៗ ឬយកទៅលក់ឱ្យអេតចាយ ។




## 3. ជនស៊ីវិលជាអ្នករងគ្រោះដោយសារគ្រាប់មីន

នៅក្នុងខេត្តដែលមានចំការមីន ប្រជាជនរស់នៅក្បែរទីនោះបានស្គាល់ទីតាំងគ្រាប់មីននិងមានមធ្យោបាយចៀសវាងគ្រោះថ្នាក់យ៉ាងច្បាស់លាស់ ។ ប៉ុន្តែ ប្រជាជនកម្ពុជាមិនតិចទេដែលពិការនិងស្លាប់ដោយគ្រាប់មីន ។ កម្មវិធីលើកកម្ពស់ការយល់ដឹងចំពោះគ្រោះថ្នាក់ដោយសារមីន ត្រូវបានរៀបចំដោយអង្គការសហប្រតិបត្តិការដែនដីតាមព្រំដែនរបស់អង្គការសហប្រជាជាតិ (UNBRO = United Nations Border Relief Operation) និងមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC) ដើម្បីអប់រំផ្សព្វផ្សាយឱ្យប្រជាជនដែលរស់នៅក្បែរមីន ឱ្យមានការប្រុងប្រយ័ត្នឱ្យកាន់តែខ្លាំងក្លាថែមទៀត ។ ប៉ុន្តែ ទោះជា មានការអប់រំផ្សព្វផ្សាយយ៉ាងនេះហើយក៏ដោយ ក៏គេសង្កេតឃើញថា ចំនួនអ្នកគ្រោះថ្នាក់នៅតែកើតមានច្រើន ដោយសារតែពួកគេត្រូវការចាំបាច់ផ្នែកជីវភាព ។

# 4. ឥទ្ធិពលនៃគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ

## 4.1. ឥទ្ធិពលទៅលើសេដ្ឋកិច្ចនិងភាពក្រីក្រ

មីននិងគ្រាប់មិនទាន់ផ្ទុះជាមហន្តរាយចំពោះសេដ្ឋកិច្ចនិងជីវិតមនុស្ស ព្រោះវាបានធ្វើឱ្យផ្ទៃដីមួយភាគធំមិនអាចប្រើប្រាស់បាន ។ ដីជាសម្បត្តិធម្មជាតិនិងជាធនធានមួយដែលមានសារប្រយោជន៍សំខាន់បំផុតសម្រាប់មនុស្ស សត្វ និងរុក្ខជាតិ ។ ប្រជាពលរដ្ឋត្រូវការដីសម្រាប់សង់លំនៅឋាន ដាំដំណាំ ធ្វើស្រែចំការ សង់សាលារៀន សង់មណ្ឌលសុខភាព វត្តអារាម កសាងផ្លូវ ឬ ស្ពានឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយ ដើម្បីដឹកកសិផលទៅកាន់ទីផ្សារ ។

ការរស់នៅក្នុងតំបន់ដែលមានគ្រាប់មីន មានឥទ្ធិពលអវិជ្ជមានជាច្រើនដែលរង់ចាំកំចាត់ជីវភាពរស់នៅដ៏មានសុវត្ថិភាពនិងធ្វើឱ្យមានជំងឺចិត្តសាស្ត្រ និងធ្វើឱ្យមានការលំបាកផ្លូវចិត្តដ៏ធំធេងសម្រាប់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ ។ មូលហេតុដែលនាំឱ្យកើតមានគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះទាក់ទងដោយផ្ទាល់ទៅនិងជីវភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ ។ ជីវភាពមិនគ្រប់គ្រាន់ក៏ជាមូលហេតុនិងជាផលប៉ះពាល់ដល់ជីវភាពក្រីក្រដែរ ។ វត្តមានគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះជាឧបសគ្គដ៏ធំចំពោះផលិតកម្មកសិកម្ម ។ កត្តានេះហើយបង្កឱ្យមានគ្រោះថ្នាក់ដល់ប្រជាជនដែលស្វែងរកអាហារនិងផ្លែឈើនៅក្នុងតំបន់ចំការមីននិងគ្រាប់មិនទាន់ផ្ទុះ ដែលជាហេតុធ្វើឱ្យពួកគេរិតតែស្ថិតក្នុងភាពក្រីក្របន្ថែមទៀត ។

ផ្អែកតាមការស្រាវជ្រាវថ្នាក់ជាតិកម្រិត ៛ របស់កម្ពុជានៅឆ្នាំ 2002 បង្ហាញថា មានភូមិចំនួន 6 416 ក្នុងចំណោមភូមិសរុបចំនួន 13 908 ភូមិ ក្នុងទូទាំងប្រទេសកម្ពុជា ដែលរងនូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គម ។



## ៤.២. អត្រាគ្រោះថ្នាក់ដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះ

មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(CMAC)បានធ្វើការកត់សម្គាល់ថា ចាប់តាំងពីឆ្នាំ 1979 មកដល់ខែមីនា ឆ្នាំ 2002 គ្រោះថ្នាក់ពីការផ្ទុះគ្រាប់មីនមានចំនួន 25 967 ករណី ក្នុងនោះមាន 16 950 ករណីបណ្តាលឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិត ។ ការរងគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ ថយចុះខ្លាំងពី 3 276 នាក់នៅឆ្នាំ 1996 មកនៅត្រឹម 279 នាក់នៅឆ្នាំ 2002 ។

គ្រោះថ្នាក់ដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះបានធ្លាក់ចុះយ៉ាងច្រើន គឺពី 450 ករណី នៅឆ្នាំ 2006 មកនៅត្រឹម 352 ករណីនៅឆ្នាំ 2007 និង 266 ករណីនៅឆ្នាំ 2008 ។ ការធ្លាក់ចុះនៃគ្រោះថ្នាក់នេះ ដោយសារតែការខិតខំប្រឹងប្រែងនិងកិច្ចសហប្រតិបត្តិការរបស់អ្នកចូលរួមជាច្រើននៅក្នុងវិស័យសកម្មភាពមីន ជាពិសេសការលើកកម្ពស់ការអប់រំ ការយល់ដឹងអំពីមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះដល់ប្រជាពលរដ្ឋតាមសហគមន៍នីមួយៗ ។



| | 1992 | 1993 | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 616 | 466 | 469 | 730 | 1295 | 1173 | 518 | 420 | 467 | 404 | 367 | 362 | 340 | 366 | 188 | 138 | 117 |
| 2 | 1573 | 2069 | 2340 | 2603 | 3025 | 1125 | 1633 | 735 | 391 | 422 | 480 | 410 | 558 | 509 | 262 | 214 | 149 |
| 3 | 2189 | 2535 | 2809 | 3333 | 4320 | 2298 | 2151 | 1155 | 858 | 826 | 847 | 772 | 898 | 875 | 450 | 352 | 266 |

1. មីន 2. យុទ្ធភណ្ឌមិនទាន់ផ្ទុះ 3. មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ

ប៉ុន្តែ ទោះជាមានការធ្លាក់ចុះយ៉ាងនេះក៏ដោយ ក៏ចំនួនគ្រោះថ្នាក់នៅតែមានកម្រិតខ្ពស់ ហើយប្រទេសកម្ពុជានៅតែគេចាត់ទុកថា ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានបញ្ហាមីនធ្ងន់ធ្ងរនៅលើពិភពលោក ។

# 5. លទ្ធផលនៃការដោះមីន

ដើម្បីការពារប្រជាពលរដ្ឋឱ្យចៀសផុតពីការរងគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ និងដើម្បីឱ្យមានសុវត្ថិភាពក្នុងការប្រើប្រាស់ដីធ្លីនៅតាមសហគមន៍ជនបទ រាជរដ្ឋាភិបាលកម្ពុជាសហការជាមួយអង្គការមនុស្សធម៌អន្តរជាតិបាននិងកំពុងអនុវត្តការបោសសំអាតមីននៅតាមដីស្រែចំការ ភូមិដ្ឋាន ទីវត្តអារាម និងនៅជុំវិញប្រាង្គប្រាសាទនានាដែលមានកប់គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ។

អង្គភាពនិងអង្គការបោសសំអាតមីននៅកម្ពុជាមាន

- កងកម្លាំងរក្សាសន្តិសុខអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(អ៊ុនតាក់ UNTAC) បានដឹកនាំ ហ្វឹកហ្វឺន បណ្តុះបណ្តាលបច្ចេកទេសបោសសំអាតមីនដល់កងទ័ពកម្ពុជានិងបានធ្វើការប្រតិបត្តិការបោសសំអាតមីនពីខែ មីនា ឆ្នាំ 1992 ដល់ ខែ តុលា 1993 ។
- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា(ស៊ីម៉ាក់ CMAC) បានបន្តសកម្មភាពបោសសំអាតមីន (បន្តពីអ៊ុនតាក់)ពីខែ វិច្ឆិកា ឆ្នាំ 1993 រហូតដល់បច្ចុប្បន្ននិងបន្តទៅអនាគត ។
- អង្គការមិនមែនរដ្ឋាភិបាលបោសសំអាតមីន(ម៉ាក-MAG)
- អង្គការមិនមែនរដ្ឋាភិបាលបោសសំអាតមីន(ហេឡូត្រាស-Halo Trust)
- អង្គការជំនួយសកម្មភាពកំចាត់មីនជប៉ុន(ជេម៉ាស់-JMAS)
- កងកម្លាំងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ

**លទ្ធផលសម្រេចបាន**

- អ៊ុនតាក់(UNTAC)ពីខែមីនា 1992 ដល់ខែតុលា 1993

| ផ្ទៃដីបោសសំអាតមីនរួច | មីនប្រឆាំងមនុស្ស | មីនប្រឆាំងរថក្រោះ | គ្រាប់មិនទាន់ផ្ទុះ |
|---|---|---|---|
| 5 479 850 $m^2$ | 19 433 គ្រាប់ | 132 គ្រាប់ | 96 486 គ្រាប់ |

- ស៊ីម៉ាក់ RCAF ម៉ាកនិងហេឡូត្រាស(1992-2008)

**លទ្ធផលនៃការបោសសំអាតមីនពីឆ្នាំ 1992-2008**

| | | CMAC | RCAF | MAG | HALO Trust | សរុបរួម |
|---|---|---|---|---|---|---|
| 1992-2008 | ផ្ទៃដីគិតជា $m^2$ | 227.368.336 | 170.640.882 | 26.433.356 | 52.062.230 | 476.504.804 |
| | ចំនួនមីនប្រឆាំងមនុស្ស | 404.523 | 161.636 | 47.405 | 200.634 | 814.198 |
| | ចំនួនមីនប្រឆាំងរថក្រោះ | 7.657 | 8.337 | 585 | 2.530 | 19.109 |
| | ចំនួនគ្រាប់មិនទាន់ផ្ទុះ | 1.370.028 | 100.168 | 140.317 | 130.318 | 1.740.831 |

# ៦. ប្រភេទមីននិងគ្រាប់មិនទាន់ផ្ទុះ

## ៦.1. ប្រភេទមីន

មីនដែលនាំមកប្រើប្រាស់លើទឹកដីកម្ពុជាមានពីរប្រភេទគឺ មីនប្រឆាំងមនុស្ស និងមីនប្រឆាំងរថក្រោះ ។

- ប្រភេទមីនប្រឆាំងមនុស្ស ៖ មីនប្រឆាំងមនុស្សមានរូបរាង ទំហំ ពណ៌ និងទម្ងន់មិនដូចគ្នាទេ ។ មីនប្រភេទនេះច្រើនមានពណ៌ស្លែដូចស្លឹកឈើដើម្បីបន្លំភ្នែកមនុស្ស ដែលផលិតពីដែក ជ័រ និងឈើ ។ មីនប្រឆាំងមនុស្សមាន 4 បែបគឺ
  - មីនខ្យល់ ៖ គេដាក់វាបង្កប់ក្នុងដី ហើយមីននេះអាចផ្ទុះនៅពេលយើងប៉ះពាល់ ឬដើរជាន់ពីលើ ។ ឥទ្ធិពលរបស់វាអាចបណ្ដាលឱ្យមនុស្ស សត្វ ដាច់ដៃ ដាច់ជើង ពេលខ្លះរហូតដល់ស្លាប់ទៀតផង ។
  - មីនអំបែង ៖ ជាទូទៅគេដាក់មីនអំបែងលើដីបន្លំជាមួយស្លឹកឈើក្នុងគុម្ពោតព្រៃ ដើម្បីបំភាន់ភ្នែកមនុស្ស ។ គេយកលួសតូចឆ្មារចងភ្ជាប់គន្លឹះសុវត្ថិភាពរបស់មីននេះ រួចបន្លាយទៅនឹងបង្គោលឈើ ឬកូនរុក្ខជាតិ ។ ពេលមនុស្ស សត្វដើរទាក់ខ្សែ មីននោះនឹងផ្ទុះ ជះអំបែងជុំវិញ ធ្វើឱ្យអ្នកដើរទាក់ខ្សែនោះរងជារបួស ពិការ ឬស្លាប់ភ្លាម ។
  - មីនលោត៖ គេដាក់មីនលោតកប់ក្នុងដី ឬលើដី ។ មីនប្រភេទនេះ បង្កគ្រោះថ្នាក់ខ្លាំងណាស់ ។ នៅពេលមនុស្សដើរជាន់ ឬដើរទាក់ខ្សែ មីននេះលោតឡើងលើស្មើដើមទ្រូងមនុស្សឈរទើបផ្ទុះ ហើយកម្ទេចអ្នកដែលដើរជាន់ ឬដើរទាក់ខ្សែនោះ ។
  - មីនកំណត់ទិស ៖ គេដាក់មីនកំណត់ទិសលើដី ឬលើមែកឈើមិនឱ្យមើលឃើញ ដើម្បីស្ទាក់ផ្លូវសត្រូវ ។ មីននេះអាចផ្ទុះនៅពេលមនុស្សដើរទាក់ខ្សែឬគេចុចបញ្ជាឱ្យផ្ទុះដោយប្រើចរន្តអគ្គិសនី(ថ្មពិល អាគុយ) ។
- ប្រភេទមីនប្រឆាំងរថក្រោះ ៖ មីនប្រឆាំងរថក្រោះមានទំហំនិងទម្ងន់ធ្ងន់ជាងមីនប្រឆាំងមនុស្ស ហើយមានកម្លាំងខ្លាំង ។ គេប្រើមីនប្រភេទនេះសម្រាប់កម្ទេចយានយន្តតូចធំ ពិសេសរថក្រោះក្នុងពេលធ្វើសង្គ្រាម ។ មីនប្រភេទនេះក៏អាចបង្កឱ្យមានគ្រោះថ្នាក់ ឬស្លាប់នៅពេលជាន់ កិនប៉ះពាល់ ឬចាប់កាន់វា ។

## ៦.២. ប្រភេទគ្រាប់មិនទាន់ផ្ទុះ

គ្រាប់មិនទាន់ផ្ទុះមាន 5 ប្រភេទគឺ គ្រាប់បែកដៃ គ្រាប់កាំភ្លើងត្បាល់ គ្រាប់កាំភ្លើងធំ គ្រាប់រ៉ុកកែត និងគ្រាប់ទម្លាក់ពីលើយន្តហោះ ។ ហេតុដែលយុទ្ធភណ្ឌទាំងនេះមិនផ្ទុះ ដោយសារតែនៅពេលគេបាញ់ វាធ្លាក់មិនចំទិសដៅ ធ្លាក់ក្នុងទឹក ឬដីទន់ ខុសបច្ចេកទេស ឬខូចមេកានិច ។ យើងមិនត្រូវប៉ះពាល់ ជំ ឬដុតគ្រាប់មិនទាន់ផ្ទុះទាំងអស់នោះទេ ព្រោះអាចផ្ទុះនិងធ្វើឱ្យយើងទទួលគ្រោះថ្នាក់របួស ពិការ និងស្លាប់បាត់បង់ជីវិត ។

## 7. ច្បាប់ហាមប្រើប្រាស់គ្រាប់មីន

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទ ។ ទោសប្បញ្ញត្តិក្នុងច្បាប់ការហាមប្រើប្រាស់គ្រាប់មីន ៖

- ជនណាកាន់កាប់ ថែរក្សាទុកដោយចេតនានូវគ្រាប់មីន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំនិងពិន័យជាប្រាក់ពីមួយលានរៀលដល់ម្ភៃលានរៀល ។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ ។
- ជនណាផលិត ជួញដូរ នាំចូល ឬនាំចេញគ្រាប់មីនគ្រប់ប្រភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់ដប់ឆ្នាំនិងពិន័យជាប្រាក់ពីដប់លានរៀលដល់ម្ភៃលានរៀល ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេជាពីរ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី 28 ខែមេសា ឆ្នាំ 1999 នាសម័យប្រជុំរដ្ឋសភាលើកទី 2 នីតិកាលទី 2 ។

## ? សំណួរ

1. តើមីនជាអ្វី ? ប្រើសម្រាប់ធ្វើអ្វី ?
2. តើខេត្តណាខ្លះដែលសំបូរមីន ? ហេតុអ្វី ?
3. តើទីកន្លែងណាខ្លះដែលត្រូវចៀសវាង មិនត្រូវចូលទៅ ដើម្បីបង្ការគ្រោះថ្នាក់ដោយសារគ្រាប់មីន?
4. តើបញ្ហាមីនមានទំនាក់ទំនងទៅនឹងភាពក្រីក្ររបស់ប្រជាជនយ៉ាងណាខ្លះ ?
5. ហេតុអ្វីបានជាគ្រោះថ្នាក់ដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ មានការថយចុះ ?
6. ចូររៀបរាប់ឈ្មោះអង្គភាពនិងអង្គការបោសសំអាតមីននៅកម្ពុជា ?
7. តើការបោសសំអាតមីនមានគោលបំណងអ្វីខ្លះ ?
8. តើមីនមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
9. តើគ្រាប់មិនទាន់ផ្ទុះមានប៉ុន្មានប្រភេទអ្វីខ្លះ ?
10. តើច្បាប់ហាមប្រើប្រាស់គ្រាប់មីនមានខ្លឹមសារដូចម្តេចខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី៣

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. នៅកម្ពុជាវិស័យសេដ្ឋកិច្ចជាតិដែលផ្តល់ការងារឱ្យប្រជាជនបានច្រើនជាងគេគឺ

☐ក. កសិកម្ម ☐ខ. ឧស្សាហកម្ម ☐គ. ទេសចរ ☐ឃ. គមនាគមន៍

3. ទីផ្សារសំខាន់ក្នុងការនាំចេញរបស់កម្ពុជាដែលមានបរិមាណទឹកប្រាក់ច្រើនជាងគេគឺ

☐ក. កាណាដា ☐ខ. សហគមន៍អឺរ៉ុប ☐គ. សហរដ្ឋអាមេរិក ☐ឃ. វៀតណាម

4. តំបន់អេកូទេសចរណ៍ដែលភ្ញៀវអន្តរជាតិចូលចិត្តទៅកម្សាន្តគឺ

☐ក. សៀមរាប ☐ខ. ភូមិភាគឦសាន ☐គ. ឆ្នេរ ☐ឃ. ភ្នំពេញ

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ផ្នែកសំខាន់ៗទាំងបួននៃវិស័យកសិកម្មរួមមាន ការដាំដុះ ព្រៃឈើ ការចិញ្ចឹមសត្វ និង ........ ។
2. ខេត្តដែលមានចម្ងាយផ្លូវវែងជាងគេគិតពីភ្នំពេញទៅ គឺខេត្ត ................................ ។
3. ក្រុមហ៊ុនដែលផ្តល់ផលិតផលនាំចេញបានរូបិយបណ្ណច្រើនជាងគេ គឺក្រុមហ៊ុន ................ ។
4. អង្គភាពដែលធ្វើសកម្មភាពបោសសំអាតមីនខ្លាំងក្លាជាងគេនៅកម្ពុជាគឺ ........................ ។

III. សំណួរ

1. ហេតុអ្វីបានជាសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកសំខាន់ទៅលើកសិកម្ម ?
2. ចូររៀបរាប់អំពីមូលហេតុ ដែលនាំឱ្យមានអត្រាគ្រោះថ្នាក់ចរាចរណ៍ខ្ពស់នៅកម្ពុជា ? តើគ្រោះថ្នាក់ចរាចរណ៍ផ្តល់ផលប៉ះពាល់យ៉ាងណាខ្លះ ចំពោះសេដ្ឋកិច្ចនិងសង្គម ?
3. តើសកម្មភាពសំខាន់ៗអ្វីខ្លះ ដែលជំរុញពាណិជ្ជកម្មឱ្យរីកចម្រើនបាន ?
4. កត្តាសំខាន់ៗអ្វីខ្លះ ដែលជួយជំរុញឱ្យវិស័យទេសចរណ៍រីកចម្រើនបានឆាប់រហ័ស ?
5. ដើម្បីចៀសវាងពីបញ្ហាមីននិងគ្រាប់មិនទាន់ផ្ទុះ តើអ្នកជួយអប់រំ ផ្សព្វផ្សាយ ដល់មិត្តភក្តិ គ្រួសារឱ្យគាត់យល់ដឹងអំពីប្រការអ្វីខ្លះ ?

IV. លំហាត់

1. នៅឆ្នាំ 2008 ផ្នែកកាត់ដេរសម្លៀកបំពាក់ប្រើប្រាស់ពលករប្រមាណ 4.90% នៃប្រជាជនសកម្ម គឺស្មើនឹង 345 860 នាក់ ។ ចូរគណនាចំនួនប្រជាជនសកម្មនៅឆ្នាំ 2008 ។
2. ស្ពានវែងៗចំនួនបីគឺ ស្ពានកោះកុង ស្ពានព្រែកព្នៅ និងស្ពានព្រែកក្ដាម មានប្រវែងសរុប 4 424m ។ គេដឹងថាស្ពានកោះកុងវែងជាងស្ពានព្រែកព្នៅ 357m និងវែងជាងស្ពានព្រែកក្ដាម 919m ។ ចូរគណនាប្រវែងស្ពាននីមួយៗ ។

ជំពូកទី 4

# នគរូបនីយកម្មនៅកម្ពុជា



*ប្លង់រាជធានីអង្គរវត្តពីលើអាកាស*

នគរូបនីយកម្មនៅកម្ពុជា គឺជាដំណើររៀបចំដែនដី កិច្ចអភិវឌ្ឍទីក្រុងនិងខេត្តនានា ពិសេសការរៀបចំប្លង់សម្រាប់ប្រើប្រាស់ដីធ្លីឱ្យបានសមស្របទៅតាមភាពរីកចម្រើនសង្គម សេដ្ឋកិច្ចជាតិ ។ គេបានរៀបចំលិខិតបទដ្ឋានសម្រាប់បម្រើការងារសំណង់នានា បានពិនិត្យការចុះបញ្ជីគ្រប់គ្រងប្រើប្រាស់ដីធ្លី និងរៀបចំបណ្តាញវាស់វែងឱ្យបានត្រឹមត្រូវ ។ ដើម្បីឱ្យមានដំណើរការល្អ ផ្នែកនគរូបនីយកម្មចាំបាច់ត្រូវមានកិច្ចសហការជាមួយក្រសួងនានាមួយចំនួនទៀតដូចជា ក្រសួងបរិស្ថាន ក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម... ។ គួររំលឹកផងដែរថា នៅសម័យ "កម្ពុជាប្រជាធិបតេយ្យ" របបសម្ភូហកម្មបានលុបបំបាត់ចោលកម្មសិទ្ធិសួនតួ(មានកម្មសិទ្ធិដីធ្លី ផ្ទះសំបែងជាដើម) ។ ខណៈនោះនគរូបនីយកម្មធ្លាក់ចុះដល់កម្រិតក្រោមសូន្យ បង្កការលំបាកច្រើនក្នុងការរៀបចំឱ្យមានប្លង់កម្មសិទ្ធិដីធ្លីផ្ទះសំបែងឡើងវិញ ។

តទៅនេះ យើងនឹងសិក្សាអំពីប្រវត្តិនគរូបនីយកម្មនៅកម្ពុជា សេដ្ឋកិច្ចតំបន់និងការបែងចែកប្រភេទក្រុង-ខេត្ត កំណើននគរូបនីយកម្មនិងបញ្ហាបរិស្ថាន ។

មេរៀនទី

# 1 លក្ខខណ្ឌប្រវត្តិសាស្ត្រនៃការអភិវឌ្ឍទីក្រុង

ចប់មេរៀននេះ សិស្សអាច

- បកស្រាយបានច្បាស់លាស់នូវអត្ថន័យនៃពាក្យនគរូបនីយកម្ម
- ពណ៌នាពីប្រវត្តិនគរូបនីយកម្មតាមសម័យកាលនីមួយៗនិងទៅអនាគតនៅកម្ពុជា ។

គេអាចវាយតម្លៃទៅលើប្រវត្តិសាស្ត្រនៃការអភិវឌ្ឍទីក្រុងរបស់ប្រទេសមួយ បានតាមរយៈវត្តមានទីតាំង ភូមិ ស្រុក និងផលិតកម្មទៅតាមទេពកោសល្យរបស់ប្រជាជន ។ វឌ្ឍនភាពនៃទីក្រុងបង្ហាញពីស្នាដៃនិងកម្រិតច្នៃប្រឌិតរបស់ប្រជាជនក្នុងការបង្កើតលំនៅឋានច្រើនបែបយ៉ាងនៅលើទឹកដីរបស់ខ្លួន ។ វិសមភាពនៃការអភិវឌ្ឍផ្នែកផលិតកម្មឆ្លុះបញ្ចាំងពីទម្រង់សេដ្ឋកិច្ច និងជីវភាពប្រជាជនតាមតំបន់នីមួយៗ ។ វឌ្ឍនភាពនៃវិទ្យាសាស្ត្របច្ចេកទេស បានជះឥទ្ធិពលដល់ការផ្លាស់ប្តូរ សមាសភាពវិជ្ជាជីវៈ និងទីតាំងលំនៅឋានខុសៗគ្នារបស់ប្រជាជន ។

នៅកម្ពុជា អ្វីៗដែលបានរៀបរាប់ខាងលើ សុទ្ធសឹងស្តែងចេញតាមរយៈប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ។

## 1. នគរូបនីយកម្មមុនសម័យអាណានិគមបារាំង

ជាទូទៅ នៅកម្ពុជាដំណុះប្រជាជនសំខាន់ៗ ច្រើនកើតមាននៅតាមដងទន្លេឬផ្លូវទឹក ដែលអាចធ្វើនាវាចរណ៍ទាក់ទងគ្នាពីកំពង់ផែមួយទៅកំពង់ផែមួយរហូតដល់រាជធានី ។ កំពង់ផែនីមួយៗមានមនុស្សត្រឹមរាប់រយនាក់ប៉ុណ្ណោះ ។ ទីតាំងកំពង់ផែនេះហើយ ដែលជាទីស្នាក់ការរបស់ចៅហ្វាយស្រុក ហើយជនជាតិចិន កូនចៅចិន ចាមជាដើម ជាអ្នកកាន់កាប់ជំនួញផ្តាច់មុខ ។ ក្រៅពីនេះ គេឃើញវាលស្រែរបស់ប្រជារាស្ត្រខ្មែរ ភូមិឋាន និងវត្តអារាមព្រះពុទ្ធសាសនា ។ នៅឯនាយ បន្ទាប់ពីវាលស្រែជាទីតាំងព្រៃរបោះ ។ និយាយរួម បណ្តុំប្រជារាស្ត្រខ្មែរមាននៅតាមកំពង់ផែនានានៃព្រះរាជាណាចក្រដែលនៅទីនោះគេឃើញមានសកម្មភាពយ៉ាងមមាញឹកផ្នែករដ្ឋបាល ការដឹកជញ្ជូនតាមផ្លូវទឹក ជំនួញដូរ ស្រែចម្ការច្បារដំណាំ ការប្រតិបត្តិជំនឿសាសនា និងការប្រមូលផលព្រៃឈើ ។

តាមពិតទៅ នគរូបនីយកម្មនៅកម្ពុជាកើតមានតាំងពីយូរលង់មកហើយ គឺមានតាំងពីមុនការមកដល់នៃពួកអាណានិគមបារាំងម្ល៉េះ ។ ខ្មែរជំនាន់ដើមរស់នៅជាក្រុម សង់ផ្ទះលើជន្ទល់ខ្ពស់ផុតពីដី ។ ខ្មែរមានកំពង់ផែទន្លេ ព្រមទាំងកំពង់ផែសមុទ្រផងដែរ(កំពង់ផែសំពៅនៅអូរកែវកម្ពុជាក្រោម) សម្រាប់ការដឹកជញ្ជូននិងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។ អាណាចក្រភ្នំ មានវ្យាធបុរៈជារាជធានី ។ កម្ពុជាសម័យចេនឡា មានភវបុរៈនិងឦសានបុរៈជារាជធានី ។ ទីក្រុងអង្គរដ៏ស្រស់បវរប្រកបដោយស្នាដៃស្ថាបត្យកម្មគ្មានពីរក្នុងលោកនាសម័យរុងរឿងបំផុតនៃប្រវត្តិសាស្ត្រកម្ពុជា មានប្រជាជនប្រមាណជាមួយលាននាក់(តាមការប៉ាន់ស្មាន) ហើយដែលប្រជាជនទូទាំងចក្រភពខ្មែរមានប្រហែលដប់លាននាក់ជាស្រេចទៅហើយនាពេលនោះ ។ ស្នាដៃផ្នែកនគរូបនីយកម្មដែលគួរឱ្យស្ញប់ស្ញែងមួយទៀតរបស់ដូនតាយើង គឺការកសាងទីក្រុងលង្វែក ដែលមានគុម្ពឫស្សីជាកំពែងការពារដ៏រឹងមាំ ។ រាជធានីចតុមុខដែលកសាងឡើងដោយព្រះបាទពញាយ៉ាត ក៏ជាស្នាដៃផ្នែកនគរូបនីយកម្មមួយទៀតយ៉ាងសំខាន់ ត្រង់ថាមានទីតាំងល្អ គឺស្ថិតនៅលើទីប្រសព្វនៃទន្លេទាំងបួន ដែលកម្រមានក្នុងលោក ។ ទឹកជំនន់ទន្លេមេគង្គ ត្រូវបានស្រូបយកមួយចំនួនធំដោយបឹងទន្លេសាបនិងហូរចាក់ទៅក្នុងសមុទ្រតាមទន្លេសំខាន់ពីរ គឺទន្លេមេគង្គនិងទន្លេបាសាក់ ដែលជាហេតុនាំឱ្យទីក្រុងភ្នំពេញគេចផុតពីគ្រោះទឹកជំនន់ ។

និយាយរួម យើងត្រូវតែទទួលស្គាល់ថា ដូនតាយើងជំនាន់ដើម ជាអ្នកមានទេពកោសល្យខ្ពស់ខាងផ្នែកនគរូបនីយកម្ម ព្រោះលោកចេះគ្រប់គ្រងនិងរៀបចំដែនដី បង្កើតឱ្យមានភូមិ ឃុំ ស្រុក ខេត្ត ទីក្រុង រាជធានី គមនាគមន៍ កំពង់ផែ ដីស្រែចម្ការ សិប្បកម្ម និងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។

## 2. នគរូបនីយកម្មពីសម័យអាណានិគមបារាំងដល់ឆ្នាំ 1969

ប្រទេសកម្ពុជាធ្លាក់ក្រោមអាណាព្យាបាលបារាំងនៅឆ្នាំ 1863 ។ នៅទសវត្សរ៍ដំបូងនៃអំណាចគ្រប់គ្រងរបស់មហាអំណាចមួយនេះ អ្វីៗដែលជាលក្ខណៈលេចធ្លោគឺ ការស្តារសន្តិសុខនយោបាយ និងកំណែលម្អ វិស័យរដ្ឋបាល ពិសេសផ្នែកពន្ធដារ ។ នៅចុងសតវត្សទី 19 កម្ពុជាទទួលបានការរីកចម្រើនមួយកម្រិត លើវិស័យសេវាកម្ម មានគមនាគមន៍ ពាណិជ្ជកម្ម និងរដ្ឋបាល ដែលជាមូលដ្ឋាននៃការអភិវឌ្ឍសេដ្ឋកិច្ច ដូចនេះ ការងារនគរូបនីយកម្មជាតម្រូវការចាំបាច់ ។

ការប្រមូលពន្ធដារនៅឆ្នាំ 1892 ប្រព្រឹត្តទៅក្រោមការត្រួតត្រារបស់រដ្ឋអំណាចបារាំង ដែលមានរេស៊ីដង់(Résident)10 នាក់ជាអ្នកគ្រប់គ្រងរដ្ឋបាលខេត្ត ហើយមានរេស៊ីដង់ជាន់ខ្ពស់(Résident Superieur) ម្នាក់ទៀតដែលមានទីស្នាក់ការនៅទីក្រុងភ្នំពេញជាអ្នកត្រួតពីលើ ។ ចន្លោះឆ្នាំ 1900-1930 គេបានកេណ្ឌប្រជារាស្ត្រខ្មែរយកទៅកសាងផ្លូវថ្នល់បានចម្ងាយ 9 000km ។ គម្រោងនគរូបនីយកម្មដ៏សំខាន់

បំផុតមួយសម្រាប់ទីក្រុងភ្នំពេញ គឺការចែកជាតំបន់ដាច់ដោយឡែកៗពីគ្នា ដូចជាតំបន់ជនជាតិបារាំង ចិន និងខ្មែរត្រូវបានសម្រេចឡើងនៅឆ្នាំ 1908 ។ ចាប់ពីពេលនោះមក ទីក្រុងភ្នំពេញទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សស្របទៅនឹងកំណើនសេដ្ឋកិច្ច ។ ក្រោយឆ្នាំ 1920 ទើបមានផ្លូវថ្នល់ខេត្ត ដែលកសាងដោយពួកអាណានិគម ។ នៅឆ្នាំ 1932 ផ្លូវថ្នល់មានទៅដល់ខេត្តបាត់ដំបង ហើយផ្លូវសំខាន់ៗនៅតាមខេត្តក៏មាន នៅក្នុងគម្រោងជាស្រេចនៅឆ្នាំ 1938 ។ ក្រៅពីនេះ បារាំងបានសាងសង់ក្រុងនៅតាមខេត្តមួយចំនួនមាន ខេត្តកណ្ដាល ព្រៃវែង កំពង់ចាម កំពង់ធំ បាត់ដំបង... ។ សព្វថ្ងៃគេឃើញគ្រឹះស្ថាននិងលំនៅឋានដែលជារចនាបថបារាំងនៅតាមខេត្តទាំងនោះ មាននៅសេសសល់តិចតួច តែមួយចំនួនធំត្រូវបាក់ស្រុតនិងជំនួសដោយអគារទំនើបថ្មីៗ ។ នៅទីក្រុងភ្នំពេញសំណង់ផ្ទះល្វែងសម័យអាណានិគមបារាំងក៏ដួលរលំអស់ទៅហើយ នៅសល់តែអគារសិក្សាវិទ្យាល័យព្រះស៊ីសុវត្ថិ ផ្សារធំថ្មី ប្រាសាទធ្វើអំពីលោហៈមួយក្នុងព្រះបរមរាជវាំង ។

ក្រោយពេលដែលរដ្ឋអំណាចបារាំងបានដកចេញផុតពីកម្ពុជា សម័យកាលថ្មីមួយនៃប្រវត្តិសាស្ត្រខ្មែរក៏ចូលមកបន្តវេន គឺសម័យសង្គមរាស្ត្រនិយមដែលបានធ្វើឱ្យកម្ពុជាមានសុខសន្តិភាពនិងវឌ្ឍនភាពលើគ្រប់វិស័យ ពិសេសវិស័យសេដ្ឋកិច្ចកើតមានស្របគ្នានឹងសកម្មភាពអភិវឌ្ឍនគរូបនីយកម្ម ។ បន្ទាប់ពីទីក្រុងភ្នំពេញ កម្ពុជាមានក្រុងធំៗពីរទៀតគឺ ក្រុងកំពង់ចាមនិងក្រុងបាត់ដំបងដោយផ្អែកលើចំនួនប្រជាជននិងកម្លាំងសេដ្ឋកិច្ច ។



*ទិដ្ឋភាពក្រុងភ្នំពេញសម័យសង្គមរាស្ត្រនិយម*

បន្ទុះសេដ្ឋកិច្ចនៅដើមឆ្នាំ 1960 បានបង្ហាញពីភាពរឹងមាំនៃកំណើនផលិតកម្ម បានទាក់ទាញវិនិយោគទុនថ្មីៗមកកាន់តំបន់ទីក្រុង ។ នៅសម័យនោះ គេឃើញមានការសាងសង់សង្កាត់លំនៅឋាននៅទីក្រុងភ្នំពេញ ហើយចំនួនប្រជាជនក្រុងមានជិត 400 000 នាក់ នៅឆ្នាំ 1962 ។ ស្នាដៃផ្នែកនគរូបនីយកម្មផ្សេងៗទៀតនាសម័យនោះមាន សំណង់វិមានឯករាជ្យ ស្ពានព្រះមុនីវង្សថ្មី(បច្ចុប្បន្នហៅថា ស្ពានមុនីវង្សចាស់)ជំនួសស្ពានចាស់ ដែលសាងសង់ឡើងពីសម័យអាណានិគម ហើយបានបាក់រលំទៅ ស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ 4 លំនៅឋានសម្រាប់ជនក្រីក្រតាមបណ្ដោយផ្លូវជាតិលេខ 4... ។

## ३. នគរូបនីយកម្មពីឆ្នាំ 1969 មកដល់បច្ចុប្បន្ន

ការពង្រីកទីក្រុងឈប់ដំណើរការនៅដំណាច់ទសវត្សរ៍ឆ្នាំ 1960 គឺនៅពេលដែលកម្ពុជាជាប់ពាក់ព័ន្ធបន្តិចម្ដងៗទៅក្នុងសង្គ្រាមវៀតណាម ។ ពីឆ្នាំ 1969-1991 មានព្រឹត្តិការណ៍ជាច្រើនដូចជា ចម្បាំងក្នុងស្រុក ការឈ្លានពានពីបរទេស នយោបាយមហាលោតផ្លោះរបស់ខ្មែរក្រហមបានបំផ្លិចបំផ្លាញមាតុភូមិកម្ពុជានិងប្រជារាស្ត្រខ្មែរយ៉ាងធ្ងន់ធ្ងរ ។

ពីឆ្នាំ 1970 ដល់ 1975 កម្ពុជាត្រូវបានឆាបឆេះដោយភ្លើងសង្គ្រាម ។ ប្រជាពលរដ្ឋខ្មែរត្រូវរត់គេចចេញពីការវាយប្រយុទ្ធគ្នារវាងកងទ័ពសាធារណរដ្ឋខ្មែរនិងកងទ័ពរំដោះ ឆ្ពោះមកកាន់ទីប្រជុំជនទីរួមខេត្ត ទីក្រុងពិសេសទីក្រុងភ្នំពេញដែលមានកិច្ចការពាររឹងមាំជាង មានសុវត្ថិភាពជាង ។ ពេលនោះប្រជាជនក្រុងភ្នំពេញកើនឡើងយ៉ាងរហ័ស គឺដល់ប្រហែល 2 លាននាក់ រស់នៅដោយសារតែជំនួយពីសហគមន៍អន្តរជាតិ ។ ទីបំផុត ទីក្រុងភ្នំពេញត្រូវឡោមព័ទ្ធនិងរំដោះដោយពួកខ្មែរក្រហម ហើយរបបសាធារណរដ្ឋខ្មែរក៏ដួលរលំទៅ ។ ក្នុងអំឡុងនោះកិច្ចអភិវឌ្ឍទីក្រុងគ្មានទេ គឺអ្វីៗដែលកម្ពុជាមានពីមុនមកត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទីស្ទើរអស់ដោយសារគ្រាប់បែក គ្រាប់ផ្លោង ការទម្លាក់គ្រាប់បែក។

ពីឆ្នាំ 1975 ដល់ 1979 (របបកម្ពុជាប្រជាធិបតេយ្យ)នគរូបនីយកម្មនៅកម្ពុជា មានលក្ខណៈបញ្ច្រាសទិសយ៉ាងចម្លែកកម្រមានក្នុងលោក ដោយពួកមេដឹកនាំខ្មែរក្រហមបានជំលៀសប្រជាជនពីទីក្រុងភ្នំពេញ 2 លាននាក់ ដោយបង្ខំឱ្យចាកចេញពីលំនៅឋានក្នុងរយៈពេល 48 ម៉ោង ។ ទីក្រុងនេះដែលធ្លាប់តែមានមនុស្សរស់នៅកកកុញ បែរជាស្ងាត់ជ្រងំ(ទីក្រុងខ្មោច) ។ គេជំលៀសប្រជាជនទៅកាន់ទីជនបទដើម្បីធ្វើការងារបង្កបង្កើនផលតាមទិសស្លោក "មានស្រូវ គឺមានអ្វីៗទាំងអស់" ។

ពីឆ្នាំ 1979 ដល់ 1991 នគរូបនីយកម្មនៅកម្ពុជាមានលក្ខណៈវិជ្ជមានឡើងវិញ តែស្ថិតក្នុងភាពរអាក់រអួល ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពវៀតណាម ដណ្ដើមបានជ័យជម្នះទាំងស្រុងលើកងទ័ពខ្មែរក្រហម នៅខែ មករា 1979 ។ កម្ពុជាត្រូវបានរំដោះ ប្រជាជនវិលត្រឡប់មកកាន់លំនៅឋានស្រុកទេសខ្លួនវិញ ។ ប៉ុន្តែកម្ពុជាមិនទាន់បានសន្តិភាព ពេញលេញទេ ។

មកដល់អំឡុងឆ្នាំ 1991-1993 ទើបស្ថានភាពតាមខេត្តនិងក្រុងនានាមានប្រក្រតីភាពឡើងវិញ ដោយសារកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃ 23 តុលា 1991 និងវត្តមានអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ(UNTAC) ។

ពីឆ្នាំ 1993 មកទល់សព្វថ្ងៃ ការងារនគរូបនីយកម្មជាភារកិច្ចស្នូលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ក្រសួងបានធ្វើការសិក្សាស្រាវជ្រាវរកប្លង់មេនគរូបនីយកម្ម គោលនយោបាយនិងនីតិវិធីសម្រាប់ដំណើរការកសាងរដ្ឋសីមា ព្រំប្រទល់តំបន់ ប្លង់គោលខេត្តក្រុងបានសហការជាមួយអាជ្ញាធរក្រុងនិងអង្គការកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP) រៀបចំទីតាំងថ្មីនៅក្រៅក្រុងដើម្បីធ្វើការផ្ទេរសំណង់អនាធិបតេយ្យចេញពីរាជធានីភ្នំពេញ ។ ការងារសាងសង់និងជួសជុលសំណង់គ្រប់ប្រភេទកើតមានឡើងគួរឱ្យកត់សម្គាល់នៅតាមទីក្រុងនិងទីប្រជុំជននានានៃព្រះរាជាណាចក្រកម្ពុជា ។ តែទន្ទឹមនឹងនេះ ក៏ឃើញលេចឡើងនូវបាតុភាពអនាធិបតេយ្យមួយចំនួនដូចជា ការពុំបានគោរពច្បាប់បទដ្ឋានបច្ចេកទេស ស្ថាបត្យកម្ម និងវិស្វកម្ម។ ដើម្បីពង្រឹងវិស័យនេះ ក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ បានចេញប្រកាសស្តីពីការគ្រប់ គ្រងសហគ្រាស ក្រុមហ៊ុន បានសិក្សាគម្រោងប្លង់សាងសង់ កំណត់បែបបទស្តីពីការសុំលិខិតអនុញ្ញាត សាងសង់ ធ្វើការផ្សព្វផ្សាយឯកសារគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងសំណង់ដល់មន្ត្រីទទួល ខុសត្រូវគ្រប់ខេត្តក្រុង ។ ចំពោះការចុះបញ្ជីដីធ្លីនិងការផ្តល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ក្រសួងបាន និងកំពុងជំរុញធ្វើឱ្យបានត្រឹមត្រូវនិងឆាប់រហ័ស ។ ក្រសួងបានចូលរួមជាមួយអាជ្ញាធរជាតិទទួលបន្ទុក កិច្ចការព្រំដែន ចុះពិនិត្យដល់កន្លែងកើតហេតុ និងចុះសិក្សាស្រាវជ្រាវតាមបណ្តោយព្រំដែនដើម្បីរៀបចំឯកសារសម្រាប់ប្រជុំពិភាក្សារឿងការងាររដ្ឋសីមានិងការបោះបង្គោលព្រំដែនរដ្ឋ ។ ក្រៅពីនេះក្រសួងបានកសាងឯកសារមូលដ្ឋានសម្រាប់រៀបចំដែនដី កសាងបទបញ្ញត្តិនគរូបនីយកម្ម ជំរុញការកសាងប្លង់ រៀបចំដែនដី ការអភិវឌ្ឍខេត្ត-ក្រុង ពិសេសក្រុងភ្នំពេញ ខេត្តព្រះសីហនុ សៀមរាប កំពង់ចាម បាត់ដំបង និងរៀបចំប្លង់ប្រើប្រាស់ដីធ្លីបម្រើឱ្យឧស្សាហកម្មកែច្នៃ តាមបណ្តោយផ្លូវជាតិលេខ 3 និងលេខ 4 សម្រាប់ការនាំចេញ រៀបចំប្លង់គោលខេត្ត-ក្រុងទាំងអស់និងតំបន់ព្រំដែនក៏ដូចជាតំបន់ទេសចរសំខាន់ៗ ពង្រឹងការងារសំណង់ ដាក់ពិន័យសំណង់ខុសប្លង់ខុសច្បាប់ និងធ្វើឯកភាវូបនីយកម្មការងារសុរិយោដីនិងភូមិសាស្ត្រនៅទូទាំងប្រទេស ។

## 4. នគរូបនីយកម្មនៅកម្ពុជានាពេលអនាគត

គោលនយោបាយដីធ្លី ជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលជាភារកិច្ចស្នូលរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គោលនយោបាយដីធ្លីជារួមមាន រដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី។

រដ្ឋបាលដីធ្លី គឺជាប្រព័ន្ធមួយដែលអនុវត្តដោយរដ្ឋដើម្បីគ្រប់គ្រងសិទ្ធិទាំងឡាយលើដីធ្លី ដែលមានជាអាទិ៍ ដំណើរការកត់ត្រានិងចុះបញ្ជីសិទ្ធិស្របច្បាប់លើទ្រព្យ កត់ត្រា ចុះបញ្ជី និងផ្សព្វផ្សាយការផ្ទេរសិទ្ធិទាំងឡាយលើទ្រព្យ គ្រប់គ្រងសារពើពន្ធពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យ និងគ្រប់គ្រងទ្រព្យរដ្ឋ។

ការរៀបចំដែនដី គឺជាប្រព័ន្ធមួយដែលអនុវត្តដោយរដ្ឋដើម្បីគ្រប់គ្រងការប្រើប្រាស់ធនធានដី បញ្ហាសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ដែលទាក់ទងទៅនឹងការបែងចែកដីធ្លី។

ការបែងចែកដីធ្លីមានចំណងដ៏រឹងមាំរវាងភាពគ្មានដីនិងភាពក្រីក្រ ដូចនេះ ការបែងចែកដីធ្លីនឹងនាំទៅរកការកាត់បន្ថយភាពក្រីក្រដោយផ្ទាល់ អាចឱ្យគេប្រើប្រាស់ដីនិងកម្លាំងពលកម្មដែលនៅទំនេរប្រកបដោយប្រសិទ្ធភាព(កំណើនសេដ្ឋកិច្ច) រួមចំណែកក្នុងការកាត់បន្ថយវិវាទដីធ្លី កាត់បន្ថយបន្ទុកផ្នែករដ្ឋបាលនិងតុលាការ និងធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងសង្គមនៅថ្នាក់មូលដ្ឋាន។

ផែនការប្រើប្រាស់ដីធ្លីសម្រាប់តំបន់ខ្លះនៅក្នុងប្រទេស ត្រូវរៀបចំជាបន្ទាន់។ តំបន់ទាំងនោះមានតំបន់ទេសចរណ៍ ដែលមានការអភិវឌ្ឍឆាប់រហ័សដូចជា ភ្នំគូលែន បូកគោ គិរីរម្យ បានលុងតំបន់ឆ្នេរ តំបន់ព្រំប្រទល់អូរស្មាច់ ប៉ោយប៉ែត កោះកុង ប៉ៃលិន...។ ផែនការប្រើប្រាស់ដីសម្រាប់ក្រុងភ្នំពេញគឺជាអាទិភាពមួយ ក៏ដូចជាច្រកព្រំដែនតាមបណ្ដោយផ្លូវជាតិដែរ។ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ នឹងដឹកនាំការរៀបចំផែនការទាំងនេះជាមួយអាជ្ញាធរមូលដ្ឋានតាមរយៈដំណាក់ការនានារួមមាន ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ការប្រមូលទិន្នន័យមូលដ្ឋានពីរូបថតថតពីលើអាកាសនិងរូបភាពពីផ្កាយរណបដោយធ្វើការងារនៅការដ្ឋានផ្ទាល់ ធ្វើការវាស់វែង និងធ្វើការប៉ាន់ប្រមាណសង្គមសេដ្ឋកិច្ច ប្រជាសាស្ត្រ និងសេដ្ឋកិច្ច។

### ? សំណួរ

1. ចូរកំណត់ន័យនៃពាក្យ "នគរូបនីយកម្ម"។
2. ចូរបង្ហាញថា ដូនតាយើងជំនាន់ដើម មានទេពកោសល្យខ្ពស់លើការងារនគរូបនីយកម្ម។
3. ហេតុអ្វីបានជានគរូបនីយកម្មនៅកម្ពុជាឈប់ដំណើរការ ចាប់ពីដំណាច់ទសវត្សរ៍ឆ្នាំ 1960មក ?
4. ហេតុអ្វីបានជាគេនិយាយថា នគរូបនីយកម្មសម័យខ្មែរក្រហមមានលក្ខណៈបញ្ច្រាសទិស ?
5. ចូរនិយាយអំពីសារៈសំខាន់នៃការអនុវត្តគោលនយោបាយបែងចែកដីធ្លីនៅកម្ពុជា។

មេរៀនទី

# 2 សេដ្ឋកិច្ចតំបន់និងការបែងចែកប្រភេទខេត្តក្រុង

**ចប់មេរៀននេះ សិស្សអាច**

- បកស្រាយបានពីសេដ្ឋកិច្ចតំបន់និងការបែងចែកប្រភេទខេត្ត-ក្រុង
- បង្ហាញពីសក្តានុភាពសេដ្ឋកិច្ចនៃឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍ ។

សេដ្ឋកិច្ចតំបន់ គឺជាសកម្មភាពផលិតកម្មនិងសេវាកម្មនានា ដែលកើតមានដោយផ្ទាល់នៅតាមតំបន់នីមួយៗ ។ ទម្រង់សេដ្ឋកិច្ច កម្លាំងផលិតកម្ម និងការអភិវឌ្ឍក្នុងតំបន់ទាំងនោះមានប្លែកៗគ្នា តែងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការរស់នៅរបស់ប្រជាជន ហើយដែលគេអាចមើលឃើញច្បាស់តាមរយៈការប្រើប្រាស់គ្រឿងសម្ភារៈរបបអាហារប្រចាំថ្ងៃ និងរូបសណ្ឋានផ្ទះសំបែងភូមិឋាន ។ កម្លាំងសេដ្ឋកិច្ចតែងទាក់ទាញប្រជាជនកាន់តែច្រើនឱ្យចូលទៅរស់នៅតំបន់នោះ ។ យោលទៅតាមទម្រង់នៃកម្លាំងសេដ្ឋកិច្ចនិងចំនួនប្រជាជន គេអាចកំណត់តំបន់រីកចម្រើនខ្លាំង ឬបង្គួរ ឬមួយមធ្យម ឬមួយអន់ថយបាន ។

តើការបែងចែកប្រភេទខេត្ត-ក្រុងនៅកម្ពុជា អាចប្រព្រឹត្តទៅបានយ៉ាងដូចម្តេច ?

## 1. សេដ្ឋកិច្ចតំបន់

សេដ្ឋកិច្ចមូលដ្ឋាននៃតំបន់មួយចំនួននៅកម្ពុជាផ្សារភ្ជាប់ទៅនឹងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ ។ ប្រជាជនភាគច្រើនរស់នៅប្រមូលផ្តុំគ្នាក្នុងតំបន់ដែលអាចដាំស្រូវបាន ។ តំបន់ទាំងនោះស្ថិតនៅភាគកណ្តាលប្រទេសគឺទំនាបកណ្តាលកម្ពុជា រួមមានតំបន់ទន្លេសាប តំបន់វាលរាប និងតំបន់ខ្លះនៃខេត្តកំពតនិងកំពង់ស្ពឺ ។ ក្រៅពីដំណាំស្រូវ តំបន់ទាំងនោះនៅមានសារៈសំខាន់សេដ្ឋកិច្ចផ្សេងៗទៀតដូចជា ការនេសាទតាមប្រព័ន្ធទន្លេសាបនិងទន្លេមេគង្គ ដំណាំចម្ការតាមដងទន្លេមានឈើហូបផ្លែនិងបន្លែបង្ការច្រើនមុខ គមនាគមន៍និងការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស ពាណិជ្ជកម្មតាមទីផ្សារនៅទីក្រុង ទីប្រជុំជន ក្រុមហ៊ុននាំចេញនាំចូល និងទេសចរណ៍តាមរមណីយដ្ឋាននានាដ៏សំបូរបែប ។ និយាយរួម ទំនាបកណ្តាលជាមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់បំផុត ។

តាមប្រវត្តិនគរូបនីយកម្ម ទីក្រុងភាគច្រើននៅកម្ពុជាត្រូវបានបង្កើតឡើងសម្រាប់ដំណើរការផ្នែករដ្ឋបាលនិងពាណិជ្ជកម្ម។ ក្រុងនៅតាមខេត្តចំនួន 20 និងកំពង់ផែនានាត្រូវបានពួកបារាំងជ្រើសរើសសម្រាប់បម្រើការងារផ្នែករដ្ឋបាល(អប់រំ នគរបាល ពន្ធដារ ...) និងជាហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ពួកគេ។ ផ្លូវថ្នល់ទាំងឡាយដែលតភ្ជាប់ពីរាជធានីភ្នំពេញទៅទីរួមខេត្តនិងតំបន់មាត់សមុទ្រកសាងឡើងសម្រាប់បម្រើឱ្យការត្រួតត្រា តាបសង្កត់របស់ពួកអាណានិគមមកលើប្រជារាស្ត្រខ្មែរ និងបម្រើឱ្យដំណើរការសេដ្ឋកិច្ចអាណានិគម ច្រើនជាងបម្រើផលប្រយោជន៍ដល់ប្រទេសកម្ពុជា។

បច្ចុប្បន្ន សេដ្ឋកិច្ចតាមខេត្តមួយភាគធំនៅតែមានលក្ខណៈជាសេដ្ឋកិច្ចចិញ្ចឹមពោះ ម្ល៉ោះហើយបរិមាណផលដែលប្រមូលបានមានកម្រិតទាប។ ដូចនេះ ដើម្បីបំពេញការបង្គ្រប់ជីវភាព កសិករត្រូវប្រកបរបរជួញដូរបន្តិចបន្តួចនៅតាមទីផ្សារដែលស្ថិតនៅតាមបណ្តោយផ្លូវថ្នល់សំខាន់ៗ។ គេសង្កេតឃើញមានឃ្លាំងផ្ទុកទំនិញនិងមជ្ឈមណ្ឌលឧស្សាហកម្មស្ថិតនៅតាមបណ្តោយផ្លូវដឹកជញ្ជូន ដែលភាគច្រើននៅក្នុងខេត្តតែម្តង។ ទន្ទឹមនឹងនេះ ចម្ការដំណាំនិងឧស្សាហកម្មមួយចំនួនមានទំនាក់ទំនងផ្ទាល់ជាមួយក្រុងភ្នំពេញ តែមានតិចតួចបំផុតជាមួយខេត្តនានា។ តាមពិត កម្លាំងមជ្ឈមណ្ឌលសេដ្ឋកិច្ចតាមខេត្តត្រូវពឹងផ្អែកលើមុខងាររដ្ឋបាលដែលជាទីស្នាក់ការនៃរដ្ឋអំណាច។ ដូចនេះ មានតែរដ្ឋាភិបាលទេទើបអាចជួយសង្គ្រោះសេដ្ឋកិច្ចតាមខេត្តដែលទន់ខ្សោយឱ្យរីកចម្រើនបានតាមមធ្យោបាយសមស្របមួយចំនួនដូចជា បើកទូលាយដល់វិនិយោគទុន តម្រង់ទិសវិនិយោគទុនឆ្ពោះទៅកាន់ខេត្តដែលអនុគ្រោះបំផុត ធានារ៉ាប់រងក្នុងការជួយរក្សាសុវត្ថិភាពទុនវិនិយោគជាដើម។

## 2. ប្រភេទខេត្តក្រុង

សេដ្ឋកិច្ចខេត្ត-ក្រុងទាំងអស់នៅកម្ពុជាមានលក្ខណៈខុសប្លែកគ្នាទាំងទិដ្ឋភាពនិងសកម្មភាព។ ទីក្រុងខុសប្លែកពីទីរួមខេត្ត ព្រោះមានសកម្មភាពមមាញឹកខាងឧស្សាហកម្ម ពាណិជ្ជកម្ម នយោបាយរដ្ឋបាល និងសិក្សាធិការ ។ល។ ទីក្រុងនិងខេត្តតែងមានទំនាក់ទំនងគ្នាទៅវិញទៅមក គឺទីក្រុង បម្រើខេត្តដោយផ្តល់មុខទំនិញសព្វបែបយ៉ាង ពិសេសផលិតផលឧស្សាហកម្មនិងសេវាកម្មទៅឱ្យខេត្ត។ ចំណែកខេត្តវិញបម្រើទីក្រុងដោយផ្តល់ផលិតផលកសិកម្មសំខាន់ជាច្រើន(ដើមនៅឯស្រែផ្លែនៅឯក្រុង) និងកម្លាំងពលកម្មដល់ទីក្រុង ជាពិសេសនៅពេលទីក្រុងមានការលូតលាស់ខ្លាំង។ ការផ្តល់ ពលករបង្កើតបានជាចលនាបំលាស់លំនៅហៅថា "ចំណាកស្រុកស្រែ"។ បើបម្លាស់លំនៅនេះមានច្រើនសន្ធឹកសន្ធាប់និងមិនវិលត្រឡប់វិញនឹងបង្កើតឱ្យមានបាតុភូតមួយហៅថា "ចំណោលស្រុកស្រែ"។

គេអាចរៀបចំឋានានុក្រមខេត្ត-ក្រុងទាំង 24 នៅកម្ពុជាជា 7 ប្រភេទដាច់ដោយឡែកពីគ្នាដោយផ្អែកលើសារៈសំខាន់សេដ្ឋកិច្ច និងចំនួនប្រជាជន។

## 2.1. ខេត្ត-ក្រុងប្រភេទទី ១

ខេត្តក្រុងទាំងឡាយណាដែលមានសេដ្ឋកិច្ចរឹងមាំនិងមានចំនួនប្រជាជនច្រើនជាងគេ ត្រូវបានចាត់ទុកថាជាខេត្តក្រុងប្រភេទទី ១ ។ ខេត្តកំពង់ចាមនិងក្រុងភ្នំពេញអាចស្ថិតក្នុងចំណាត់ថ្នាក់នេះ ព្រោះមានសេដ្ឋកិច្ចរឹងមាំ ជាមជ្ឈមណ្ឌលទាក់ទាញខ្ពស់ខាងសេដ្ឋកិច្ច (វិនិយោគទុនជាតិនិងអន្តរជាតិ) និងមានប្រជាជនច្រើនជាងគេ(កំពង់ចាម 1 676 992 នាក់ ភ្នំពេញ 1 327 615 នាក់ ឆ្នាំ 2008) ។



*ក្រុងភ្នំពេញ*

## 2.2. ខេត្តរឹងមាំ

ខេត្តរឹងមាំ គឺខេត្តទាំងឡាយណាដែលមានសេដ្ឋកិច្ចរីកលូតលាស់ខ្លាំងក្លា និងមានប្រជាជនច្រើន ។ ការសិក្សាស្រាវជ្រាវមួយអាចបញ្ជាក់បានថា ខេត្តកំពង់ចាម កណ្តាល និងបាត់ដំបងត្រូវទទួលបានចំណាត់ថ្នាក់នេះ ។

ខេត្តកំពង់ចាមមានប្រជាជនច្រើនជាងគេក្នុងបណ្តាខេត្តក្រុងទាំងអស់នៅទូទាំងប្រទេស គឺ 1 679 992 នាក់ ក្នុងចំនួននេះបុរសមាន 818 662 នាក់ ស្ត្រីមាន 861 330 នាក់ គិតជាអត្រាភេទមាន 95% និងទំហំគ្រួសារមធ្យមមាន 4.5 នាក់(ឆ្នាំ 2008) ។ ខេត្តកំពង់ចាមមានឧស្សាហកម្មធុនតូចនិងសិប្បកម្មចំនួន 3 213 កន្លែង មានផ្ទៃដីដាំស្រូវចំនួន 200 374 ហិចតា និងផ្ទៃដីប្រមូលផល 197 243 ហិចតា គិតជាទិន្នផលមធ្យមមាន 2.34 ត/ហិចតា ។ ក្រៅពីដំណាំស្រូវខេត្តកំពង់ចាមនៅមានដំណាំកៅស៊ូ ថ្នាំជក់ ពោត សណ្តែកសៀង ដំឡូងមី ...ទៀត ។

ខេត្តកណ្តាលមានប្រជាជនច្រើនបន្ទាប់ពីខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ គឺមានចំនួន 1 265 280 នាក់ ក្នុងនោះបុរសមាន 612 692 នាក់ ស្ត្រីមាន 652 588 នាក់ គិតជាអត្រាភេទមាន 93.9% និងមានទំហំគ្រួសារមធ្យម 4.9 នាក់(ឆ្នាំ 2008) ។ ខេត្តកណ្តាលមានឧស្សាហកម្មធុនតូចនិងសិប្បកម្មចំនួន

1 193 កន្លែង មានផ្ទៃដីដាំស្រូវ 91 523 ហិចតា ផ្ទៃដីប្រមូលផល 89 674 ហិចតា និងទិន្នផលមធ្យម 2.81 ត/ហិចតា ។ ក្រៅពីដំណាំស្រូវគេឃើញមានដំណាំចម្ការដូចជា ពោត សណ្ដែក ល្ង ថ្នាំជក់ បន្លែ និងផ្លែឈើច្រើនមុខ ។ ការចិញ្ចឹមសត្វ របរឡើងត្នោត និងនេសាទក៏មានសារៈសំខាន់ណាស់ដែរ ។

ខេត្តបាត់ដំបងមានប្រជាជន 1 025 174 នាក់ ក្នុងនោះបុរសមាន 506 351 នាក់ ស្ត្រី 518 823 នាក់ គិតជាអត្រាភេទមាន 97.6% និងមានទំហំគ្រួសារមធ្យម 4.8 នាក់ ។ ខេត្តបាត់ដំបងមានឧស្សាហកម្មតូច និងសិប្បកម្ម 1 031 កន្លែង ។ ទឹកដីនេះត្រូវបានគេទទួលស្គាល់ជាទូទៅថា ជា " ជង្រុកស្រូវ " នៃកម្ពុជា ព្រោះសេដ្ឋកិច្ចខេត្តបាត់ដំបងមានអំណោយផលខ្លាំងក្លាបំផុតក្នុងផលិតកម្មស្រូវ ។ ផ្ទៃដីប្រើប្រាស់សម្រាប់ផលិតផលស្រូវមានប្រហែល 240 000 ហិចតានិងមានការកើនឡើងជារៀងរាល់ឆ្នាំ ។ បរិមាណផលស្រូវដែលប្រមូលបានមានច្រើនជាង 500 000 តោន បញ្ចេញលក់បានប្រហែល 300 000 តោន ទាំងនៅលើទីផ្សារក្នុងស្រុកនិងក្រៅប្រទេស ។ ភោគផលដទៃទៀតរបស់ខេត្តមានជាពិសេស ផលផលនៃបឹងទន្លេសាប ពោតស ពោតក្រហម សណ្ដែកសៀង សណ្ដែកដី ឈើហូបផ្លែ(ក្រូចពោធិ៍សាត់ ដូងខ្ទិះ...) ដាំដុះលើផ្ទៃដីជិត 50 000 ហិចតា ។

## 2.3. ខេត្តក្រុងផ្សារភ្ជាប់នឹងវិស័យទេសចរណ៍



*អង្គរវត្តក្នុងខេត្តសៀមរាប*

សព្វថ្ងៃខេត្តក្រុងដែលមានសកម្មភាពសេដ្ឋកិច្ចផ្សារភ្ជាប់វិស័យទេសចរមាន ខេត្តសៀមរាប ក្រុងភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តកណ្ដាល ។ ភ្ញៀវទេសចរបរទេសដែលបានមកដល់ទឹកដីអង្គរ(សៀមរាប) មានចំនួនកើនឡើងជាលំដាប់គឺ 561 000 នាក់ នៅឆ្នាំ 2004 និង 677 000 នាក់ នៅឆ្នាំ 2005 កើនបានជិត 50% នៃចំនួនភ្ញៀវទេសចរបរទេសដែលបានចូលមកលេងកម្សាន្តនៅកម្ពុជា ជារៀងរាល់ឆ្នាំ ។ ក្រុងភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ជាមជ្ឈមណ្ឌលទេសចរដ៏ធំមួយ មានភ្ញៀវជាតិនិងអន្តរជាតិគ្រប់ផ្នែកចេញចូល ចុះឡើងយ៉ាងច្រើនជារៀងរាល់ថ្ងៃ ពិសេសភ្ញៀវទេសចរបរទេស ។

ដោយសារភាពសំបូររមណីយដ្ឋានធម្មជាតិ(ឆ្នេរខ្សាច់ ទឹកធ្លាក់ កោះ...)និងវត្តមាននៃកំពង់ផែសមុទ្រថ្នាក់អន្តរជាតិ ខេត្តព្រះសីហនុក៏ជាតំបន់ទេសចរណ៍មួយដ៏សំខាន់។ ភ្ញៀវទេសចរជាតិនិងបរទេស តែងទៅសម្រាកកម្សាន្តលំហែកាយនៅទីនោះ ពិសេសនៅថ្ងៃបុណ្យប្រពៃណីជាតិនិងបុណ្យអន្តរជាតិ រីឯខេត្តកណ្តាលវិញក៏មានរមណីយដ្ឋានល្អៗផ្ទាល់របស់ខ្លួនមួយចំនួនដែរដូចជា ភ្នំបាសិត ភ្នំអដ្ឋរស្ស(ឧដុង្គ) ស្ពានភ្នំ វត្តអង្គរជ័យ វត្តធនមន្ត វត្តវិហារសួគ៌...រមណីដ្ឋានគៀនស្វាយ កោះឧកញ៉ាតី កោះដាច់...។ កោះដាច់មានឆ្នេរខ្សាច់សក្បុស ជាកន្លែងទាក់ទាញភ្ញៀវទេសចរឱ្យមកលេងកម្សាន្ត។ កោះដាច់មានរមណីយដ្ឋានវប្បធម៌ដ៏វិសេសមួយទៀត គឺសិប្បកម្មតម្បាញហូល ផាមួង ចរបាប់ ក្រមា... ដែលបានបង្ហូតរាងកាយយ៉ាងសង្ហាលើទីផ្សារក្នុងស្រុក។ ភ្ញៀវទេសចរអាចចូលទៅទស្សនាស្នាដៃតម្បាញនេះដល់មូលដ្ឋានផ្ទាល់តែម្តងនិងអាចទិញទុកជាវត្ថុអនុស្សាវរីយ៍ទៀតផង។

## 2.4. ខេត្តក្រុងផ្សារភ្ជាប់នឹងសកម្មភាពកំពង់ផែ

ខេត្តព្រះសីហនុមានកំពង់ផែសមុទ្រដ៏ធំមួយ ជាកំពង់ផែថ្នាក់អន្តរជាតិ ដែលអាចឱ្យនាវាសមុទ្រតូចធំចេញចូលចតបានគ្រប់ពេល បានដាក់ឱ្យប្រើប្រាស់តាំងពីឆ្នាំ 1960 មកម្ល៉េះ គឺកំពង់ផែព្រះសីហនុ។ កំពង់ផែនេះជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ព្រោះអាចធានារ៉ាប់រងបាននូវការនាំចេញនិងការនាំចូលសំដៅលើកស្ទួយជីវភាពប្រជាជន។

ខេត្តកោះកុងក៏មានកំពង់ផែសមុទ្រមួយដែរនៅក្រុងខេមរភូមិន្ទសម្រាប់ដឹកជញ្ជូនអ្នកដំណើរនិងទំនិញទៅមកភ្ជាប់ទៅក្រុងព្រះសីហនុ។ សព្វថ្ងៃកំពង់ផែនេះនៅមានសកម្មភាពដឹកជញ្ជូនជាបន្ទាប់បន្សំនៅឡើយ ដោយសារដំណើរតាមផ្លូវថ្នល់ជាតិលេខ 48 មានលក្ខណៈងាយស្រួលជាង។

កំពង់ផែភ្នំពេញមានសកម្មភាពមមាញឹកជាងគេ ក្នុងចំណោមកំពង់ផែនានាតាមដងទន្លេមេគង្គនិងប្រព័ន្ធទន្លេសាប ព្រោះជាកំពង់ផែទន្លេផងនិងជាកំពង់ផែសមុទ្រផង។ នាវាសមុទ្រធុនមធ្យមអាចចេញចូលកំពង់ផែនេះបានគ្រប់រដូវ តាមទន្លេមេគង្គក្រោម។

ខេត្តកំពង់ចាមមានកំពង់ផែសំខាន់មួយ បន្ទាប់ពីកំពង់ផែក្រុងភ្នំពេញ ដែលមានមាត់ច្រាំងសម្រាប់ចូលចតប្រវែង 3km មានសកម្មភាពច្រើន ដោយសារសេដ្ឋកិច្ចខេត្តរីកចម្រើន។ នៅទល់មុខក្រុងកំពង់ចាម មានកំពង់ផែមួយទៀត គឺកំពង់ផែទន្លេបិទ ក៏មានសកម្មភាពខ្លាំងក្លាណាស់ដែរ ព្រោះនៅរដូវទឹកដំឡើងម្តងៗមានកប៉ាល់ដឹកជ័រកៅស៊ូ ចេញចូលមិនឈប់ឈរ។

កំពង់ផែខេត្តសៀមរាបមានសកម្មភាពដឹកជញ្ជូនអ្នកដំណើរ ទំនិញ និងភ្ញៀវទេសចរ ទទួលរងនូវការប្រកួតប្រជែងពីការដឹកជញ្ជូនតាមផ្លូវថ្នល់ជាតិលេខ 6 ដែលបានសាងសង់ឡើងវិញរួចហើយ។

ក្រៅពីនេះកំពង់ផែទន្លេផ្សេងៗទៀតមាន កំពង់ផែក្រុងកំពង់ឆ្នាំង កំពង់ផែក្រុងក្រចេះ កំពង់ផែក្រុងស្ទឹងត្រែង ... ។ នាវាចរណ៍ពីក្រុងក្រចេះទៅក្រុងស្ទឹងត្រែងមានលក្ខណៈងាយស្រួលតែនៅរដូវទឹកជំនោរឡើង ។ នៅរដូវទឹកស្រក នាវាចរត្រូវរំខានដោយទឹកជ្រោះនៅស្រុកសម្បូណ៌ ។

## 2.5. ខេត្តផ្សារភ្ជាប់នឹងសេដ្ឋកិច្ចព្រំដែន



*ច្រកទ្វារប៉ោយប៉ែត*

ប្រទេសកម្ពុជាមានទីតាំងភូមិសាស្ត្រជាប់ជាមួយប្រទេសវៀតណាម ឡាវ និងថៃ ។ ជាទូទៅខេត្តដែលស្ថិតនៅតាមព្រំដែនតែងមានទំនាក់ទំនងពាណិជ្ជកម្មស្របច្បាប់និងមិនស្របច្បាប់ ជាមួយប្រទេសទាំងនោះ ដែលអាចជួយឱ្យខេត្តមានកំណើនសេដ្ឋកិច្ចបាន ។ ទំនាក់ទំនងពាណិជ្ជកម្មប្រព្រឹត្តទៅតាមច្រករបៀងដែលបើកជាផ្លូវការតាមកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលមានដូចជា ច្រកចាំយាម (កោះកុង) ច្រកផ្សារព្រំ(ប៉ៃលិន) ច្រកប៉ោយប៉ែត(បន្ទាយមានជ័យ) ច្រកអូរស្មាច់(ឧត្តរមានជ័យ) ច្រកបាវិត(ស្វាយរៀង) ច្រកភ្នំដិន(តាកែវ) ច្រកជ្រៃធំនិងក្អមសំណ(កណ្ដាល)... ។ ច្រកព្រំដែនតូចៗដទៃទៀតមាន ច្រកសំពៅលូន(បាត់ដំបង) ច្រកដាក់ដាំ(មណ្ឌលគិរី) ច្រកអូរយ៉ាដាវ(រតនគិរី) ច្រកត្រពាំងផ្លុង(កំពង់ចាម)... ។ កំណើនពាណិជ្ជកម្មតាមខេត្តកាន់តែមានលក្ខណៈប្រសើរឡើងក្រោយពេលផ្លូវថ្នល់អន្តរជាតិបាងកក-ភ្នំពេញ-ហូជីមិញស្ថាបនារួច ហើយកាន់តែត្រូវបានពង្រឹងដោយសំណង់ផ្លូវដែកភ្ជាប់រដ្ឋធានីសិង្ហបុរីទៅគុនមិញ ខេត្តយូណាន់(ចិន) កាត់តាមទីក្រុងកូឡាឡាំពួរ បាងកក ភ្នំពេញ ហូជីមិញ និងហាណូយ ។

### 2.6. ខេត្តដែលមានកម្លាំងសេដ្ឋកិច្ចខ្សោយ

ខេត្តមួយចំនួននៅកម្ពុជាមានសកម្មភាពឧស្សាហកម្មនិងពាណិជ្ជកម្មនៅទន់ខ្សោយ ។ ខេត្តបែបនេះមានសក្តានុភាពនៃកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលខ្លីនៅទាបដូចជា ខេត្តតាកែវ ព្រៃវែង កំពត កំពង់ឆ្នាំង និងកំពង់ធំ ។ បើនិយាយពីដង់ស៊ីតេមធ្យមនៃប្រជាជនតាមខេត្តទាំងនោះវិញឃើញថា ខេត្តតាកែវមានដង់ស៊ីតេខ្ពស់ជាងគេ (237 នាក់/$km^2$) បន្ទាប់មកគឺខេត្តព្រៃវែង (194 នាក់/$km^2$) ខេត្តកំពត (120 នាក់/$km^2$) ខេត្តកំពង់ឆ្នាំង (85 នាក់/$km^2$) និងខេត្តកំពង់ធំ (61 នាក់/$km^2$) ។ តើដង់ស៊ីតេប្រជាជនអាចជះឥទ្ធិពលទៅលើការអភិវឌ្ឍសេដ្ឋកិច្ចខេត្តដែរឬទេ ? មែនហើយ ក្នុងផ្នែកសេដ្ឋកិច្ច ក្រៅពីធនធានជាមាសប្រាក់ គ្រឿងសម្ភារៈ ធនធានមនុស្សជាកត្តារុញច្រានសេដ្ឋកិច្ចដែលមិនអាចខ្វះបាន ។

### 2.7. ខេត្តដាច់ស្រយាល

ខេត្តទាំងឡាយណាដែលស្ថិតនៅឆ្ងាយៗពីរាជធានី ជាប់ព្រំដែនប្រទេសជិតខាង ឆ្ងាយពីផ្លូវពាណិជ្ជកម្ម ពីហេដ្ឋារចនាសម្ព័ន្ធទំនើប ពិសេសមានប្រជាជនរស់នៅតិច និងមានសកម្មភាពសេដ្ឋកិច្ចខ្សោយ គឺជាប្រភេទខេត្តដាច់ស្រយាល ។ ខេត្តប្រភេទនេះច្រើនស្ថិតនៅភូមិភាគខាងជើង ខាងកើត និងឦសានប្រទេស ជាប់ព្រំដែនប្រទេសថៃ ឡាវ និងវៀតណាម ដូចជាខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងក្រចេះ ។ តំបន់ដាច់ស្រយាលទាំងនោះលាតសន្ធឹងលើផ្ទៃដីជាង 60 ពាន់ $km^2$ មានប្រជាជនសរុបជាង 800 ពាន់នាក់ គិតជាដង់ស៊ីតេប្រជាជនមធ្យមមាន 13.32 នាក់/$km^2$ ។ ទោះបីមានផ្លូវថ្នល់ជាតិភ្ជាប់ខេត្តដាច់ស្រយាលទាំងនោះមករាជធានីភ្នំពេញក៏ដោយ ក៏ហាក់ដូចជានៅតែដាច់ស្រយាលដដែល ព្រោះថាសកម្មភាពពាណិជ្ជកម្មក្តី សេវាកម្មដទៃទៀតក្តីនៅមិនទាន់មានភាពរស់រវើកនៅឡើយ ។

## 3. សក្តានុភាពតំបន់និងការផុសឡើងនៃប៉ូលកំណើន

តំបន់ទាំងឡាយនៅកម្ពុជា សុទ្ធតែមានសារៈសំខាន់សេដ្ឋកិច្ចដោយឡែកៗពីគ្នា ដែលបង្កើតបានជាសក្តានុភាពតំបន់ ។ ការទាញយកផលប្រយោជន៍ពីសក្តានុភាពតំបន់នីមួយៗ មានទិសដៅពិតប្រាកដគឺការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនិងការបង្កើតការងារជូនប្រជាជន ។ ទន្ទឹមនឹងនេះ ក៏បណ្តាលឱ្យមានការលេចឡើងនូវប៉ូលកំណើន(ប៉ូលសេដ្ឋកិច្ច) ។ គេអាចកំណត់បានថា ភ្នំពេញជាប៉ូលសេដ្ឋកិច្ចទី 1 ខេត្តព្រះសីហនុជាប៉ូលទី 2 និងសៀមរាបជាប៉ូលទី 3 ។

## ៣.1. ការវិនិយោគផ្នែកឧស្សាហកម្មនិងពាណិជ្ជកម្ម

នៅកម្ពុជា ការបណ្ដាក់ទុនលើវិស័យឧស្សាហកម្មនិងពាណិជ្ជកម្មបានចាប់ផ្ដើមតាំងពីដើមទសវត្សរ៍ឆ្នាំ 1990 ជាកត្តានាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចនិងជាប្រភពផ្ដល់ការងារជូនប្រជាជន ។ ប៉ុន្តែសកម្មភាពទាំងពីរផ្នែកនេះហាក់ដូចជានៅប្រមូលផ្ដុំគ្នានៅឡើយ ពិសេសនៅទីក្រុងភ្នំពេញនិងតំបន់ជិតខាងជុំវិញ ដែលបង្កើតបានជាប៉ូលកំណើនដ៏ធំបំផុតមួយនៅក្នុងប្រទេស ។

ការសិក្សាមួយស្ដីអំពីការអភិវឌ្ឍក្រុងឆ្នាំ 1995 បានបង្ហាញថា ការវិនិយោគទុនមានច្រើននៅភ្នំពេញ លើសបណ្ដាខេត្តក្រុងផ្សេងៗទៀតទាំងអស់ ។ ការវិនិយោគទុននៅទីក្រុងច្រើនមានលក្ខណៈសោភ័ណ ដូចជា ក្រុមហ៊ុននាំចូលនូវគ្រឿងសង្ហារិម គ្រឿងតុបតែងលំនៅឋាន គ្រឿងសំអាងកាយ ក្រុមហ៊ុន សំណង់ផ្ទះល្វែង អគារខ្ពស់ៗ ភូមិគ្រឹះ បណ្ដាញលូបង្ហូរទឹកសំអុយ ទឹកម៉ាស៊ីន បណ្ដាញខ្សែអគ្គិសនី ជាដើម ។ ការវិនិយោគផ្នែកនេះទទួលបានជោគជ័យច្រើនជាងការវិនិយោគលើផ្នែកផ្សេងៗទៀតនៅតាមខេត្ត ព្រោះវាផ្ដល់ឥទ្ធិពលលើការប្រើប្រាស់កាន់តែច្រើន(ពេញនិយម) ។

## ៣.2. សក្ដានុភាពកសិកម្ម

តំបន់ដែលអនុគ្រោះខ្លាំងដល់ការងារស្រែចម្ការ និងតំបន់បញ្ចូលទឹកដែលអាចទាក់ទាញការធ្វើវិនិយោគនិងអាចបន្សល់ផលសម្រាប់កែច្នៃនិងនាំចេញ ។ ផ្ទៃដីដាំដុះស្រូវវស្សាកើនពី 1 709 925 ហិចតា (1993) ដល់ 1 915 592 ហិចតា(1999) ។ ផ្ទៃដីដាំស្រូវនៅរដូវប្រាំងកើនដល់ 248 683 ហិចតា (1998) ។ នៅឆ្នាំ 2007 ផ្ទៃដីដាំស្រូវសរុបមាន 2 585 905 ហិចតា ផលិតផលស្រូវឡើងដល់ 6 727 127 តោន គិត ជាទិន្នផលមធ្យមមាន 2.6ត/ហិចតា ។ ទិន្នផលស្រូវបានកើនឡើងជាលំដាប់ដោយសារការយល់ដឹងរបស់កសិករយើងក្នុងការធ្វើជម្រើសពូជ ការប្រើប្រាស់ជី បច្ចេកទេសដាំដុះ ការការពារនិងថែទាំ ។

ការពង្រីកការបញ្ចូលទឹកខ្នាតតូចនិងមធ្យម និងការបញ្ចូលទឹកបន្ថែមនៅដើមរដូវភ្លៀង អាចឱ្យគេពង្រីកផ្ទៃដីដាំដុះបាន 800 000 ហិចតា ដោយអង្គការកសិកម្មក្នុងស្រុក CEDAC ។ កិច្ចការនេះអាចជួយកសិករកម្ពុជាផលិតស្រូវបានប្រមាណ 12 ទៅ 13 លានតោនក្នុងមួយឆ្នាំ ដែលអាចធ្វើឱ្យកម្ពុជាក្លាយទៅជាប្រជាជាតិនាំស្រូវចេញយ៉ាងសំខាន់មួយក្នុងពិភពលោក ។

ដំណាំកៅស៊ូក៏ជាកសិផលមួយដ៏សំខាន់ ជាប្រភពផ្ដល់រូបិយប័ណ្ណ និងការងារជូនប្រជាជន ។ ប្រទេសកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការពង្រីកដំណាំកៅស៊ូ ព្រោះមាននៅសល់ដីក្រហមច្រើនសម្រាប់ដំណាំនេះ ។ ការចិញ្ចឹមសត្វ ក៏មានសារៈសំខាន់ណាស់ដែរនៅកម្ពុជាសព្វថ្ងៃ ទាំងដំណាំកៅស៊ូ ទាំងការចិញ្ចឹមសត្វ អ្វីដែលចាំបាច់នោះ គឺទុនវិនិយោគ ។

## ៣.៣. សក្តានុភាពផ្នែកទេសចរណ៍



ការទាញយកអត្ថប្រយោជន៍ពីផ្នែកទេសចរណ៍នៅកម្ពុជា មានលក្ខណៈអំណោយផលខ្ពស់ណាស់ ព្រោះប្រទេសយើងសំបូរភោគទ្រព្យទេសចរណ៍ធម្មជាតិ វប្បធម៌ប្រវត្តិសាស្ត្រ និងកែច្នៃ។ សារៈសំខាន់សេដ្ឋកិច្ចផ្នែកនេះគឺ ការបង្កើតការងារ ចំណូលរូបិយប័ណ្ណ និងពន្ធដារ។ ការធ្វើវិនិយោគទុនលើវិស័យនេះត្រូវបានទទួលការលើកទឹកចិត្តយ៉ាងខ្លាំងដូចជា ការសាងសង់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត ទីលានកូនគោល និងសេវាដឹកជញ្ជូន។ល។

ប្រទេសកម្ពុជាមានលទ្ធភាពច្រើនណាស់ក្នុងការពង្រីកឧស្សាហកម្មទេសចរណ៍។ បើពង្រីកបានកាន់តែប្រសើរ ភ្ញៀវទេសចរបរទេសចូលមកទស្សនាកម្ពុជា កាន់តែមានចំនួនច្រើនឡើង ហើយចំណូលថវិកាជាតិកាន់តែកើន ជីវភាពប្រជាជនកាន់តែត្រូវបានលើកកម្ពស់ សេដ្ឋកិច្ចជាតិកាន់តែត្រូវបានលើកស្ទួយ។

## ៣.៤. សារៈសំខាន់ផ្នែកការដឹកជញ្ជូន

ការដឹកជញ្ជូនជាសកម្មភាពមួយដើរតួនាទីយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ បើវិស័យនេះមានកម្រិតអភិវឌ្ឍន៍ទាប សង្គមសេដ្ឋកិច្ចរបស់ប្រទេសណាមួយនោះក៏មានដំណើរការលូតលាស់យឺតយ៉ាវដែរ។ នៅកម្ពុជា ទីក្រុងភ្នំពេញលេចធ្លោជាងគេលើផ្នែកដឹកជញ្ជូននេះ និង ត្រូវបានពង្រឹងដោយការកសាងហេដ្ឋារចនាសម្ព័ន្ធ។ បច្ចុប្បន្ននេះ ទីក្រុងភ្នំពេញជាទីបំបែកនៃផ្លូវគមនាគមន៍គ្រប់ប្រភេទទៅកាន់ទីក្រុងនៃខេត្តនានានៅកម្ពុជា ពិសេសផ្លូវជាតិ។ ទីក្រុងនៃខេត្ត ក៏ជាទីបំបែកនៃផ្លូវថ្នល់ខេត្តទៅកាន់ទីប្រជុំជនស្រុក ឃុំ តែច្រើនតែជាផ្លូវក្រាលក្រួសក្រហមនៅឡើយ សង្ឃឹមថា ទៅអនាគតផ្លូវទាំងនោះនឹងទទួលបានការរីកចម្រើន(ក្រាលកៅស៊ូ)។ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានស្នាដៃក្នុងការសាងសង់ផ្លូវថ្នល់ជាច្រើនខ្សែនិងស្ពានជាច្រើនកន្លែង សម្រួលដល់ការដឹកជញ្ជូនក្នុងស្រុកនិងទៅក្រៅប្រទេស។ ម្យ៉ាងទៀត ទីក្រុងភ្នំពេញបានទទួលផលយ៉ាងសំខាន់ពីយន្តបថអន្តរជាតិដែលភ្ជាប់ទីក្រុងបាងកក-ភ្នំពេញ-ហូជីមិញ ក្នុងនោះមានខេត្តដទៃទៀតដែរដូចជា ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងស្វាយរៀង។

## សំណួរ

1. ចូរកំណត់ន័យនៃពាក្យ "សេដ្ឋកិច្ចតំបន់"។
2. តើសេដ្ឋកិច្ចតំបន់ទំនាបកណ្ដាលកម្ពុជា រួមមានអ្វីខ្លះ ?
3. តើសេដ្ឋកិច្ចតាមខេត្តមួយចំនួនធំនៅកម្ពុជា មានលក្ខណៈដូចម្ដេច ?
4. តើគេបែងចែកប្រភេទខេត្តក្រុងនៅកម្ពុជា ដោយផ្អែកលើអ្វីខ្លះ ?
5. តើប្រទេសកម្ពុជាអាចមានសក្ដានុភាពសេដ្ឋកិច្ច លើផ្នែកអ្វីខ្លះ ?
6. តើសក្ដានុភាពផ្នែកកសិកម្មនៅកម្ពុជា មានយ៉ាងដូចម្ដេចខ្លះ ?
7. ចូរនិយាយអំពីសក្ដានុភាពផ្នែកទេសចរណ៍នៅកម្ពុជា។

មេរៀនទី

# 3 កំណើននគរូបនីយកម្មនិងបញ្ហាបរិស្ថាន

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់បានពីកង្វក់អាកាស ការរំខានដោយសំឡេង ប្រភេទកាកសំណល់ ការគ្រប់គ្រងកាកសំណល់ និងបញ្ហាទឹកជន់នៅប្រទេសកម្ពុជា ។

កំណើននគរូបនីយកម្ម គឺជាការរីកសាយនៃការរៀបចំ ការពង្រីក និងការបង្កបង្កើតទីក្រុង ។ កំណើននេះមានកម្រិតខ្ពស់ណាស់នៅកម្ពុជា ។ បច្ចុប្បន្នប្រជាជនក្រុងបានកើនក្នុងអត្រាពី 18.2% ទៅ 19.5% (ជំរឿន 2008) ។ កំណើនខ្ពស់នៃប្រជាជនក្រុងតម្រូវឱ្យមានការកែលម្អបរិស្ថានក្រុង ។ ទន្ទឹមនឹងនេះក៏បង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានដែរ ។ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននៅទីក្រុងហួសសម័យ (ក្រោមកម្រិតមុនឆ្នាំ 1970) មិនគ្រប់គ្រាន់ដើម្បីឆ្លើយតបតាមសំណូមពរដែលកាន់តែធំឡើងៗបានឡើយ ។ ហេដ្ឋារចនាសម្ព័ន្ធចាស់ពេកនិងកំណើនសំណង់លំនៅដ្ឋាន ពិសេសសំណង់អនាធិបតេយ្យបណ្ដាលឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ។

តើបញ្ហាទាំងនោះមានអ្វីខ្លះ ? ហើយតើរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ដោះស្រាយសម្រេចបានស្នាដៃយ៉ាងដូចម្ដេចខ្លះ ?

## 1. កង្វក់អាកាស

កង្វក់អាកាសនៅទីក្រុងបណ្ដាលមកពីធូលី ដែលពាក់ព័ន្ធនិងថ្នល់មិនទាន់ក្រាលកៅស៊ូ និងផ្សែងដែលពាក់ព័ន្ធនឹងម៉ាស៊ីនភ្លើងនិងយានយន្តគ្រប់ប្រភេទ ។ ប្រភពមួយទៀតនៃកង្វក់អាកាស គឺក្លិនអសោចិ៍ដែលភាយចេញពីសំរាមស្អុយរលួយតាមចិញ្ចើមថ្នល់ ភាយចេញពីមាត់លូទឹកស្អុយ និងពីស្ថានីយបូមទឹកស្អុយ ។ សហគ្រាសឧស្សាហកម្មនៅតាមទីក្រុងច្រើនតែប្រើប្រាស់គ្រឿងបរិក្ខារចាស់ ហើយគ្មានការត្រួតពិនិត្យផ្នែកបរិស្ថានដូចជា យានដ្ឋានជួសជុលរថយន្ត ផលិតកម្មស្បែកជើង ថ្នាំលាបដី ថ្មពិល សាប៊ូ... ដែលបានបំភាយឧស្ម័នពុលយ៉ាងច្រើនទៅក្នុងអាកាស ។ សព្វថ្ងៃនេះ ផ្លូវថ្នល់នៅទីក្រុងភ្នំពេញនិងទីក្រុងដទៃទៀតមួយចំនួនធំនៅកម្ពុជា សុទ្ធតែចាក់កៅស៊ូ ។ បញ្ហាចំពោះមុខ គឺការថែទាំផ្លូវទាំងនោះដើម្បីប្រើប្រាស់បានយូរ និងកុំឱ្យធូលីហុយ ។ ចំពោះផ្សែងម៉ាស៊ីន ភ្លើង យានយន្ត

និងរោងចក្រខ្លះ គួរតែត្រូវបានត្រួតពិនិត្យ ផាកពិន័យ និងកែលម្អ។ អាជ្ញាធរក្រុងត្រូវ ជំរុញនិងបង្កើនសមត្ថភាពដឹកជញ្ជូនសំរាមឱ្យបានល្អជាងនេះដើម្បីចៀសវាងក្លិនអសោចិ៍។ ចំណែកក្លិនអសោចិ៍នៃទឹកសំអុយ គួរតែត្រូវបានអនុវត្តវិធីសាស្រ្ត ឬបច្ចេកទេសដកហូតក្លិនអសោចិ៍ ឬធ្វើប្រព្រឹត្តកម្មទឹកសំអុយជាមុនសិន មុននឹងបង្ហូរទៅកាន់ស្ទឹង ទន្លេ។ ដូចគ្នានេះដែរ ឧស្ម័នពុលចេញពីសហគ្រាសឧស្សាហកម្មត្រូវតែត្រួតពិនិត្យឱ្យបានដិតដល់ពីភ្នាក់ងារបរិស្ថានដោយសហការជាមួយអាជ្ញាធរដែនដី។

## 2. ការរំខានដោយសូរសំឡេង

ប្រភពសំខាន់ៗនៃការរំខានដោយសំឡេងនៅក្នុងទីក្រុងទាំងឡាយនៅកម្ពុជា ទាក់ទងនឹងម៉ាស៊ីនភ្លើងនិងយានយន្តគ្រប់ប្រភេទ ពិសេសភាពចំណាស់នៃគ្រឿងយន្តទាំងនោះ។ គ្រឿងម៉ាស៊ីនចាស់ៗតែងលាន់សូរខ្លាំងពេលធ្វើដំណើរការ ខុសពីគ្រឿងម៉ាស៊ីនថ្មីដែលផ្តល់ភាពស្ងាត់ល្អ។ គ្រឿងម៉ាស៊ីនចាស់ៗអាចធ្វើដំណើរការបានដោយមិនបញ្ចេញសូរស័ព្ទខ្លាំង ដរាបណាទទួលបានការត្រួតពិនិត្យ ឬជួសជុលត្រឹមត្រូវ។ កន្លងមក ផលិតកម្មនិងការចែកចាយថាមពលអគ្គិសនីរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មិនអាចបំពេញតម្រូវការជូនអតិថិជនក្នុងមជ្ឈដ្ឋានក្រុងបានគ្រប់គ្រាន់ទេ ដែលជាហេតុនាំឱ្យការប្រើប្រាស់ម៉ាស៊ីនភ្លើងតាមសណ្ឋាគារ ភោជនីយដ្ឋាន ការិយាល័យ និងតាមលំនៅឋានឯកជន។ សព្វថ្ងៃ ការបំពេញតម្រូវការខាងថាមពលអគ្គិសនីនៅតាមទីក្រុងមួយចំនួនជូនប្រជាជនហាក់ដូចជា មានភាពល្អប្រសើរជាងកាលកន្លងមកច្រើនណាស់ដោយសារការយកចិត្តទុកដាក់ផលិតថាមពលអគ្គិសនីក្នុងស្រុកនិងការនាំចូលថាមពលអគ្គិសនីពីវៀតណាមនិងថៃ។ ដូចនេះ ការប្រើប្រាស់ម៉ាស៊ីនភ្លើងក៏ត្រូវបានកាត់បន្ថយ ការរំខានដោយសូរសំឡេងនិងការបំពុលអាកាសដោយផ្សែង ក៏មិនសូវខ្លាំងក្លា។ ដោយភាពសំបូរផ្លូវទឹក កម្ពុជាគួរត្រូវបានទទួលការផ្គត់ផ្គង់អគ្គិសនីគ្រប់គ្រាន់និង លើសតម្រូវការថែមទៀតផង ។ វារីអគ្គិសនីជាថាមពលស្អាត មិននាំឱ្យប៉ះពាល់ដល់បរិស្ថានក្រុង ដូចអគ្គិសនីបានមកពីចំហេះឥន្ធនៈដទៃទៀតឡើយ។

ប្រភពផ្សេងៗទៀតនៃការរំខានដោយសំឡេងគឺ ការប្រើប្រាស់ឧបករណ៍សូរសព្ទក្នុងកម្រិតសំឡេងខ្ពស់ ពេលបុណ្យទាននិងពិធីផ្សេងៗ សំឡេងយន្តហោះចុះចត ឬហោះហើរចេញដំណើរពីព្រលានយន្តហោះ ពិសេសពីអាកាសយានដ្ឋានភ្នំពេញនិងសៀមរាប។

## ៣. ភាគសំណល់រាវនិងប្រព័ន្ធលូទឹកស្អុយ

នៅកម្ពុជាការគ្រប់គ្រងកាកសំណល់រាវមានជាបឋម គឺការបង្ហូរតាមបណ្តាញលូកប់ក្នុងដី ឬប្រឡាយ យកទៅស្តុកទុកក្នុងអាងដែលជាបឹងធម្មជាតិ។ បន្ទាប់មក គេបូមទឹកស្អុយទាំងនោះ ទម្លាក់ទៅក្នុងទន្លេនិងបឹងនានាដោយមិនបានធ្វើប្រព្រឹត្តកម្មទឹកសំអុយនោះជាមុនទេ។ នៅភ្នំពេញមានបណ្តាញលូបង្ហូរទឹកស្អុយ ស្ថានីយបូមទឹកចំនួន១ និងអាងស្តុកទឹកមួយចំនួនទៀតដូចជា បឹងត្របែក បឹងសាឡាង បឹងទំពុនដែលទើបតែត្រូវបានរៀបចំឡើងវិញសម្រាប់រំដោះទឹកចេញពីទីក្រុង សំដៅកាត់បន្ថយការលិចលង់លំនៅឋានអ្នកស្រុក ផ្លូវថ្នល់។ ក្រៅពីនេះ គេឃើញមានសំណង់អាងស្តុកទឹកមួយចំនួនទៀតដើម្បីរំដោះទឹកភ្លៀងចេញពីតំបន់ខ្លះដូចជា នៅមុខរដ្ឋសភាចាស់ជាដើម។ បន្ទាប់មកទើបគេបូមចេញពីអាងស្តុកទម្លាក់ទៅក្នុងទន្លេតែម្តង។



*ការរៀបចំប្រព័ន្ធលូ*

នៅទីក្រុងភ្នំពេញនិងក្រុងផ្សេងៗទៀត ពីមុនបញ្ហាប្រព័ន្ធលូបង្ហូរទឹកស្អុយនិងទឹកភ្លៀងបានចោទឡើង។ បណ្តាញលូជាច្រើនប្រើការលែងកើត ដោយសារភាពចាស់ទ្រុឌទ្រោមនិងកង្វះការថែទាំ។ លើសពីនេះទៅទៀត ស្ថានីយបូមទឹកខ្លះពុំមានដំណើរការ ដោយខ្វះគ្រឿងបន្លាស់ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីមិនបានល្អ។ ប្រព័ន្ធលូខូចខាត ទឹកភ្លៀងហូរមិនទាន់ ជូនខ្ទុរចេញពីមាត់លូហូរចូលលំនៅឋានលិចលង់ជាច្រើនថ្ងៃ នៅកន្លែងខ្លះនៃទីក្រុង។ ទឹកកខ្វក់អាចចូលលាយឡំជាមួយទឹកទទួលទាន បណ្តាលឱ្យកើតជំងឺតម្កាត់ផ្សេងៗដូចជា រាករូស អាសន្នរោគជាដើម។

ក្រសួងសាធារណការនិងដឹកជញ្ជូននិងសាលាក្រុង ជាអ្នកទទួលខុសត្រូវលើការប្រើប្រាស់ និងការថែទាំបណ្តាញលូទឹកស្អុយនិងទឹកភ្លៀងនៅទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗទៀតនៃប្រទេស ។ ប៉ុន្តែសមត្ថភាពបច្ចេកទេសនៅមានកម្រិត សម្ភារៈនិងគ្រឿងបន្លាស់មានមិនគ្រប់គ្រាន់ ម្ល៉ោះហើយប្រសិទ្ធភាពការងាររបស់ក្រសួងក៏ធ្លាក់ចុះ ។

ការប្រមូលទុកដាក់កាកសំណល់នៅទីក្រុងធំៗនៃប្រទេសកម្ពុជានៅតែជាបញ្ហាចម្បង ដែលអាជ្ញាធរក្រុងត្រូវប្រឈមមុខដោយសារតែកំណើនប្រជាជនក្រុង កំណើនឧស្សាហកម្ម និងភ្ញៀវទេសចរ ។ បញ្ហាខាងលើនេះ តម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំយុទ្ធសាស្ត្រកែលម្អការគ្រប់គ្រងកាកសំណល់ និងផ្តល់អាទិភាពឱ្យដល់ទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប ដែលជាមជ្ឈមណ្ឌលបីប្រកបដោយសក្តានុភាពសេដ្ឋកិច្ចខ្ពស់ ។

ជារួម បើធៀបទៅនឹងកាលពីមួយ ឬពីរទសវត្សរ៍មុនឃើញថា ការគ្រប់គ្រងកាកសំណល់នៅកម្ពុជាទទួលបានការអភិវឌ្ឍជាបន្តបន្ទាប់ដូចជា បណ្តាញលូចាស់តូចចង្អៀត ខូចខាតបែកបាក់ ត្រូវបានគាស់កាយយកចេញ ដាក់ជំនួសដោយបណ្តាញលូថ្មី មានទំហំធំជាងមុន ។ សំណង់អនាធិបតេយ្យត្រូវបានរំដោះចេញពីប្រឡាយនិងអាងស្តុកដើម្បីឱ្យចរន្តទឹកស្អុយហូរបានល្អ មិនបង្កការកកស្ទះ ។ ស្ថានីយបូមទឹកស្អុយក៏ទទួលបានកំណែលំអ និងបំពាក់គ្រឿងបរិក្ខារថ្មីៗមួយចំនួនជាបន្ថែមទៀត ។ បើការកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រភេទនេះនៅតែមានជាបន្ត នៅពេលអនាគតទីក្រុងភ្នំពេញក្តី ទីក្រុងដទៃទៀតក្តី នឹងមិនមានទឹកជំនន់លិចផ្លូវ លំនៅឋានក្នុងពេលមានភ្លៀងធ្លាក់ធំៗទៀតឡើយ ។



*ស្ថានីយបូមទឹកស្អុយនៅបឹងត្របែក*

## 4. ការគ្រប់គ្រងកាកសំណល់នៅទីក្រុង



*អ្នករស់នឹងគំនរសំរាម*

ការទុកដាក់កាកសំណល់នៅទីក្រុងចោទជាបញ្ហាបរិស្ថានចម្បងមួយ ដែលទីក្រុងនានាកំពុងតែប្រឈមមុខ ។ ទីក្រុងសំខាន់ៗនៃប្រទេសកម្ពុជា កំពុងជួបប្រទះកំណើនដ៏ឆាប់រហ័សនៃបរិមាណកាកសំណល់រឹង ចាប់ពីពេលចម្បាំងក្នុងស្រុកបានបញ្ចប់មក ។

សំណល់រឹងទាំងនោះ មានប្រភពចេញមកពីលំនៅឋាន ទីផ្សារ ហាងទំនិញ ភោជនីយដ្ឋាន សណ្ឋាគារ ការដ្ឋានសំណង់ រោងចក្រឧស្សាហកម្ម សិប្បកម្ម មន្ទីរពេទ្យ ការិយាល័យសាធារណៈ និងក្រុមហ៊ុននានា... ។ កាកសំណល់ទាំងនោះមានសារធាតុសរីរាង្គ (ដែលអាចបំបែកធាតុជីវៈបាន) សារធាតុប្លាស្ទិច កែវ និងលោហៈ ។ កាកសំណល់សរីរាង្គមិនសូវមានគ្រោះថ្នាក់ទេ តែកាកសំណល់ខ្លះទៀតបង្កគ្រោះថ្នាក់ខ្លាំង (កាកសំណល់ដែលមានប្រភពចេញពីឧស្សាហកម្ម មន្ទីរពេទ្យ...) ។ កាកសំណល់ទាំងអស់ ទោះជាប្រភេទណាក៏ដោយសុទ្ធតែនាំមកនូវផលប៉ះពាល់ដល់បរិស្ថាន បើមិនច្រើនក៏តិចតួចដែរ ។

ក្រុងភ្នំពេញ ក្រុងសៀមរាប និងក្រុងព្រះសីហនុ ដែលជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ទាំងបីនៅកម្ពុជាបច្ចុប្បន្ន មានកំណើនប្រជាជនខ្ពស់ រួមទាំងកំណើនសកម្មភាពឧស្សាហកម្ម សិប្បកម្ម និងទេសចរផង ។ កំណើនទាំងនេះនាំមកនូវកំណើនបរិមាណកាកសំណល់ជាប្រាកដ ។ បរិមាណកាកសំណល់នៅទីក្រុងភ្នំពេញនឹងកើនឡើងបីដង គឺពី 464 តោន/ថ្ងៃ នៅឆ្នាំ 1996 ដល់ 1409 តោន/ថ្ងៃ នៅឆ្នាំ 2010 ។ គេរំពឹងថា សំណល់រឹងនៅក្រុងសៀមរាបនិងក្រុងព្រះសីហនុ ស្ថិតនៅក្នុងបរិមាណតិចនៅឡើយ គឺប្រមាណ 47 តោន/ថ្ងៃនៅសៀមរាប និង 43 តោន/ថ្ងៃនៅក្រុងព្រះសីហនុ ។

នៅមុនពេលប្រគល់សិទ្ធិគ្រប់គ្រងសំរាមទៅក្រុមហ៊ុនឯកជនកាន់កាប់ (មករា 1996) ផ្នែកគ្រប់គ្រងសំរាមនៃមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញជាអ្នកទទួលខុសត្រូវក្នុងការប្រមូលនិងទុកដាក់សំរាមនៅទីក្រុងភ្នំពេញ ។ សាលាក្រុងបានប្រគល់សិទ្ធិផ្តាច់មុខឱ្យដល់ក្រុមហ៊ុនឯកជនមួយឈ្មោះ PPC ក្នុងការប្រមូលសំរាមសម្រាប់រយៈពេល 50 ឆ្នាំ ។ ក្រុមហ៊ុននេះមានភារកិច្ចផ្គត់ផ្គង់រថយន្តនិងសម្ភារៈផ្សេងៗដល់ក្រុមហ៊ុនទទួលសិទ្ធិផ្តាច់មុខបីទៀត ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការប្រមូលសំរាមនិងយកទៅចាក់ចោល ។ បច្ចុប្បន្ន យើងឃើញក្រុមហ៊ុន សិនទ្រី (CENTRI) កំពុងធ្វើប្រត្តិបត្តិការក្នុងរឿងនេះនៅទូទាំងរាជធានីភ្នំពេញ ។ ក្រុមហ៊ុននេះមានភ្នាក់ងារសម្អាតសំរាមតាមដងវិថីនានានៃទីក្រុងភ្នំពេញ និងភ្នាក់ងារប្រមូលសំរាមដាក់រថយន្ត យកទៅចាក់ចោលនៅទីលានចាក់សំរាមស្ទឹងមានជ័យ ។ ឥឡូវសកម្មភាពប្រមូលសំរាម ហាក់ដូចជាមានភាពទៀងទាត់គ្រាន់បើ បើពុំនោះសោតទេ សំរាមតាមលំនៅឋាននិងស្អុយរលួយ ហៀរទឹក ជះក្លិនអាក្រក់ ប៉ះពាល់ដល់បរិស្ថានក្រុងជាក់ជាមិនខាន ។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺរថយន្តដែលដឹកជញ្ជូនសំរាមមានទឹកលេចចេញ ហៀរកក្លិកក្លាក់តាមផ្លូវដែលមានចរាចរណ៍ច្រើន ចោលក្លិនមិនល្អដល់អ្នកដំណើរ ។ មន្ទីរសាធារណការនិងដឹកជញ្ជូន និងក្រុមហ៊ុនគួរមានវិធានការអនុវត្តចំពោះបញ្ហានេះ ព្រោះអាចនាំឱ្យប៉ះពាល់ទៅដល់សោភ័ណភាពក្រុងនិងមោទនភាពជាតិផងដែរ ។ ក្រុមហ៊ុនសិនទ្រីក៏បានទទួលសិទ្ធិក្នុងការរៀបចំទុកដាក់សំរាមនៅក្រុងព្រះសីហនុដែរ ហើយនិងកំពុងសិក្សាលើគម្រោងប្រមូលសំរាមនៅក្រុងតាខ្មៅ(ខេត្តកណ្តាល)ទៀត ។ ចំណែកការទុកដាក់សំរាមនៅក្រុងសៀមរាប ជាបន្ទុករបស់ក្រុមហ៊ុន MICC Co.ltd in Siam Reap Cambodia ។

នៅប្រទេសកម្ពុជា កន្លែងចាក់សំរាមនៅមិនទាន់បានរៀបចំទៅតាមបច្ចេកទេសវិទ្យាសាស្ត្រអ្វីទេ ។ គេចាក់សំរាមកណ្តាលវាល ម្ល៉ោះហើយក្លិនអសោចិ៍នៃសំរាមតែងសាយភាយទៅលើភូមិដ្ឋានអ្នកស្រុកយើងដែលរស់នៅជុំវិញ ។ សំរាមបណ្តាលឱ្យកើតមានសត្វរុយ ដែលជាភ្នាក់ងារ ចម្លងជំងឺតម្កាត់ផ្សេងៗ ពិសេសរោគរាកមួលនិងអាសន្នរោគ ។ គុណភាពខ្យល់នៅក្បែរកន្លែងចាក់សំរាមមានក្លិនមិនល្អ ដោយសារការដុតសំរាមនិងធូលីដែលហុយចេញពីការចាក់សំរាម ។ ប្រជាជនដែលរស់នៅក្បែរកន្លែងចាក់សំរាម ងាយទទួលរងជំងឺផ្លូវដង្ហើមណាស់ដោយសារផ្សែងដែលភាយ ចេញពីការដុតសំរាមទាំងនោះ ។ ឧស្ម័នដែលភាយចេញពីការបំបែកធាតុជីវៈនៅកន្លែងចាក់សំរាម រួមជាមួយបង់សែននិងវិនីលក្លរីត (ឧស្ម័នម្យ៉ាង) ជាដើមហេតុនៃជំងឺមហារីក ។ នៅកន្លែងចាក់សំរាម ទឹកលេចចេញតែងផ្ទុកទៅដោយមេរោគនិងសារធាតុពុល តែងហូរនៅលើផ្ទៃដី ឬជ្រាបចូលទៅក្នុងប្រភពទឹកក្រោមដី ធ្វើឱ្យទឹកខូចគុណភាព ជួនកាលបង្កឱ្យមានគ្រោះថ្នាក់ធំធេងណាស់ទៀតផង ។ ម្យ៉ាងទៀត

កន្លែងចាក់សំរាមទាំងនោះ ជាកន្លែងដែលជនក្រីក្រខុរគតិចូលទៅរើសរបស់របរផ្សេងៗ យកទៅលក់បានប្រាក់កាសបន្តិចបន្តួចសម្រាប់ចិញ្ចឹមជីវិត តែក៏ត្រូវប្រថុយប្រថាននិងផលប៉ះពាល់ដល់សុខភាពផ្ទាល់របស់ខ្លួនចៀសមិនផុត ។ សត្វស្រុកចូលទៅរកចំណីអាហារ ដែលអាចចម្លងមេរោគ ឬសារធាតុគីមីពុល តាមរយៈខ្សែចង្វាក់ចំណីអាហារ ។

តើគួរធ្វើយ៉ាងណាឱ្យការទុកដាក់សំរាមនៅកម្ពុជាមានលក្ខណៈប្រសើរជាងនេះ នៅពេលដែលយើងមិនទាន់មានកន្លែងចោលសំរាមតាមបែបបច្ចេកទេសវិទ្យាសាស្ត្រនិងគេនៅឡើយនោះ ? ជំហានដំបូង គឺជួយកាត់បន្ថយក្លិនមិនល្អនៃឧស្ម័នដែលភាយចេញនិងជួយកំចាត់សត្វរុយដែលរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ពិសេសនៅពេលទទួលទានអាហារ ដោយកិនបង្ហាប់សំរាម គ្របដោយដីជាស្រទាប់ៗ ។ មធ្យោបាយមួយទៀត ប្រសិនបើអាចអនុវត្តបាននោះអាចជួយឱ្យយើងកាត់បន្ថយ កាកសំណល់រឹងបានមួយចំនួនធំ គឺវិធីញែកសំរាមដាក់ក្នុងថង់ផ្សេងៗគ្នាតាមលំនៅឋាន ដូចជាសំរាមដែលអាចបំបែកធាតុជីវៈបាន គេយកទៅធ្វើជាជីបង្កើនគុណភាពដី លោហៈ កែវ និងប្លាស្ទិចអាចយកទៅធ្វើកំណៃច្នៃជាថ្មី ។

## 5. បញ្ហាទឹកជំនន់



*ទឹកជំនន់នៅប្រទេសកម្ពុជា*

ដូចដែលយើងបានលើកយកមកសិក្សា ត្រង់ចំណងជើងរងទី 3 ខ្លះៗរួចមកហើយថា ទឹកជំនន់ជាបញ្ហាចម្បងមួយនៅកម្ពុជា ។ នៅតាមមជ្ឈដ្ឋានក្រុង ទឹកជំនន់បណ្ដាលមកពីទឹកស្ទឹង ទន្លេ និងទឹកភ្លៀង ។ ដោយសារមានទំនប់ធំៗជាខ្សែក្រវាត់ការពារច្រើនសង្កាត់ ច្រើនជាន់ ទីក្រុងភ្នំពេញ អាច

ចៀសផុតពីការគំរាមកំហែងនៃទឹកជំនន់ពីទន្លេមេគង្គ ។ ប៉ុន្តែមានម្តងម្កាលដែរ ដែលកម្ពស់ទឹកទន្លេត្រង់ចតុមុខឡើងដល់កម្រិតប្រកាសភាពអាសន្ន ហើយការលើកទំនប់បន្ថែមតាមមាត់ទន្លេជួប ឧបសគ្គនិងសំណង់ថ្មីៗ ពិសេសសំណង់អនាធិបតេយ្យដែលបច្ចុប្បន្ន បានរំដោះចេញពីទីតាំងនោះបានមួយចំនួនធំហើយ ។ មានពេលខ្លះទឹកភ្លៀងដែលធ្លាក់នៅតំបន់ជួរភ្នំក្រវាញខាងកើត បានហូរសំរុកមកកាន់ទីទំនាប បន្ថែមពីលើទឹកជំនន់នៃទន្លេ បង្កឱ្យមានគ្រោះភ័យគំរាមកំហែងខ្លាំងដល់ ខេត្តកំពង់ស្ពឺនិងខេត្តកណ្តាល ចំណែកភាគខាងលិចទីក្រុងភ្នំពេញប៉ះពាល់តិចតួចដែរ ។

មកទល់បច្ចុប្បន្ន រាល់ពេលមានភ្លៀងធ្លាក់ខ្លាំង ចំណុចខ្លះនៃទីក្រុងភ្នំពេញនៅតែរងនូវទឹកជំនន់ខ្លះក្នុងរយៈពេលយូរ ខ្លះក្នុងរយៈពេលខ្លី បង្កការលំបាកដល់ការរស់នៅនិងការធ្វើចរាចរណ៍របស់ប្រជាជន ។ រីឯទីក្រុងនៃខេត្តមួយចំនួនទៀត ក៏មានបញ្ហាជំនន់ទឹកភ្លៀងនេះដែរ ។

## ? សំណួរ

1. ចូរកំណត់ន័យនៃពាក្យ "កំណើននគរូបនីយកម្ម" ។
2. តើបញ្ហាបរិស្ថាន ដែលបណ្តាលមកពីកំណើននគរូបនីយកម្មមានអ្វីខ្លះ ? ចូររៀបរាប់ ។
3. ចូរនិយាយអំពីរបៀបគ្រប់គ្រងសំណល់រាវនៅទីក្រុងភ្នំពេញ ។
4. ចូរនិយាយអំពីរបៀបទុកដាក់កាកសំណល់រឹងនៅប្រទេសយើង ។
5. តើការចាក់ចោលកាកសំណល់រឹងនៅកណ្តាលវាល បណ្តាលឱ្យមានគ្រោះថ្នាក់ដែរ ឬទេ ? ចូរពន្យល់ ។
6. តើអ្នកយល់ដូចម្តេច ចំពោះការទុកដាក់សំណល់រឹងនិងរាវនៅកម្ពុជាសព្វថ្ងៃ ?

## ? សំណួរបញ្ចប់ជំពូកទី៤

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ការសាងសង់ផ្លូវថ្នល់នៅកម្ពុជាក្នុងសម័យអាណានិគមនិយមបារាំង ប្រព្រឹត្តទៅដោយសារ

☐ក. ជំនួយអន្តរជាតិ ☐ខ. ជំនួយសេដ្ឋកិច្ចបារាំង

☐គ. កំលែនប្រជារាស្ត្រខ្មែរ ☐ឃ. កំលែនប្រជាជនវៀតណាម

2. បើគិតពីកម្លាំងសេដ្ឋកិច្ចនិងចំនួនប្រជាជន ខេត្តកំពង់ធំត្រូវបានចាត់ទុកថាជា

☐ក. ខេត្តរឹងមាំ ☐ខ. ខេត្តទន់ខ្សោយ

☐គ. ខេត្តមធ្យម ☐ឃ. ខេត្តខ្លាំងខាងទេសចរ

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ការសាងសង់ទីក្រុងអង្គរជាភស្តុតាងបញ្ជាក់ច្បាស់ពីការងារផ្នែក........................................
ដ៏ពិសិដ្ឋរបស់បុព្វបុរសខ្មែរ ។

2. ប៉ូលសេដ្ឋកិច្ចទាំងបីរបស់ប្រទេសកម្ពុជាសព្វថ្ងៃគឺភ្នំពេញ ......................និង...................... ។

3. ខេត្តផ្សារភ្ជាប់នឹងសេដ្ឋកិច្ចព្រំដែនមាន..............................និង.............................. ។

4. អ្វីៗដែលនាំឱ្យប៉ះពាល់ដល់សោភ័ណក្រុងនិងមោទនភាពជាតិគឺ...............................និង
.............................. ។

III. សំណួរត្រិះរិះ

1. ចូរបង្ហាញឱ្យឃើញថា ដូនតាខ្មែរជំនាន់ដើមមានទេពកោសល្យខ្ពស់ លើការងារនគរូបនីយកម្ម ។

2. ចូរនិយាយអំពីសារៈសំខាន់នៃការអនុវត្តគោលនយោបាយបែងចែកដីធ្លីនៅកម្ពុជាសព្វថ្ងៃ ។

3. តើគេអាចរំដោះខេត្តតាមព្រំដែនមួយចំនួន ឱ្យចេញផុតពីភាពដាច់ស្រយាលបានដោយមធ្យោបាយណា ?

4. តើកម្ពុជាមានសក្តានុភាពសេដ្ឋកិច្ច លើផ្នែកអ្វីខ្លះនាពេលបច្ចុប្បន្ន ? ចូររៀបរាប់ ។

5. តើបញ្ហាបរិស្ថាន ដែលបណ្តាលមកពីកំណើននគរូបនីយកម្មនៅកម្ពុជាមានអ្វីខ្លះ ? ចូររៀបរាប់ ។

6. តើអ្នកយល់ដូចម្តេច ចំពោះការទុកដាក់សំណល់រឹងនិងរាវនៅទីក្រុងកម្ពុជាបច្ចុប្បន្ននេះ ?

#### ជំពូកទី 5

# មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចពិភពលោក



*ប្រង់ផតប៉ូលសេដ្ឋកិច្ចពិភពលោកមួយនៅទ្វីបអឺរ៉ុប*

កាលពីដើម ទ្វីបអឺរ៉ុបមានប៉ូលជំរុញសេដ្ឋកិច្ចជាច្រើនដែលជាធានីនៃការដោះដូរនិងធានីហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចមួយនិងទទួលបានការរីកធំធាត់រហូតដល់កម្រិតថ្នាក់ពិភពលោក។ តាំងពីមួយសតវត្សរ៍កន្លងមក ប្រព័ន្ធពិភពលោកមួយបានចាប់កំណើតឡើង ព្រមទាំងក្តោបក្តាប់ប្រជាជនលើភពផែនដីស្ទើរតែទាំងអស់។ ប្រព័ន្ធនេះអាចប្រៀបបានទៅនឹងដងខ្លួនមនុស្សដែលអាចធ្វើសកម្មភាពដោយសារតែប្រព័ន្ធសរសៃប្រសាទកណ្តាលមួយ គឺជាមេត្រូប៉ូលទាំងឡាយដែលក្នុងនោះអំណាចហិរញ្ញវត្ថុ អំណាចនវកម្ម(ការបង្កើតថ្មី) នៃការសម្រេច ភាពម្ចាស់ការលើការដោះដូរ និងភ្នាក់ងារនានាបានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងសេដ្ឋកិច្ចពិភពលោក។

មេរៀនទី

# 1 មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយ

**ចប់មេរៀននេះ សិស្សអាច**

- អធិប្បាយពីមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ច : សារៈសំខាន់នៃអំណាចហិរញ្ញវត្ថុ មជ្ឈមណ្ឌលនៃការសម្រេច មជ្ឈមណ្ឌលស្រាវជ្រាវ ភាពម្ចាស់ការលើភ្លុច និងអំណាចនយោបាយ ។

តើមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដ៏ធំមួយត្រូវមានធនធាននិងអំណាចអ្វីខ្លះ ?

លក្ខណៈសម្គាល់សំខាន់បំផុតនៃមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយមានអំណាចហិរញ្ញវត្ថុ អំណាចនៃការសម្រេច នៃការស្រាវជ្រាវនិងនវកម្ម ភាពម្ចាស់ការលើភ្លុចទាំងឡាយ និងអំណាចនយោបាយ ។

## 1. សារៈសំខាន់នៃអំណាចហិរញ្ញវត្ថុ

ការផ្ទេរមូលធនចាំបាច់សម្រាប់សកម្មភាពសេដ្ឋកិច្ច ជាកិច្ចការរបស់បណ្តាញធនាគារសំខាន់ៗ ។ ធនាគារជំនួញ ធនាគារផ្ញើប្រាក់ ឬធនាគារសម្រាប់ក្រុមហ៊ុនឧស្សាហកម្មធំៗ ត្រូវបានពង្រឹងចាប់តាំងពីសង្គ្រាមលោកលើកទី 2 មកម្ល៉េះ ។ ធនាគារទាំងនោះមានតួនាទីដ៏ចម្បងមួយនៅប្រទេសជប៉ុន សហរដ្ឋអាមេរិក និងអឺរ៉ុបខាងលិច ខន្ទីមគ្នានិងក្រុមហ៊ុនរបរ ក្រុមហ៊ុនធានារ៉ាប់រង ឬសេវាហិរញ្ញវត្ថុ ។ សកម្មភាពទាំងអស់នេះប្រមូលផ្តុំជាពិសេសនៅក្នុងមេត្រូប៉ូល : ធនាគារធំៗជាងគេក្នុងពិភពលោកចំនួន 50 ស្ថិតនៅរាយប៉ាយក្នុងទីក្រុងចំនួន 15 ទីក្រុងតូក្យូមាន 12 ញូយ៉កនិងប៉ារីសមាន 5 ទីក្រុងឡុងមាន 3 ។ អំណាចហិរញ្ញវត្ថុផ្តល់តួនាទីឱ្យមេត្រូប៉ូលទាំងនោះធ្វើសេចក្តីសម្រេចក្នុងការវិនិយោគទុនអន្តរជាតិ ។

មជ្ឈមណ្ឌលហិរញ្ញវត្ថុឯកទេសខ្លះពឹងផ្អែកលើចំណងទាក់ទងរវាងធនាគារនិងទីផ្សារហាងឆេងហិរញ្ញវត្ថុ ឬពាណិជ្ជកម្ម ដូចជាករណីទីក្រុងសឺណែវ ប្រង់ផត នៅអឺរ៉ុប ហុងកុង ឬអូសាកា នៅអាស៊ីជាដើម ។ ឯកទេសកម្មនេះផ្អែកលើភាពងាយស្រួលស្របច្បាប់ដែលបានផ្តល់ឱ្យដល់មូលធនទាំងឡាយនៅក្នុង "ស្ថានសួគ៌សារពើពន្ធ" (តំបន់រួចពន្ធ) មាន បាហាម៉ា ហុងកុង ប៉ាណាម៉ា ប៊ែម្មូដ លុចសំបួ និងឡាយតិនស្តេន ។ ហេតុដូច្នេះហើយ បានជាមេត្រូប៉ូលពិភពលោកធំៗមានគ្រប់មធ្យោបាយដើម្បីធ្វើការសម្រេចគឺ បណ្តាញធនាគារយ៉ាងច្រើន អង្គការផ្សារតម្លៃ(ទីផ្សារហាងឆេង) ដ៏សំបូរបែប ទីស្នាក់ការធនាគារអន្តរជាតិដូចជា ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ស៊ីធីក្រុងឡុង វ៉លស្ទ្រីត(Wall Street) នៅញូយ៉ក សង្កាត់ម៉ារូនូជី(Marunouchi) នៅតូក្យូ មានអំណាចហិរញ្ញវត្ថុមួយគ្មានគូប្រៀប ។

## 2. មជ្ឈមណ្ឌលនៃការសម្រេច

អំណាចនៃការសម្រេច ត្រូវបានប្រមូលផ្តុំនៅក្នុងមជ្ឈមណ្ឌលមួយចំនួនដែលមានឯកសិទ្ធិនៃអន្តរគោលខាងជើង ដែលជាអ្នករៀបចំចាត់ចែងលំហាពិភពលោក ។

នៅក្នុងបណ្តាប្រទេសសេដ្ឋកិច្ចផែនការ មានមជ្ឈមណ្ឌលនៃការសម្រេចតែមួយគត់ កាន់កាប់ដោយអំណាចនយោបាយ ដែលតាំងនៅក្នុងរដ្ឋធានីនិងដឹកនាំផ្តាច់មុខនូវផលិតកម្ម វិនិយោគទុន រួមទាំងការដោះដូរផង ។ ហេតុដូច្នេះហើយ បានជានៅអតីតសហភាពសូវៀត ទីក្រុងមូស្គូជាអ្នកចាត់ចែងសេដ្ឋកិច្ចរបស់ប្រទេសទាំងមូល ហើយថែមទាំងមានឥទ្ធិពលទៅលើសេដ្ឋកិច្ចរដ្ឋប្រជាធិបតេយ្យប្រជាមានិតដទៃទៀតផង ព្រោះទីក្រុងមូស្គូជាទីស្នាក់ការនៃអង្គការ CAEM មានន័យថា ក្រុមប្រឹក្សាសេដ្ឋកិច្ចជួយគ្នាទៅវិញទៅមក(Conseil d'Assistance Economique Mutuelle) ។

នៅក្នុងពិភពមូលធននិយម មជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ៗប្រមូលផ្តុំស្ទើរតែទាំងអស់នៅសហរដ្ឋអាមេរិក អឺរ៉ុបខាងលិច វេណាន និងនៅប្រទេសជប៉ុន ។ នៅសហរដ្ឋអាមេរិកគ្រាន់តែក្នុងក្រុងញូយ៉កមួយមានដល់ទៅ 13 ទីស្នាក់ការ សង្គម ក្នុងបណ្តាទីស្នាក់ការទាំង 30 នៃក្រុមហ៊ុនធំៗបំផុតក្នុងពិភពលោក ។ ប៉ុន្តែ ប្រទេសតូចៗដូចជាប្រទេសស៊ុីស(មានទីក្រុងស៊ូរិច បាល និងសឺណែវ) ពេអ៊ីបា ឬហូឡង់(មានទីក្រុងអាំស្ទែដាំនិងរ៉ូទែដាំ) និងប្រទេសលុចសំបួ រក្សាទុកអំណាចបញ្ជាកម្រិតថ្នាក់ពិភពលោកដោយសារតែភាពសម្បូរមូលធននិងគំនិតច្នៃប្រឌិតពីមជ្ឈដ្ឋានពាណិជ្ជកម្ម ។

មេត្រូប៉ូលខ្លះត្រូវបានពង្រឹងតួនាទីដោយសារវត្តមាននៃទីស្នាក់ការអង្គការអន្តរជាតិធំៗជីសកម្ម មានដូចជា ONU នៅទីក្រុងញូយ៉ក UNESCO នៅទីក្រុងប៉ារីស សហភាពសមុទ្រអន្តរជាតិនៅទីក្រុងឡុង OPEC នៅទីក្រុងវៀន(Vienne)ប្រទេសអូទ្រីសជាដើម ។

ក្រុមហ៊ុនពាណិជ្ជកម្មអន្តរជាតិនានា ជាភ្នាក់ងារប្រកបដោយឯកសិទ្ធិនៃពិភវូបនីយកម្មសេដ្ឋកិច្ច ផ្តល់អំណាចដ៏ធំធេងមួយឱ្យដល់ទីក្រុងដូចជា ហាំបួ អង់វែ មីឡង់ ឬអូសាកា ។

និយាយរួម ទីតាំងហិរញ្ញវត្ថុសំខាន់ៗបង្កើតបានជាលំហាហិរញ្ញវត្ថុអន្តរជាតិមួយ... ។ គេឃើញមានទីតាំងហិរញ្ញវត្ថុខ្នាតអន្តរជាតិចំនួនប្រមាណជា 10 ដែលក្នុងនោះមានមជ្ឈមណ្ឌលបង្វិលបីក្នុងការធ្វើចរាចរណ៍ប្រាក់កាសលើពិភពលោកគឺ ញូយ៉ក ឡុង និងតូក្យូ ។ ញូយ៉ក ជាមជ្ឈមណ្ឌលហិរញ្ញវត្ថុធំបំផុតក្នុងលោក ជាទីផ្សារពិភពលោក ដែលបើក 24 ម៉ោងលើ 24 ម៉ោង ។ ទីតាំងហិរញ្ញវត្ថុក្រុងតូក្យូទទួលបានការរីកចម្រើនអស្ចារ្យណាស់ ។ ទីក្រុងឡុង អាចឈរនៅជួរទីមួយបានដោយសារការបន្ធូរបន្ថយបទវិន័យនៃទីផ្សារភាគហ៊ុនកាលពីឆ្នាំ 1985 ។

## 3. មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍

នៅក្នុងប្រទេសឧស្សាហកម្មមួយចំនួនតូច របកគំហើញសំខាន់ៗផ្នែកវិទ្យាសាស្ត្រ និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា បានមកពីមជ្ឈមណ្ឌលស្រាវជ្រាវ ឬមន្ទីរពិសោធន៍របស់សហគ្រាសធំៗ ដែលតាំងនៅក្នុងមជ្ឈដ្ឋានបញ្ញវន្តសមស្របមួយ ។ ហេតុនេះហើយបានជាភាពម្ចាស់ការលើថាមពលនុយក្លេអ៊ែរក្នុងស្រុក ជាឯកសិទ្ធិរបស់រដ្ឋចំនួន 26 ដែលនៅទ្វីបអឺរ៉ុបមានដល់ទៅ 15 រដ្ឋ ។ វឌ្ឍនភាពផ្នែកព័ត៌មានវិទ្យាធ្វើឱ្យសម្ភារៈមួយចំនួនក្លាយទៅជាវត្ថុដែលគេលែងត្រូវការយ៉ាងឆាប់រហ័ស ។ មានតែសហគ្រាសធំៗនិងមជ្ឈមណ្ឌលខ្លះៗប៉ុណ្ណោះដែលអាចប្រឈមមុខនឹងតម្លៃវិនិយោគចាំបាច់ដ៏ខ្ពស់បាន ។

បដិវត្តន៍ឧស្សាហកម្មនេះមានមណ្ឌលសកម្មប្រមូលផ្តុំនៅជិតៗមជ្ឈមណ្ឌលបណ្តុំវិនិយោគ និង "រូបធាតុប្រផេះ" ។ មណ្ឌលសកម្មសំខាន់ៗស្ថិតនៅតំបន់ប៉ាស៊ីហ្វិកដូចជា ស៊ីលីខុនវ៉ាលេក្បែរសាន់ហ្វ្រាន់ស៊ីស្កូ និងស៊ូគូបាជិតតូក្យូ ។ វង់ព្រះអាទិត្យអាមេរិកនិងមេកាឡូប៉ូលជប៉ុនស្ថិតនៅក្នុងក្រុមនាំមុខ ពីមុខប៉ូលបច្ចេកវិទ្យាអឺរ៉ុប ។ ឧស្សាហកម្មស្រួចស្រាល់របស់ប្រទេសជប៉ុនប្រមូលផ្តុំនៅទីជិតៗនៃសកលវិទ្យាល័យ និងការស្រាវជ្រាវក្នុងបុរីវិទ្យាសាស្ត្រ ឬតិចណូប៉ូលចំនួន 16 ដែលទទួលបានការឧបត្ថម្ភគាំទ្រពី M.I.T.I (ក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មអន្តរជាតិ) ។ ប្រទេសជប៉ុនបង្កើតបានមេកាឡូប៉ូលីសរបស់ខ្លួនដែលលាតសន្ធឹងលើបណ្តោយជាង 1 200km តាមឆ្នេរប៉ាស៊ីហ្វិកនិងសមុទ្រក្នុង គឺជាអ្វីៗដែលជនជាតិអាមេរិកបាននឹកស្រមៃថា មានកម្រិតត្រឹមខ្នាតទីក្រុងបូស្តុន(Boston) ឬស៊ីលីខុនវ៉ាលេ(Silicon Valley) កាលពីជាង 30ឆ្នាំមុន ។

"បុរីបញ្ញវន្ត" ទាំងឡាយត្រូវបានតភ្ជាប់គ្នារួចជាស្រេចដោយស៊ិនកង់សិន(Shinkansen) រថភ្លើងដើរដោយកម្លាំងម៉ាញេទិច ។ ចំណែកព័ត៌មានវិញរត់ច្រវាត់លឿនដូចផ្លេកបន្ទោររវាងបុរីទាំងនោះ ។ អចលនវត្ថុបញ្ញា សំណង់ដ៏អស្ចារ្យកើតមានជាបន្តបន្ទាប់ ។

នៅខាងជើងក្រុងតូក្យូ ប្លែនអ៊ីបារ៉ាគី(La Plaine d'Ibaraki) ជាបុរីមួយក្នុងបណ្តាបុរីសំខាន់ៗនិងជឿនលឿនបំផុតនៅតំបន់នោះ ។ នៅជុំវិញសកលវិទ្យាល័យស៊ូគូបា(Tsukuba) មានមជ្ឈមណ្ឌលស្រាវជ្រាវនិងរោងចក្រឧស្សាហកម្មប្រមាណជាជប់ត្រូវបានបង្កើតឡើងដោយបានប្រើប្រាស់និងផលិតគ្រឿងសម្ភារៈប្រកបដោយបច្ចេកវិទ្យាខ្ពស់ក្រោមការគាំទ្ររបស់រដ្ឋ និងមានបុគ្គលិកធ្វើការ ចំនួន 200 000 នាក់ ដែលក្នុងនោះមានចំនួន 1/4 ធ្វើការផ្នែកសិក្សាអប់រំនិងស្រាវជ្រាវ ។

## 4. ភាពជាម្ចាស់ការលើភ្នូច

ភ្លូចសំខាន់សម្រាប់បម្រើឱ្យមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចគឺភ្លូចព័ត៌មាននិងការដឹកជញ្ជូន។ កំណើនប្រព័ន្ធទូរគមនាគមន៍(ផ្កាយរណប ខ្សែកាប តេឡេម៉ាទិក) និងការរីកចម្រើនផ្នែកដឹកជញ្ជូនទំនិញ(រថយន្ត រថភ្លើង នាវា ឬយន្តហោះ) នាំមកនូវបណ្ដុំអំណាចនៃការធ្វើសេចក្ដីសម្រេចទៅលើសេដ្ឋកិច្ច។

មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចតែងប្រមូលផ្ដុំមធ្យោបាយ ប្រមែប្រមូលព័ត៌មានទាំងឡាយ : ទីភ្នាក់ងារសារព័ត៌មានធំៗ អាចធានារ៉ាប់រងបាននូវទំនាក់ទំនងនៅក្នុងគ្រប់ប្រទេសដូចជា អាសូស៊ីអេធីតប្រេសអាមេរិក(American Associated Press) ទីភ្នាក់ងារសារព័ត៌មានតាស(Tass) នៅរុស្សីឬហ្វ្រង់-ប្រេស (France-Presse)។ ជាចំណុចប្រសព្វនៃការដឹកជញ្ជូនផងដែរ : អូហា (O'Hare) នៅឈីកាគោ កេណ្ណឺឌីនិងនេវ៉ាកនៅញូយ៉ក អ័រលីនិងរ៉យស៊ី(Orly et Roissy)នៅប៉ារីស ណារីតានៅតូក្យូ ជាអាកាសយានដ្ឋាន ដែលមមាញឹកបំផុតក្នុងលោក។ ទីក្រុងខ្លះទទួលបានការអភិវឌ្ឍដោយផ្អែកលើព្រលានយន្តហោះរបស់ខ្លួនដូចជាករណី ដាឡាស់-ហ្វតវើត(Dallas-Fort Worth)នៅសហរដ្ឋអាមេរិក។

## 5. អំណាចនយោបាយ

អំណាចនយោបាយធ្វើអន្តរាគមន៍ផងដែរក្នុងជីវភាពសេដ្ឋកិច្ច។ ញូយ៉កពុំមែនជារដ្ឋធានីរបស់សហរដ្ឋអាមេរិកទេ ហើយក៏ពុំមែនជារដ្ឋធានីរបស់រដ្ឋណាមួយក្នុងចំណោមរដ្ឋទាំង 50 ដែរ។ ប៉ុន្តែមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចជាច្រើន ជារដ្ឋធានីរបស់ប្រទេសដូចជានៅប្រទេសបារាំង ឬក៏ជាទីស្នាក់ការ របស់អង្គការសេដ្ឋកិច្ចធំៗដូចជាព្រុចសែល ជាទីស្នាក់ការនៃសហគមន៍សេដ្ឋកិច្ចអឺរ៉ុប C.E.E(Communauté Economique Européenne) សព្វថ្ងៃក្លាយទៅជាសហភាពអឺរ៉ុប។

ការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកពឹងផ្អែកលើសកម្មភាពនៃមេត្រូប៉ូលធំៗ ដែលប្រមូលផ្ដុំអំណាចហិរញ្ញវត្ថុ អំណាចសម្រេច មជ្ឈមណ្ឌលផ្នែកទំនាក់ទំនង និងរបកគំហើញបច្ចេកវិទ្យា ហើយជូនកាលអំណាចនយោបាយផងដែរ។

## ? សំណួរ

1. ប្រព័ន្ធពិភពលោកមួយបានចាប់កំណើតឡើង។ តើប្រព័ន្ធពិភពលោកនោះគឺជាអ្វី ?
2. តើអំណាចហិរញ្ញវត្ថុសំខាន់ៗមាននៅទីណាខ្លះ ? ចូររៀបរាប់។
3. តើអំណាចហិរញ្ញវត្ថុដែលខ្លាំងគ្មានគូប្រៀប មាននៅទីណាខ្លះ ? ចូររៀបរាប់។
4. តើអំណាចនៃការសម្រេចមាននៅទីណាខ្លះ ? ចូររៀបរាប់។
5. តើគេអាចសម្គាល់ថា ជាប៉ូលជំរុញសេដ្ឋកិច្ចមួយបាន តាមរយៈអ្វីខ្លះ ?

មេរៀនទី

# 2 អំណាចសេដ្ឋកិច្ចពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីអំណាចសេដ្ឋកិច្ចពិភពលោក : មជ្ឈមណ្ឌលជំរុញសំខាន់ៗ មជ្ឈមណ្ឌលបន្ទាប់បន្សំ និងមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចពិភពលោក ។

សេដ្ឋកិច្ចពិភពលោកមានប៉ូលសំខាន់បីហៅថា "ត្រីប៉ូល" ដែលក្នុងនោះគេតែងប្រទះឃើញមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចសំខាន់ៗ និងបន្ទាប់បន្សំ ។ តើប៉ូលសេដ្ឋកិច្ចទាំងនោះមាននៅទីណាខ្លះ? តើគេអាចរៀបចំឋានានុក្រមមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចបានយ៉ាងដូចម្ដេច ? មជ្ឈមណ្ឌលទាំងឡាយទោះក្នុងកម្រិតណាក៏ដោយ តែងបង្កើតបានជាភូមិសាស្ត្រអំណាចសេដ្ឋកិច្ចពិភពលោកមួយ ។

## 1. មជ្ឈមណ្ឌលជំរុញសំខាន់ៗ

មជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចធំៗ គឺជាមជ្ឈមណ្ឌលទាំងឡាយណាដែលមានមុខងារពេញលេញ ពោលគឺត្រូវមានគ្រប់លក្ខណៈទាំងអស់ដូចដែលបានសិក្សារួចមកហើយ ។

ទោះបីមានដំណើរថយក្រោយមួយជំហានក្ដី ក៏ទីក្រុងញូយ៉កនៅតែទទួលចំណាត់ថ្នាក់ជាមជ្ឈមណ្ឌលពិភពលោកទី 1 ព្រោះនៅទីនោះគេឃើញមានបន្សំអានុភាពជាតិនិងអន្តរជាតិ ។ ឱនភាពមុខងារឧស្សាហកម្មរបស់ទីក្រុងនេះត្រូវបានទូទាត់ជំនួសវិញដោយការជំរុញមុខងារសេវាកម្មឱ្យដល់កម្រិតអន្តរជាតិ ។ ទីក្រុងញូយ៉កតាងបានប្រហែល 8% នៃអានុភាពឧស្សាហកម្មសហរដ្ឋអាមេរិក 1/3 នៃទំហំសេវាកម្ម និងប្រមូលផ្ដុំបាន 20% នៃទីស្នាក់ការសង្គមរបស់សហគ្រាសធំៗនិងពហុជាតិ ។ លើសពីនេះទៅទៀត ញូយ៉កមានទីផ្សារហាងឆេងដ៏សំខាន់មួយគឺ ញូយ៉កស្តុកអិចឆេង(NewYork Stock Exchange) ។ ញូយ៉កក៏ជាមជ្ឈមណ្ឌលនៃអង្គការអន្តរជាតិជាច្រើនផងដែរ ដូចជាទីស្នាក់ការអង្គការសហប្រជាជាតិ នៅភាគខាងកើត ម៉ិនហាថិន(Manhattan) ។

ទីក្រុងញូយ៉កស្ថិតនៅចំកណ្ដាលទីប្រជុំជនមួយ ។ ទីក្រុងនេះមានប្រជាជនចំនួន 18.3 លាននាក់ (ឆ្នាំ 2005) ចែកជា 5 មណ្ឌល ដែលក្នុងនោះ ម៉ិនហាថិន មានមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ធំមួយហៅថា សិនត្រល ប៊ីស៊ីនីស ឌីសទ្រិច Central Business District (C.B.D) ចែកចេញជាពីរផ្នែក :

- ប៉ែកខាងត្បូងមាន ដោនថោន (Down Town) ដែលជាទីតាំងនៃទីផ្សារហ៊ុនរបស់ញូយ៉ក (New york Stock Exchange) ទីស្នាក់ការធនាគារកណ្តាលអាមេរិក (Federal Reserve Bank) និងធនាគារសំខាន់ៗមួយចំនួនទៀត ។ បំមធំៗសម្បើមទាំងឡាយជាទីតាំងនៃមជ្ឈមណ្ឌលសហគ្រាសឧស្សាហកម្មធានារ៉ាប់រងនិងសេវា(អាមេរិកអិចប្រេស American Express, មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក World Trade Center) ។
- នៅប៉ែកកណ្តាលនៃម៉ិនហាថិន(Manhattan) មានមីតថោន(Mid Town) ជា C.B.D ទី 2 ធ្វើសកម្មភាពលើផ្នែកផ្សេងៗដូចជា ទីស្នាក់ការធនាគារនានា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ទូរទស្សន៍ C.B.S, N.B.S កាសែត ទស្សនាវដ្តី) និងមជ្ឈមណ្ឌលវប្បធម៌ ។



បំមភ្លោះពីរនៅកណ្តាលសង្កាត់ម៉ិនហាថិន ជាមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក

មជ្ឈមណ្ឌលទាំងពីរនេះនៅឃ្លាតឆ្ងាយពីគ្នាត្រឹមតែ 5km ប៉ុណ្ណោះ ភ្ជាប់គ្នាដោយបណ្តាញផ្លូវគមនាគមន៍ដ៏ញឹកនិងភ្ជាប់ទំនាក់ទំនងទៅខាងក្រៅ តាមរយៈព្រលានយន្តហោះអន្តរជាតិបី(ជី អេហ្វ កេណ្ណឺឌី J.F.Kennedy, នីវ៉ាក Newark, ឡា កាឌៀ La Guardia) និងតាមមធ្យោបាយទូរគមនាគមន៍ក្នុងបណ្តាមធ្យោបាយជឿនលឿនបំផុតនៅលើភពផែនដី ។ ភាពម្ចាស់ការផ្នែកព័ត៌មាន និងការប្រមូលផ្តុំសកម្មភាពចាត់ចែងការងារបានក្លាយទៅជាកត្តាសំខាន់នៃប៉ូលជំរុញសេដ្ឋកិច្ច ។

ទីក្រុងតូក្យូប្រមូលផ្តុំ 60% នៃទីស្នាក់ការសង្គមរបស់កុងក្លូមេរ៉ា(Conglomérats)និងធនាគារធំៗនៃប្រទេសជប៉ុន និងពង្រីកតួនាទីរបស់ខ្លួនជាបន្តបន្ទាប់ក្នុងការធ្វើអន្តរជាតូបនីយកម្មសេដ្ឋកិច្ចជាតិខ្លួន ។ ទីក្រុងនេះមានប្រជាជនចំនួន 30 លាននាក់(ឆ្នាំ 2005) គឺជាទីក្រុងដែលមានប្រជាជនច្រើនជាងគេបំផុតក្នុងលោក ។



*មជ្ឈមណ្ឌលពាណិជ្ជកម្ម ស៊ីនជូគូ នៅតូក្យូ*

តូក្យូពុំមែនជាមេត្រូប៉ូលស្ថិតនៅឯកោដូចទីក្រុងប៉ារីសទេ តែជាស្នូលនៃមេកាឡូប៉ូលជប៉ុនដែលប្រមូលផ្តុំមុខងារកាន់តែច្រើនឡើងៗលើវិស័យរដ្ឋបាល ឧស្សាហកម្ម និងវប្បធម៌។ ឧស្សាហកម្មស្រួចស្រាល់របស់ជប៉ុនចំនួនពាក់កណ្តាលត្រូវបានសាងសង់ឡើងនៅតាមបរិមណ្ឌលទីក្រុងតូក្យូ ។ រាជធានីនេះពង្រឹងប្រៀបខ្លាំងរបស់ខ្លួនជានិច្ច លើផ្នែកបច្ចេកទេសថ្មីនៃព័ត៌មាននិងគមនាគមន៍ ។ ទីផ្សារហាងឆេងនៅទីក្រុងតូក្យូបានទទួលចំណាត់ថ្នាក់លេខពីរផងដែរក្នុងពិភពលោក ។ សកលវិទ្យាល័យប្រហែលមួយរយ រួមទាំងសកលវិទ្យាល័យ "តូដាយ"(Todai) ដ៏ល្បីល្បាញផងនិងវិទ្យាស្ថានស្រាវជ្រាវចំនួនពាក់កណ្តាលតាំងទីនៅទីក្រុងតូក្យូ ។ បុរីវិទ្យាសាស្ត្រដ៏ទំនើបបំផុតមួយបានរីកលូតលាស់ក្នុងតិចណូប៉ូល ស៊ូគូបា នាតំបន់ទំនាប កាន់តូ(Kanto) ។ ការស្រាវជ្រាវជាគន្លឹះនៃអានុភាពជប៉ុន ។

ទ្វីបអឺរ៉ុប មានមេកាឡូប៉ូលមួយដែលក្នុងនោះមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយចំនួនធំប្រកបទៅដោយអានុភាពមិនសូវជាខ្លាំងភ្លា តែមានមុខងារច្រើនបែបយ៉ាងដូចជា

- **ទីក្រុងឡុង(ប្រទេសអង់គ្លេស)** ជាប៉ូលជំរុញសេដ្ឋកិច្ចមួយដ៏ធំ ដូចគ្នានឹងទីក្រុងតូក្យូ ឬញូយ៉កដែរ បំពេញមុខងារខាងធនាគារ ហិរញ្ញវត្ថុ ធានារ៉ាប់រង ... ។ ស្ថិតនៅភាគខាងជើងនៃ

មេកាឡូប៉ូលអឺរ៉ុប ទីក្រុងឡុងក៏ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងជាមេត្រូប៉ូលលេខមួយប្រចាំទ្វីប និងមានប្រជាជនចំនួន ១១ លាន នាក់ ។

- **ទីក្រុងប៉ារីស(ប្រទេសបារាំង)** ប្រមូលផ្ដុំសហគ្រាសខ្នាតអន្តរជាតិទាំងអស់នៅអឺរ៉ុបបានចំនួន 1/4 ។ ប៉ារីសក៏ជាទីក្រុងលេខមួយខាងជំនួបប្រជុំជាអន្តរជាតិផងដែរ ។




*ទីក្រុងប្រជុំក្រុងនិងបណ្ដុំប្រជុំក្រុង*




*មេកាឡូប៉ូល មេកាប៉ូល និងមេត្រូប៉ូល*




*មេត្រូប៉ូល មេកាប៉ូល មេកាឡូប៉ូល*

- នៅប្រទេសអាល្លឺម៉ង់ **តំបន់រ៉ាំង-រួ (Rhin-Ruhr)** បង្កើតបានជាកញ្ចុំក្រុងមួយដែលមានលក្ខណៈពហុប៉ូល ប៉ុន្តែឯកទេសកម្មទាំងឡាយនៃមជ្ឈមណ្ឌលនីមួយៗមិនបាននាំមកនូវផលប៉ះពាល់ដល់ទំនាក់ទំនងក្នុងតំបន់ឡើយ ។ **ទីក្រុងឌូសែលដហ្វ (Dusseldorf)** ជាមជ្ឈមណ្ឌលហិរញ្ញវត្ថុនិងពាណិជ្ជកម្មគ្រឿងប្រណីត ។ **ទីក្រុងប្រង់ផរ** ជាទីផ្សារភាគហ៊ុននិងទីស្នាក់ការសង្គម ។ **ក្រុងកូឡូញ** ជាមជ្ឈមណ្ឌលឧស្សាហកម្មនិងពាណិជ្ជកម្ម ។ តំបន់រួ ដែលយកឈ្មោះតាមដៃទន្លេរ៉ាំង សព្វថ្ងៃមានប្រជាជនចំនួន ១៨ លាននាក់ រស់នៅក្នុងទីក្រុងដ៏ច្រើន និងមានទីក្រុងចំនួនប្រមាណ 30 ដែលមានប្រជាជនលើសពី 100 000 នាក់ ។ បណ្ដាញក្រុងញឹកបំផុតមាននៅកណ្ដាលមេកាឡូប៉ូលអឺរ៉ុបនិងកកើតឡើងនៅជុំវិញទីក្រុងនានាដែលមានមនុស្សរាប់លាននាក់ : ក្រុងឌូសែលដហ្វ កូឡូញ អេសសិន(Essen) និងដកមុន(Dortmund) ។ ចំណែកឌីសបួ(Duisbourg) ជាកំពង់ផែ ទន្លេធំបំផុតក្នុងលោក(40 លានតោន) ។

## 2. មជ្ឈមណ្ឌលបន្ទាប់បន្សំ

នៅសហរដ្ឋអាមេរិក មជ្ឈមណ្ឌលថ្មីៗនៃតំបន់សាន់បែល(Sun Belt) ឬវង់ព្រះអាទិត្យ បានរីកលូតលាស់នឹងក្លាយទៅជាមជ្ឈមណ្ឌលនវកម្មនិងជាចំណុចប្រសព្វនៃគមនាគមន៍ដូចជាសាន់ហ្វ្រាន់ស៊ីស្កូ ឡូសអង់សឺឡែស ដាឡាស ឬហ៊ូស្តុន ។

ទ្វីបអឺរ៉ុប មានមជ្ឈមណ្ឌលពីមួយៗមកយ៉ាងច្រើន ហើយនៅតែជាផ្នែកហិរញ្ញវត្ថុនិងពាណិជ្ជកម្មដ៏មានសារៈសំខាន់ដែលដូចជា អាំស្ទែដាំ នៅតំបន់រ៉ង់ស្តាត-ហូឡង់ មីឡង់(អ៊ីតាលី) ឬតំបន់ត្រីប៉ូលស៊ុីស មានក្រុងសឺណែវ បាល និងស៊ូរិច ។ គេត្រូវរាប់បញ្ចូល លុចសំបួ ថែមទៀត ដែលបច្ចុប្បន្ននេះមាន ធនាគារចំនួនជាង 120 និងជាង 700 ទីស្នាក់ការសង្គមកិច្ចនៃសហគ្រាសអាមេរិក អឺរ៉ុប និងជប៉ុន ។

នៅប្រទេសជប៉ុន បណ្តុំទីក្រុងអូសាកា មានទាំងអំណាចឧស្សាហកម្ម ហិរញ្ញវត្ថុ និងពាណិជ្ជកម្មកម្រិតថ្នាក់អន្តរជាតិផង អាចចាត់ទុកថាជាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចមួយ អាចប្រកួតប្រជែងជាមួយតូក្យូបាន ។

ជារឿយៗនៅក្នុងប្រទេសកំពុងអភិវឌ្ឍ មេត្រូប៉ូលធំៗបានដើរតួជាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចត្រឹមកម្រិតថ្នាក់ជាតិតែប៉ុណ្ណោះ ។ ប៉ុន្តែទីក្រុង សៅ ប៉ូឡូ របស់ប្រទេសប្រេស៊ីល និងទីក្រុង ជោហានេសបួ(Johannesburg) នៅអាហ្វ្រិខាងត្បូង ជាមជ្ឈមណ្ឌលដែលបានបំពេញតួនាទីខ្នាតអន្តរជាតិដែរ ។ នៅទ្វីបអាស៊ីទីក្រុងសិង្ហបុរី ហុងកុង សេអ៊ូល បានអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យឈានដល់កម្រិតថ្នាក់ពិភពលោក ។

## 3. ភូមិវិទ្យានៃមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចពិភពលោក

នៅក្នុងសេដ្ឋកិច្ចពិភពលោក លំនឹងនៃការតាំងទីមជ្ឈមណ្ឌលសេដ្ឋកិច្ចកំពុងទទួលបានការផ្លាស់ប្តូរយ៉ាងពេញទំហឹងដោយសារតែវឌ្ឍនភាពខាងការដឹកជញ្ជូនដែលអាចផ្តល់ការផ្គត់ផ្គង់ថាមពលបានគ្រប់ទីកន្លែងនិងរូបធាតុដើមដោយតម្លៃថោក និងដោយសារការវិវត្តផ្នែកខ្សែគមនាគមន៍ ។

ភូមិវិទ្យានៃប៉ូលសម្រេចនិងសកម្មភាពឧស្សាហកម្មអាមេរិក ក៏ទទួលបានការផ្លាស់ប្តូរ ។ ទីប្រជុំក្រុងចំនួនម្ភៃដែលស្ថិតនៅរាយប៉ាយលើទឹកដីអាមេរិក សព្វថ្ងៃកំពុងតែជួយជំរុញសេដ្ឋកិច្ចរបស់ប្រទេស ។ ទីប្រជុំក្រុងនីមួយៗ ធ្វើទំនាក់ទំនងផ្ទាល់ជាមួយពិភពខាងក្រៅ ។ ក្រុមហ៊ុនយន្តហោះ បូអីង (Boeing)មិនអាចតាំងនៅតែ ស៊ីថល(Seattle) ឬក្រុមហ៊ុនកូកា-កូឡា នៅតែអាត្លង់តាបានទៀតឡើយ ។

ចំណែកនៅអឺរ៉ុបខាងជើងវិញ នៅជុំវិញសកលវិទ្យាល័យធំៗរបស់អង់គ្លេស ហូឡង់ ឬអាល្លឺម៉ង់ ទំនាក់ទំនងរវាងការស្រាវជ្រាវផ្នែកបច្ចេកទេសនិងឧស្សាហកម្មប្រព្រឹត្តទៅបានយ៉ាងប្រសើរបំផុត ។

ប៉ុន្តែស្ថានភាពមានការប្រែប្រួល : សកម្មភាពស្រាវជ្រាវត្រូវបានទាក់ទាញ ដូចគ្នានិងសកម្មភាពផ្សេងៗទៀតដែរ ឆ្ពោះទៅភាគខាងត្បូង តំបន់ក្តៅ តំបន់ភ្នំ។ នៅប្រទេសអាល្លឺម៉ង់ ទីក្រុង ស្ទុតហ្គាត (Stuttgart)និង **មុយនិច** (Munich) បាននាំមុខទីក្រុងហាំបួ និងទីក្រុងទាំងឡាយនៃ តំបន់រួ (Ruhr)។ សកលវិទ្យាល័យនិងមន្ទីរពិសោធន៍ ច្រើនសាងសង់នៅទីជនបទ ឬទីក្រុងធុនមធ្យម នៅតំបន់មាត់សមុទ្រ ឬតំបន់ភ្នំ។

## ? សំណួរ

1. តើទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិក បានបំពេញមុខងារអ្វីខ្លះ ?
2. តើម៉ិនហាថិន(Manhattan)ជាអ្វី ? ម៉ិនហាថិនចែកចេញជាប៉ុន្មានផ្នែក។ ចូរនិយាយអំពីផ្នែកនីមួយៗ។
3. ចូរនិយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់ទីក្រុងតូក្យូ។
4. តើទ្វីបអឺរ៉ុបមានប៉ូលជំរុញសេដ្ឋកិច្ចនៅទីណាខ្លះ ? ចូរនិយាយអំពីមុខងារជំរុញសេដ្ឋកិច្ច របស់ទីក្រុងឡុង។
5. តើតំបន់រ៉ាំង-រួ ស្ថិតនៅទីណា ? តើទីក្រុងសំខាន់របស់តំបន់នេះមានឈ្មោះអ្វីខ្លះ ?
6. ចូរនិយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់តំបន់រ៉ាំង-រួ។
7. ចូរនិយាយអំពីមុខងារជំរុញសេដ្ឋកិច្ចរបស់តំបន់សាន់បែល របស់សហរដ្ឋអាមេរិក។
8. តើទ្វីបអឺរ៉ុបមានមជ្ឈមណ្ឌលបន្ទាប់បន្សំណាខ្លះ ? ចូររៀបរាប់។
9. តើប្រទេសកំពុងអភិវឌ្ឍមានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរឬទេ ? ចូរបង្ហាញ។
10. តើភូមិវិទ្យាមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ច កកើតឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី៥

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ទីក្រុងសំខាន់របស់ប្រទេសមួយឬតំបន់មួយ ដែលមានឥទ្ធិពលទៅលើទីក្រុងដទៃទៀតហៅថា

☐ក. ប៉ូលសេដ្ឋកិច្ច ☐ខ. មេត្រូប៉ូល

☐គ. មេកាប៉ូល ☐ឃ. មេកាឡូប៉ូល

2. ជោហានេសបួ (Johannesburg) ជាទីក្រុងសំខាន់មួយនៅ

☐ក. អាហ្វ្រិកខាងជើង ☐ខ. អាហ្វ្រិកណ្ដាល

☐គ. អាហ្វ្រិកខាងត្បូង ☐ឃ. អាហ្វ្រិកខាងកើត

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. អំណាចហិរញ្ញវត្ថុមួយគ្មានគូប្រៀប មាននៅម៉ារូនូជី(ជប៉ុន) វ៉លស្ទ្រីត(សហរដ្ឋអាមេរិក) និង................................. ។

2. តំបន់ត្រីប៉ូលស៊ីសមានទីក្រុងបីគឺ បាល .................... និង ....................... ។

3. ត្រីប៉ូល(Triade) គឺជាប៉ូលជំរុញសេដ្ឋកិច្ចពិភពលោកទាំងបីមាន សហរដ្ឋអាមេរិក .............. និង ................ ។

4. អចលនវត្ថុបញ្ជាប្រើសម្រាប់សម្គាល់.............................ដែលកើតមានជាបន្តបន្ទាប់នៅប្រទេសជប៉ុន ។

5. នៅទ្វីបអាស៊ីមានទីក្រុងបីដែលបានសម្រេចជោគជ័យក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនគឺ ទីក្រុងសិង្ហបុរី.................... និង.................... ។

III. សំណួរត្រិះរិះ

1. តើប្រព័ន្ធសេដ្ឋកិច្ចពិភពលោកគឺជាអ្វី ? ចូរពន្យល់ ។

2. តើអំណាចហិរញ្ញវត្ថុនិងអំណាចនៃការធ្វើសេចក្ដីសម្រេចសំខាន់ៗ មាននៅទីណាខ្លះ ? ចូររៀបរាប់ ។

3. តើទីក្រុងញូយ៉ករបស់សហរដ្ឋអាមេរិក បានបំពេញមុខងារសេដ្ឋកិច្ចអ្វីខ្លះ ? ចូរបង្ហាញ ។

4. តើប្រទេសកំពុងអភិវឌ្ឍមួយចំនួន មានមជ្ឈមណ្ឌលជំរុញសេដ្ឋកិច្ចដែរ ឬទេ ? ចូរពន្យល់ ។

5. តើគេអាចសម្គាល់ថា មជ្ឈមណ្ឌលមួយជាប៉ូលជំរុញសេដ្ឋកិច្ចបាន ដោយសារអ្វីខ្លះ ?

6. តើភូមិវិទ្យាប៉ូលជំរុញសេដ្ឋកិច្ចពិភពលោក កកើតឡើងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ ?

# ជំពូកទី 6 សហរដ្ឋអាមេរិក



សហរដ្ឋអាមេរិកមាន 50រដ្ឋ ។ រដ្ឋអាឡាស្កានិងកោះហាវ៉ៃត្រូវបានបញ្ចូលជារដ្ឋទី 49 និង 50 ក្នុងឆ្នាំ 1959 ។ ប្រទេសនេះ ជាប្រទេសមូលធននិយមដ៏ធំមួយក្នុងពិភពលោកដែលមានផ្ទៃដី 9 363 123 $km^2$ ជាប់ចំណាត់ថ្នាក់លេខ 4 បន្ទាប់ពីប្រទេសរុស្ស៊ី កាណាដា និងចិន ហើយធំជាងប្រទេសកម្ពុជា 52ដង ។ ផ្ទៃដីនេះផ្តល់សក្តានុភាពកសិកម្មនិងព្រៃឈើដ៏ធំធេង ព្រមទាំងមានភោគទ្រព្យរ៉ែជាច្រើនទៀត ។ ភាពធំធេងនៃផ្ទៃដី ភាពរប៉ាត់រប៉ាយនៃធនធានធម្មជាតិ និងតម្រូវការក្នុងការធ្វើដំណើររបស់ប្រជាជននិងការដោះដូរផលិតផល បានជំរុញឱ្យសហរដ្ឋអាមេរិកធ្វើការរៀបចំបណ្តាញគមនាគមន៍ដែលផ្តល់លទ្ធផលដ៏ប្រសើរ ។

សហរដ្ឋអាមេរិកជាសង្គមមួយដែលចម្រុះដោយជនជាតិ ហើយប្រទេសនេះជាប់លេខមួយក្នុងពិភពលោកខាងចំណូលស្រុក ។ ចំណែកសេដ្ឋកិច្ចប្រទេសនេះ ជាមហាអំណាចកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្មពិភពលោក ។

ជំពូកនេះ យើងនឹងលើកយកតែប្រព័ន្ធសេដ្ឋកិច្ច នយោបាយសហរដ្ឋអាមេរិកគ្រប់គ្រងលំហប្រជាជនសហរដ្ឋអាមេរិក និងលំហសេដ្ឋកិច្ចនៃសហរដ្ឋអាមេរិកមកសិក្សាប៉ុណ្ណោះ ។

# 1 ប្រព័ន្ធសេដ្ឋកិច្ច រដ្ឋបាល និងនយោបាយសហរដ្ឋអាមេរិក

**ចប់មេរៀននេះ សិស្សអាច**

☐ បកស្រាយនិងពន្យល់បានអំពីប្រព័ន្ធសេដ្ឋកិច្ច រដ្ឋបាល និងនយោបាយសហរដ្ឋអាមេរិក និងតួនាទីរបស់រដ្ឋសហព័ន្ធ ។

សហរដ្ឋអាមេរិក ជាប្រទេសមូលធននិងជាមហាអំណាចទី 1 ខាងសេដ្ឋកិច្ចពិភពលោក ។ ជីវិតសេដ្ឋកិច្ចរបស់ប្រទេសនេះ គឺការប្រកួតប្រជែងគ្នារវាងសហគ្រាសឯកជនក្នុងការស្វែងរកកំរៃផ្ទាល់ខ្លួន ។ តម្លៃដ៏សំខាន់របស់សហរដ្ឋអាមេរិក គឺសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការបង្កើតសហគ្រាស ។ សហរដ្ឋអាមេរិកជារដ្ឋសហព័ន្ធដែលមានរដ្ឋ 50 ហើយប្រជាជនមានដើមកំណើតពីជាតិសាសន៍ផ្សេងៗគ្នាជាច្រើន ។ រដ្ឋនីមួយៗមាន រដ្ឋធានី ច្បាប់ និងបុគ្គលិកលក្ខណៈរៀងៗខ្លួន ។ ស្ថាប័ននានាត្រូវបានបង្កើតដោយរដ្ឋធម្មនុញ្ញឆ្នាំ 1787 ដែលជារដ្ឋធម្មនុញ្ញមានចំណាស់ជាងគេលើពិភពលោក ។




រដ្ឋនៃសហរដ្ឋអាមេរិក

# 1. សហរដ្ឋអាមេរិកជាប្រទេសមូលធននិយមមួយដ៏សំខាន់

## 1.1. គ្រឹះនៃអរិយធម៌អាមេរិក

គោលការណ៍ពីរដែលជាប្រភពនៃកំណត់កំណើតប្រជារាស្ត្រអាមេរិក ហើយដែលមានចែងនៅក្នុងសេចក្តីប្រកាសឯករាជ្យនាថ្ងៃទី 4 ខែ កក្កដា ឆ្នាំ 1776 គឺ

- មនុស្សគ្រប់រូបមានសិទ្ធិរស់នៅដោយស្មើភាពគ្នា(សមភាព) និងប្រកបដោយសុភមង្គល ។
- សេរីភាពបុគ្គលដែលជាគោលការណ៍មួយ បង្កលក្ខណៈល្អចំពោះការពង្រីងបុគ្គលភាព ហើយកម្មសិទ្ធិឯកជនអាចឱ្យមនុស្សម្នាក់ៗទាញផ្លែផ្កាពីការងាររបស់គេ ។

រដ្ឋាភិបាលអាមេរិកត្រូវធានានូវសិទ្ធិជាមូលដ្ឋានទាំងឡាយរបស់បុគ្គលម្នាក់ៗ ។ ក៏ប៉ុន្តែ បុគ្គលម្នាក់ៗក៏ត្រូវតែអនុវត្តកាតព្វកិច្ចបញ្ចេញពលកម្មដើម្បីចិញ្ចឹមជីវិតផងដែរ ។ ការគោរពដាច់ខាតចំពោះបុគ្គល ជំនឿលើការងារសង្គមនិងសហគមន៍ ជាមាគ៌ារស់នៅនៃសង្គមអាមេរិក ។

កម្លាំងចលករនៃជីវិតសេដ្ឋកិច្ចអាមេរិក គឺការប្រកួតប្រជែងគ្នារវាងសហគ្រាសឯកជន ក្នុងការស្វែងរកប្រាក់ចំណេញរៀងៗខ្លួន ។ គន្លឹះដ៏សំខាន់ក្នុងសង្គម គឺសេរីភាពរបស់បុគ្គលម្នាក់ៗក្នុងការបង្កើតសហគ្រាស ដែលជាតម្លៃសារវន្តសម្រាប់សហរដ្ឋអាមេរិក ។ ប្រព័ន្ធសេដ្ឋកិច្ចនោះផ្អែកលើច្បាប់ទីផ្សារ គឺការពង្រីកទីផ្សារ តម្រូវការនៃគំនិតច្នៃប្រឌិត និងផលិតភាពការងារខ្ពស់ដើម្បីយកឈ្នះ លើគូប្រជែង ។

## 1.2. សម័យកាលនៃសហគ្រាសធំៗ

សេរីនិយមខាងសេដ្ឋកិច្ចធ្វើឱ្យអ្នកបង្កើតសហគ្រាសធំៗប្រឈមមុខនឹងជម្រើសមួយដ៏លំបាក ។ សហគ្រាសតូចៗជាងពីរភាគបីដែលកើតឡើងរៀងរាល់ឆ្នាំនោះត្រូវរលាយបាត់ទៅវិញក្នុងអំឡុងពេល 5ឆ្នាំ ហើយកសិដ្ឋានប្រមាណ 3 លាន ក៏ត្រូវរលាយរូបដែរក្នុងរយៈពេល 30 ឆ្នាំ ។ ក្រុមហ៊ុនសហគ្រាសអនាមិកទាំងអស់សម្រេចបាន 80% នៃទឹកប្រាក់ជំនួញរបស់សហគ្រាសអាមេរិក ។ ដើមទុនរបស់គេបានមកពីអ្នកចូលហ៊ុនរាប់លាននាក់និងអ្នកវិនិយោគដទៃទៀត ។ ពួកចុងក្រោយនេះ ជាអ្នកគ្រប់គ្រងមូលធនដ៏សម្បើម ។ សហគ្រាសធំៗបង្ហាញពីចរិតលក្ខណៈនៃប្រព័ន្ធសេដ្ឋកិច្ចអាមេរិក ។ ទោះបីក្រុមហ៊ុនតូចៗមានសមត្ថភាពបង្កើតរបៀបថ្មីៗក៏ដោយ ក៏ក្រុមហ៊ុនទាំងនោះគេចមិនផុតពីការលេបត្របាក់របស់ក្រុមហ៊ុនធំៗ ដែលមានមូលធនដ៏ច្រើនសន្ធឹកសន្ធាប់បានឡើយ ។

សព្វថ្ងៃ ក្រុមហ៊ុនសហរដ្ឋអាមេរិកស្ថិតក្នុងចំណោមក្រុមហ៊ុនធំជាងគេលើពិភពលោកទាំង 100 ។ ក្រុមហ៊ុនឧស្សាហកម្មធំជាងគេប្រមាណ 500 តាងឱ្យប្រហែល 85 % នៃសកម្មភាពទូទាំងប្រទេស ។ សហគ្រាសពហុជាតិបានបង្កើនឥទ្ធិពលខាងការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ដោយធ្វើវិនិយោគទុនអស់យ៉ាងច្រើន ។ ក្នុងវិស័យនេះ អាមេរិកផ្តល់ឥណទានរហូតដល់ 362 700 លានដុល្លារអាមេរិក ស្មើនឹង 2.6% នៃផលិតផលក្នុងស្រុកសរុបដែលមាន 13 844 000 លានដុល្លារ គឺលើសសហគមន៍អឺរ៉ុប ដែលប្រើឥណទានអស់ 274 200 លានដុល្លារអាមេរិក ស្មើនឹង 1.7% នៃផលិតផលក្នុងស្រុកសរុប និងលើសអាស៊ីដែលប្រើឥណទានអស់ 334 400 លានដុល្លារអាមេរិក ស្មើនឹង 1.9% នៃផលិតផលក្នុងស្រុកសរុប (ឆ្នាំ 2007 : IMAGES ECONOMIQUES DU MONDE 2010) ។ សហគ្រាសឧស្សាហកម្មនិងមន្ទីរពិសោធន៍នៅតាមសកលវិទ្យាល័យមានទំនាក់ទំនងគ្នាយ៉ាងល្អក្នុងការបញ្ចូលនិងបង្កើតរបៀបថ្មីដោយសហគ្រាសធំៗជាអ្នកផ្តល់ជំនួយឧបត្ថម្ភដ៏ច្រើនដល់មន្ទីរពិសោធន៍នៃសកលវិទ្យាល័យទាំងនោះ ។

- ការធ្វើវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងពិភពលោកឆ្នាំ 2007 (គិតជាលានដុល្លារ US)

| ប្រទេសនិងតំបន់ផ្សេងៗ | ផលិលផលក្នុងស្រុកសរុប | ការស្រាវជ្រាវនិងអភិវឌ្ឍន៍ | ភាគរយស្រាវជ្រាវធៀបនឹងផលិតផលក្នុងស្រុកសរុប |
|---|---|---|---|
| សរុបពិភពលោក | 54 685 000 | 1 057 000 | 1.9 |
| សហរដ្ឋអាមេរិក | 13 844 000 | 362 000 | 2.6 |
| សហគមន៍អឺរ៉ុប | 15 851 000 | 274 200 | 1.7 |
| អាល្លឺម៉ង់ | 2 810 000 | 70 500 | 2.5 |
| បារាំង | 2 047 000 | 43 400 | 2.1 |
| រាជាណាចក្ររួម | 2 137 000 | 38 000 | 1.8 |
| អាស៊ី | 17 267 000 | 334 400 | 1.9 |
| ជប៉ុន | 4 290 000 | 142 900 | 3.3 |
| ចិន | 6 991 000 | 100 000 | 1.4 |
| ឥណ្ឌា | 2 989 000 | 20 600 | 0.7 |
| កូរ៉េខាងត្បូង | 1 201 000 | 35 800 | 3.0 |

*ប្រភព : រូបភាពសេដ្ឋកិច្ចពិភពលោកឆ្នាំ 2010*

ក្រៅពីសហគ្រាសឧស្សាហកម្មថាមពល រថយន្ត អេឡិចត្រូនិច និងបរិក្ខារអគ្គិសនី សហរដ្ឋអាមេរិកបានឈានមុខគេក្នុងឧស្សាហកម្មប្រណិតមួយចំនួនធំដូចជា កុំព្យូទ័រនិងផ្នែកព័ត៌មានវិទ្យា ឧបករណ៍បង្កើតពាក្យតូចៗ ផ្នែកអវកាស ផលិតផលឱសថ ជីវៈតិចណូឡូស៊ី សម្ភារៈថ្មីៗ និងការស្រោចស្រង់បរិស្ថាន ។

ឧស្សាហកម្មសេវាក៏ជាវិស័យមួយទៀតរបស់សហរដ្ឋអាមេរិកដែលមានក្រុមហ៊ុនល្បីល្បាញរាយពាសពេញពិភពលោក ។ ពុំមានបណ្តាញអឺរ៉ុប ឬជប៉ុនខាងអាហាររហ័ស (Fast Food) ណាដែលអាចប្រកួតជាមួយ ម៉ាក់ដូណាល់(Mc Donald's) ភីសាហ៊ុត(Piza Hut) ឬខិនថឹកឃីឈីខិន(Kentucky Chicken)របស់អាមេរិកបានឡើយ ។

## 1.3. កម្លាំងប្រឆាំងសហគ្រាស

ដើម្បីប្រឆាំងនិងឥទ្ធិពលរបស់សហគ្រាសធំៗ សមាគមមួយចំនួនដែលជាកម្លាំងប្រឆាំង ត្រូវបានគេបង្កើតឡើង ។ ក្នុងនោះ គេឃើញមានសមាគមការពារបរិស្ថាន ឬសមាគមអ្នកប្រើប្រាស់ដែលផ្តល់តួនាទីសំខាន់ដល់ពួកអ្នកប្រើប្រាស់ ។ សហជីពនិយមបានរីកដុះដាលតាំងពីអំឡុងឆ្នាំ 1960 នៃសតវត្សទី 20 ក្រោមរូបភាពជាសហជីពតាមមុខវិជ្ជាជីវៈ ហើយបន្ទាប់មកក្រោមរូបភាពជាសហជីពឧស្សាហកម្ម ។ សហគ្រាសនីមួយៗអាចមានសហជីពមួយដែលមានតួនាទីជាអ្នកចរចាជាមួយម្ចាស់សហគ្រាស ។ សហជីពភាគច្រើនប្រមូលផ្តុំនៅក្នុងសហជីពកណ្តាលដ៏ធំមួយ ( A.F.L = American Federation of Labour)និងនៅក្នុងអង្គការសមាជ (C.I.O = Congress for Industriel Organization) ។ បន្ទាប់ពីមានការប្រតិបត្តិខុសបទបញ្ជា ជាពិសេសនៅអំឡុងឆ្នាំ 1980 បានធ្វើឱ្យសកម្មភាពសហជីពត្រូវចុះថយ ។ ក្នុងវិស័យសេវាកម្ម គេឃើញអត្រានៃការចូលជាសមាជិកសហជីពមានតិចជាង 7% ។

# 2. លទ្ធិប្រជាធិបតេយ្យនិងសហព័ន្ធនិយម

## 2.1. ជារដ្ឋសហព័ន្ធមួយ

ប្រជាជាតិអាមេរិកពុំដែលស្គាល់បដិវត្តន៍ឬរបបផ្តាច់ការឡើយ ។ សហរដ្ឋអាមេរិកជារដ្ឋសហព័ន្ធមួយដែលមានរដ្ឋចំនួន 50 ហើយដែលប្រជាជនមានដើមកំណើតផ្សេងគ្នាជាច្រើនជាតិសាសន៍និងពណ៌សម្បុរ ។ រដ្ឋនីមួយៗមានរដ្ឋធានី ច្បាប់ និងបុគ្គលិកលក្ខណៈរបស់ខ្លួន ។ ស្ថាប័ននានាបានត្រូវបង្កើតឡើងដោយរដ្ឋធម្មនុញ្ញឆ្នាំ 1787 ។ រដ្ឋធម្មនុញ្ញនេះជាស្ថាប័នដែលមានចំណាស់ជាងគេលើពិភពលោក ហើយដែលជនជាតិអាមេរិកយកចិត្តទុកដាក់អនុវត្តយ៉ាងខ្លាំង ។ រដ្ឋសហព័ន្ធឈរលើការបែងចែកអំណាចនិងការត្រួតពិនិត្យគ្នាទៅវិញទៅមកនៃអំណាចទាំងបីគឺ អំណាចនីតិប្រតិបត្តិ (ប្រធានា

ធិបតី) អំណាចនីតិប្បញ្ញត្តិ(សភា) និងអំណាចតុលាការ(តុលាការកំពូល)។ ដើមដំបូង គេបានរៀបចំអំណាចទាំងបីនេះ ដើម្បីពង្រឹងសហព័ន្ធ ធានារ៉ាប់រងយុត្តិធម៌ រក្សាសន្តិសុខក្នុងស្រុក និងកិច្ចការពាររួម។ រដ្ឋសហព័ន្ធបានពង្រីកមុខការនិងសមត្ថភាព ជាពិសេសលើវិស័យនយោបាយក្រៅប្រទេសនិងវិស័យសេដ្ឋកិច្ចដើម្បីជាប្រយោជន៍ដល់ប្រធានាធិបតី។ ប្រធានាធិបតីត្រូវបានគេជ្រើសរើសតាមរយៈការបោះឆ្នោតជាសកលពីសំណាក់ប្រជាពលរដ្ឋសម្រាប់អាណត្តិរយៈពេល 4ឆ្នាំ។ ប្រធានាធិបតីអាចឈរឈ្មោះយ៉ាងច្រើនបានពីរដង។ ប្រធានាធិបតីមានទីប្រឹក្សាជាច្រើននិងរដ្ឋលេខាធិការគ្រប់ក្រសួងជាជំនួយ។ រដ្ឋលេខាធិការក្រសួងនីមួយៗមានភារកិច្ចទទួលខុសត្រូវចំពោះមុខប្រធានាធិបតី។ ប្រធានាធិបតីនិងព្រឹទ្ធសភា អាចត្រួតពិនិត្យគ្នាទៅវិញទៅមកលើផ្នែកខ្លះៗ ហើយព្រឹទ្ធសភាពុំអាចផ្តួលរំលំប្រធានាធិបតីបានឡើយ ប៉ុន្តែអាចបង្កើតសម្ពាធទៅលើប្រធានាធិបតី ពីព្រោះព្រឹទ្ធសភាជាអ្នកបោះឆ្នោតសម្រេចឥណទាន។ ឯប្រធានាធិបតីវិញ ក៏ពុំអាចរំលាយព្រឹទ្ធសភាបានដែរ ប៉ុន្តែមានសិទ្ធិជំទាស់ចំពោះព្រឹទ្ធសភាដែលមិនអនុម័តច្បាប់តាមការស្នើសុំ។

## 2.2. រដ្ឋទាំង 50

រដ្ឋនីមួយៗនៃសហព័ន្ធ មានអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ អំណាចនីតិប្រតិបត្តិកាន់កាប់ដោយទេសាភិបាលម្នាក់ដែលជាប់ដោយការជ្រើសតាំង ហើយអំណាចនីតិប្បញ្ញត្តិមានសភាពីរ ដែលជាប់ដោយការជ្រើសតាំងដែរ។ រដ្ឋនីមួយៗមានតំណាងពីររូបធ្វើការនៅព្រឹទ្ធសភា (សមាជ)។ សិទ្ធិរបស់រដ្ឋនីមួយៗសំខាន់ខ្លាំងណាស់ក្នុងវិស័យសង្គមនិងអប់រំ។ ខាងវិស័យអប់រំសហរដ្ឋអាមេរិកពុំមានប្រព័ន្ធឯកភាពគ្នាទេ។

## 2.3. តួនាទីនៃរដ្ឋសហព័ន្ធ

គោលការណ៍នៃសហគ្រាសសេរីពុំដែលទទួលការបោះបង់ចោលឡើយ។ តួនាទីរបស់រដ្ឋមិនមែនដើម្បីត្រួតត្រាសហគ្រាសទេ ប៉ុន្តែនៅពេលដែលសហគ្រាសទាំងនោះប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គម រដ្ឋសហព័ន្ធត្រូវធ្វើអន្តរាគមន៍ ដូចជាខាងវិស័យដឹកជញ្ជូន ថាមពលនិងកិច្ចការពារបរិស្ថានជាដើម។ ឯរដ្ឋមានតួនាទី ជាអ្នកត្រួតពិនិត្យនិងដាក់បទវិន័យតែប៉ុណ្ណោះ។ រដ្ឋផ្តល់ជំនួយដល់វិស័យកសិកម្ម នៅពេលដែល កសិករមានបំណុលដោយឱ្យលុយពួកគេខ្ចី ដើម្បីបង្កើនសមត្ថភាពខាងការរក្សាទុកគ្រឿងឧបភោគបរិភោគកសិកម្មឱ្យបានត្រឹមត្រូវ។

រដ្ឋក៏ធ្វើអន្តរាគមន៍ផងដែរក្នុងវិស័យផ្សេងៗនៃសេដ្ឋកិច្ចដោយផ្តល់ហិរញ្ញវត្ថុដល់ការស្រាវជ្រាវ។ រដ្ឋចំណាយទឹកប្រាក់ប្រមាណ 3.5% នៃផលិតផលក្នុងស្រុកសរុប ចំពោះកិច្ចការពារជាតិ(2003)

7.2% នៃផលិតផលក្នុងស្រុកសរុបសម្រាប់វិស័យសុខាភិបាល(2005) និង 5.6% សម្រាប់វិស័យអប់រំ (2004)។ នៅឆ្នាំ 2008 ដោយសារមានវិបត្តិជាមួយប្រទេសអ៊ីរ៉ាក់និងអាហ្វហ្គានីស្ថាន អាមេរិកបានបង្កើនការចំណាយទៅលើកិច្ចការពារប្រទេសខ្ពស់បំផុតឈានមុខគេ រហូតដល់ចំនួនថវិកា 607 000 លានដុល្លារអាមេរិក គឺស្មើនឹង 41% នៃការចំណាយសរុបទូទាំងពិភពលោក ដែលមាន 1 464 000 លានដុល្លារអាមេរិក មិនតែប៉ុណ្ណោះ រដ្ឋបញ្ជាទិញរោងចក្រនុយក្លេអ៊ែរ អាវុធយុទ្ធភណ្ឌ យន្តហោះ ហើយក៏គាំទ្រសហគ្រាសឯកជនជាច្រើនដែរ។ ក្រៅពីការទទួលខុសត្រូវលើវិស័យអប់រំ ការពារជាតិ និងនយោបាយសង្គមសេដ្ឋកិច្ច រដ្ឋទាំង 50 របស់សហព័ន្ធបានទទួលខុសត្រូវលើផ្នែកគមនាគមន៍ដើម្បីសម្រួលដល់ចរាចរណ៍របស់ប្រជាជននិងសម្រួលក្នុងការដឹកជញ្ជូន វិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។

## ? សំណួរ

1. តើសេដ្ឋកិច្ចអាមេរិកផ្អែកលើគ្រឹះអ្វីខ្លះ ?
2. ដើម្បីពង្រីកទីផ្សារ តើសេដ្ឋកិច្ចអាមេរិកផ្អែកលើច្បាប់ទីផ្សារដូចម្ដេចខ្លះ ?
3. ហេតុអ្វីបានជាសហគ្រាសតូចៗនិងកសិដ្ឋានត្រូវរលាយបាត់រូប ? ដើម្បីជំរុញការស្រាវជ្រាវរបៀបថ្មីៗ តើសហគ្រាសធំៗធ្វើយ៉ាងដូចម្ដេច ?
4. តើសហគ្រាសអាមេរិកឈានមុខគេ លើផ្នែកសកម្មភាពអ្វីខ្លះ ?
5. តើឧស្សាហកម្មសេវាអ្វីខ្លះ ដែលល្បីល្បាញរាយពាសពេញពិភពលោក ? ហេតុអ្វី ?
6. តើគេបង្កើតសហជីពដើម្បីអ្វី ?
7. តើរដ្ឋនីមួយៗនៃសហព័ន្ធមានអំណាចអ្វីខ្លះ ដើម្បីគ្រប់គ្រង ? ប្រធានាធិបតីមានអាណត្តិប៉ុន្មានឆ្នាំ ? ហើយអាចឈរឈ្មោះឱ្យគេបោះឆ្នោតបានប៉ុន្មានដង ?
8. តើរដ្ឋសហព័ន្ធ ធ្វើអន្តរាគមន៍ទៅលើបញ្ហាអ្វីខ្លះ ?

មេរៀនទី

# 2 សហរដ្ឋអាមេរិកគ្រប់គ្រងលំហ

**ចប់មេរៀននេះ សិស្សអាច**

- □ អាចបកស្រាយបានពីវិសាលភាពរបស់សហរដ្ឋអាមេរិកនិងសារៈសំខាន់របស់វា និងពន្យល់បានពីភាពរីកចម្រើននៃវិស័យគមនាគមន៍ ដែលជាកត្តាជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនេះ ។

ភាពធំធេងនៃផ្ទៃដី ភាពសំបូរបែបនៃធនធានធម្មជាតិ និងទីតាំងភូមិសាស្ត្រជាគ្រឹះមួយនៃមហាអំណាចសហរដ្ឋអាមេរិក ។ លក្ខណៈនេះបានធ្វើឱ្យអាមេរិកក្លាយជាប្រទេសមហាសេដ្ឋីនិងជាមហាអំណាចខាងបណ្ដាញដឹកជញ្ជូននិងគមនាគមន៍ក្នុងពិភពលោក ។




*បណ្ដាញការដឹកជញ្ជូននៅសហរដ្ឋអាមេរិក*

# 1. វិសាលភាពជាគ្រឹះមួយនៃអានុភាពរបស់សហរដ្ឋអាមេរិក

សហរដ្ឋអាមេរិកមាន 50រដ្ឋ ។ រដ្ឋអាឡាស្កា (ទិញពីរុស្សីនៅឆ្នាំ 1867) និងរដ្ឋហាវ៉ៃ (បញ្ចូលជាឧបសម្ព័ន្ធនៅឆ្នាំ 1898) ត្រូវបានបញ្ចូលជារដ្ឋទី 49 និងទី 50 ក្នុងឆ្នាំ 1959 ។ ប្រទេសនេះជាប្រទេសមូលធននិយមដ៏ធំមួយនៅក្នុងពិភពលោក មានផ្ទៃដី 9 363 520 km$^2$ ជាប់ចំណាត់ថ្នាក់ទី 4 បន្ទាប់ពីប្រទេសរុស្សី កាណាដា និងចិន ហើយធំជាងប្រទេសកម្ពុជា 52ដង និងមានទំហំប៉ុនទ្វីបអឺរ៉ុប ។ រដ្ឋ 48 នៅក្បែរៗជាផ្ទាំងតែមួយ ហើយរដ្ឋពីរទៀតនៅឆ្ងាយពីគេ គឺរដ្ឋអាឡាស្កា នៅជាប់ប្រទេសកាណាដាប៉ែកខាងជើង និងកោះហាវ៉ៃ ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ។ ពីកើតទៅលិច គឺពីទីក្រុងញូយ៉ក ទៅសាន់ហ្វ្រាន់ស៊ីស្កូ មានប្រវែង 4 500 km និងពីជើងទៅត្បូង គឺពីព្រំប្រទល់ប្រទេសកាណាដាទៅប្រទេសម៉ិចស៊ិក មានប្រវែង 2 500 km ។ វិសាលភាពនេះផ្តល់សក្តានុពលកសិកម្មនិងព្រៃឈើដ៏ធំធេង ។ ដីដាំដំណាំគ្របដណ្តប់ 1/5 នៃផ្ទៃដី ។ នៅតំបន់ខាងជើងគេដាំស្មៅនិងស្រូវសាលី ហើយនៅតំបន់ខាងត្បូងគេដាំកប្បាស ស្រូវ និងក្រូច ។ កោះហាវ៉ៃសំបូរដំណាំម្នាស់ រដ្ឋកាលីហ្វ័រនី សំបូរដំណាំទំពាំងបាយជូរ និងរដ្ឋអាឡាស្កាសំបូររ៉ែប្រេងកាត សំណ និងស័ង្កសី ។

ចម្ងាយឆ្នេរប្រវែង 20 000 km និងសណ្ឋានដី បានបង្កលក្ខណៈដ៏ល្អចំពោះអាជីវកម្មក្នុងលំហសមុទ្រ ។ កំពង់ផែធំៗសំខាន់ៗមាន ញូយ៉ក ហ្វីឡាដែលហ្វី បាល់ទីម័រ ស៊ីថល នូវ៉ែលអ័រឡេអង់ ឡូសអង់សឺឡែស សាន់ហ្វ្រាន់ស៊ីស្កូ ។ ការសណ្តូកដ៏វែងលើរយៈបណ្តោយនិងរយៈទទឹង ព្រមទាំងជំនួបនៃចរន្តទឹកសមុទ្រក្នុងលំហនៃឆ្នេរអាត្លង់ទិក បញ្ជាក់ឱ្យយើងដឹងថា សហរដ្ឋអាមេរិក សំបូរធនធានធម្មជាតិនិងមានសកម្មភាពនេសាទយ៉ាងខ្លាំងក្លា ។

# 2. មជ្ឈដ្ឋានធម្មជាតិ

## 2.1. ភាគខាងកើត(ភ្នំអាប៉ាឡាស)

ជួរភ្នំអាប៉ាឡាស លាតសន្ធឹងពីជើងទៅត្បូង ជាភ្នំចាស់សឹករេចរិលមានប្រវែងបណ្តោយ 1 500 km ទទឹងពី 200 km ទៅ 300 km និងមានកម្ពស់ខ្សោយ គឺមិនលើសពី 2 000 m ឡើយ ដែលងាយស្រួលក្នុងការឆ្លងកាត់ ។ ភ្នំនេះមានចំណោតខេរនៅផ្នែកខាងលិច ហើយមានចំណោតខ្លាំងនៅប៉ែកខាងកើត ។ ជួរភ្នំអាប៉ាឡាសផ្តល់ប្រយោជន៍ដល់សេដ្ឋកិច្ចខ្លាំងណាស់ ព្រោះសំបូរទៅដោយកំណប់រ៉ែដែក ប្រេងកាត ជាពិសេសរ៉ែធ្យូងថ្ម ដែលតាំងពីសតវត្សទី 19មកបានបង្កលក្ខណៈដ៏រឹងមាំមួយដល់ការអភិវឌ្ឍឧស្សាហកម្មដែកថែបឱ្យមានការរីកចម្រើន ។ ជួរភ្នំនេះក៏ផ្តល់សក្តានុពលខាងធារាសាស្ត្រផងដែរ ។ ទំនប់ទឹកជាច្រើនបានដើរតួនាទីជាចម្បងក្នុងឧស្សាហកម្មនិងរបាយក្រុង ។ នៅឆ្នាំ

1930 គេបានចាប់ផ្ដើមកសាងទំនប់វារីអគ្គិសនីមួយកន្លែងលើទន្លេ គេនៅស៊ីនិងកសាងបន្ដថែមទៀតជាច្រើន ដែលសព្វថ្ងៃមានលើសពី 40កន្លែង ។ នៅឆ្នាំ 2008 សហរដ្ឋអាមេរិក ជាប់ចំណាត់ថ្នាក់ទី 4 ផ្នែកវារីអគ្គិសនី បន្ទាប់ពី ចិន កាណាដា និងប្រេស៊ីល ដែលមានចំណែក 7.9% នៃផលិតផលសរុបពិភពលោក ។

## 2.2. ទំនាបកណ្ដាល

ទំនាបកណ្ដាលមានផ្ទៃដីធំធេង រាបស្មើស្ទើរតែទាំងអស់ លើកលែងតែកូនភ្នំខ្លះៗចុំណោះដូចជាភ្នំ អូសាក(Ozark) ជាដើម ។ ទំនាបនេះលាតសន្ធឹងពីភ្នំ អាប៉ាឡាសទៅភ្នំថ្ម និងពីបឹងធំទៅឈូងម៉ិកស៊ិក មានប្រវែងប្រមាណ 1 500 km ។

នៅប៉ែកខាងជើងបឹងធំទាំង 5 គឺបឹងលើ(បឹងស៊ុបប៉េរីយ័រ) បឹងមីស៊ីកេន បឹងអេរីយេ បឹងអុងតារីយ៉ូ និងបឹងហ៊្យូរុន ដែលមានកំណើតតាំងពីសម័យទឹកកកនៃស័កទី 4 ធ្វើឱ្យដីតំបន់នេះពុំសូវមានជីជាតិ ។ នៅខាងត្បូង មានទំនាបធំៗប្រកបដោយដីមានជីជាតិសម្រាប់ដំណាំ ជាតំបន់កសិកម្មដ៏ខ្លាំងជាងគេរបស់សហរដ្ឋអាមេរិក ។

មីស៊ីស៊ីពី ជាទន្លេដ៏សំខាន់មានប្រវែង 4 000 km និងបើគិតទាំងស្ទឹងមីស្សួរីផងមានប្រវែង 4 800 km ជាប្រព័ន្ធផ្លូវទឹកវែងជាងគេក្នុងពិភពលោកបានហូរកាត់និងជ្រៀមតំបន់ទំនាបកណ្ដាល ។

តំបន់ទំនាបកណ្ដាលសំបូរទៅដោយរ៉ែដែក ។ នៅទីនោះ អណ្ដូងរ៉ែអ៊ីដ្រូកាបូធំៗចំនួនពីរ ដែលគេកំពុងធ្វើអាជីវកម្ម គឺមួយនៅលើទ្វីបនិងមួយទៀតនៅតាមឆ្នេរ (តំបន់តិចសាស់និងល្វីស្យាន) ។

## 2.3. ភាគខាងលិច (ភ្នំថ្ម)

តំបន់ប្រព័ន្ធភ្នំថ្ម ស្ថិតនៅភាគខាងលិចនៃសហរដ្ឋអាមេរិក ដែលមានជួរភ្នំផងនិងខ្ពង់រាបផង ។ ប្រព័ន្ធភ្នំថ្មចែកជា 3 ផ្នែក គឺភ្នំថ្មនៅខាងកើត ខ្ពង់រាប(ទូលំទូលាយ)នៅកណ្ដាល ដូចជាខ្ពង់រាបកូឡុំប៊ីយ៉ា និងជួរភ្នំក្មេងនៅខាងលិច ។ នៅប្របភ្នំ អាប៉ាឡាស មានទំនាបកំទេចកំណមួយ ដែលរីកធំពីទន្លេហាត់សុន ទៅឈូងម៉ិកស៊ិក ។ ជួរភ្នំថ្មនេះ ជារបាំងធម្មជាតិមួយដែលមានកម្ពស់លើសពី 4 000 m ប៉ុន្តែមិនបង្កើតជាឧបសគ្គដល់ចរាចរណ៍ទេ ។ ភ្នំថ្មសម្បូរដោយរ៉ែមានតម្លៃជាច្រើនដូចជាអ៊ុយរ៉ាញ៉ូម ប្រាក់ មាស និងប្រភពថាមពល ។ តំបន់អារីសូណា ផ្ដល់បរិមាណទង់ដែងដ៏ច្រើននិងផលិតកម្មថាមពលក៏ខ្លាំងក្លាណាស់ដែរ ឯអ៊ីដ្រូកាបូមាននៅកាលីហ្វ័រនីភាគខាងត្បូង អាឡាស្កា វីយ៉ូមីង វារីអគ្គិសនីមាននៅអាង កូឡូរ៉ាដូ និងកូឡុំប៊ីយ៉ា ហើយធ្យូងថ្មមាននៅវីយ៉ូមីង ។ ចំណែកឯនៅភូមិភាគនិរតីវិញសម្បូរទៅដោយពន្លឺព្រះអាទិត្យ ជាកត្តាសំខាន់ដែលធ្វើឱ្យភូមិភាគនេះក្លាយទៅជាលំនៅឋានសម្រាប់និវត្តជននិងជាតំបន់ទេសចរណ៍ ។ នៅកាលីហ្វ័រនីខាងត្បូងនិងអារីសូណា(អ្វាស៊ីស)

សកម្មភាពកសិកម្មមានភាពសម្បូរបែប ដោយសារភាពសម្បូរកម្តៅព្រះអាទិត្យនិងការធ្វើកសិកម្មបញ្ចូលទឹក។ ភាពសម្បូរបែបនៃទេសភាពដូចជា ភ្នំដីចំចេង កាញ៉ុង(អន្លង់ជ្រៅ) វាលលំហ ជួរភ្នំតាមតំបន់ឆ្នេរប្រកបដោយច្រាំងចោតនិង សោភ័ណភាពនៃទីតាំងបានជំរុញកិច្ចអភិវឌ្ឍផ្នែកសកម្មភាពទេស ចរណ៍។ ជារៀងរាល់ឆ្នាំឧទ្យានជាតិទាក់ទាញទេសចររាប់លាននាក់។

## 3. អាកាសធាតុ

សហរដ្ឋអាមេរិកមានអាកាសធាតុច្រើនបែប ហើយតំបន់ខ្លះមានអាកាសធាតុពិបាកទ្រាំ។ គេចែកតំបន់អាកាសធាតុជាបីផ្នែកធំៗ។

### 3.1. នៅតំបន់ខាងលិច

មានអាកាសធាតុមហាសមុទ្រលើជាយឆ្នេរចង្អៀតចន្លោះភ្នំនិងមហាសមុទ្រ។ ខាងជើង សាន់ហ្វ្រាន់ស៊ីស្កូ គេប្រទះអាកាសធាតុត្រជាក់បង្គួរ ត្រជាក់ប្រហែលនិងអាកាសធាតុនៅតំបន់អេកូស (ប្រទេសអង់គ្លេស) មានសីតុណ្ហភាពទៀងទាត់ សម្បូរភ្លៀង(លើសពី 1 m/ឆ្នាំ)។ តំបន់នេះមានឈើអំបូរស្រល់ច្រើន។ ហួសទៅត្បូងបន្តិចអាកាសធាតុមានលំនាំ មេឌីទែរ៉ាណេ។

### 3.2. លើភ្នំខាងលិចរហូតដល់ខ្សែបណ្តោយលេខ 100

មានអាកាសធាតុស្ងួត ហើយពិបាកទ្រាំ។ ខ្យល់ក្តៅបក់តាមចន្លោះភ្នំថ្ម ធ្វើឱ្យសីតុណ្ហភាពមានដល់ 20°C ដែលអាចរំលាយទឹកកកសំឡីបានយ៉ាងឆាប់រហ័សនៅរដូវផ្ការីក។ ក្នុងទំនាបធំៗ ចន្លោះកម្តៅនិងសម្ងួតមានកម្រិតខ្ពស់។ ដីច្រើនមានពណ៌ប្រផេះឬត្នោតខ្ចី។ ព្រៃមានដុះតែក្នុងជ្រលង ឬលើសណ្ឋានដីខ្ពស់ៗ។ មណ្ឌលវាលស្តិបលាតសន្ធឹងលើខ្ពង់រាបនិងភ្នំថ្ម។ វាលលំហដែលមានរុក្ខជាតិបន្លានិងអំបូរដំបងយក្ស លាតសន្ធឹងក្នុងរដ្ឋ អារីសូណា និងម៉ិកស៊ិកថ្មី។ ទំនាបខ្ពស់ៗខ្វះរុក្ខជាតិណាស់។ ខ្សែទឹកភ្លៀងខណ្ឌតំបន់ពីរឱ្យដាច់ពីគ្នា

- តំបន់ខាងលិច ជាតំបន់ដែលត្រូវការបញ្ចូលទឹកក្នុងស្រែចំការ
- តំបន់ខាងកើត ជាតំបន់ដែលមានទឹកគ្រប់គ្រាន់។

### 3.3. តំបន់អាត្លង់ទិក

មានអាកាសធាតុកណ្តាលទ្វីប។ ខ្សែទឹកត្រជាក់ឡាប្រាដរ ធ្វើឱ្យរដូវត្រជាក់លើឆ្នេរខាងជើងកាន់តែត្រជាក់ខ្លាំងថែមទៀត។ ភ្លៀងធ្លាក់នៅរដូវក្តៅមានកម្ពស់ 0.5m នៅខាងជើង និង 1m នៅខាងត្បូង។ អាកាសធាតុនេះធ្វើឱ្យរុក្ខជាតិដុះលូតលាស់បានល្អ។ តំបន់ខាងជើងជាមណ្ឌលព្រៃមានស្លឹកតាមរដូវ លាយឡំដោយឈើអំបូរស្រល់កាន់តែច្រើនឡើងៗនៅក្បែរទន្លេសាំងឡូរ៉ង់។ ប៉ុន្តែ នៅខាង

លិចទន្លេ មីស៊ីស៊ីពី មានវាលស្មៅនិងដីពណ៌ខ្មៅប្រហាក់ប្រហែលដី ឈែណូស្យូម នៅប្រទេសរុស្ស៊ី ។ ក្បែរឈូងមិុកស៊ិក នៅរដូវក្តៅខ្យល់បក់មកពីសមុទ្រ(ខ្យល់ត្រជាក់) ឆ្ពោះទៅរកទ្វីប(ខ្យល់ក្តៅ) ។ តំបន់ខាងត្បូង-កើត ទទួលខ្យល់មូសុងសើម ដែលមានសំពាធយ៉ាងខ្សោយ ហ្វារីកាន សាហាវដូចព្យុះទីផុងនៅចុងបូព៌ាដែរ ។ នៅរដូវត្រជាក់មានភ្លៀងធ្លាក់ម្តងម្កាលដែរ ។

ដូច្នេះយើងឃើញថា អាកាសធាតុអាមេរិកមានច្រើនបែប ហើយពុំមានលក្ខណៈពិបាកទ្រាំពេកទេ ទោះជានៅតំបន់ខាងត្បូងដែលមានរយៈទទឹងប្រហែលវាលលំហសាហារ៉ាក៏ដោយ(ឈូងមិុកស៊ិក) អាកាសធាតុបែបនេះ ជាកត្តានាំឱ្យមានដំណាំច្រើនយ៉ាង ទាំងដំណាំត្រជាក់បង្គួរ ទាំងដំណាំតំបន់ត្រូពិក ដូចជាស្រូវ កប្បាស ពោត ក្រូច អំពៅ។ល ។

# 4. បណ្តាញដឹកជញ្ជូននិងគមនាគមន៍ដ៏អស្ចារ្យ

## 4.1. គ្រឹះសំខាន់មួយនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក

ការដឹកជញ្ជូននិងគមនាគមន៍ ពុំអាចកាត់ផ្តាច់ពីការអភិវឌ្ឍសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានឡើយ ។ ភាពធំធេងនៃដែនដី ភាពរាយប៉ាយនៃប្រជាជន ភោគទ្រព្យ និងសកម្មភាព តម្រូវការយ៉ាងខ្លាំងក្លាក្នុងការដើរហើររបស់ប្រជាជននិងការដោះដូរផលិតផលក្នុងសេដ្ឋកិច្ចមួយដែលមានការលូតលាស់ទាំងវិស័យឧស្សាហកម្មនិងកសិកម្មបានជំរុញឱ្យមានការរៀបចំការដឹកជញ្ជូននិងគមនាគមន៍ដោយប្រើប្រាស់កម្លាំងសកម្មរាប់លាននាក់ ។

## 4.2. គមនាគមន៍

### ក. ផ្លូវដែក

ផ្លូវដែកនៅតែជាមធ្យោបាយដឹកជញ្ជូនលេខ ១ ។ នៅសហរដ្ឋអាមេរិក ពិសេសការដឹកជញ្ជូនទំនិញ ។ បណ្តាញញឹកមានតែនៅតំបន់ខាងកើតទេ ។ ផ្លូវដែកកាត់ទ្វីបភ្ជាប់តំបន់មហាសមុទ្រប៉ាស៊ីហ្វិកទៅមហាសមុទ្រអាត្លង់ទិក ។ ផ្លូវដែកកាត់ទ្វីបទី 1 បានធ្វើហើយនៅឆ្នាំ 1869 ដោយភ្ជាប់ពីក្រុងញូយ៉កទៅសាន់ហ្វ្រាន់ស៊ីស្កូ ។ ផ្លូវដែកមានប្រវែងសរុប 310 000 km ។ ប៉ុន្តែជាង 50ឆ្នាំចុងក្រោយនេះ ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវដែកត្រូវចុះថយយ៉ាងខ្លាំង ដោយសារគេនិយមធ្វើដំណើរតាមផ្លូវថ្នល់វិញ តែផ្លូវដែកនៅតែមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកជញ្ជូនទំនិញដដែល ។ គម្រោងអភិវឌ្ឍន៍ផ្លូវដោយប្រើប្រាស់រថភ្លើងល្បឿនលឿន (TGV) មាននៅ ផ្លរីដា ឡូសអង់សឺឡែស ញូយ៉ក ស៊ិកាហ្គោ វ៉ាស៊ិនតោន ប៉ុន្តែគេធ្វើសម្រាប់ចម្ងាយផ្លូវមធ្យមនិងខ្លីៗប៉ុណ្ណោះ ។

### ខ. ផ្លូវថ្នល់

ផ្លូវថ្នល់មានសកម្មភាពខ្លាំងជាងគេខាងដឹកជញ្ជូនអ្នកដំណើរសម្រាប់ចម្ងាយខ្លីនិងមធ្យម ។ ការដឹកជញ្ជូនទំនិញតាមរថយន្តធំៗផ្តល់ការងារបានច្រើន ដោយប្រើរយៈពេលតែ 4 ថ្ងៃប៉ុណ្ណោះពីឆ្នេរអាត្លង់ទិក ទៅកាន់ឆ្នេរប៉ាស៊ីហ្វិក ។

ផ្លូវថ្នល់មានប្រវែងសរុប 620 000 km និងផ្លូវយន្តបថមានប្រវែង 82 000 km ដែលជានាងលំចរាចរណ៍រថយន្តទេសចរណ៍ 145 លានគ្រឿង និងរថយន្តធម្មតា 45 លានគ្រឿង ។ នៅសហរដ្ឋអាមេរិក រថយន្តសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនមានរហូតដល់ 157 លានគ្រឿង គឺរថយន្តមួយគ្រឿងសម្រាប់មនុស្ស 1.7 នាក់(លេខ 1 ពិភពលោក គ្រួសារ 55% ដែលមានរថយន្តយ៉ាងតិច 2 គ្រឿង) និងរថយន្តដឹកទំនិញ 50 លានគ្រឿង ។ សព្វថ្ងៃល្បឿនបើកបរមានកម្រិតយឺតជាងមុន គឺ 80 km/h សម្រាប់ផ្លូវថ្នល់និង 120km/h សម្រាប់ផ្លូវយន្តបថ ។ ជាមធ្យមពលរដ្ឋអាមេរិកម្នាក់ធ្វើដំណើរតាមរថយន្តក្នុងចម្ងាយផ្លូវ 19 200 km/ឆ្នាំ ។

| បណ្តាញគមនាគមន៍ | ភាគរយ |
|---|---|
| ផ្លូវដែក | 37.3 |
| ផ្លូវថ្នល់ | 25.3 |
| បំពង់បង្ហូរ | 21.2 |
| ផ្លូវទឹក | 15.8 |
| ផ្លូវអាកាស | 0.4 |

*ការបែងចែកការដឹកជញ្ជូនទំនិញក្នុងប្រទេស*

### គ. ផ្លូវទឹក

មានសារៈសំខាន់ណាស់សម្រាប់ចរាចរណ៍ទំនិញនៅផ្នែកឦសានប្រទេស (បឹងធំទាំង 5) ។ ប្រព័ន្ធបឹងទាំង 5 បើកចំហទៅរកមហាសមុទ្រអាត្លង់ទិកតាមទន្លេសាំងឡូរ៉ង់ ឬតាមព្រែកជីក អេរីយេ និងទន្លេហាត់សុន ។ ទន្លេមីស៊ីស៊ីពីនិងដៃរបស់វា(ទន្លេមីស្សួរី អូហាយ៉ូ និងតេណេស៊ី) ជាផ្លូវទឹកមួយដែលគេនិយមប្រើប្រាស់បំផុតនៅលើពិភពលោក តែមានសកម្មភាពតិចជាងផ្នែកឦសាន ។

កងនាវាពាណិជ្ជកម្មនិងកំពង់ផែសមុទ្របម្រើការប្តូរផ្តោះក្នុងប្រទេសផងនិងក្រៅប្រទេសផង ។ មានកំពង់ផែធំៗបួននៅតាមឆ្នេរមហាសមុទ្រអាត្លង់ទិក គឺបស្តុន ញូយ៉ក ហ្វីឡាដែលហ្វី បលធីម៉ ។ តាមឆ្នេរមហាសមុទ្រប៉ាស៊ីហ្វិក មានកំពង់ផែសំខាន់ៗ គឺសាន់ហ្វ្រាន់ស៊ីស្កូនិងឡូសអង់សឺឡែស ។ នៅបឹងធំមានកំពង់ផែ ស៊ីកាហ្គោ ឌុយលុត និងឌីត្រយ ។ នៅឈូងមិុកស៊ិកមានកំពង់ផែ នូវែលអ័រឡេអង់ ហ៊ូស្តុន និងគកពុយគ្រីស្ទី ។

ក្នុងចំណោមកំពង់ផែធំៗឈានមុខគេទាំង 20 ក្នុងពិភពលោក មានកំពង់ផែសហរដ្ឋអាមេរិក ចំនួន 3 គឺកំពង់ផែ ហ៊ូស្តុន(ចំណាត់ថ្នាក់លេខ 10 = 227 លានតោនក្នុងឆ្នាំ 2008) កំពង់ផែ ល៊ីស្យានខាងត្បូង(ចំណាត់ថ្នាក់លេខ 12 = 212 លានតោនក្នុងឆ្នាំ 2008) និងកំពង់ផែ ឡូសអង់សឺឡែស(ចំណាត់ថ្នាក់លេខ 18 = 170 លានតោនក្នុងឆ្នាំ 2008) ។

សហរដ្ឋអាមេរិកក៏មានកំពង់ផែកុងតឺន័រធំៗចំនួន 2 ផងដែរ ក្នុងចំណោមកំពង់ផែកុងតឺន័រឈានមុខគេទាំង 20 លើពិភពលោក គឺកំពង់ផែ ឡុងប៊ិច (លេខ 17) និងកំពង់ផែ ញូយ៉ក (លេខ 20) ។

## ឃ. ផ្លូវអាកាស



*អាកាសយានដ្ឋានសហរដ្ឋអាមេរិក*

ការដឹកជញ្ជូនតាមផ្លូវអាកាសមានសកម្មភាពកើនឡើងជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ ។ នៅឆ្នាំ 1960 ការដឹកជញ្ជូនតាមផ្លូវអាកាសមាន 4% ហើយឡើងដល់ 10% នៅឆ្នាំ 1970 14% នៅឆ្នាំ 1980 និង 18% នៅឆ្នាំ 1988 ។ ខន្ទិម និងវិបត្តិសេដ្ឋកិច្ចពិភពលោក ឆ្នាំ 2007-2008 ការដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈអន្តរជាតិ ក៏ទទួលរងនូវវិបត្តិដូចគ្នា ។ គេសង្កេតឃើញការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវ

| មធ្យោបាយដឹកជញ្ជូន | ភាគរយ |
|---|---|
| រថយន្ត | 81.0 |
| យន្តហោះ | 17.2 |
| រថយន្តក្រុង | 1.2 |
| ផ្លូវដែក | 0.6 |

*ការបែងចែកការដឹកជញ្ជូនទំនិញក្នុងស្រុក*

អាកាសនៅសហរដ្ឋអាមេរិកមានការថយចុះចាប់ពីឆ្នាំ 2007មក ។ ប៉ុន្តែអាមេរិកនៅតែរក្សានូវឧត្តមភាពក្នុងពិភពលោកខាងការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ។ គ្រប់ទីក្រុងទាំងអស់សុទ្ធតែមានចំណតអាកាសយានផ្ទាល់ខ្លួន(2008-2009) ។ ក្នុងចំណោមអាកាសយានដ្ឋានពិភពលោកឈានមុខគេទាំង 20មាន 9ជារបស់សហរដ្ឋអាមេរិក ក្នុងនោះមានអាកាសយានដ្ឋានអាត្លង់តា ឈីកាហ្គោ ឡូសអង់សឺឡែស ដាឡាស ដង់វែរ ញូយ៉ក ឡាសវេហ្គា ហ៊្វូស្តុន និងហេនិច ។

## ង. បណ្តាញបំពង់ប្រេងកាតនិងបំពង់ឧស្ម័ន

មានសារៈសំខាន់ជាងគេក្នុងពិភពលោក ។ បំពង់ប្រេងកាតមានប្រវែង 300 000 km និងបំពង់ឧស្ម័នមានប្រវែង 550 000 km ។ ក្រៅពីនេះ នៅមានបំពង់បង្ហូរធ្យូងថ្មថែមទៀត ។

## ច. សកម្មភាពព័ត៌មានវិទ្យា

សហរដ្ឋអាមេរិកសំបូរមធ្យោបាយទំនើបបំផុតសម្រាប់ផ្សព្វផ្សាយគ្រប់ព័ត៌មានទាំងអស់នៅក្នុងប្រទេស ។ ប្រជាជនចំនួន 77.4% ដែលប្រើប្រាស់ទូរស័ព្ទចល័ត ។ ការលូតលាស់នៃការធ្វើសន្និសីទតាមទូរទស្សន៍និងគ្រប់វិធីកែច្នៃនិងចាប់យកព័ត៌មាន បញ្ជាក់អំពីសារៈសំខាន់និងការរីកលូតលាស់នៃទូរគមនាគមន៍សហរដ្ឋអាមេរិក ។

## ? សំណួរ

1. តើវិសាលភាពសហរដ្ឋអាមេរិក ផ្តល់សក្តានុភាពចំពោះវិស័យកសិកម្មដូចម្តេចខ្លះ ?
2. តើជួរភ្នំអាប៉ាឡាសមានសារៈសំខាន់សេដ្ឋកិច្ចយ៉ាងណាខ្លះ ?
3. តើអ្វីដែលជាកត្តាសំខាន់សម្រាប់តំបន់ទំនាបកណ្តាល ក្នុងវិស័យសេដ្ឋកិច្ច ?
4. ហេតុអ្វីបានជាភូមិភាគនិរតីនៃភាគខាងលិចក្លាយជាតំបន់ទេសចរណ៍និងជាលំនៅឋានសម្រាប់និវត្តជន ?
5. គេចែកអាកាសធាតុនៅសហរដ្ឋអាមេរិកជាប៉ុន្មានផ្នែក ? អ្វីខ្លះ ?
6. តើការដឹកជញ្ជូនទំនិញ តាមមធ្យោបាយណាច្រើនជាងគេ ?
7. ហេតុអ្វីបានជាប្រជាជនអាមេរិកចូលចិត្តធ្វើដំណើរតាមផ្លូវថ្នល់ ?
8. ហេតុអ្វីបានជាសហរដ្ឋអាមេរិកសំបូរកំពង់ផែធំៗ ?
9. ហេតុអ្វីបានជាសកម្មភាពដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសមានការកើនឡើង ចាប់ពីឆ្នាំ 1960មក ?
10. ចូររៀបរាប់អំពីភាពរីកចម្រើនផ្នែកព័ត៌មានវិទ្យារបស់សហរដ្ឋអាមេរិក ។

# 3 ប្រជាជនសហរដ្ឋអាមេរិក

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីសង្គមសហរដ្ឋអាមេរិក ដែលមានជាតិសាសន៍ច្រើននិង មានការប្រែប្រួលប្រជាជនឥតឈប់ឈរ
- ❑ បកស្រាយបាន អំពីប្រជាជនទីក្រុងនៅសហរដ្ឋអាមេរិកនិងរៀបរាប់បានពីល្បឿននៃកំណើនប្រជាជនរបស់ប្រទេសនេះ ។

នៅឆ្នាំ 2009 សហរដ្ឋអាមេរិកមានប្រជាជន 314 659 000 នាក់ ។ ក្នុងឆ្នាំ 2008 ប្រជាជនប្រទេសនេះមានអត្រាកំណើនប្រចាំឆ្នាំ 0.6% អត្រាជាតិប្រមាណ 1.4% និងអត្រាមរណប្រមាណ 0.8% ។ សង្គមអាមេរិកចម្រុះដោយជាតិសាសន៍ជាច្រើន ហើយវិសមភាពសង្គមក៏នៅតែមានដែរ ។ របាយប្រជាជនមានភាពផ្ទុយគ្នាជាខ្លាំងរវាងភាគឦសានដែលមានប្រជាជនរស់នៅកុះករ ភាគខាងត្បូងនិងខាងលិចមានប្រជាជនរស់នៅបង្គួរ និងភាគកណ្ដាលខ្វះប្រជាជនរស់នៅ ហើយទីក្រុងនីមួយៗក៏មានដង់ស៊ីតេពុំស្មើគ្នាដែរ ។ នៅឆ្នាំ 2009 សហរដ្ឋអាមេរិកមានប្រជាជនទីក្រុង 79% ។




*ដង់ស៊ីតេប្រជាជនអាមេរិកនិងទីក្រុងដែលមានប្រជាជនលើស 1 លាននាក់*

# 1. ចំណូលស្រុក (សង្គមមួយមានជាតិសាសន៍ច្រើន)

រហូតដល់ឆ្នាំ 1914 ទ្វីបអឺរ៉ុបបានផ្តល់បង្អែកយ៉ាងមាំដល់សហរដ្ឋអាមេរិក ទាំងខាងវិស័យមនុស្ស ទាំងខាងវិស័យមូលធន ។ នេះជាកត្តាដែលជំរុញសេដ្ឋកិច្ចឱ្យមានល្បឿនរហ័ស ។

## 1.1. កុលសម្ព័ន្ធជនជាតិស្បែកក្រហម

កុលសម្ព័ន្ធ ជាអ្នកមកតាំងលំនៅដំបូងគេលើទឹកដីនេះ មានចំនួនតិចតួចនាដើមសតវត្សទី 17 ។ នៅពេលដែលនិគមជនទី 1 បានចូលមកដល់(តាមការប៉ាន់ស្មានរបស់អ្នកប្រវត្តិសាស្ត្រ) ពួកកុលសម្ព័ន្ធជនជាតិស្បែកក្រហមមានចំនួនពី 1 លាន ទៅ 10 លាននាក់សម្រាប់អាមេរិកខាងជើង គិតរួមទាំងប្រទេសកាណាដាផង(បើគិតនៅតែអាមេរិក មានចំនួន 530 000 នាក់) ។ នៅឆ្នាំ 1890 ពួកគេនៅសល់តែ 248 000 នាក់ប៉ុណ្ណោះ ដោយសារសង្គ្រាមដឹកនាំដោយពួកនិគមជនជាអ្នកត្រួសត្រាយ(ពួកស្បែកស) ធ្វើការវាយដណ្តើមយកភាគខាងលិច ។ សព្វថ្ងៃ ជនជាតិស្បែកក្រហម(អាមេរាំងឌីយាង ឬអាំងឌីយៀង) មានចំនួនប្រមាណជាងពីរលាននាក់ ដែលរស់នៅតំបន់បម្រុងភាគខាងលិច ។ នៅទីនោះគេរស់នៅក្នុងភាពក្រីក្រដោយសារជំនួយពីរដ្ឋសហព័ន្ធ ឬពីការលក់វត្ថុសិប្បកម្មឱ្យភ្ញៀវទេសចរ ហើយអ្នកខ្លះទៀតរស់ដោយសារប្រាក់ពន្ធដែលក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែនៅតំបន់នោះបង់ឱ្យ ។

ពីឆ្នាំ 1820 ដល់ ឆ្នាំ 1960 ជនជាតិអឺរ៉ុបប្រហែល 41 លាននាក់បានមកដល់ ហើយចំនួន 3/4 បានតាំងលំនៅរហូត ។ រហូតដល់ចុងសតវត្សទី 19 ប្រជាជនច្រើនមកពីប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ។ ដូច្នេះហើយ បានជាសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានទទួលផលល្អពីចំណូលស្រុកនេះ ព្រោះជនចំណូលស្រុកច្រើនជាមនុស្សពេញវ័យ ដែលបានទទួលការអប់រំជាស្រេចនៅទ្វីបអឺរ៉ុប ។ ចាប់ពីឆ្នាំ 1900 មក ទើបមានប្រជាជននៃតំបន់មិនសូវជឿនលឿនចូលមកច្រើន ដូចជាមកពីអឺរ៉ុបប៉ែកខាងត្បូង អាហ្វ្រិក និងអាស៊ី ។

## 1.2. ជនជាតិស្បែកខ្មៅ

ពួកនេះជាសាច់សាលោហិតនៃទាសករ ដែលគេបាននាំចូលពីទ្វីបអាហ្វ្រិកយកមកធ្វើការក្នុងចំការកប្បាសធំៗ(ចំការកប្បាស)នៅតំបន់ខាងត្បូង ចាប់ពីសតវត្សទី 16 មក ។ នៅពេលលុបបំបាត់របបទាសភាពឆ្នាំ 1865 ពួកស្បែកខ្មៅមានចំនួន 4.5 លាននាក់និងបច្ចុប្បន្នមានប្រមាណជាង 30 លាននាក់ ។ ក្រោយសង្គ្រាមបំបែកស្រុក ពួកគេនាំគ្នាទៅធ្វើការងារក្នុងឧស្សាហកម្មធំៗនៅភាគខាងជើង ។ សព្វថ្ងៃ អាស្រ័យដោយមានបណ្តុំក្រុងធំៗនៃខ្សែក្រវាត់ព្រះអាទិត្យបានបំផុសឱ្យពួកគេធ្វើបំលាស់លំនៅត្រឡប់ទៅខាងត្បូងវិញ ។

ពួកស្បែកខ្មៅបានសម្របចូលក្នុងសង្គមអាមេរិកកាន់តែប្រសើរឡើង ដែលមានអ្នកខ្លះមានជីវភាពកម្រិតខ្ពស់ ប៉ុន្តែគេក៏សង្កេតឃើញមានសង្កាត់អនាធិបតេយ្យ (សង្កាត់ពួកស្បែកខ្មៅក្រីក្រ) ក្នុងទីប្រជុំជនធំៗ ដែលនៅទីនោះមានទុរ្ភិក្ស អំពើហិង្សា ឧក្រិដ្ឋកម្ម គ្រឿងញៀន ពេស្យាចារ ។ល ។

## 1.3. ពួកអេស្ប៉ាញ

ចំណូលស្រុកថ្មីៗច្រើនតែជាពួកអេស្ប៉ាញ ដែលភាគច្រើនមកពីប្រទេសគុយបានិងម៉ិកស៊ិក ហើយច្រើនទៅរស់នៅតំបន់វង់ព្រះអាទិត្យ(Sunbelt) គឺជាជនជាតិភាគតិចទី 2 បន្ទាប់ពីជនជាតិស្បែកខ្មៅ ។ ក្នុងចំណោមនោះ គេឃើញមាននិយោជិកលួចលាក់ជាច្រើនទៅបម្រើការងារក្នុងសហគ្រាសកសិកម្មធំៗនៅភាគខាងត្បូង ។ ភាសាអេស្ប៉ាញ៉ុល ជាភាសានិយាយទី 2 នៅសហរដ្ឋអាមេរិក ដែលនៅក្នុងរដ្ឋខ្លះនៃភាគខាងត្បូងប្រជាជនភាគច្រើននិយមប្រើភាសាអេស្ប៉ាញ៉ុល ។

## 1.4. ជនជាតិអាស៊ី

ជនជាតិអាស៊ីមករស់នៅសហរដ្ឋអាមេរិកតាំងពីពាក់កណ្តាលសតវត្សទី 19 មកម្ល៉េះ ដោយធ្វើការក្នុងសំណង់ផ្លូវរថភ្លើង(ជនជាតិចិន)ហើយរស់នៅតាមឆ្នេរខាងលិច ។ ចាប់ពីឆ្នាំ 1960 មក អ្នកចំណូលស្រុកភាគច្រើនមានប្រភពមកពីទ្វីបអាស៊ីនិងអាមេរិកឡាទីន ។ ក្រោយសង្គ្រាមនៅវៀតណាម គេសង្កេតឃើញ មានអ្នកភៀសខ្លួនមកពីឥណ្ឌូចិន ។ សព្វថ្ងៃជនជាតិអាស៊ី មានចំនួនជាង 8 លាននាក់នៅសហរដ្ឋអាមេរិក ដែលក្នុងនោះមាន 1.6 លាននាក់ជាជនជាតិចិន 1.4 លាននាក់ជាជនជាតិហ្វីលីពីន 0.9 លាននាក់ជាជនជាតិជប៉ុន 0.8 លាននាក់ជាជនជាតិកូរ៉េ និងប្រមាណ 1 លាននាក់មកពីឧបទ្វីបឥណ្ឌូចិន ។ អ្នកចំណូលស្រុកជនជាតិអាស៊ីតែងសុខចិត្តទទួលយកបៀវត្សរ៍ស្ដួចស្ដើង ហើយថែមទាំងកាន់កាប់ជំនួញតូចតាចនិងទិញបានដីធ្លី ផ្ទះសំបែងថែមទៀត ជាហេតុធ្វើឱ្យប៉ះពាល់ដល់ការងាររបស់ជនជាតិអាមេរិកស្បែកស ។

## 1.5. ជនជាតិអឺរ៉ុប

បច្ចុប្បន្នមានជាង 80% នៃប្រជាជនអាមេរិក ។ ពួកស្បែកសបានចូលមករស់នៅបន្តបន្ទាប់គ្នាពីរដ្ឋនានានៃទ្វីបអឺរ៉ុប ដោយសារជម្លោះសាសនា បដិវត្តន៍នយោបាយ វិបត្តិកសិកម្ម និងឧស្សាហកម្ម ។ ប្រជាជននានាដែលបានមកតាំងទីនៅសហរដ្ឋអាមេរិកមាន អង់គ្លេស អៀរឡង់ ស្កង់ឌីណាវ(ស.វ. ទី 17-18-19) ។ ចាប់ពីឆ្នាំ 1917 ដល់ឆ្នាំ 1952 គេបានកម្រិតចំណូលស្រុកនៃពួកស្លាវនិងពួកឡាតាំង ។ ចាប់ពីឆ្នាំ 1965 មក មានច្បាប់កម្រិតចំណូលស្រុកមកពីប្រទេសដទៃៗទៀត ។ ប៉ុន្តែអាមេរិកបានលើកទឹកចិត្តចំពោះលំហូរចូលនៃបញ្ញាជន ដូចជាអ្នកស្រាវជ្រាវ និងអ្នកប្រាជ្ញជាដើម ពិសេសបញ្ញាជនពីទ្វីបអឺរ៉ុប ។

និគមកម្មបានធ្វើពីមហាសមុទ្រអាត្លង់ទិក ទៅមហាសមុទ្រប៉ាស៊ីហ្វិក ។ ក្រោយសង្គ្រាមទាមទារឯករាជ្យ(1783)ប្រជាជនរស់នៅប្រជ្រៀតគ្នាក្នុងរដ្ឋ 13 ចន្លោះមហាសមុទ្រអាត្លង់ទិកនិងភ្នំអាប៉ាឡាស ។ ប្រហែលឆ្នាំ 1820 ព្រំប្រទល់ប្រជាជនស្បែកសបានទៅដល់តំបន់ខាងត្បូងបឹងធំនិងតាមបណ្តោយទន្លេមីស៊ីស៊ីពី ។ ការត្រួសត្រាយបានបន្តទៅតំបន់ខាងលិច ចាប់ពីពេលដែលសហរដ្ឋអាមេរិកទិញបានតំបន់ថ្មីៗពីប្រទេសឯទៀតគឺ លុីស្យាន(ទិញពីបារាំងឆ្នាំ 1803) ផ្លរីដា(ទិញពីអេស្ប៉ាញឆ្នាំ 1819) តិចសាស់ មិុកសុិកថ្មី និងកាលីហ្វ័រនី(ទិញពីមិុកសុិកឆ្នាំ 1845 ទៅ 1848) និងអូរេកុង(ទិញពីអង់គ្លេសឆ្នាំ 1846) ។



*ប្រជាជនប្រកបដោយពហុជាតិសាសន៍*

## 2. ប្រជាសាស្ត្រសហរដ្ឋអាមេរិក

ក្នុងទំហំដី 9 363 520km$^2$ សហរដ្ឋអាមេរិកមានប្រជាជនចំនួន 314 659 000 នាក់ នៅឆ្នាំ 2009 ជាប់ចំណាត់ថ្នាក់លេខ 3 បន្ទាប់ពីប្រទេសចិន(2009 : 1 353 311 000 នាក់ ផ្ទៃដី = 9 596 961km$^2$) និងប្រទេសឥណ្ឌា(2009 : 1 198 003 000 នាក់ ផ្ទៃដី = 3 287 263km$^2$) ។ ដង់ស៊ីតេប្រជាជននៅទូលាយនៅឡើយ គឺ 34 នាក់/km$^2$ ។ កំណើនប្រជាជនមានល្បឿនយឺតបន្តិចម្តងៗ ចាប់ពីឆ្នាំ 1960 មក ។ នៅឆ្នាំ 2008 អត្រាកំណើនប្រជាជនប្រចាំឆ្នាំមាន 0.6% (អត្រាជាតិប្រមាណមាន 1.4% និងអត្រាមរណប្រមាណមាន 0.8%) ។ លក្ខណៈបែបនេះ គេសង្កេតឃើញមាននៅក្នុងប្រទេសឧស្សាហកម្មជឿនលឿនមួយចំនួន ដោយសារតែកំណើនការងារនារី កំណើនភាពខ្វះការងារធ្វើ និងវិធីទប់ស្កាត់កុំឱ្យមានកូន ។




*ការវិវត្តប្រជាជនអាមេរិក*




| | 1960 | 1970 | 1980 | 1993 |
|---|---|---|---|---|
| លើស 65 ឆ្នាំ | 9 | 10 | 11 | 13 |
| ពី 15 ទៅ 65 ឆ្នាំ | 61 | 61.5 | 66 | 65 |
| ក្រោម 15 ឆ្នាំ | 30 | 28.5 | 23 | 22 |

*ពីរ៉ាមីតអាយុប្រជាជនអាមេរិក (1990)*

នៅឆ្នាំ 2008 អត្រាមរណប្រមាណកុមារ 0.65% និងអាយុសង្ឃឹមរស់របស់ប្រជាជនរហូតដល់ 81 ឆ្នាំសម្រាប់មនុស្សស្រី និង 75 ឆ្នាំសម្រាប់មនុស្សប្រុស ។ អត្រាលទ្ធភាពបង្កកំណើតរបស់ស្ត្រីមាន 2.1 ។ អត្រាជនអន្តោប្រវេសន៍មាន 0.4% ។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សមានតម្លៃ 0.951 (ចំណាត់ថ្នាក់ទី 10 ឆ្នាំ 2006) និងផលិតផលក្នុងស្រុកសម្រាប់សរុបមនុស្សម្នាក់ មាន 39 820 ដុល្លារអាមេរិក (ជាប់លេខ 2 ឆ្នាំ 2004 បន្ទាប់ពីលុចសំបួរ = 61 610 ដុល្លារអាមេរិក) ។

នៅឆ្នាំ 2008 ប្រជាជនវ័យចាស់លើស 65 ឆ្នាំ មានចំនួន 13% និងកុមារក្រោមអាយុ 15 ឆ្នាំ មាន 20% ។ នេះបញ្ជាក់ឱ្យឃើញថា ទម្រង់ប្រជាជនអាមេរិកមានលក្ខណៈជាទម្រង់ប្រជាជនចំណាស់ ។ តាមការសិក្សាបានឱ្យដឹងថា បច្ចុប្បន្នប្រជាជនអាមេរិកចំនួនជាង 1 លាននាក់មានអាយុលើសពី 85 ឆ្នាំ ហើយចំនួននេះនឹងកើនដល់ប្រមាណជាង 10 លាននាក់នៅឆ្នាំ 2050 ដែលបណ្តាលមកពីកត្តារីកចម្រើនខាងសុខភាព ពិសេសមកពីការចូលចិត្តធ្វើដំណើរកម្សាន្ត (ទេសចរណ៍) របស់មនុស្សចាស់នៅសហរដ្ឋអាមេរិក ។

## 3. ប្រជាជនក្រុង

នៅឆ្នាំ 2007 ប្រជាជនអាមេរិកចំនួន 79% រស់នៅទីក្រុង និងនៅឆ្នាំ 2010 មានចំនួន 82.1% ។ រថយន្តបង្កលក្ខណៈឱ្យបណ្តុំក្រុងលាតសន្ធឹងបានវែង ហើយពលរដ្ឋភាគច្រើនរស់នៅក្នុងតំបន់ក្រុងដ៏ធំសម្បើម ។ ប្រជាជនជាងពាក់កណ្តាលបានរស់នៅក្នុងទីក្រុង ដែលមានប្រជាជនលើសពី 1 លាន នាក់ ។

### 3.1. បណ្តាញក្រុង

បណ្តាញក្រុងបានកកើតឡើងនៅពេលដែលសហរដ្ឋអាមេរិកអភិវឌ្ឍដែនដី ដែលមានដំណុះប្រជាជនឆ្ពោះទៅខាងលិច ។ បច្ចុប្បន្នសំណុំក្រុងចំនួន 39 ដែលមានប្រជាជនលើសពី 1 លាននាក់ ។

នៅភាគឦសាន ផ្ទៃដីក្រុងតាមឆ្នេរមហាសមុទ្រអាត្លង់ទិកប្រមូលផ្តុំមនុស្សរាប់សិបលាននាក់ក្នុង នោះក្រុងធំៗដែលលេចធ្លោជាងគេមានដូចជា បស្តុន ញូយ៉ក ហ្វីឡាដែលហ្វី បលធីម័ វ៉ាស៊ីនតោន ឌីស៊ី ។ បណ្តាញក្រុងទាំងនោះមានភាពញឹកស្អេក ។ បណ្តាញក្រុងមានភាពញឹកបង្គួរនៅភាគខាងត្បូង ផ្នែកខាងក្នុងប្រទេសដូចជា អាត្លង់តា មិមភីស ដាឡាស់ សានអានតូនីញ៉ូ តែបណ្តាញក្រុងមានភាព រង្វើលនៅតំបន់កណ្តាលនិងខាងលិច ។ នៅតំបន់ឆ្នេរមហាសមុទ្រប៉ាស៊ីហ្វិក បណ្តាញទីក្រុងបែរជាញឹក ទៅវិញដូចជា ស៊ីថល សាន់ហ្វ្រាន់ស៊ីស្កូ ឡូសអង់សឺឡែស ។ ប៉ុន្តែ សហរដ្ឋអាមេរិកក៏មានទីក្រុង តូចៗដែរ ជាពិសេសនៅភាគខាងលិច ដែលច្រើនប្រមូលផ្តុំតាមបណ្តោយស្ថានីយសេវាសំខាន់ណាមួយ ភោជនីយដ្ឋាន និងហាងទំនិញទាំងឡាយ ។ ក្រុងសំខាន់ៗជាច្រើនស្ថិតនៅតាមដងទន្លេ តាមផ្លូវដែក តាមឆ្នេរ ឬត្រង់តំបន់មានភោគទ្រព្យរ៉ែ ។

គេសង្កេតឃើញមានកំណើនយ៉ាងលឿននៃទីក្រុងនៅក្នុងតំបន់វង់ព្រះអាទិត្យ ដែលកើតឡើងដោយសារចំណូលស្រុកនៃពួកអាស៊ីនិងម៉ិកស៊ិក និងមានអាកាសធាតុស្រួលរស់នៅសម្រាប់ពួកនិវត្តជន ជាតំបន់ទំនាញឧស្សាហកម្មធំៗ មានបច្ចេកវិទ្យាខ្ពស់ និងមានសេវាកម្មផ្សេងៗជាច្រើនស្ថិតក្នុងតំបន់នោះ ។

**ទីក្រុងធំៗរបស់សហរដ្ឋអាមេរិក ក្នុងចំណោមទីក្រុងធំៗទាំង 30 ក្នុងពិភពលោក(2003)**

| ទីក្រុង | ចំណាត់ថ្នាក់ | ចំនួនប្រជាជន(លាននាក់) | | | បម្រែបម្រួលប្រចាំឆ្នាំ(%) | |
|---|---|---|---|---|---|---|
| | | 1975 | 2003 | 2015 | 2003 - 2005 | 2010 - 2015 |
| ញូយ៉ក | លេខ 3 | 15.9 | 18.3 | 19.7 | 0.7 | 0.6 |
| ឡូសអង់សឺឡែស | លេខ 11 | 8.9 | 12.0 | 12.9 | 0.6 | 0.6 |
| ស៊ីកាហ្គោ | លេខ 25 | 7.2 | 8.6 | 9.4 | 0.9 | 0.7 |

## 4. របាយប្រជាជនមិនស្មើគ្នា

របាយប្រជាជនអាមេរិកមានភាពខុសគ្នាយ៉ាងខ្លាំង ។ ប្រជាជនប្រមាណពាក់កណ្តាលបានប្រមូលផ្តុំរស់នៅខាងកើតទន្លេមីស៊ីស៊ីពី ។ តំបន់ឆ្នេរនិងតំបន់បឹងធំមានប្រជាជនច្រើនជាងគេ ។ តំបន់ទាំងនេះប្រមូលផ្តុំក្រុងធំៗដែលហៅថាមេកាប៉ូលីស គឺពីវ៉ាស៊ីនតោនឌីស៊ីទៅបស្តុន ឬអ័ក្សកាលីហ្វ័រនីពីសាន់ហ្វ្រាន់ស៊ីស្កូទៅឡូសអង់សឺឡែសនិងសាន់ឌីយេហ្គោ ។ នៅក្នុងប្រទេសចាប់ពីខ្សែបណ្តោយទី 100 ដង់ស៊ីតេប្រជាជនមានតិចជាង 15 នាក់/$km^2$ ។ របាយប្រជាជនមិនស្មើគ្នានេះបណ្តាលមកពីមជ្ឈដ្ឋានធម្មជាតិ ដែលផ្តល់លក្ខណៈងាយស្រួល ឬពិបាករស់នៅ ។

ប្រជាជនអាមេរិកចូលចិត្តចល័តណាស់ ។ គេធ្វើដំណើរឆ្ពោះទៅទិសខាងលិច រួចទៅទិសខាងត្បូង គឺទៅរកតំបន់ទំនាញព្រះអាទិត្យដែលបង្កលក្ខណៈល្អដល់រដ្ឋតិចសាស់ ផ្លរីដា និងកាលីហ្វ័រនីដែលជារដ្ឋមានប្រជាជនច្រើនជាងគេ(លើស 30 លាននាក់) ។ ក៏មានរបាយប្រជាជនមិនស្មើគ្នារវាងជាតិសាសន៍ផ្សេងៗផងដែរ ។ ជនជាតិអេស្ប៉ាញរស់នៅច្រើនជាងគេ នៅទីក្រុង អែលប៉ាសូ(El Paso) មីយ៉ាមី(Miami) ឡូសអង់សឺឡែស ញូយ៉ក និងស៊ីកាហ្គោ ។ ពួកស្បែកខ្មៅរស់នៅច្រើនជាងគេនៅទីក្រុង ឌីត្រយ អាត្លង់តា និងនូវ៉ែលអ័រឡេអង់ ។ រីឯជនជាតិអាស៊ីរស់នៅច្រើនក្នុងទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ឡូអង់សឺឡែស និងញូយ៉ក ។

**របាយប្រជាជន ជនជាតិភាគតិចនៅសហរដ្ឋអាមេរិក(ឆ្នាំ 2000)**

| ទីក្រុង | ជនជាតិស្បែកស | | ជនជាតិស្បែកខ្មៅ | ជនជាតិអាស៊ី | ជនជាតិផ្សេងទៀត |
|---|---|---|---|---|---|
| | ពួកស្បែកស (មិនគិតអេស្ប៉ាញ) | អេស្ប៉ាញ | | | |
| អាត្លង់តា | 31 | 4 | 61 | 2 | 2 |
| ស៊ីកាហ្គោ | 31 | 26 | 37 | 4 | 2 |
| ឌីត្រយ | 10 | 5 | 82 | 1 | 2 |
| អែលប៉ាសូ | 19 | 76 | 3 | 1 | 1 |
| ឡូសអង់សឺឡែស | 30 | 47 | 11 | 10 | 2 |
| មីញ៉ាមី | 5 | 66 | 22 | 1 | 6 |
| ញូអរលាន | 26 | 3 | 67 | 2 | 2 |
| ញូយ៉ក | 35 | 27 | 27 | 10 | 1 |
| សាន់ហ្វ្រាន់ស៊ីស្កូ | 44 | 14 | 8 | 31 | 3 |
| មធ្យមអាមេរិក | 67.8 | 12.9 | 12.7 | 3.8 | 2.8 |

*ប្រភព : ជំរឿន ស.រ.អា. 2000*

## 5. ប្រទេសអ្នកមានក៏មានអ្នកក្រ

ថ្វីត្បិតសហរដ្ឋអាមេរិកជាប្រទេសមហាអំណាចលេខ 1 ក្នុងពិភពលោកក៏ដោយ ក៏គេសង្កេតឃើញមានប្រជាជនមួយចំនួនរស់នៅក្នុងភាពក្រីក្រ ។ នៅឆ្នាំ 2004 ប្រជាជនចំនួនប្រមាណ 35 លាននាក់ (12% នៃប្រជាជនសរុប) ស្ថិតក្នុងភាពក្រីក្រ ពិសេសនៅរដ្ឋភាគខាងត្បូង ។

គម្លាតជីវភាពសង្គមមានកម្រិតខ្ពស់ គឺប្រជាជនថ្នាក់ខ្ពស់ប្រមាណ 10% កាន់កាប់ 57% នៃសម្បត្តិជាតិ ក្នុងនោះមានអ្នកដឹកនាំសហគ្រាស មន្ត្រីជាន់ខ្ពស់ និងអ្នកមានវិជ្ជាជីវៈសេរីផ្សេងៗ។ ថ្នាក់មធ្យមមាន កម្មករជំនាញ និយោជិត និងអ្នករាជការ ។ ឯវណ្ណៈទាបគឺជាអ្នកទទួលបានកម្រៃតិច ធ្វើការមិនគ្រប់ពេល មិនស្ថិតស្ថេរ ឬគ្មានការងារធ្វើ ។

**អ្នកបាត់អាជីពនិងប្រជាជនរស់ក្នុងភាពក្រីក្រនៅសហរដ្ឋអាមេរិក(2004)**

| | ជនជាតិស្បែកស | | ស្បែកខ្មៅ | អាស៊ី |
|---|---|---|---|---|
| | ពួកស្បែកស(មិនគិតអេស្ប៉ាញ) | អេស្ប៉ាញ | | |
| អ្នកបាត់អាជីព | 5.5 | 8.4 | 11.8 | គ្មានតួលេខ |
| ប្រជាជនរស់ក្នុងភាពក្រីក្រ | 9.4 | 21.2 | 22.1 | 10.8 |

## ? សំណួរ

1. តើរបាយប្រជាជនអាមេរិកមានលក្ខណៈដូចម្ដេច ? ចូររៀបរាប់ ។
2. តើអ្នកដែលមកតាំងទីដំបូងគេនៅសហរដ្ឋអាមេរិកមានឈ្មោះអ្វី ? ហេតុអ្វីបានជាពួកគេមានចំនួនតិចតួចនាពេលបច្ចុប្បន្ន ?
3. តើចំណូលស្រុកជនជាតិអាស៊ីផ្ដល់ផលប៉ះពាល់អ្វីខ្លះដល់សង្គមអាមេរិក ? ហេតុអ្វី ?
4. ហេតុអ្វីបានជាអាមេរិកមានកំណើនប្រជាជនយឺត ?
5. តើសហរដ្ឋអាមេរិកជាប្រទេសមានកសិកម្មជឿនលឿន ។ ហេតុអ្វីបានជាវិស័យនេះ ប្រើប្រាស់កម្លាំងប្រជាជនសកម្មតិចម្ល៉េះ(2%) ?
6. តើពីរ៉ាមីតអាយុប្រជាជនអាមេរិកមានទម្រង់ចាស់ ឬក្មេង ? ហេតុអ្វី ?
7. តើតំបន់ណាខ្លះដែលមានទីក្រុងញឹកខ្លាំង និងមិនសូវញឹក ?
8. តើមូលហេតុអ្វីដែលធ្វើឱ្យមានរបាយប្រជាជនមិនស្មើគ្នា ?
9. ហេតុអ្វីបានជាតំបន់ខ្សែរង្វង់ព្រះអាទិត្យមានការរីកចម្រើនផ្នែកទីក្រុងឆាប់រហ័ស ?
10. តើជនជាតិភាគតិចណាខ្លះដែលរស់ក្នុងភាពក្រីក្រ ? ហេតុអ្វី ?

# 4 លំហសេដ្ឋកិច្ចសហរដ្ឋអាមេរិក

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីសេដ្ឋកិច្ចសហរដ្ឋអាមេរិក រ៉ែនិងថាមពល លំហឧស្សាហកម្ម កសិកម្ម និងពាណិជ្ជកម្មក្រៅប្រទេស ។

ក្នុងឋានៈជាមហាអំណាចដ៏ធំមួយ សហរដ្ឋអាមេរិកបានគ្រប់គ្រងលំហសេដ្ឋកិច្ចដ៏ធំទូលាយហួសពីក្របខ័ណ្ឌទឹកដីរបស់ខ្លួនទៅទៀត ។ ថាមពល រ៉ែ កសិកម្ម និងឧស្សាហកម្មបានបង្ហាញពីភាពទំនាក់ទំនងគ្នាយ៉ាងខ្លាំងក្លារវាងទឹកដីខាងក្នុងនិងខាងក្រៅប្រទេស ។ តាមរយៈសមត្ថភាពត្រួតត្រាលំហសេដ្ឋកិច្ចក្នុងស្រុកនិងសមត្ថភាពធ្វើសកម្មភាពធ្វើសក្ក៏យទៅលើទីផ្សារខាងក្រៅ សហរដ្ឋអាមេរិកអាចបង្ហាញ ឬក៏កាត់បន្ថយឧត្តមភាពរបស់ខ្លួន ។

ក្នុងពេលបច្ចុប្បន្ន តើសហរដ្ឋអាមេរិកបានទទួលចំណាត់ថ្នាក់លេខប៉ុន្មាននៅក្នុងប្រព័ន្ធពិភពលោក ? តើឥទ្ធិពលសហរដ្ឋអាមេរិកទៅលើប្រព័ន្ធពិភពលោកប្រព្រឹត្តទៅដូចម្តេច ?

ផ្ទុយទៅវិញ តើប្រព័ន្ធពិភពលោកបានធ្វើឱ្យរបៀបរៀបចំសេដ្ឋកិច្ចសហរដ្ឋអាមេរិកមានការកែប្រែដូចម្តេច ?

## 1. រ៉ែនិងថាមពល

### 1.1. ការប្រើប្រាស់រ៉ែនិងថាមពលមួយខ្លាំងក្លា

សហរដ្ឋអាមេរិកជាប់ចំណាត់ថ្នាក់លេខ 1 ក្នុងពិភពលោកខាងការប្រើប្រាស់រ៉ែ ។ ដីខាងក្រោមរបស់ប្រទេសនេះសំបូរធនធានច្រើនប្រភេទ ពិសេសនៅតំបន់ភ្នំភាគខាងលិច ។ សហរដ្ឋអាមេរិកជាប់លេខ 2 ក្នុងពិភពលោកខាងផលិតកម្មទង់ដែង សំណ និងប្រាក់ លេខ 7 ខាងរ៉ែដែក (30.7 លានតោនឆ្នាំ 2003) ។ ប៉ុន្តែសហរដ្ឋអាមេរិកត្រូវការនាំចូលរ៉ែក្នុងបរិមាណដ៏ច្រើន ពិសេសរ៉ែដែកពីប្រទេសកាណាដា ប្រេស៊ីល វេណេស៊ុយអេឡា និងអូស្ត្រាលីថែមទៀត ។

សហរដ្ឋអាមេរិកក៏ជាប្រទេសប្រើប្រាស់ថាមពលដ៏ធំជាងគេក្នុងពិភពលោក តែផលិតកម្មអាចបំពេញបានត្រឹម 85% នៃតម្រូវការប៉ុណ្ណោះ ដែលចាំបាច់ត្រូវនាំចូលឧស្ម័នធម្មជាតិនិងជាពិសេសប្រេងកាត (50% នៃប្រេងកាតប្រើប្រាស់) ។ គ្មានប្រទេសណាមួយដែលចំណាយលើការនាំចូលប្រេងធ្ងន់ធ្ងរបែបនេះឡើយ ។

ដើម្បីកាត់បន្ថយភាពចំណុះគេខាងថាមពល សហរដ្ឋអាមេរិកបានបំបែកការផ្គត់ផ្គង់ប្រេងមកពីផ្សេងៗជាច្រើនកន្លែង (តំបន់ក្បែរបូហ្គាំ ប្រទេសម៉ិកស៊ិក វេណេស៊ុយអេឡា នីហ្សេរីយ៉ា ឥណ្ឌូណេស៊ី) ។ សហរដ្ឋអាមេរិកគ្មាននយោបាយថាមពលជាប់លាប់និងបន្តបន្ទាប់ទេ ។ វិធានការអនុវត្តបន្ទាប់ពីវិបត្តិប្រេងកាតលើកទី 2 (ដើម្បីសន្សំសំចៃថាមពលនិងលើកទឹកចិត្តដល់ផលិតកម្មនិងការស្រាវជ្រាវរុករកប្រេងកាត) មិនត្រូវបានប្រកាន់ខ្ជាប់ទៀតឡើយ ។

## 1.2. អ៊ីដ្រូកាបួ

ផលិតកម្មប្រេងត្រូវបានកាត់បន្ថយជាលំដាប់នាប៉ុន្មានឆ្នាំចុងក្រោយនេះ(460 លានតោននៅឆ្នាំ 1987, 420 លានតោន នៅឆ្នាំ 1991, 360 លានតោនឆ្នាំ 2002, 350.5 លានតោននៅឆ្នាំ 2003) ។ "ពួករៀមច្បង" គឺក្រុមហ៊ុនប្រេងធំៗ (អ៊ិចសុន ម៉ូបាយ តិចសាស់ សូខល គុល) ជាអ្នកផ្គត់ផ្គង់ទីផ្សារសហរដ្ឋ ពិសេសតាមការធ្វើអាជីវកម្មប្រេងនៅឯបរទេស ។ នៅលើទឹកដីជាតិប្រេងកាតត្រូវបានទាញយកជាចំណែកៗដោយក្រុមហ៊ុនឯករាជតូចៗ ក្រុមហ៊ុនប្រមាណ 7 000 មានអណ្តូងប្រេងតែពីរ ឬបីប៉ុណ្ណោះ ។ អណ្តូងប្រេងសំខាន់ៗមាននៅតំបន់ឈូងម៉ិកស៊ិកភាគកណ្តាលប្រទេស កាលីហ្វ័រនី និងអាឡាស្កា ។

ផលិតកម្មឧស្ម័នធម្មជាតិ ពិសេសនៅក្នុងរដ្ឋតិចសាស់និងលូវីស្យាន ដែលរ៉ាប់រងបានចំនួន $\frac{2}{3}$ នៃផលិតកម្មមានការថយចុះចាប់ពីបណ្តាឆ្នាំ 1970 មក ទោះបីអាជីវកម្មប្រព្រឹត្តទៅលើអណ្តូងកាន់តែជ្រៅទៅៗក៏ដោយ ។

ការបំបែកកន្លែងផលិតកម្មនិងកន្លែងប្រើប្រាស់តម្រូវឱ្យមានការស្ពាបនាបណ្តាញបំពង់បង្ហូរប្រេងនិងឧស្ម័នយ៉ាងញឹកបំផុតក្នុងពិភពលោក(1 300km សម្រាប់បំពង់បង្ហូរប្រេងកាតតាមអាឡាស្កា) ។ រោងចក្រចំរាញ់ប្រេងកាតធំៗច្រើនស្ថិតនៅជិតតំបន់ជីកកាស់ នៅក្នុងតំបន់ប្រើប្រាស់ច្រើននៃភាគឦសាននិងក្បែរកំពង់ផែដែលជាកន្លែងនាំចូលប្រេងកាត ។

## 1.3. ធ្យូងថ្ម

កង្វះប្រេងកាតនាំឱ្យធ្យូងថ្មមានអនាគតល្អ ព្រោះធ្យូងថ្មមានកំណប់ធំៗជាងកំណប់អ៊ីដ្រូកាបួ ។ ការធ្វើឱ្យមានសំខុះជាថ្មីក្នុងការទាញយកធ្យូងថ្ម នាំឱ្យផលិតកម្មរំកិលឆ្ពោះទៅភូមិភាគខាងលិច ។ នៅក្នុងអាងអាប៉ាឡាសដែលបានផ្តល់ចំនួន $\frac{2}{5}$ នៃផលិតកម្មជាតិនៅឡើយ ។ មជ្ឈមណ្ឌលសកម្មភាពជីកកាស់ត្រូវបានផ្លាស់ទីទៅកាន់រដ្ឋ ខឹនថិកឃី រដ្ឋធ្យូងថ្មលេខ 2 ។ កំណប់ធ្យូងធំៗបំផុតមាននៅតំបន់ទំនាបកណ្តាល(រដ្ឋអ៊ីលីណយ) និងនៅតំបន់ភ្នំថ្មដែលមានវីយ៉ូមីងជារដ្ឋធ្យូងថ្មលេខ 1 ។

នៅក្នុងអាងមួយចំនួនការទាញយកវ៉ែធ្យូងកណ្ដាលវាលបានធ្វើឱ្យតម្លៃធ្យូងថយចុះ តែបញ្ហាដឹកជញ្ជូនបានចោទឡើង ។ ធ្យូងថ្មពីរដ្ឋវីយ៉ូមិងត្រូវបានដឹកតាមរថភ្លើងធំៗ ឬតាមបំពង់បង្ហូរធ្យូង ។ មួយភាគនៃផលិតកម្មអាចនាំចេញដោយតម្លៃថោក ឆ្ពោះទៅប្រទេសកាណាដា ជប៉ុន និងអ៊ីតាលី ។

## 1.4. ផលិតកម្មអគ្គិសនី

ថាមពលអគ្គិសនី បានមកពីរោងចក្រទែមិច ដែលតាំងនៅក្បែរអណ្ដូងវ៉ែធ្យូងនិងអ៊ីដ្រូកាបួ ឬជិតមជ្ឈមណ្ឌលប្រើប្រាស់ ។ ផលិតកម្មអគ្គិសនីសហរដ្ឋអាមេរិកបានលេខ 1 ក្នុងពិភពលោក (3 011 750 លាន kWh នៅឆ្នាំ 1990, 3 778 512 លាន kWh នៅឆ្នាំ 2003) ។

អគ្គិសនីបឋមបានមកពីកម្លាំងទឹកនិងនុយក្លេអ៊ែរតាងបានតែ 30% នៃផលិតកម្មអគ្គិសនីសរុប ។ វារីអគ្គិសនីអាមេរិកសំខាន់បំផុតក្នុងពិភពលោក បន្ទាប់ពីប្រទេសកាណាដា ។ នៅភាគខាងកើតមានមជ្ឈមណ្ឌលវារីអគ្គិសនីជាច្រើនកន្លែងមានទំហំល្មមស្ថិតនៅតាមបណ្ដោយជួរទឹកធ្លាក់(Fall Line) ត្រង់ចំណុចប្រសព្វនៃជើងភ្នំអាប៉ាឡាសនិងទំនាបឆ្នេរអាត្លង់ទិក នៅតាមអាងនៃទន្លេតេនេស៊ីនិងទន្លេសាំងឡូរ៉ង់ ។ ទំនប់ទឹកធំៗសម្បើមត្រូវបានស្ថាបនានៅភូមិភាគខាងលិច តាមអាងទន្លេកូឡូរ៉ាដូនិងកូឡុំប៊ីយ៉ា។

នៅពេលផលិតកម្មវារីអគ្គិសនីថយចុះ ផលិតកម្មថាមពលនុយក្លេអ៊ែរមានការកើនឡើង (606 900 លាន kWh នៅឆ្នាំ 1990, 763 700 លាន kWh នៅឆ្នាំ 2003) ។ កំណាប់រ៉ែអ៊ុយរ៉ាញ៉ូមស្ថិតនៅរប៉ាត់រប៉ាយតាមរដ្ឋនានានៃភូមិភាគខាងលិច ។ រោងចក្រនុយក្លេអ៊ែរជាច្រើនត្រូវបានកសាងឡើងជិតតំបន់ប្រើប្រាស់ធំៗនៅក្នុងទសវត្សរ៍ឆ្នាំ 1960 និងឆ្នាំ 1970 (លេខ 1 ក្នុងពិភពលោក) ។ ប៉ុន្តែ ក្រោយពីគ្រោះថ្នាក់នៃរោងចក្រថាមពលនុយក្លេអ៊ែរនៅទ្រីម៉ាយអ៊ីសឡិនកាលពីឆ្នាំ 1979 សហរដ្ឋអាមេរិកបានដាកមករកបម្រើបម្រាស់រោងចក្រទែមិច ដែលដើរដោយធ្យូងថ្មនិងអ៊ីដ្រូកាបួវិញ ។

ថាមពលថ្មី(ថាមពលព្រះអាទិត្យ ថាមពលខ្យល់ ថាមពលភ្នំភ្លើង) ទទួលបានការនិយមពីសាធារណជននិងទទួលបានជោគជ័យនៅភូមិភាគនិរតី តែមានចំណែកតិចតួចនៅឡើយក្នុងផលិតកម្មថាមពលរបស់សហរដ្ឋអាមេរិក ។

# 2. លំហាត់ឧស្សាហកម្ម

## 2.1. មហាអំណាចឧស្សាហកម្មលេខមួយ



ឧស្សាហកម្ម ស.រ.អ.

ឧស្សាហកម្មអាមេរិកប្រើប្រាស់ប្រជាជនសកម្មតែ 25% សម្រេចបាន 30% នៃផលិតផលជាតិសរុប ផ្តល់បាន $\frac{1}{4}$ នៃផលិតកម្មឧស្សាហកម្មពិភពលោក ហើយជាប់លេខ ១ ក្នុងវិស័យជាច្រើន ។

ប៉ុន្តែ ឧស្សាហកម្មអាមេរិកតែងរងការប្រកួតប្រជែងយ៉ាងខ្លាំងគ្នាពីប្រទេសជប៉ុន សហភាពអឺរ៉ុប និងប្រទេសឧស្សាកម្មថ្មីនៃអាស៊ី ។ សហរដ្ឋអាមេរិកបានខាតបង់យ៉ាងច្រើនលើទីផ្សារដោយការថយចុះនៃផលិតកម្មដែកថែប សំណង់រថយន្ត និងនាវា ។

ប្រឈមមុខនឹងវិបត្តិ ឧស្សាហកម្មខ្លះប្រកាន់យកជំហរដកថយ ដូចជានៅក្នុងឧស្សាហកម្មដែក ចំនួនពលករត្រូវបានកាត់បន្ថយអស់ 50% ក្នុងរយៈពេល 20 ឆ្នាំ ។ ឧស្សាហកម្មខ្លះទៀតបានផ្ទេរសកម្មភាពមួយផ្នែកទៅក្នុងប្រទេសកំពុងអភិវឌ្ឍ ព្រោះនៅទីកន្លែងនោះតម្លៃពលកម្មថោក ។ ឧស្សាហកម្មមួយចំនួនធំបានផ្លាស់ប្តូរទីតាំងផលិតកម្មនៅក្នុងប្រទេស ពិសេសឆ្ពោះទៅកាន់រដ្ឋភាគខាងត្បូង ។

សហគ្រាសខ្លះបានជ្រើសរើសយកយុទ្ធសាស្ត្រឧស្សាហកម្មថ្មី ដូចជាការកាត់បន្ថយប្រាក់ឈ្នួល ការបញ្ចូលបច្ចេកវិទ្យាខ្ពស់ទៅក្នុងផលិតកម្ម ការប្រើប្រាស់ប្រព័ន្ធមនុស្សយន្ត ការរៀបចំរោងចក្រដើរដោយស្វ័យប្រវត្តិដែលត្រូវការកម្លាំងពលកម្មតិច ។ ទន្ទឹមនឹងនេះ ទំនាក់ទំនងសង្គមក៏មានការវិវត្តដោយហេតុថាក្រុមហ៊ុនពលករទទួលបានការបណ្តុះបណ្តាលកាន់តែល្អប្រសើរនិងប្រកបដោយប្រសិទ្ធភាព ។

## 2.2. ឧស្សាហកម្មប្រពៃណី

ឧស្សាហកម្មប្រភេទនេះមានតាំងពីយូរយារណាស់មកហើយនៅលើទឹកដីអាមេរិក មានលោហកម្មដែក លោហកម្មក្រៅពីដែក វាយនភ័ណ្ឌនិងសំណង់រថយន្ត ហើយដែលធ្លាប់បាននិងកំពុងស្ថិតក្នុងភាពប្រកួតប្រជែងយ៉ាងខ្លាំងក្លាពីខាងក្រៅ ។

សហរដ្ឋអាមេរិកបានជាប់លេខ 1 លើពិភពលោកខាងឧស្សាហកម្មដែករហូតដល់ចុងទសវត្សរ៍ឆ្នាំ 1960 ។ សព្វថ្ងៃឧស្សាហកម្មប្រភេទនេះធ្លាក់មកនៅជួរទីបីដោយផលិតបានដែកថែបចំនួន 90.4 លានតោន ស្មើនឹង 9.4% នៃផលិតផលពិភពលោកនៅឆ្នាំ 2003 បន្ទាប់ពីប្រទេសចិន(220.1 លានតោន ស្មើនឹង 22.8%)និងប្រទេសជប៉ុន(110.5 លានតោនស្មើនឹង 11.5%) ។ បើពិតក្នុងផលិតកម្មពិភពលោក ផលិតកម្មដែកថែបសហរដ្ឋអាមេរិកបានថយចុះពី 55% (ឆ្នាំ 1945) មក 12% (ឆ្នាំ 1994) និង 9.4% (ឆ្នាំ 2003) ។

ឧស្សាហកម្មអាលុយមីញ៉ូមនៅតែមានការរីកចម្រើន ។ ក្រុមហ៊ុនពហុជាតិនានាដូចជា អលខូ (Alcoa) រេណាល(Reynolds) ខេហ្ស៊ឺ(Kaiser) និងអាម៉ាក្ស(Amax) សម្រេចបាន $\frac{3}{4}$ នៃផលិតកម្មដ៏ធំមួយស្មើនឹង 22% នៃផលិតកម្មពិភពលោក ។ រោងចក្រជាច្រើនតាំងនៅតំបន់សំបូរថាមពលអគ្គិសនីនៃជ្រលងទន្លេ កូឡូរ៉ាដូ កូឡុំប៊ីយ៉ា និងតេនីស៊ី ឬតំបន់នាំចូលបុកស៊ីតនៃឈូងមិកស៊ិក ។

ឧស្សាហកម្មវាយនភ័ណ្ឌកំពុងត្រូវបានផ្លាស់ប្តូរទីតាំង ដែលពីដំបូងតាំងនៅភូមិភាគឦសាន (រដ្ឋអង់គ្លេសថ្មី រដ្ឋញូយ៉ក) បន្ទាប់មក បានផ្លាស់ទីឆ្ពោះទៅខាងត្បូង ដើម្បីស្វែងរកក្រុមហត្ថពលករដែលខ្វះជំនាញនិងមានតម្លៃថោក ។ បណ្តុំឧស្សាហកម្ម អនុគ្រោះដល់ការធ្វើទំនើបកម្មនិងធ្វើឱ្យវាយនភណ្ឌអាមេរិកក្លាយជាផ្នែកមួយផ្តល់ផលច្រើនជាងគេក្នុងពិភពលោក ។ សហគ្រាស 5 ក្នុងចំណោម 10 ដែលធំជាងគេក្នុងលោកជារបស់សហរដ្ឋអាមេរិក ។ ប្រទេសនេះរ៉ាប់រងបានជិត $\frac{1}{4}$ នៃផលិតកម្មពិភពលោកខាងសំពត់សំលៀក ។

ឧស្សាហកម្មរថយន្តជាប់លេខ 2 បន្ទាប់ពីជប៉ុន ។ ស្ថាបនិកជាតិជប៉ុន បន្ទាប់មកកូរ៉េបានមកតាំងទីរោងចក្ររថយន្តនៅសហរដ្ឋអាមេរិក ។ ប៉ុន្តែក្រុមហ៊ុនរថយន្តអាមេរិកធំៗបី(សេនេរ៉ាល់ម៉ូទ័រ ហ្វត និងគ្រីស្លែ) បានសាកល្បងជួសជុលផលប៉ះពាល់ដោយបានចូលភាគហ៊ុនជាមួយគូប្រជែងជាតិអាស៊ី តាមរយៈការបង្កើតសាខានានា សំដៅជណ្តើមទីផ្សារឡើងវិញ ។ បណ្តុំរោងចក្រនៅតំបន់បឹងធំជុំវិញឌីត្រយ(ធានីរថយន្ត) មានការចុះខ្សោយ រីឯរដ្ឋកាលីហ្វ័រនីនិងភូមិភាគខាងត្បូងទទួលបានការរីកចម្រើនខ្លាំងក្នុងវិស័យនេះ ។ រដ្ឋមីស៊ីគេនបានបាត់បង់អស់ជាង 30% នៃការងារវិស័យរថយន្តនៅទសវត្សរ៍ឆ្នាំ 1980 ។ នៅឆ្នាំ 2003 សំណង់រថយន្តអាមេរិកបានឈរនៅជួរទី 1 ដោយផលិតបានរថយន្តដល់ទៅ 12.136 លានគ្រឿងស្មើនឹង 19.6% នៃផលិតកម្មពិភពលោក ។ ចំណែកជប៉ុនវិញឈរនៅជួរទី 2 ដោយផលិតបាន 10.286 លានគ្រឿងត្រូវជា 16.6% នៃផលិតកម្មពិភពលោក ។

## ២.៣. ឧស្សាហកម្មបញ្ញា

ឧស្សាហកម្មប្រភេទនេះ អាចហៅបានតាមរយៈឈ្មោះផ្សេងៗទៀតដូចជាឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ ឧស្សាហកម្មរូបធាតុប្រផេះ និងឧស្សាហកម្មស្រួចស្រាល់ ដែលផលិតមុខជំនាញដោយទាមទារក្រុមហត្ថពលករមានកម្រិតជំនាញខ្ពស់ ការស្រាវជ្រាវទុកជាមុន ការផ្សាំទៅនឹងបច្ចេកវិទ្យាចំឡែក និងមានការផ្លាស់ប្តូររហ័សនិងជាប់ជានិច្ច ។

ឧស្សាហកម្មគីមីអាមេរិកខ្លាំងក្លាណាស់ ។ ក្រុមហ៊ុនឌុយប៉ុងដឺនឺមួ(Dupont de Nemours)ជាប់លេខ 1 ក្នុងពិភពលោក ឈ្មោះក្រុមហ៊ុនធំៗរបស់អាល្លឺម៉ង់ដូចជា ហ៊ិច(Hoechst) ប៊ីអេអែសអែហ្វ (B.A.S.F) និងបាយឺ(Bayer) ។ ការស្រាវជ្រាវនិងតម្លៃបន្ថែមមានធំធេងណាស់ ធ្វើឱ្យផ្នែកនេះអាចរក្សាឧត្តមភាពរបស់ខ្លួនតាំងពីទីផ្សារវត្ថុធាតុប្លាស្ទិចនិងជ័រ រហូតដល់កៅស៊ូនិងថ្នាំលាងសំអាត ។ ការចំរាញ់ប្រេងកាតនៅតែជាសកម្មភាពមួយខ្លាំងក្លាបំផុតក្នុងលោក (ជាប់លេខ 1) ដោយផលិតបាន 831.911 លានតោនត្រូវជា 20.3% នៃផលិតកម្មពិភពលោកនៅឆ្នាំ 2003 ។

ឧស្សាហកម្មគីមីមាននៅក្បែរអណ្តូងរ៉ែដែលមានពាសពេញដែនដីដូចជា ផូស្វាតនៅរដ្ឋផ្លរីដា អំបិលនៅរដ្ឋមីស៊ីកេន រដ្ឋអ៊ូតាស ឬឈូងម៉ិកស៊ិក ស្ពាន់ធ័រនៅរដ្ឋតិចសាស់ ។ គីមីសរីរាង្គផ្សារភ្ជាប់ទៅនឹងធ្យូងថ្ម(ភ្នំអាប៉ាឡាស) ទៅនឹងការចំរាញ់ប្រេងកាត(ហ៊្វូស្តុន បាតុងរូ ឡូសអង់សឺឡែស) ។

ឧត្តមភាពអាមេរិកកើតមានឡើងយ៉ាងខ្ជាប់ខ្ជួនលើផ្នែកសំណង់គ្រឿងអគ្គិសនី(សេនេរ៉ាល់អេឡិចទ្រិច)និងគ្រឿងអេឡិចត្រូនិក ដោយបានទទួលអំណោយផលពីទីផ្សារក្នុងស្រុក ។ ទោះបីឧស្សាហកម្មជប៉ុនជាន់ពន្លិចឧស្សាហកម្មអាមេរិកខាងអេឡិចត្រូនិកសម្រាប់មហាជន ហើយដណ្តើមយកចំណាត់ថ្នាក់លេខ 1 ខាងគ្រឿងផ្សំក៏ដោយ ក៏សហរដ្ឋអាមេរិកនៅតែសម្រេចបាន 40% នៃផលិតកម្មអេឡិចត្រូនិកពិភពលោក ។ វិស័យព័ត៌មានវិទ្យាដែលមានភាពប្រសើរជាងគេ ជារបស់សហគ្រាសធំៗដូចជា អាយប៊ីអឹម(I.B.M) ឌីជីថលអេគីបមិន(Digital Equipement) អិនស៊ីអ(N.C.R) យូឡិត-ប៉ាកាដ (Hewlett-Pakard) ។ សាខាអេឡិចត្រូនិកទាំងឡាយមានទីតាំងក្នុងទីក្រុងធំៗក្បែរសកលវិទ្យាល័យវិទ្យាសាស្ត្រនានា ។

ឧស្សាហកម្មយន្តហោះនិងយានអវកាសស្ថិតក្នុងចំណោមស្នាដៃវិសេសបំផុត ។ សហគ្រាសអាមេរិកចំនួន 9 មានមុខនៅក្នុងចំណោមសហគ្រាស 10 ដែលធំជាងគេក្នុងលោកខាងផ្នែកយានអវកាស ។ ក្រុមហ៊ុនយន្តហោះបូអ៊ិញ(Boeing)ប្រើប្រាស់បុគ្គលិកអស់ជាង 80 000 នាក់និងគ្របដណ្តប់បាន $\frac{2}{3}$ នៃតម្រូវការពិភពលោកខាងដំណើរផ្លូវឆ្ងាយ ។ រោងចក្រយន្តហោះនិងយានអវកាសស្ថិតនៅរាយប៉ាយពាសពេញដែនដី តែមានច្រើនជាងគេនៅតាមឆ្នេរអាត្លង់ទិកជុំវិញតំបន់បឹងធំក្នុងរដ្ឋតិចសាស់ កាន់សាស់ និងឆ្នេរប៉ាស៊ីហ្វិក ។ សហរដ្ឋអាមេរិករ៉ាប់រងបាន 61% នៃផលិតកម្មយានអវកាស-ពិភពលោកទល់នឹង32% សម្រាប់សហភាពអឺរ៉ុប ។

## 3. កសិកម្មអាមេរិក

សហរដ្ឋអាមេរិកជាមហាអំណាចកសិកម្មលេខ ១ ផងដែរ ។ អានុភាពកសិកម្មស្ថិតនៅចន្លោះឧត្តមភាពនិងភាពចំណុះពិភពលោកខាងក្រៅ ។

កសិកម្មអាមេរិកទទួលបានការបំពាក់គ្រឿងយន្តមួយដ៏អស្ចារ្យនិងការបង្កើនអានុភាពតាមរយៈការស្រាវជ្រាវក្សេត្រសាស្ត្រជឿនលឿនមួយ អាចធ្វើឱ្យសហរដ្ឋអាមេរិកក្លាយទៅជាផលិតករនិងអ្នកនាំចេញកសិផលលេខ ១ ក្នុងលោក ។ ឯកទេសកម្មតាមតំបន់(វង់កសិកម្ម) លែងមានលក្ខណៈដាច់ណាត់ ដោយផ្តល់លទ្ធភាពឱ្យដល់ការដាំដុះដំណាំផ្សេងៗយ៉ាងសម្បូរបែប ។

ដោយប្រើប្រាស់តែ 2.7% នៃប្រជាជនសកម្ម កសិកម្មអាមេរិកបានផ្គត់ផ្គង់ពហុដ្ឋានកសិអាហារមួយ(20% នៃប្រជាជនសកម្ម) ដែលរៀបចំឡើងនិងធ្វើសមាហរ័ណយ៉ាងខ្លាំងក្លាដោយសហគ្រាសពហុជាតិ(F.M.N) ដូចជា អលទ្រីយ៉ា(Altria) និងប៉ិបស៊ីកូ(Pepsico) ។ ពហុជាតិដ៏មានអានុភាពទាំងនោះអាចដាក់សម្ពាធទៅលើរដ្ឋាភិបាល ដើម្បីបានទទួលជំនួសក្នុងការនាំចេញដែលជាគន្លឹះនៃកសិ-ពាណិជ្ជកម្ម ។

ទីផ្សារអន្តរជាតិជាអាយុជីវិតនៃកសិកម្មអាមេរិក ។ នៅពេលណាទីផ្សារលោកខាងត្បូង ឬអឺរ៉ុបកាត់បន្ថយការបញ្ជាទិញ កសិករតែងជួបការលំបាកស្តុកកសិផលកាន់តែរីកធំ តម្លៃផលិតផលក៏ស្រុតចុះ កសិករបង្ខំចិត្តលក់ដីស្រែចម្ការ អាជីវកម្មទ្រង់ទ្រាយតូចបានបាត់បង់បន្តិចម្តងៗ កសិដ្ឋានធំៗក៏លេចឡើង ។ ដើម្បីជួយដោះស្រាយបញ្ហាជូនប្រជាកសិករ រដ្ឋាភិបាលសហព័ន្ធបានធ្វើអន្តរាគមន៍ជាប្រចាំក្នុងការរកទីផ្សារ កាត់បន្ថយស្តុកធញ្ញជាតិតាមការផ្តល់ជំនួយស្បៀងដល់ប្រទេសក្រីក្រ បង្កើតរោងចក្រកែច្នៃកសិផល ជួយបង់ខាតក្នុងការនាំចេញ ផ្តល់ឥណទានខ្លះដល់កសិករ ... ។

## 4. ពាណិជ្ជកម្មក្រៅប្រទេស

ថ្វីបើមានទីផ្សារក្នុងស្រុកដ៏ធំទូលាយនិងកម្លាំងផលិតកម្មដ៏ខ្លាំងក្លា សហរដ្ឋអាមេរិកជាមហាអំណាចលេខ ១ ខាងពាណិជ្ជកម្ម ហើយក៏ជាអ្នកនាំចូលលេខ ១ ក្នុងលោក ។ ទោះបីដៃគូប្រពៃណីរបស់សហរដ្ឋអាមេរិកជាសមាជិកដទៃទៀតនៃទ្រីយ៉ាត(ប៉ូលសេដ្ឋកិច្ចទាំងបីនៃពិភពលោក)ក៏ដោយ ក៏ការបង្កើតតំបន់ពាណិជ្ជកម្មសេរីនៃអាមេរិកខាងជើង(NAFTA = North America Free Trade Area) បានជួយពង្រឹងជំហររបស់ប្រទេសកាណាដានិងម៉ិកស៊ិកដែរ ។

ជញ្ជីងពាណិជ្ជកម្មសហរដ្ឋអាមេរិកបានចំណេញជាប់រហូតដល់ដើមទសវត្សរ៍ឆ្នាំ 1980 រួចចាប់ផ្តើមបាត់បង់តុល្យភាពជាប់រហូតដល់សព្វថ្ងៃ ។ តើឧត្តមភាពសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកនឹងក្លាយទៅជាយ៉ាងណា ? សហរដ្ឋអាមេរិក អាចរក្សាមុខមាត់និងជំហររឹងមាំបានដោយសារការទទួលបាន

ផលចំណេញច្រើនពីការនាំចេញសេវានិងការផ្ទេរមូលធនពីបរទេសដែលនាំឱ្យជញ្ជីងខ្វះខាត់របស់គេអាចរក្សាតុល្យភាពបាន ។

នៅពេលដែល NAFTA បានរៀបចំពិធីបុណ្យរំលឹកខួប 10 ឆ្នាំរបស់ខ្លួនកាលពីខែមករា ឆ្នាំ 2004 រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអាមេរិក( លើកលែងប្រទេសគុយបា) ចំនួន 34 រូបត្រៀមខ្លួននិងបង្កើតតំបន់ដោះដូរសេរីនៃអាមេរិក (ZLEA) នៅដំណាច់ឆ្នាំ 2005 យ៉ាងយូរ ។ ប៉ុន្តែមានឧបសគ្គជាច្រើនដែលត្រូវជម្នះ ដូចជាគម្លាតអភិវឌ្ឍន៍សេដ្ឋកិច្ច អស្ថិរភាពនយោបាយនៅក្នុងប្រទេសខ្លះ ជំនួយលើវិស័យកសិកម្មនិងបញ្ហាបរិស្ថាន ។




*លំនាំចេញចូល ស.រ.អ.*

*ពាណិជ្ជកម្មក្រៅប្រទេស ស.រ.អ. ឆ្នាំ 2000*

## សំណួរ

1. តើធនធានថាមពលសំខាន់ៗរបស់សហរដ្ឋអាមេរិកមានអ្វីខ្លះ ? មាននៅទីណាខ្លះ ?
2. តើសហគ្រាសអាមេរិកប្រើយុទ្ធសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយវិបត្តិ ?
3. តើឧស្សាហកម្មប្រពៃណីរបស់សហរដ្ឋអាមេរិកមានអ្វីខ្លះ ?
4. ចូរនិយាយអំពីស្ថានភាពឧស្សាហកម្មវាយនភ័ណ្ឌអាមេរិក ។
5. តើអ្វីទៅដែលហៅថាឧស្សាហកម្មបញ្ញា ? ហេតុអ្វីបានជាប្រទេសមហាអំណាចខិតខំប្រឹងប្រែងអភិវឌ្ឍវិស័យឧស្សាហកម្មបញ្ញា ?
6. តើការបាត់បង់តុល្យភាពនៃជញ្ជីងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក នាំឱ្យប៉ះពាល់ដល់ឧត្តមភាពរបស់ប្រទេសដែរ ឬទេ ? ចូរពន្យល់ ។

## ? សំណួរបញ្ចប់ជំពូកទី៦

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់**

1. សហរដ្ឋអាមេរិកមានរដ្ឋចំនួន

☐ក. 48 ☐ខ. 50 ☐គ. 52 ☐ឃ. 58 ។

2. សកម្មភាពដឹកជញ្ជូនអ្នកដំណើរសំខាន់ជាងគេនៅសហរដ្ឋអាមេរិកគឺ

☐ក. ផ្លូវអាកាស ☐ខ. ផ្លូវដែក ☐គ. ផ្លូវថ្នល់ ☐ឃ. ផ្លូវទឹក ។

3. រដ្ឋដែលមានប្រជាជនរស់នៅច្រើនជាងគេគឺ

☐ក. ញូយ៉ក ☐ខ. កាលីហ្វ័រនី ☐គ. តិចសាស់ ☐ឃ. ផ្លរីដា ។

**II. ចូរចំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ជួរភ្នំដែលស្ថិតប៉ែកខាងកើតនៃសហរដ្ឋអាមេរិកមានឈ្មោះថា ជួរភ្នំ .............................. ។
2. អាកាសយានដ្ឋានដែលចំនិងទទួលអ្នកដំណើរបានច្រើនជាងគេគឺអាកាសយានដ្ឋាន ........... ។
3. តំបន់ដែលពួកនិវត្តជនចូលចិត្តទៅរស់នៅគឺតំបន់ ........................................................ ។

**III. សំណួរ**

1. តើគ្រិះសេរីភាពបុគ្គលផ្តល់ផលល្អចំពោះសេដ្ឋកិច្ចអាមេរិកដូចម្តេចខ្លះ ?
2. ហេតុអ្វីបានជាសហគ្រាសធំៗនៅអាមេរិក ផ្តល់ជំនួយឧបត្ថម្ភដល់មន្ទីរពិសោធន៍នៃសកលវិទ្យាល័យនានា ?
3. តើសហគ្រាសធំៗនៅអាមេរិក ស្ថិតក្នុងវិស័យឧស្សាហកម្មអ្វីខ្លះ ? ចូររៀបរាប់ឱ្យបានបួនវិស័យឧស្សាហកម្ម ។
4. តើតំបន់ទំនាបកណ្តាលសហរដ្ឋអាមេរិកមានសារៈសំខាន់ចំពោះកសិកម្មដូចម្តេច ? ហេតុអ្វី ?
5. តើការដឹកជញ្ជូនផ្នែកណាដែលមានសកម្មភាពមមាញឹកជាងគេ ? ហេតុអ្វី ?
6. ហេតុអ្វីបានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចទី ១ បើប្រទេសនេះទើបតែកើតថ្មី ?
7. ហេតុអ្វីបានជាសហរដ្ឋអាមេរិកសំបូរទៅដោយចំណូលស្រុក ? ចាប់ពីឆ្នាំ 1960 មកតើចំណូលស្រុកច្រើនមកពីទ្វីបណាខ្លះ ? ហេតុអ្វី ?
8. អានុភាពកសិកម្មសហរដ្ឋអាមេរិកស្ថិតនៅចន្លោះឧត្តមភាពនិងភាពចំណុះ ។ ចូរពន្យល់អំណះអំណាងនេះ ។

**IV. លំហាត់**

1. នៅឆ្នាំ 2009 សហរដ្ឋអាមេរិកមានប្រជាជន 314 659 000 នាក់និងមានប្រជាជនទីក្រុង 80% ។ ចូរគណនាចំនួនប្រជាជនរស់នៅជនបទ ។
2. នៅឆ្នាំ 2008 ប្រជាជនវ័យចាស់លើស 65 ឆ្នាំមាន 13% និងកុមារក្រោមអាយុ 15 ឆ្នាំមាន 20% ។ ចូរគណនាភាគរយនៃប្រជាជនសកម្ម ។

ជំពូកទី 7

# ប្រទេសជប៉ុន




*ប្រទេសជប៉ុន*

ប្រទេសជប៉ុនជាកម្រងកោះមួយតូចចង្អៀតរាងដងធ្នូស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ឈមមុខឆ្ពោះខាងកើតនៃទ្វីបអាស៊ី ខ្វះធនធានរ៉ែនិងថាមពល សម្បូរគ្រោះធម្មជាតិ មានប្រជាជនច្រើននិងខ្ទេចខ្ទាំដោយសង្គ្រាមលោកលើកទី 2 ។ តើជនជាតិជប៉ុន កសាងទឹកដីខ្លួន ពិសេសសេដ្ឋកិច្ចជាតិបានរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យស្ញប់ស្ញែងដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ ? តើជប៉ុនអាចរក្សាតំណែងជាមហាអំណាចសេដ្ឋកិច្ចពិភពលោកបានដោយមធ្យោបាយណាខ្លះ ?

មេរៀនទី

# 1 ត្រឹះនៃមហាអំណាចជប៉ុន

**ចប់មេរៀននេះ សិស្សអាច**

❑ រៀបរាប់បានពីគ្រឹះនៃមហាអំណាចជប៉ុន ការបើកចំហទៅរកពិភពលោក និងការរៀបចំសេដ្ឋកិច្ច ។

ប្រទេសជប៉ុនជាកម្រងកោះមានកោះទាំងអស់ចំនួនជាង 4 000 ដែលក្នុងនោះមានកោះធំៗបួនគឺ

- កោះហុកកៃដូ (យេសូ) ស្ថិតនៅប៉ែកខាងជើង
- កោះហុងដូ (ហុងស្យូ) ដែលធំជាងគេស្ថិតនៅកណ្ដាល
- កោះស៊ីកុក (ស៊ីកុគូ) ស្ថិតនៅប៉ែកខាងត្បូង
- កោះត្យូស្យូ ស្ថិតនៅខាងត្បូងបំផុត ។

ក្រោយបរាជ័យនៅឆ្នាំ 1945 និងត្រូវបំផ្លាញទាំងស្រុង ប្រទេសជប៉ុនបានងើបឡើងយ៉ាងរហ័សតែបីទសវត្សរ៍ ទៅកាន់ឋានៈជាមហាអំណាចពិភពលោក ដោយសារតែជំនួយរបស់សហរដ្ឋអាមេរិកពីខាងដើមទី ប៉ុន្តែក៏ដោយសារការខិតខំប្រឹងប្រែងគួរឱ្យចាប់អារម្មណ៍និងជម្រើសសេដ្ឋកិច្ចប្រកបដោយវិចារណញ្ញាណរបស់ខ្លួនដែរ ។

## 1. ការបើកចំហជាចាំបាច់ទៅរកពិភពលោក

មុននឹងកសាងបានសេដ្ឋកិច្ចមួយរីកចម្រើនសំបូរសប្បាយ ជនជាតិជប៉ុនត្រូវតែទម្លាប់រស់នៅដោយចំនួនច្រើនក្នុងមជ្ឈដ្ឋានធម្មជាតិមួយពោរពេញទៅដោយអរិភាពបំផុត ។

### 1.1. ការលំបាកបង្កឡើងដោយធម្មជាតិ

កម្រងកោះជប៉ុនមានលក្ខណៈតូចចង្អៀតដាច់ចេញពីគ្នាជាផ្នែកៗ សំបូរភ្នំដែលគ្របដណ្ដប់លើ 3/4 នៃផ្ទៃប្រទេស ។ ភ្នំទាំងនោះមិនសូវជាខ្ពស់ប៉ុន្មានទេលើកលែងតែភ្នំភ្លើងភូជីយ៉ាម៉ា (3776 m) ប៉ុន្តែដាច់ចេញជាកំណាត់ៗ និងមានអាកាសធាតុខុសៗគ្នាដោយសារតែការសណ្ដូកយ៉ាងវែងតាមរយៈទទឹងហើយសំណើមខ្ពស់ជាលក្ខណៈរួមរបស់ប្រទេស ។ របបភ្លៀងនៅប្រទេសជប៉ុនត្រូវកំណត់ដោយរបបខ្យល់មូសុង ដែលនាំមកនូវភាពសំបូរធនធានទឹកនិងគម្របព្រៃឈើប្លែកៗ ។ ចំណែកទំនាបវិញមានមិន

លើសពី 16% នៃផ្ទៃប្រទេស ដែលនៅទីនោះប្រជាជនជប៉ុនប្រមូលផ្តុំគ្នារស់នៅយ៉ាងកុះករ ។ ជនជាតិជប៉ុនគោរពស្រឡាញ់ព្រៃឈើណាស់ គេមិនកាប់បំផ្លាញទេ ។ គេតែងវាតទីនៅលើសមុទ្រដើម្បីយកដីសាងសង់លំនៅឋាន សួនច្បារ ច្បារដំណាំ រោងចក្រឧស្សាហកម្ម... តាមរបៀបធ្វើដីឡើន ឬប៉ុលឌ័ ។

គ្រោះធម្មជាតិតែងកើតមានជាញឹកញាប់ ដូចជាការផ្ទុះភ្នំភ្លើង ព្យុះទីផុង រញ្ជួយដី និងរលកយក្សស៊ូណាមិ ។ រញ្ជួយដីមួយនៅឆ្នាំ 1923 បានបំផ្លាញទីក្រុងតូក្យូនិងបណ្តាលឱ្យមានជនរងគ្រោះដល់ទៅជាង 100 000 នាក់ ។ រញ្ជួយដីមួយទៀតនៅឆ្នាំ 1995 ក្នុងក្រុងខូបេ បានបំផ្លាញទ្រព្យសម្បត្តិអស់យ៉ាងច្រើននិងសម្លាប់មនុស្សអស់ជាង 500 នាក់ ។ ថ្មីៗនេះ (2011) រលកយក្សស៊ូណាមិបានបំផ្លាញជីវិតមនុស្សនិងទ្រព្យសម្បត្តិអស់យ៉ាងច្រើនថែមទៀត ។

## 1.2. ការផ្តុំគ្នារស់នៅលើកម្រងកោះ

នៅលើទឹកដីដ៏តូចចង្អៀតនិងសំបូរគ្រោះធម្មជាតិ ជនជាតិជប៉ុនរស់នៅក្នុងក្តីបារម្ភចំពោះលើ្សសចំណុះប្រជាជន ។ នៅដើមសតវត្សទី 18 ជប៉ុនមានប្រជាជន 26 លាននាក់ ចំនួននេះហាក់ដូចជាឈានដល់ព្រំដែននៃភាពអនុគ្រោះជាស្រេចទៅហើយ ។ នៅឆ្នាំ 1950 ចំនួននេះឡើងដល់ 84 លាននាក់ឆ្នាំ 1992 មាន 124 លាននាក់ ឆ្នាំ 2009 មានជាង 127 លាននាក់ ឆ្នាំ 2030 នឹងមានដល់ 134 លាននាក់ ។ នៅឆ្នាំ 2009 ដង់ស៊ីតេប្រជាជនជប៉ុនមធ្យមមាន 336 នាក់ / $km^2$ ។ ប៉ុន្តែតំបន់ឧស្សាហកម្មតាមឆ្នេរមានជាង 1200 នាក់ / $km^2$ ។

តាមពិតទៅ ទោះបីមានដង់ស៊ីតេខ្ពស់បែបនេះក្តី ក៏ប្រទេសជប៉ុនមិនមានបញ្ហាលើសប្រជាជនឡើយ ដោយហេតុថាវឌ្ឍនភាពសេដ្ឋកិច្ចអាចស្រូបយកធនធានមនុស្សបានទាន់ពេល ហើយជនជាតិជប៉ុនមានទម្លាប់រស់នៅលើលំហតូចចង្អៀតបានប្រសើរជាងពួកលោកខាងលិច ។ ប្រជាជនជប៉ុនប្រមូលផ្តុំគ្នារស់នៅតាមឆ្នេរនៃសមុទ្រក្នុង ចំណែកឆ្នេរនៃសមុទ្រជប៉ុននិងកោះភាគខាងជើងមានមនុស្សរស់នៅតិចនៅឡើយ (64 នាក់ / $km^2$ នៅកោះហុកកៃដូ) ។ 80% នៃប្រជាជនជប៉ុនរស់នៅក្នុងទីក្រុង ។ ពីតូក្យូទៅភូគូអូកាគឺជាមេកាឡូប៉ូលជប៉ុន "តូកៃដូ" (Tokaido) ដែលមានប្រជុំជនតូក្យូជាស្នូល (30 លាននាក់) និងពហុដ្ឋានអូសាកា- ខូបេ- ក្យូតូ (17 លាននាក់) ។

ភាពសំបូរប្រជាជនជាកត្តាដ៏សំខាន់នាំឱ្យជប៉ុនទទួលជោគជ័យ ដោយមិនបានហាមឃាត់ការអនុវត្តនយោបាយប្រឆាំងកំណើតឡើយ ។ ច្បាប់បានអនុញ្ញាតឱ្យរំលូតកូននិងធ្វើឱ្យអាបានដោយសេរី ដោយពង្រីកការផ្សព្វផ្សាយវិធីធ្វើកុំឱ្យមានគភ៌ ។ នយោបាយនេះទទួលបានលទ្ធផលយ៉ាងឆាប់រហ័សទាំងនៅទីក្រុងនិងជនបទ ។ អត្រាជាតិប្រមាណបានថយចុះពី 34% នៅឆ្នាំ 1947 10%(1992) មកត្រឹម 7.64% នៅឆ្នាំ 2009 ។

ការប្រែប្រួលទម្រង់ប្រជាសាស្ត្រនេះ នាំមកនូវផលវិបាកជាច្រើន ។ កំណើនប្រជាសាស្ត្រមានការថយចុះ ។ អត្រាកំណើនមធ្យមប្រចាំឆ្នាំមាន 10.8% នៅឆ្នាំ 1970 មកនៅត្រឹម 3% (1992) 2% (2000-2005) និង -1.91% (2009) ។ ការធ្លាក់នៃអត្រាជាតិប្រមាណបានបន្ធូរបន្ថយបន្ទុកគ្រួសារផងនិងរដ្ឋផង ។ រីឯចំនួនមនុស្សដែលឈានដល់វ័យចូលនិវត្តន៍កាន់តែតិច ហើយប្រជាជនសកម្មកាន់តែមានច្រើន ។ សេដ្ឋកិច្ចជប៉ុនរីកចម្រើនក្រោមទិដ្ឋភាពពីរ គឺផលិតកម្មនិងការប្រើប្រាស់ ។

ប៉ុន្តែ ភាពចំណាស់នៃប្រជាជនជប៉ុនសព្វថ្ងៃកាន់តែមានល្បឿនខ្លាំង ។ មនុស្សអាយុលើសពី 65ឆ្នាំមាន 5.7%នៅឆ្នាំ 1960 13% (1992) និង 22.2%នៅឆ្នាំ 2009 ។ ស្ថានភាពនេះបានជះឥទ្ធិពលទៅលើសេដ្ឋកិច្ចជាតិដោយហេតុថា ចំនួនប្រជាជនសកម្មមានការថយចុះ ។ គេសាកល្បងកែលំអស្ថានភាពដោយពន្យារអាយុចូលនិវត្តន៍ឱ្យដល់ 70ឆ្នាំ ការកម្រិតប្រាក់សោធន ។ គេមានគម្រោងឱ្យមនុស្សចាស់ចេញទៅរស់នៅក្នុងប្រទេសក្រៅដែលតម្លៃជីវភាពមិនសូវខ្ពស់ ។




*ពីរ៉ាមីតអាយុប្រជាជនជប៉ុនបង្ហាញពីភាពចំណាស់នៃប្រជាជនជប៉ុន*

## 1.3. ភាពចំណុះប្រទេសក្រៅ

ប្រទេសជប៉ុនហាក់ដូចជាស្ថិតនៅដាច់តែឯងដោយសារទីតាំងភូមិសាស្ត្ររបស់ខ្លួនជាដែនដីកោះតាមបណ្ដោយឆ្នេរនៃមហាសមុទ្រប៉ាស៊ីហ្វិក ។ ប៉ុន្តែ ជប៉ុនក៏បានផ្ញើទំនាក់ទំនងសេដ្ឋកិច្ចជាមួយប្រទេសផ្សេងៗមួយចំនួនដែរ ដោយសារតែភាពក្មេងខ្ចីនៃកំណកំណើតទឹកដីដែលជាកត្តានាំឱ្យខ្វះវត្ថុធាតុដើមនិងថាមពល ។ ចំពោះចំណីអាហារក៏ដូចគ្នានេះដែរ ធនធានដីនិងសមុទ្រមានមិនគ្រប់គ្រាន់ ។ អាជីវកម្មបែបអតិផលនៅតែជាកង្វល់រហូតដល់សព្វថ្ងៃ ។

ពិភពជនបទជប៉ុនគឺជាពិភពនៃដំណាំស្រូវ ។ លក្ខខណ្ឌអាកាសធាតុអាចឱ្យគេដាំដុះដំណាំបានច្រើនមុខ ពីដំណាំត្រូពិក រហូតដល់ដំណាំត្រជាក់បង្គួរ (ដំឡូងបារាំង) តែអនុគ្រោះដល់ដំណាំស្រូវដែលត្រូវការទឹកនិងកម្ដៅជាច្រើនខែ ។ ជាប្រពៃណីគេដាំដំណាំស្ងួត (ស្រូវសាលី អក) ដំណាំតែ មននិងបន្លែច្រើនមុខ ។ ដីដាំដុះមានរាងជាធរណីមាត្រ ត្រូវបានថែទាំយ៉ាងហ្មត់ចត់ ដោយម្ចាស់កម្មសិទ្ធិតូចៗ តម្រូវឱ្យមានការងារមួយដ៏លំបាកនិងកិច្ចសហការរបស់អ្នកភូមិផង ។

កសិករបានទទួលទំនើបកម្មដោយផ្អែកលើការប្រើប្រាស់ជីនិងយន្តកម្ម ។ វឌ្ឍនភាពកសិកម្មបានមកពីកំណែទម្រង់ដីធ្លីដែលតម្រូវឱ្យអនុវត្តដោយពួកអាមេរិកកាលឆ្នាំ 1945 ។ កំណែទម្រង់នេះបានបង្កើតឱ្យមានស្រទាប់កសិករដែលជាម្ចាស់កម្មសិទ្ធិដីធ្លីតូចតាច ។ ទោះបីផលិតកម្មស្រូវក្នុងស្រុកមានតម្លៃខ្ពស់ជាងនៅលើពិភពលោកក៏ដោយ ក៏បានកម្រិតការនាំចូលស្រូវបានមួយភាគយ៉ាងសំខាន់ ។ ទោះបីមានកិច្ចការពារបែបនេះក្ដីក៏ចំនួនកសិករបានថយចុះយ៉ាងច្រើន ពី 6 លានគ្រួសារនៅឆ្នាំ 1960 មក 3 លានគ្រួសារនៅឆ្នាំ 1993 ។ សព្វថ្ងៃ ចំនួនកសិករជប៉ុនតាង 4.4% នៃប្រជាជនសកម្ម ត្រូវជា 2.9 លាននាក់ ប្រហែលជាងមួយលានគ្រួសារ(ឆ្នាំ 2009) ។ មុខរបរផ្សេងទៀត ឬអាជីវកម្មពាក់កណ្ដាលពេលតែងកើតមានជាទូទៅ : 80% នៃគ្រួសារកសិករមានធនធានដទៃទៀត បន្ថែមពីលើផលទុនកសិកររបស់ខ្លួនដែលក្នុងចំនួននោះ 68% ពឹងផ្អែកលើរបរផ្សេងទៀត អាចផ្ដល់ប្រាក់កំរៃខ្ពស់ជាងកំរៃដែលបានមកពីការងារកសិកម្ម ។

ភោគទ្រព្យសំខាន់មួយទៀតគឺ ភោគផលនេសាទ ។ ជនជាតិជប៉ុនជាអ្នកបរិភោគត្រីដ៏ធំមួយក្នុងលោក ។ ជប៉ុនបានជាប់ចំណាត់ពិភពលោកលេខ 4 ខាងការនេសាទ បន្ទាប់ពីបានលេខមួយអស់រយៈពេលយ៉ាងយូរមក ។ ផលិតផលនេសាទផ្គត់ផ្គង់បាន 50% នៃប្រូតេអ៊ីនដែលបានមកពីសត្វ ។ នាវា-រោងចក្រ តែងស្វែងរកចាប់ត្រីសូម៉ុងនិងក្ដាមនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិកខាងជើង ត្រីបាឡែនក្នុងដែនសមុទ្រតំបន់អង់តាកទិក ត្រីតុងក្នុងដែនសមុទ្រត្រូពិក ។ ការកម្រិតព្រំដែនសិទ្ធិនេសាទដោយប្រទេសមហាអំណាចនិងបទបញ្ញត្តិអន្តរជាតិនៅឆ្នាំ 1977 បានកំណត់អធិបតេយ្យភាពដែនសមុទ្រដល់ទៅ 200 ម៉ាយ (1 ម៉ាយ =1609m) សម្រាប់ប្រទេសមានឆ្នេរនាំឱ្យការនេសាទរបស់ជប៉ុនជួបបញ្ហា ។ ជនជាតិជប៉ុននៅបានយកចិត្តទុកដាក់ទៅលើវារីវប្បកម្ម មានការចិញ្ចឹមត្រី ក្ដាម បង្កង និងការដាំសារាយ ។

តម្រូវការចំណីអាហារនៅតែជាភាពចាំបាច់ ។ ភាពចំណុះប្រទេសក្រៅខាងស្បៀងនៅតែមានជាបន្ត ។ ជប៉ុនជាអ្នកនាំចូលផលិតផលអាហារលេខមួយក្នុងពិភពលោក មានធញ្ញជាតិ 70% នៃការប្រើប្រាស់ សណ្ដែកសៀង 90% ស្ករ 60% សាច់គោ 30% ។ កម្រិតស្វ័យគ្រប់គ្រាន់មាន 80% នៅឆ្នាំ 1960 មក 50% នៅឆ្នាំ 1992 និង 11.5% នៅឆ្នាំ 1996 ហើយបញ្ហាសុវត្ថិភាពស្បៀងនាំមកនូវក្ដីកង្វល់មួយ ។ ជនជាតិជប៉ុនត្រូវតែទទួលយកនូវតម្លៃដ៏ខ្ពង់ខ្ពស់មួយក្នុងការចំណាយទៅលើចំណីអាហារ(26% នៃការចំណាយលើការប្រើប្រាស់ក្នុងគ្រួសារ) ។

ប្រឈមទៅនិងភាពលូតលាស់ដ៏ខ្លាំងក្លានៃសេដ្ឋកិច្ច ប្រទេសជប៉ុនត្រូវចំណាយទៅលើការនាំចូលផលិតផលអាហារ ថាមពលនិងវត្ថុធាតុដើម ។ ជនជាតិជប៉ុនយល់ច្បាស់ណាស់ថា ការផ្គត់ផ្គង់ទាំងនោះពឹងផ្អែកទាំងស្រុងទៅលើការដោះដូរក្រៅប្រទេស ។

## 2. ការរៀបចំសេដ្ឋកិច្ច

ជោគជ័យរបស់ប្រទេសជប៉ុន អាចពន្យល់បានមួយផ្នែកធំតាមរយៈការរៀបចំនយោបាយនិងសង្គមដ៏ចំឡែកមួយ ។ រដ្ឋធ្វើអន្តរាគមន៍ក្នុងជីវភាពសេដ្ឋកិច្ច ដោយបើកទូលាយឱ្យដល់គំនិតផ្តួចផ្តើមរបស់សហគ្រាសធំៗដែលបង្កើតបានជាកុងគ្លូមេរ៉ាដ៏ខ្លាំងក្លា ប៉ុន្តែក៏មានការចូលរួមជាមួយសហគ្រាសតូចនិងមធ្យមផងដែរ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចមួយទីផ្សារនិយម ។ ទំនាក់ទំនងសង្គមបានគួបផ្សំការព្រមព្រៀងគ្នានិងឋានានុក្រម និងធ្វើឱ្យសហគ្រិនទទួលបានផលចំណេញពីក្រុមកម្មករ ដែលមានវិន័យមានការបណ្តុះបណ្តាលល្អនិងមានជីវភាពរស់នៅសមរម្យ ទោះបីពួកគេមានការរីកចម្រើនថ្មីៗនេះក្តី ។ យុទ្ធសាស្ត្ររបស់សហគ្រាសធំៗនិងរដ្ឋសំដៅឆ្ពោះទៅការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សេវាឱ្យដល់សហគ្រាសពិសេសសហគ្រាសធំៗ ហើយនិងកិច្ចការពារទីផ្សារក្នុងស្រុកទប់ទល់នឹងការប្រកួតប្រជែងពីខាងក្រៅតាមវិធានការមួយចំនួនយ៉ាងប៉ិនប្រសប់ ។

### 2.1. កិច្ចការពារទីផ្សារក្នុងស្រុក

ជនជាតិជប៉ុនមានទីផ្សារក្នុងស្រុកមួយដ៏ធំទូលាយដែលពួកគេបានការពារជានិច្ចកាល ។ ទោះក្នុងសម័យម៉ីអ៊ីយិ (1867-1912) ឬក៏ក្នុងសម័យរីកចម្រើនខ្ពស់ (1955-1973) ជប៉ុនបានកសាងវឌ្ឍនភាពរបស់ខ្លួនដោយផ្តើមចេញពីទីផ្សារក្នុងស្រុក ។ កាលណាគេមានក្តីបារម្ភចំពោះវិបត្តិសេដ្ឋកិច្ចនិងការប្រកួតប្រជែងពីបរទេស គេងាកមករកការប្រើប្រាស់ផលិតផលក្នុងស្រុកជានិច្ច ។ ដូចនេះ ការហូរទំនិញបរទេសចូលមកក្នុងទីផ្សារជប៉ុនគឺជាការលំបាកគ្រប់ពេល ។ កិច្ចការពារនិយមនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការនិយមប្រើប្រាស់ផលិតផលជាតិ ។

### 2.2. ប្រសិទ្ធភាពនៃសេដ្ឋកិច្ចព្រមព្រៀង

រដ្ឋាភិបាលជប៉ុនមានប្រពៃណីដ៏យូរមកហើយក្នុងការធ្វើអន្តរាគមន៍និងចូលរួមយ៉ាងសកម្មក្នុងការតម្រង់ទិសនិងការប្រកួតប្រជែងលើវិស័យសេដ្ឋកិច្ច ។ រដ្ឋាភិបាលជប៉ុនអនុវត្តការងារនេះដោយប្រើសំពាធពន្ធដារកំណត់មួយ ។ ការចំណាយផ្នែកសង្គមនិងយោធាបានបន្ថយបន្ថយប្រាក់ថ្លៃដើមបានយ៉ាងច្រើន ។ ភាពចំឡែករបស់ជប៉ុនស្ថិតនៅត្រង់ការព្រមព្រៀងគ្នារវាងសហគ្រាសនិង មីទី M.I.T.I

(ក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មអន្តរជាតិ) លើដំណោះស្រាយទំនាស់ ក៏ដូចជាការរៀបចំយុទ្ធសាស្ត្រសេដ្ឋកិច្ច។ មីទី បានរៀបចំសម្រួលមធ្យោបាយផ្ទើអន្តរាគមន៍របស់រដ្ឋនិងដឹកនាំការពិចារណាលើសេចក្តីសម្រេច ដែលត្រូវប្រកាន់យកសម្រាប់រយៈពេលវែងដើម្បីផលប្រយោជន៍សហគ្រាសនិងប្រទេស។ ជោគជ័យរបស់ មីទី មានជាច្រើនលើកដូចជា អាចការពារឧស្សាហកម្មដែលទើបចាប់កំណើតនៅទសវត្សរ៍ 50-60 និងការប្តូរសកម្មភាពឧស្សាហកម្មជប៉ុនឱ្យទៅជាឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ ឬឧស្សាហកម្មរូបធាតុប្រផេះនៅឆ្នាំ 1970-1971 ។ តុល្យការនៃសេដ្ឋកិច្ចព្រមព្រៀងនេះមានលក្ខណៈវិជ្ជមានយ៉ាងធំធេង។

## 2.3. ទិកនិយមសេដ្ឋកិច្ច

ទិកនិយមសេដ្ឋកិច្ចគឺជាសហវិជ្ជមានរវាងសហគ្រាសធំៗនិងសហគ្រាសតូចនិងមធ្យម PME នានា។

តាំងតែពីសម័យម៉ីអ៊ីយិមកម្លេះ ក្រុងក្លូមេរ៉ាដ៏មានឥទ្ធិពលត្រូវបានចាប់កំណើតឡើងក្រោមមូលធនគ្រួសារនៅជុំវិញធនាគារនិងក្រុមហ៊ុនពាណិជ្ជកម្មអន្តរជាតិគឺ "សៃបាត់ស៊ូ" (Zaibatsu) ដ៏ល្បីល្បាញ។ នៅក្រោយបរាជ័យឆ្នាំ 1945 ក្រុងក្លូមេរ៉ាទាំងនោះត្រូវបានរៀបចំឡើងវិញដោយផ្អែកលើមូលដ្ឋានហិរញ្ញវត្ថុច្រើនជាង។ សព្វថ្ងៃជប៉ុនមានក្រុមហ៊ុនធំៗជាច្រើនដែលលេចធ្លោលើសគេឯង ដូចជា មីតស៊ុយប៊ីស៊ី ស៊ុយមីតូម៉ូ ម៉ិតស៊ុ ធនាគារភូជិ ធនាគារសាន់វ៉ា ធនាគារដាអ៊ិជិកាំងយូរ។ ប៉ុន្តែ 90% នៃសហគ្រាសឧស្សាហកម្មដែលប្រើកូនឈ្នួលតិចជាង 300 នាក់ប្រមូលផ្តុំកម្មករបានជិត 75% គឺជាពិភពនៃ PME (Petites set Moyennes Entreprises)។ PME ទាំងនោះចំណុះឱ្យក្រុមហ៊ុនធំៗ ព្រោះខ្លួនជាផលិតករតូចតាច ហើយដើម្បីឱ្យឈរជើងបាន ត្រូវតែបង្ខំឱ្យកម្មករព្រមទទួលប្រាក់ខែទាប ស្វែងរកកម្មករស៊ីថ្លៃថោកនិងជានិច្ចកាលត្រូវផ្សារខ្លួនទៅនឹងតម្រូវការរបស់ក្រុមហ៊ុនធំៗ។ ផ្អែកលើមូលដ្ឋាននៃការរៀបចំសេដ្ឋកិច្ចដ៏ធំសម្បើម PME ត្រូវមានភាពទន់ភ្លន់និងតួនាទីជាអ្នកកាត់បន្ថយដំណើរជោរនាចនៃសេដ្ឋកិច្ច។

## 2.4. សូកូសូសាគន្លឹះនៃអានុភាពពាណិជ្ជកម្ម

តើសូកូសូសា (Sogo Shosha) ជាអ្វី ? ជា "ហាងជំនួញបញ្ចូលគ្នា" តែតាមពិតវាជា "សហគ្រាសពហុសេវា"។ សហគ្រាសជាច្រើនដែលប្រកបរបរជំនួញ ប៉ុន្តែមានសហគ្រាសចំនួន ១ ប៉ុណ្ណោះដែលជា "សូកូសូសា" ពិតប្រាកដ។

សូកូសូសាមានតួនាទីក្នុងការទិញលក់ដឹកជញ្ជូនស្តុកទុក ធានារ៉ាប់រងនិងនាំចេញនាំចូល ។ គឺជាក្រុមហ៊ុនជប៉ុនសម្រាប់បម្រើសេវាឱ្យក្រុមហ៊ុនជប៉ុនដទៃទៀត ។ មានសហគ្រាសជាច្រើនបានផ្ទុកផ្តាក់ការលក់ដូរនិងការឃោសនាផ្សព្វផ្សាយផលិតផលរបស់ខ្លួនទៅឱ្យសូកូសូសាណាមួយ ។ មុខងារទីពីរគឺជាធនាគារិក សម្រាប់ PME ដែលជាអតិថិជនអ្នកទទួលការងារបន្ត ឬជាអ្នកផ្គត់ផ្គង់ឱ្យដល់ក្រុមសហគ្រាសធំៗ ។

ដូច្នេះ អំណាចសូកូសូសាមានធំធេងណាស់ ព្រោះសូកូសូសាទាំង ៩ សម្រេចបាន 1/3 នៃផលិតផលជាតិសរុបរបស់ប្រទេសជប៉ុននិងគ្រប់គ្រងបាន 40% នៃពាណិជ្ជកម្មក្នុងស្រុក កាន់កាប់សឹងតែផ្តាច់មុខនូវការនាំចូល 70% និងធានារ៉ាប់រងបានចំនួន 45% នៃការនាំចេញរបស់ប្រទេស ។

## 2.៥. របៀបគ្រប់គ្រងតាមបែបជប៉ុន

ជនជាតិជប៉ុនបានអភិវឌ្ឍគំរូគ្រប់គ្រងសហគ្រាសមួយដោយផ្អែកលើផលិតភាពនិងការស្រុះស្រួលគ្នា ។

ជនជាតិជប៉ុនស្វាហាប់ណាស់ចំពោះការងារ ហើយដែលបានចាប់ផ្តើមតាំងតែពីពេលនៅសិក្សាមកម្ល៉េះ ។ ប្រព័ន្ធសិក្សាអប់រំរបស់ប្រទេសជប៉ុនគឺជា "ចក្រភពនៃការប្រកួតប្រជែង" ។ ការខំប្រឹងប្រែងក្នុងវិស័យអប់រំជាតិមានធំធេងណាស់ យុវជន 94% បានបញ្ចប់មធ្យមសិក្សាហើយ 37% បានចូលរៀននៅសកលវិទ្យាល័យ ។ សាលារៀនមានឋានានុក្រមយ៉ាងត្រឹមត្រូវ ហើយមានតែសិស្សឆ្នើមទេទើបអាចចូលរៀននៅសកលវិទ្យាល័យដ៏ល្បីៗបាន ។ សកលវិទ្យាល័យ "តូដាយ" នៅតូក្យូ សិស្សអាចចូលរៀនបានតាមការប្រឡងជ្រើសរើសដែលត្រូវប្រកួតប្រជែងគ្នាយ៉ាងស្វិតស្វាញបំផុត ។

ប្រព័ន្ធសិក្សាអប់រំជប៉ុនមានទិសដៅបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយសមត្ថភាព ទន់ភ្លន់ ស្ម័គ្របម្រើ ស្មោះត្រង់ និងគោរពវិន័យ ។ នៅពេលបំពេញការងារ យុវជនទាំងអស់ទទួលបានការបណ្តុះបណ្តាលបន្ថែមទៀតនៅតាមសហគ្រាស ។ ដោយមានជំនឿមោះមុតលើតម្លៃនៃសញ្ញាបត្រនេះហើយ ទើបគ្រួសារជប៉ុនហ៊ានចំណាយប្រាក់កាសយ៉ាងច្រើនដើម្បីឱ្យកូនខ្លួនបានចូលរៀនក្នុងគ្រឹះស្ថានសិក្សាល្អៗបំផុត ។ ចំណែកពួកកូនៗវិញខំប្រឹងរៀនសូត្រយ៉ាងសម្បើម (70 ម៉ោងក្នុងមួយសប្តាហ៍សម្រាប់រៀនមេរៀន រៀនគួរបន្ថែម និងធ្វើលំហាត់) ។

ផលិតភាពនៃពលករជប៉ុនមានកម្រិតខ្ពស់ណាស់ ។ រយៈពេលបំពេញការងារយូរ ទោះបីជាមានទំនោរទៅរកការកាត់បន្ថយក្តី ។ ក្នុងមួយសប្តាហ៍ ការងារជារឿយៗមានច្រើនជាង 5 ថ្ងៃហើយ ជាធម្មតាទៅហើយ គេត្រូវធ្វើការបន្ថែមម៉ោងដោយមិនទទួលប្រាក់កំរៃ ។ ការឈប់សម្រាករយៈពេលខ្លី (15 ថ្ងៃ)ប្រព្រឹត្តទៅដោយប្តូរវេនគ្នាជាច្រើនដង ។ អត្រាអវត្តមានមានកម្រិតទាបណាស់ ហើយករណី

កូដកម្មក៏កម្រកើតមានដែរ ។ នៅតាមសហគ្រាសធំៗបៀវត្សមានកម្រិតខ្ពស់គ្រាន់បើ ប៉ុន្តែតម្លៃជីវភាពក៏ខ្ពស់ដែរ ។ អត្រាខ្វះការងារធ្វើទាបបំផុត (ប្រហែល 2% នៃប្រជាជនសកម្ម) ។ ជំនួយសង្គមមានស្ដួចស្ដើង ពិសេសរបបនិវត្តជន ។

ភាពស្មោះត្រង់ វិន័យ ការមូលមតិគ្នា ការស្វែងរកការស្រុះស្រួលគ្នា ជាចំណុចសំខាន់នៃ "ការគ្រប់គ្រងតាមបែបជប៉ុន" ។

## ? សំណួរ

1. តើគំនាបសង្កត់ពីធម្មជាតិទៅលើប្រទេសជប៉ុនមានអ្វីខ្លះ ? ហេតុអ្វីបានជាជប៉ុនរងនូវបាតុភូតធម្មជាតិទាំងនោះ ?
2. ហេតុអ្វីបានជាបញ្ហាលើសចំណុះប្រជាជនអាចដោះស្រាយបាននៅប្រទេសជប៉ុន ?
3. ហេតុអ្វីបានជាប្រទេសជប៉ុនស្ថិតក្នុងភាពចំណុះប្រទេសក្រៅ ?
4. ហេតុអ្វីបានជាប្រទេសជប៉ុនអាចការពារទីផ្សារក្នុងស្រុកបាន ?
5. ចូរកំណត់ន័យនៃពាក្យ "ទ្វិកនិយមសេដ្ឋកិច្ច" និង "សូកូសូសា" ។
6. ចូរបង្ហាញពីគម្រូគ្រប់គ្រងសហគ្រាសតាមបែបជប៉ុន ។

មេរៀនទី

# 2 ជប៉ុនជណ្ដើមទីផ្សារពិភពលោក

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីការរីកចម្រើននៃសេដ្ឋកិច្ចជប៉ុន មហាអំណាចឧស្សាហកម្មនិងមហាអំណាចពាណិជ្ជកម្មក្នុងពិភពលោក ។

សេដ្ឋកិច្ចជប៉ុនទទួលបានជោគជ័យត្រចះត្រចង់ណាស់ ទោះបីវិបត្តិដែលកើតមានសព្វថ្ងៃមិនបានត្រាប្រណីក៏ដោយ ។ ការខិតខំក្រោយបរាជ័យឆ្នាំ 1945 ជប៉ុនបានបោះមួយជំហានយ៉ាងវែងមកកាន់ឋានៈលេខមួយនៅទ្វីបអាស៊ីនិងលេខពីរលើពិភពលោក សព្វថ្ងៃលេខបីបន្ទាប់ពីសហរដ្ឋអាមេរិកនិងចិន ។ ជប៉ុនបានកសាងភាពល្បីល្បាញនេះដោយផ្អែកលើមូលដ្ឋានឧស្សាហកម្ម ។ ទន្ទឹមនឹងនេះគេឃើញជប៉ុនប្រើយុទ្ធសាស្ត្រសេដ្ឋកិច្ចប្លែកៗជាច្រើនទៀត ដូចជាយុទ្ធសាស្ត្រឧស្សាហកម្ម យុទ្ធសាស្ត្រពាណិជ្ជកម្មជាដើម ។

## 1. ការរីកចម្រើនដ៏អស្ចារ្យនៃសេដ្ឋកិច្ចជប៉ុន

វឌ្ឍនភាពសេដ្ឋកិច្ចនេះនាំឱ្យមានការកោតស្ញប់ស្ញែងនិងការខ្លាចក្រែងផងដែរ ។ មកទល់ពេលនេះ គ្មានប្រទេសណាមួយធ្វើបានដូចនិងបានឆាប់រហ័ស ក្នុងការរត់ប្រណាំងផ្នែកកំណើនសេដ្ឋកិច្ចនៅឡើយទេ ។ ក្នុងរយៈពេលមួយសតវត្សផលិតកម្មឧស្សាហកម្មបានកើនឡើងមួយរយដង ។ ជប៉ុនមានប្រជាជនតិចជាង 2.4% នៃប្រជាជនពិភពលោកសម្រេចបាន 15% នៃផលទុនពិភពលោក ។

### 1.1. ឧស្សាហូបនីយកម្មចាប់ពីចុងស.វ.ទី 19

ក្រោយពេលដែលសង្គ្រាមលោកលើកទីពីរបញ្ចប់ទៅ ប្រទេសជប៉ុនដែលចាញ់សង្គ្រាមយ៉ាងអាម៉ាស់ មិនបានស្គាល់នូវវឌ្ឍនភាពអស់ពេលជិតមួយសតវត្សមកហើយ ។ ជារដ្ឋសក្តិភូមិរហូតមកដល់សតវត្សទី 19 ប្រទេសនេះបានអភិវឌ្ឍវិស័យឧស្សាហកម្មរបស់ខ្លួនយ៉ាងលឿនចាប់ពីឆ្នាំ 1868 (សម័យម៉ីអ៊ីយិ) ។ ពេលនោះ សេដ្ឋកិច្ចជប៉ុនប្រមូលផ្តុំក្នុងកណ្តាប់ដៃគ្រួសារអ្នកមានធំៗមួយចំនួនហៅថា "សៃបាត់ស៊ូ" ដែលរៀបចំតាមបែបយោធាក្រោមអន្តរាគមន៍យ៉ាងខ្លាំងក្លារបស់រដ្ឋដោយផ្អែកលើភាពសំបូរពលករស៊ីថ្លៃថោក ។

ជាមួយនិងបរាជ័យរបស់ខ្លួននៅឆ្នាំ 1945 ប្រទេសជប៉ុនត្រូវស្ថិតនៅក្រោមការកាន់កាប់របស់សហរដ្ឋអាមេរិក ហើយធ្លាក់ក្នុងភាពក្រីក្រនិងមានអតិផរណាទៀតផង ។ ជប៉ុនត្រូវព្រមទទួលយករបបគ្រប់គ្រងតាមបែបសភានិយមនិងការប្រមូលផ្តុំសេដ្ឋកិច្ច ។ ប៉ុន្តែសង្គ្រាមត្រជាក់ ជ័យជំនះរបស់ពួកកុំម្មុយនិស្តនៅប្រទេសចិន បានជំរុញឱ្យសហរដ្ឋអាមេរិកប្តូរនយោបាយមកចងសម្ព័ន្ធភាពជាមួយជប៉ុននិងជួយលើកស្ទួយសេដ្ឋកិច្ចតាមរយៈជំនួយពិសេស ។

## 1.2. កំណើនសេដ្ឋកិច្ច (1950-1973)

ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1950មក សេដ្ឋកិច្ចជប៉ុនបានឈានចូលក្នុងសម័យកាល "កំណើនខ្ពស់មួយ" ដ៏យូរដែលកត់សម្គាល់ដោយនវកម្មដែលជំរុញឱ្យមានការរីកចម្រើន មានឧស្សាហកម្មដែកថែបនិងសំណង់នាវា ។ កំណើនឧស្សាហកម្មបានរីកសាយទៅលើផ្នែកគ្រឿងបរិក្ខារនិងគ្រឿងឧបភោគបរិភោគជាប់លាប់ មានរថយន្ត ដែកថែប គីមីប្រេងកាត គ្រឿងអេឡិចត្រូនិកសម្រាប់មហាជន ។ កំណើននេះនាំឱ្យមានការរៀបចំរចនាសម្ព័ន្ធឧស្សាហកម្មឡើងវិញដោយតម្រង់ទៅរកការពង្រីកសហគ្រាសនិងសេរីភាវូបនីយកម្មនៃបណ្តូរដែលនាំមកនូវការលូតលាស់ផ្នែកការនាំចេញ ។

អត្រាកំណើនប្រចាំឆ្នាំក្នុងអំឡុងពេលនោះមានជាមធ្យម 10% ជួនកាល 15% ។ ពីឆ្នាំ 1955 ដល់ 1961 កើតមាន "កំណើនទូទៅមួយ" ដែលក្នុងនោះការងារថ្មីចំនួន 3 លានត្រូវបានបង្កើតឡើង ។ ភាពឥតការងារនិងការងារមិនពេញលេញលែងកើតមានទៀតហើយ ភាពខុសគ្នានៃប្រាក់បៀវត្សន៍ត្រូវបានកាត់បន្ថយ កម្រិតជីវភាពត្រូវបានលើកកម្ពស់ ។ ពីឆ្នាំ 1961 ដល់ 1965 សេដ្ឋកិច្ចហាក់ដូចជានៅទ្រឹង ។ ប៉ុន្តែ តម្រូវការក្នុងស្រុកសម្រាប់គ្រួសារជប៉ុននិងវិនិយោគសាធារណៈបានធ្វើឱ្យសេដ្ឋកិច្ចមានសន្ទុះទៅមុខទៀត ។

ជារឿយៗជនជាតិជប៉ុនយល់ច្បាស់ណាស់ថា យុទ្ធសាស្ត្រឧស្សាហកម្មដែលផ្អែកលើឧស្សាហកម្មមូលដ្ឋាន ជាមួយនឹងការនាំចូលរូបធាតុដើមនិងថាមពលមិនមានសារៈសំខាន់អ្វីឡើយ ។ វិបត្តិប្រេងកាតបានបណ្តាលឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ ។

## 1.3. យុទ្ធសាស្ត្រថ្មីនិងការរៀបចំឡើងវិញក្រោយឆ្នាំ 1973

ប្រទេសជប៉ុនត្រូវតែផ្សាំសេដ្ឋកិច្ចខ្លួនទៅនឹងវិបត្តិជាច្រើនដែលនាំឱ្យមានការលំបាក ហើយជួនកាលនាំឱ្យមានការចុះថយសេដ្ឋកិច្ចទៀតផង ដូចជាវិបត្តិប្រេងកាតឆ្នាំ 1973 និងឆ្នាំ 1979 ការបង្កើនតម្លៃប្រាក់យ៉េននៅចន្លោះឆ្នាំ 1985-1988 (បណ្តាលឱ្យទំនិញនាំចេញឡើងថ្លៃ) វិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ 1989-1990 និងថ្មីៗកន្លងមកនេះ (ឆ្នាំ 2009) ជាដើម ។

នៅក្នុងគ្រប់ករណីទាំងអស់ ប្រទេសជប៉ុនបានទប់ទល់និងវិបត្តិដោយរៀបចំឡើងវិញនូវឧបករណ៍ផលិតកម្ម ។ ម្ចាស់សហគ្រាសនិងរដ្ឋ (ពិសេសក្រសួងឧស្សាហកម្មនិងពាណិជ្ជកម្មដ៏មានអំណាច MITI) បានពង្រឹងសេដ្ឋកិច្ចដោយផ្អែកលើការបង្កើនការនាំចេញលើការតាំងទីផលិតកម្មមួយចំនួននៅក្រៅប្រទេសនិងលើការអភិវឌ្ឍទីផ្សារក្នុងស្រុក ។ ការនាំចេញកាន់តែច្រើនអាចឱ្យគេនាំចូលផលិតផលចាំបាច់បានកាន់តែច្រើនដែរ ។

យុទ្ធសាស្ត្រនេះរៀបចំឡើងលើចំណុចសំខាន់បី

- ចំណុចទី 1 : គេបានបំបែករចនាសម្ព័ន្ធផលិតកម្មដោយផ្តោតការយកចិត្តទុកដាក់ថ្មីទៅលើ PME ដែលអាចផ្សុំខ្លួននិងប្តូរសកម្មភាពបានឆាប់រហ័ស ។ ទន្ទឹមនឹងនេះ គេក៏ពង្រីកផ្នែកសេវាផងដែរ ។
- ចំណុចទី 2 : គេធ្វើអន្តរជាតូបនីយកម្មសេដ្ឋកិច្ចដ៏ធំទូលាយបំផុតមួយ តាមរយៈការបង្កើនវិនិយោគនៅក្រៅប្រទេស ពិសេសលើផ្នែករថយន្ត យន្តូបករណ៍ ឧបករណ៍អគ្គិសនីនិងឧបករណ៍អេឡិចត្រូនិច ។
- ចំណុចទី 3 : គេបោះបង់ផ្នែកដែលទទួលបានការបញ្ជាទិញតិច ឬផ្នែកដែលប្រើប្រាស់ថាមពលខ្លាំង ផ្នែកដែលផ្តល់តម្លៃបន្ថែមទាបហើយដែលប្រទេសដទៃទៀតអាចផលិតបានដោយតម្លៃទាប ។ ផ្ទុយទៅវិញគេអភិវឌ្ឍផ្នែក "ឧស្សាហកម្មបញ្ញា" ដែលទាមទារក្រុមពលករជំនាញ ការស្រាវជ្រាវខ្លាំងក្លា (ស្រាវជ្រាវ-អភិវឌ្ឍន៍) ផ្នែកអេឡិចត្រូនិចមនុស្សយន្ត... ។

នៅចន្លោះឆ្នាំ 1970 និង 1983 ផលិតកម្មម៉ាស៊ីនអគ្គិសនីនិងអេឡិចត្រូនិចកើនឡើង 16% ក្នុងមួយឆ្នាំនៅប្រទេសជប៉ុនទល់នឹង 7% នៅសហរដ្ឋអាមេរិក ។ ពិព័រណ៍អន្តរជាតិរបស់សកលវិទ្យាល័យស៊ូគូបា កាលពីឆ្នាំ 1985 បានបង្ហាញសមត្ថភាពផ្នែកនវកម្មនៃប្រទេសជប៉ុន ដែលពីពេលមុនលោកខាងលិចចាត់ទុកជាជនជាតិជប៉ុនគ្រាន់តែជាអ្នកចម្លងបច្ចេកវិទ្យាតាមគេ គ្មានអ្វីដែលគួរឱ្យចំឡែកនោះឡើយ ។

យុទ្ធសាស្ត្រនេះភ្ជាប់ទៅនឹងសារៈសំខាន់នៃផលិតភាពនិងការរៀបចំបែងចែកដ៏ល្អប្រសើរមួយដែលអាចឱ្យជប៉ុនដណ្តើមទីផ្សារខាងក្រៅ ធានារ៉ាប់រងបាននូវជញ្ជីងពាណិជ្ជកម្មមួយដែលចំណេញយ៉ាងច្រើន ។ ផលចំណេញទាំងនេះត្រួបផ្សំទៅនឹងអត្រាសន្សំសំចៃខ្ពស់របស់គ្រួសារជប៉ុន ជាហេតុនាំឱ្យប្រទេសមហាអំណាចមួយនេះមានប្រៀបខ្លាំងខាងហិរញ្ញវត្ថុហើយក្លាយជាម្ចាស់បំណុលធំលេខមួយក្នុងលោក ។

ប្រៀបខ្លាំងនេះផ្ទុយពីអ្វីដែលជប៉ុនមាននៅលើឆាកនយោបាយអន្តរជាតិ "ធំហួសខ្នាតផ្នែកសេដ្ឋកិច្ច តែតូចតឿផ្នែកនយោបាយ" ។ ជប៉ុនជាមហាអំណាចសេដ្ឋកិច្ចលេខបីក្នុងពិភពលោក បន្ទាប់ពីសហរដ្ឋអាមេរិកនិងសាធារណរដ្ឋចិនប្រជាមានិតនឹងក្លាយទៅជាអ្នកទទួលបន្ទុកខុសត្រូវជាសកលនៅសតវត្សទី 21 នេះ ។

## 2. មហាអំណាចឧស្សាហកម្ម

ជោគជ័យសេដ្ឋកិច្ចមិនធម្មតារបស់ជប៉ុនបានបង្ហាញច្បាស់តាមរយៈបរិមាណនិងគុណភាពផលិតកម្ម និងក៏តាមការផ្ញើវិនិយោគផងដែរ ។ តែក្នុងអំឡុងប៉ុន្មានទសវត្សរ៍ប៉ុណ្ណោះ ជប៉ុនបានបង្កើតឯតទគ្គកម្មឧស្សាហកម្មជាច្រើន ។

### 2.1. ទីតាំងប្រទេសជប៉ុនក្នុងពិភពលោក

បច្ចុប្បន្ន ប្រទេសជប៉ុនជាប្រទេសឧស្សាហកម្មលេខពីរក្នុងពិភពលោក បន្ទាប់ពីសហរដ្ឋអាមេរិក ។ ជប៉ុនបានជាប់ចំណាត់ថ្នាក់លេខមួយខាងសំណង់រថយន្ត នាវា ទូរទស្សន៍ ម៉ាស៊ីនថតរូបនិងមនុស្សយន្ត ។ ចាប់ពីឆ្នាំ 1994 មក សំណង់រថយន្តបានទទួលចំណាត់ថ្នាក់លេខពីរ (សហរដ្ឋអាមេរិកលេខមួយ) ។ ផ្នែកដែកថែប សំពត់សំយោគនិងប៉ូលីម៉ែជាប់លេខពីរ ។ ផ្នែកអាលុយមីញ៉ូម ចំរាញ់ប្រេងកាត អគ្គិសនី អគ្គិសនីនុយក្លេអ៊ែ ជាប់លេខបី ។ ជប៉ុនបានខិតខំប្រឹងប្រែងជាងពេលណាៗទាំងអស់ លើផលិតកម្មគ្រឿងផ្សំអេឡិចត្រូនិចនិងបានបំពេញភាពយឺតយ៉ាវរបស់ខ្លួនលើវិស័យកុំព្យូទ័រ ។ វឌ្ឍនភាពផ្នែកបច្ចេកវិទ្យារបស់ជប៉ុនបានធ្វើឱ្យប្រជាជាតិឧស្សាហកម្មចាស់ (អឺរ៉ុបខាងលិច) និងថ្មី (សហរដ្ឋអាមេរិក) ធ្លាក់ក្នុងក្តីបារម្ភ ។




*ជប៉ុនក្នុងពិភពលោក*

## 2.2. ឧស្សាហកម្មមួយគ្មានធនធានធម្មជាតិ

ជប៉ុនជាប្រទេសតែមួយគត់ដែលបានកសាងឧស្សាហកម្មដ៏ធំមួយនៅលើទឹកដីរបស់ខ្លួន ដែលមិនឃើញមានធនធានចាំបាច់ជារូបធាតុដើមនិងថាមពលអ្វីឡើយ ។ ស្ថានភាពនេះតម្រូវឱ្យជប៉ុនបើកចំហសេដ្ឋកិច្ចយ៉ាងទូលាយទៅរកប្រទេសក្រៅពោលគឺ ជប៉ុនត្រូវស្ថិតក្នុងភាពចំណុះគេជានិច្ចកាល ។ ប្រទេសជប៉ុនមានរ៉ែខ្លះៗដែរ ដូចជាដែក ទង់ដែង សំណ ឬស្ពាន់ធ័រ ប៉ុន្តែកំណប់រ៉ែទាំងនោះមានចំណុះតិច ។ ភាពសំបូរនៃទីតានមិនអាចទូទាត់ឱ្យកង្វះខាតរ៉ែទាំងស្រុងបានឡើយ ។ ជប៉ុនត្រូវទិញចូលពីបរទេស (កាន់តែច្រើនឡើងៗពីអូស្ត្រាលី) នូវបុកស៊ីត 100% រ៉ែដែក 92% ម៉ង់កាណែស 93% ដែលចាំបាច់សម្រាប់ឧស្សាហកម្មខ្លួន ។

ឧស្សាហកម្មជប៉ុនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរខ្លាំងជាពិសេសក្នុងវិស័យថាមពល ។ ធ្យូងថ្មមាននៅកោះគ្យូស្យ៊ូនិងហុកកៃដូតែពិបាកជីកយកហើយថ្លៃផង ដែលនាំឱ្យផលិតកម្មចុះថយ( 50 លានតោននៅឆ្នាំ 1960 8 លានតោនឆ្នាំ 1991 ) ។ នៅក្នុងប្រទេសមួយដែលមានភ្នំច្រើននិងសំបូរភ្លៀងធ្វើឱ្យផលិតកម្មវារីអគ្គិសនីមានសារៈសំខាន់ខ្លាំងដែលតាងបានជិត 12% នៃផលិតកម្មអគ្គិសនី ។ ជប៉ុនត្រូវបង្ខំចិត្តទិញអីដ្រូកាបួក្នុងបរិមាណដ៏ច្រើនពីបរទេសដើម្បីធ្វើដំណើរការឧស្សាហកម្ម (ជាង 200 លានតោនដែល 60% មកពីមជ្ឈិមបូព៌ា) ។ ជប៉ុនជាអ្នកនាំចូលលេខពីរបន្ទាប់ពីសហរដ្ឋអាមេរិក ។

ដោយសារវិបត្តិប្រេងកាតកើតមានជាបន្តបន្ទាប់ ជប៉ុនបានខិតខំយ៉ាងខ្លាំងក្លាក្នុងការបន្ថយភាពចំណុះគេខាងថាមពល ដោយអភិវឌ្ឍវិស័យអគ្គិសនីនុយក្លេអ៊ែរ ។ នៅឆ្នាំ 1991 ប្រទេសនេះមានរោងចក្រនុយក្លេអ៊ែរចំនួន 32 ដែលកំពុងផលិតអគ្គិសនីផ្គត់ផ្គង់បាន 26% នៃអគ្គិសនីសរុប ជាប់លេខបួនបន្ទាប់ពីសហរដ្ឋអាមេរិក បារាំង និងរុស្ស៊ី ។ នៅឆ្នាំ 2003 ជប៉ុនបានទទួលចំណាត់ថ្នាក់លេខបីបន្ទាប់ពីសហរដ្ឋអាមេរិកនិងបារាំងជាមួយផលិតកម្ម 230.100 លាន kWh ។

សេរីភាពនិងសុវត្ថិភាពនៃការផ្គត់ផ្គង់ថាមពលគឺជា បញ្ហាស្លាប់រស់របស់ជប៉ុន ។ ជាក់ស្តែងជប៉ុននៅតែបន្តអភិវឌ្ឍវិស័យនេះ ក្នុងពេលដែលប្រទេសដទៃបានកាត់បន្ថយល្បឿន ។ ទោះបីកើតមានមហន្តរាយនៅឈែណូប៊ីល (Tchernobyl) កាលពីឆ្នាំ 1986 ក៏ដោយ ក៏ជប៉ុននៅតែផ្សព្វផ្សាយផែនការមួយសំដៅបង្កើនផលិតកម្មអគ្គិសនីនុយក្លេអ៊ែរឱ្យបានប្រហែល 60% នៃថាមពលអគ្គិសនីសរុបរបស់ប្រទេស ។

## 2.3. ឧស្សាហកម្មមូលដ្ឋានដ៏រឹងមាំ

លោហកម្មជប៉ុនទទួលបានការរីកលូតលាស់មួយយ៉ាងឆាប់រហ័ស ។ ឧស្សាហកម្មដែកថែបតាំងនៅតាមតំបន់ឆ្នេរ ឬលើ "ប៉ុលឌែ" ដែលបង្កការងាយស្រួលក្នុងការផ្គត់ផ្គង់រ៉ែដែកនិងធ្យូងថ្ម និងស្រួលនាំដែកថែបចេញទៅលក់ក្រៅប្រទេស ។ ផលិតកម្មដែកថែបបានថយចុះពី 22 លានតោន (ឆ្នាំ 1960)

មក 112 លានតោន (1979) ហើយស្ថិតនៅទ្រឹងជុំវិញ 96 លានតោន ដោយសាររងការប្រកួតប្រជែងពីបណ្តាប្រទេសកំពុងអភិវឌ្ឍមួយចំនួន ។ នៅឆ្នាំ 1990 ជាមួយផលិតផលជាង 110 លានតោន ជប៉ុនជាប់លេខមួយឈ្នះប្រទេសរុស្ស៊ីនិងសហរដ្ឋអាមេរិក ។ នៅឆ្នាំ 2005 ជប៉ុនជាប់លេខពីរ (113 លានតោន) បន្ទាប់ពីចិននិងនៅពីមុខសហរដ្ឋអាមេរិក ។ ជប៉ុននាំរ៉ែដែកចូលទាំងស្រុងពីប្រទេសអូស្ត្រាលី ប្រេស៊ីល ចិន... ។ ឧស្សាហកម្មដែកថែបមានលក្ខណៈប្រមូលផ្តុំកម្រិតខ្ពស់និងទំនើបបំផុត (ស្វ័យប្រវត្តិកម្មមួយពេញលេញ) ដូចគ្នានិងលោហកម្មទីតាន ឬទង់ដែងដែរ ។

ឧស្សាហកម្មគីមីជប៉ុនក៏មានសន្ទុះខ្លាំងក្លាណាស់ដែរ គីមីប្រេងកាតនិងគីមីកាបូនបង្កើតបានជាកុំប៊ីណា (ពហុដ្ឋានឧស្សាហកម្មធំៗ) ជាមួយឧស្សាហកម្មដែកនៅតាមឆ្នេរ ។ សមត្ថភាពចំរាញ់ប្រេងកាតបាន 210 លានតោនជាប់ចំណាត់ថ្នាក់លេខបី ។ គីមីប្រេងកាតផ្តល់ផលិតសំយោគ ជ័រ ប្លាស្ទិចនិងកៅស៊ូសំយោគបានលេខពីរក្នុងលោក ។ ផ្តើមចេញពីគីមីប្រេងកាតជប៉ុនមានគីមីស្រួចស្រាល់ ឬផលិតកម្មគ្រឿងសំអាងកាយទៀត ។ ផលិតកម្មរូបធាតុប្លាស្ទិចជាប់លេខពីរដែរ បន្ទាប់ពីសហរដ្ឋអាមេរិកនិងស្ថិតនៅពីមុខអាឡឺម៉ង់និងបារាំង ។

សំណង់នាវាបានក្លាយជាឯកទេសកម្មមួយរបស់ជប៉ុន ។ ការដ្ឋានសំណង់ណាងាសាគី កូបេ យ៉ូកូហាម៉ា ធានារ៉ាប់រងបាន 50% នៃតម្រូវការពិភពលោក (នាវាដឹកប្រេង នាវាដឹករ៉ែ នាវាផ្ទុកកុងតឺន័រ) ។ សំណង់នាវាបានធ្លាក់ចុះដោយសារការប្រកួតប្រជែងពីកូរ៉េខាងត្បូង ។



*ដីរៀនឧស្សាហកម្មនៅអូសាកា*

ឧស្សាហកម្មរថយន្តមានការលូតលាស់យ៉ាងចំឡែកនិងមានដំណើរប្រព្រឹត្តទៅយ៉ាងប្រសើរ ។ ការរីកចម្រើនបានចាប់ផ្តើមឡើងជាមួយទោចក្រយានយន្ត (ហុងដា ស៊ុយស៊ុយគី កាវ៉ាសាគី) ។ ចាប់ពីឆ្នាំ 1950 មក ផលិតកម្មរថយន្តកើនឡើង 200 ដងតាងបាន 10% នៃផលិតកម្មឧស្សាហកម្មជប៉ុន 20% នៃលំនាំចេញ 1/4 នៃទីផ្សារពិភពលោក ។ ពីឆ្នាំ 1965 ដល់ 1990 នៅពេលដែលផ្នែកផ្សេងៗនៃឧស្សាហកម្មជប៉ុនស្រុតចុះ ដូចជាវាយនភ័ណ្ឌដែលជាចលករនៃសន្ទុះឧស្សាហកម្ម ប្រទេសជប៉ុនបានក្លាយទៅជាស្ថាបនិករថយន្តដ៏ធំមួយក្នុងលោក ។ យុទ្ធសាស្ត្រជប៉ុនក្នុងផ្នែកនេះបង្កើតបានជាគម្រូមួយ ។ ជាដំបូងយកតាមលំនាំផតនិយមដែលអាចឱ្យគេអាចធានារ៉ាប់រងបាននូវការដណ្តើមទីផ្សារក្នុងនិងក្រៅប្រទេស ដោយការអនុវត្តគោលការណ៍ថ្មីរបស់ក្រុមហ៊ុនតូយ៉ូតាដ៏ចម្បងរបស់ជប៉ុន ការងារជាក្រុម វង់គុណភាព គ្មានគុណវិបត្តិ និង "ទាន់ពេលវេលា" សំដៅកាត់បន្ថយ ឬលុបបំបាត់ស្តុក ។

បណ្ដាឆ្នាំ 1990 គឺជាពេលវេលាដែលត្រូវធ្វើការត្រួតពិនិត្យឡើងវិញ ។ ក្នុងទសវត្សរ៍ឆ្នាំ 1980 ការតាំងទីរោងចក្រនៅក្រៅប្រទេសក៏ដូចជាការចូលហ៊ុនគ្នាជាមួយសហគ្រាសបរទេសធំៗអាចបង្ហាញបានថា បច្ចុប្បន្នប្រទេសជប៉ុនស្ថាបនាវថយន្តនៅខាងក្រៅបានច្រើនជាងជប៉ុននាំចេញ ។

## 2.4. ឧស្សាហកម្មបញ្ញា

ក្រោមសម្ពាធនៃវិបត្តិនិងចំពោះមុខការប្រកួតប្រជែងពីអន្តរជាតិ ឧស្សាហកម្មបានសម្របខ្លួនដោយងាកទៅរកផលិតកម្មដែលទាមទារបច្ចេកទេសជឿនលឿន ។ អាស្រ័យហេតុដូចនេះហើយបានជាក្រោយឆ្នាំ 1973 "ឧស្សាហកម្មធុនធ្ងន់និងឧស្សាហកម្មគីមី" ត្រូវជំនួសដោយ "ឧស្សាហកម្មបញ្ញា" ដែលតម្រូវឱ្យមានការរៀបចំឡើងវិញយ៉ាងស៊ីជម្រៅ ។ ក្នុងការបង្កើនសមត្ថភាពផលិតកម្ម ប្រសិទ្ធភាពពាណិជ្ជកម្មនៅលើទីផ្សារក្នុងស្រុកនិងក្រៅប្រទេស និងរបកគំហើញផលិតផលថ្មីៗ គេបានប្រាក់ចំណេញទៅលើ "ការស្រាវជ្រាវ-អភិវឌ្ឍន៍" មានដល់ទៅ 20% នៃទុនវិនិយោគសរុប ។

តារាងផលិតផលឧស្សាហកម្មជប៉ុនកាន់តែសំបូរបែប ។ ផ្នែកអេឡិចត្រូនិច (ស៊ីមីកុងឌុចទ័រ) ទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ។ ក្នុងចំណោមផលិតករស៊ីមីកុងឌុចទ័រសំខាន់ៗទាំងប្រាំ មានបីជារបស់ជប៉ុន ណិច (NEC) ហ៊ីតាស៊ី (Hitachi) តូស៊ីបា (Toshiba) ។ ឧត្ដមភាពរបស់សហរដ្ឋអាមេរិកលើផ្នែកព័ត៌មានវិទ្យានៅតែជាការពិត ប៉ុន្តែជនជាតិជប៉ុនដណ្ដើមបានទីផ្សារក្នុងស្រុកជាស្រេច ហើយការងារផលិត កុំព្យូទ័រ "ជំនាន់ទីប្រាំ" សំដៅទម្លុះទីផ្សារអាមេរិក ។ ឧស្សាហកម្មមនុស្សយន្តរីកចម្រើនយ៉ាងខ្លាំងក្លា ។ ប្រទេសជប៉ុនជាផលិតករនិងអ្នកប្រើប្រាស់មនុស្សយន្តធំជាងគេបំផុតក្នុងលោក ។ សហគ្រាសសំខាន់បំផុតគឺ ភូជិតស៊ូជានូ (Fujitsu Fanu) គ្រប់គ្រងបាន 50% នៃទីផ្សារពិភពលោក ផ្នែកយន្តូបករណ៍ត្រួតពិនិត្យដោយខួរបញ្ញា ។ ប្រទេសជប៉ុនជាប់លេខពីរខាងសម្ភារៈថ្មី ពិសេសសេរ៉ាមិចឧស្សាហកម្ម ជីវៈសេរ៉ាមិចក៏ដូចជាក្នុងផ្នែកជីវៈតិចណូឡូស៊ីដែរ ។ ចំពោះវិស័យឧស្សាហកម្មសំណង់ប្រទេសជប៉ុនក៏ទទួលបានជោគជ័យសម្បើមណាស់ដែរ ដូចជាសំណង់ប៉ុលឡែ ជីវឿន ស្ពាននិងផ្លូវរូងក្រោមសមុទ្រភ្ជាប់កោះនានាជាដើម ។

# 3. មហាអំណាចជប៉ុនក្នុងពាណិជ្ជកម្មពិភពលោក

## 3.1. ការនាំចេញជាចលករនៃការលូតលាស់

ពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុនមានតិចតួចស្ដួចស្ដើងតាំងពីយូរណាស់មកហើយ ។ ចាប់ពីដើមទសវត្សរ៍ឆ្នាំ 1970 ផលិតកម្មសំដៅជាសំខាន់ឆ្ពោះទៅទីផ្សារក្នុងស្រុក ។ ជប៉ុននាំចេញស្ទើរមិនដល់ 10% នៃផលិតផលរបស់ខ្លួនផង ។ តើនៅពេលណាទើបពាណិជ្ជកម្មក្លាយទៅជាចលករនៃការរីកលូត

លាស់របស់ជាតិ ? ពីដំបូងពាណិជ្ជកម្មនេះមានការខាតបង់ច្រើន ព្រោះថាជប៉ុនត្រូវនាំចូលផលិតផលអាហារ ថាមពល រូបធាតុដើមនិងគ្រឿងបរិក្ខាជាច្រើននៅពេលដែលខ្លួនអាចនាំចេញតែបន្តិចបន្តួច (វាយនភណ្ឌគ្រឿងប្រើប្រាស់មិនសូវមានគុណភាព) ។

ស្ថានភាពបានផ្លាស់ប្តូរនិងប្រែប្រួលទាំងស្រុង ។ ក្នុងការនាំចូលគេឃើញមានតែចំណីអាហារនិងថាមពល ចំណែកផលិតផលឧស្សាហកម្មឃើញមានការនាំចូលតិចតួចទោះបីជាមានទំនោរក្នុងការនាំចូលកើនឡើងក៏ដោយ ។ ការនាំចេញមានច្រើនសម្បើម (98%) ដែលសុទ្ធសឹងតែជាផលិតផលមានតម្លៃបន្ថែមខ្ពស់ ក្នុងនោះមានតាំងពីរថយន្តរហូតដល់ម៉ាស៊ីនថតចម្លងនិងប្រដាប់ផ្សាយសំឡេង (ម៉ាញ៉េតូស្កូប) គ្រឿងសម្ភារៈបរិក្ខារដូចជាគ្រឿងផ្គុំអេឡិចត្រូនិច សីមីកុងទ័រ គ្រឿងផ្គុំខ្នាតតូច (Microprocesseurs) នៃកុំព្យូទ័រនិងមនុស្សយន្ត (Robots) ។

ជប៉ុនជាមហាអំណាចពាណិជ្ជកម្មលេខបីក្នុងពិភពលោក បន្ទាប់ពីសហរដ្ឋអាមេរិកនិងអាល្លឺម៉ង់ ជាមួយនិងអាវុធពាណិជ្ជកម្មដ៏ខ្លាំងសម្បើមមួយ គឺសូកូសូសា ។ ការបានចំណេញច្រើនផ្នែកពាណិជ្ជកម្មនាំឱ្យប្រទេសដៃគូព្រួយបារម្ភនិងខឹងសំបារពិសេសសហរដ្ឋអាមេរិក ។

## 3.2. ការបង្កើតផ្លូវពាណិជ្ជកម្មអន្តរជាតិ

ជាបឋមការដោះដូរក្រៅប្រទេសតម្រង់ឆ្ពោះទៅសហរដ្ឋអាមេរិក បន្ទាប់មកទៅអាស៊ី (ពិសេសប្រទេសឧស្សាហកម្មថ្មីនៃអាស៊ី) និងទីបីទៅសហភាពអឺរ៉ុប ។ ទីផ្សារដ៏ធំធេងរបស់ចិនក៏បានបើកទ្វារហើយដែរ រីឯប្រទេសជប៉ុនក៏ជាអ្នកផ្គត់ផ្គង់ដ៏ធំបំផុត ។ ចំពោះការនាំចូលវិញ មជ្ឈិមបូព៌ា គឺជាទីផ្សារសំខាន់បំផុតមួយខាងការផ្តល់អ៊ីដ្រូកាបួឱ្យដល់ប្រទេសជប៉ុន ។

ពាណិជ្ជកម្មអន្តរជាតិរបស់ជប៉ុនដែលជួនកាលតាងបានតែ 11% នៃផលិតផលជាតិសរុប តែងពាក់ព័ន្ធទៅនិងភាពប្រកួតប្រជែងខ្លាំងគ្នាពីផលិតផលក្នុងស្រុក ។ ប្រទេសជប៉ុនផ្តល់ផលិតផលប្រកបដោយគុណភាពនិងប្រសិទ្ធភាពពាណិជ្ជកម្មខ្ពស់ ព្រោះទទួលបានការទាក់ទាញខ្លាំង ទោះបីតម្លៃទំនិញមានការកើនឡើងក្តី ។

នៅលើទឹកដីខ្លួនផ្ទាល់ជប៉ុនរងការប្រកួតប្រជែងដ៏ខ្សោយមួយ ។ នេះមិនមែនជាការងាយស្រួលទេដែលនាំចូលទំនិញទៅលក់នៅប្រទេសជប៉ុននោះ ព្រោះអ្នកនាំចូលត្រូវជួបការលំបាកជាច្រើនដូចជា របាំងភាសា ការនិយមប្រើប្រាស់តែផលិតផលជាតិខ្លួន ឧបសគ្គបង្កឡើងដោយច្បាប់ទម្លាប់របស់ជប៉ុន ការចែកចាយទំនិញប្រព្រឹត្តទៅតាមរយៈបណ្តាញឈ្មួញកណ្តាលដ៏ច្រើនជាដើម ។

## សំណួរ

1. តើចំណុចខ្លាំងនៃឧស្សាហកម្មជប៉ុនចន្លោះឆ្នាំ 1950-1973 មានអ្វីខ្លះ ?
2. តើជប៉ុនដោះស្រាយវិបត្តិសេដ្ឋកិច្ចយ៉ាងដូចម្ដេច ?
3. ក្នុងការដោះស្រាយវិបត្តិសេដ្ឋកិច្ចជប៉ុនបានប្រើយុទ្ធសាស្ត្រអ្វីខ្លះ ?
4. តើឧស្សាហកម្មមូលដ្ឋានរបស់ជប៉ុនមានអ្វីខ្លះ ?
5. តើឧស្សាហកម្មបញ្ញារបស់ជប៉ុនធ្វើសកម្មភាពលើផ្នែកអ្វីខ្លះ ?
6. តើឧស្សាហកម្មរថយន្តជប៉ុនទទួលបានការរីកចម្រើនដូចម្ដេចខ្លះ ? តើយុទ្ធសាស្ត្រឧស្សាហកម្មជប៉ុនមានយ៉ាងដូចម្ដេចខ្លះ ?
7. ហេតុអ្វីបានជាពាណិជ្ជកម្មអន្តរជាតិរបស់ជប៉ុនទទួលបានជោគជ័យ ?
8. ហេតុអ្វីបានជាការហូរចូលទំនិញបរទេសចូលមកទីផ្សារក្នុងស្រុករបស់ជប៉ុនជួបការលំបាក ?

## សំណួរបញ្ចប់ជំពូកទី៧

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់**

1. កោះធំជាងគេរបស់ប្រទេសជប៉ុនគឺ

☐ក. កោះហុកកៃដូ ☐ខ. កោះហុងស៊ូ ☐គ. កោះស៊ីកុគូ ☐ឃ. កោះគ្យូស៊ូ ។

2. ជប៉ុនព្យាយាមកាត់បន្ថយភាពចំណុះគេផ្នែកថាមពលដោយផ្អែកលើការអភិវឌ្ឍផលិតកម្ម

☐ក. ថាមពលព្រះអាទិត្យ ☐ខ. ថាមពលវារីអគ្គិសនី

☐គ. ថាមពលខ្យល់ ☐ឃ. ថាមពលអគ្គិសនីនុយក្លេអ៊ែរ ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. នៅប្រទេសជប៉ុនតំបន់ដែលមានប្រជាជនរស់នៅកុះករជាងទីណាៗទាំងអស់គឺ.................. នៃភាគខាងត្បូងកោះហុងដូ ។
2. របៀបគ្រប់គ្រងសហគ្រាសតាមបែបជប៉ុនផ្អែកលើ.......... និង................................ ។

**IV. សំណួរត្រិះរិះ**

1. ចូរកំណត់ន័យនៃពាក្យ "ទ្វិកនិយមសេដ្ឋកិច្ច" និង "សូកូសូសា" ។
2. ចូរនិយាយអំពីការសិក្សាអប់រំនៅប្រទេសជប៉ុន ។
3. តើយុទ្ធសាស្ត្រសេដ្ឋកិច្ចជប៉ុនផ្អែកលើចំណុចសំខាន់ៗអ្វីខ្លះ ? ចូររៀបរាប់ ។
4. ក្នុងវិស័យសេដ្ឋកិច្ច តើប្រទេសជប៉ុនជាប់ចំណាត់ថ្នាក់ល្អៗលើផ្នែកអ្វីខ្លះ ? ចូររៀបរាប់ ។
5. តើឧស្សាហកម្មបញ្ញារបស់ជប៉ុនធ្វើសកម្មភាពលើផ្នែកអ្វីខ្លះ ?
6. ហេតុអ្វីបានជាប្រទេសមហាអំណាចងាកមករកឧស្សាហកម្មបញ្ញាទៅវិញ ? ចូរពន្យល់ ។

# ជំពូកទី 8 សហភាពអឺរ៉ុប (EU)



សហភាពអឺរ៉ុបមានកំណើតកំណើតពី "សហគមន៍អឺរ៉ុបនៃធ្យូងថ្មនិងដែកថែប" (CECA) ដែលមានប្រទេសចំនួន 6 ធ្លាប់ជាសត្រូវនិងគ្នាជាសមាជិក គឺប្រទេសបារាំង អាល្លឺម៉ង់ អ៊ីតាលី បែលហ្ស៊ិក លុចសំបួ និងហូឡង់ ។ សហភាពនេះបានរីកចម្រើនធំធាត់ជាលំដាប់ ក្លាយជាមហាអំណាចសេដ្ឋកិច្ច ដោយឈរលើវឌ្ឍនភាពរបស់ប្រទេសសមាជិកនីមួយៗ ដែលសម្រេចបានពីមុនៗមក ។ ភូមិសាស្ត្រដីចម្លែកនៃផ្សាររួមនេះអាស្រ័យទៅនឹងថាមពលទឹកដីដែលនាំឆ្ពោះទៅរកសមាហរណកម្មសេដ្ឋកិច្ចនៃប្រទេសសមាជិកទាំងនោះ ។ សមិទ្ធផលរបស់សហភាពអឺរ៉ុបបានបង្ហាញពីឆន្ទៈធ្វើឱ្យ "ពិភពដ៏ចំណាស់" មួយនេះ ស្ទុះទៅមុខនិងកសាងអនាគតថ្មី ។

តើ "សហភាពអឺរ៉ុប" ជាអ្វី ? គឺជាសមាគមសេដ្ឋកិច្ចនិងនយោបាយដ៏ធំសម្បើមមួយ ដែលមានរដ្ឋនៅអឺរ៉ុបទាំងអស់ចំនួន 27 ជាសមាជិក ដោយឈរលើគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។

តទៅនេះ យើងនឹងសិក្សាពីការរៀបចំសហភាពអឺរ៉ុប អានុភាពសេដ្ឋកិច្ច និងលំហសេដ្ឋកិច្ច ។

មេរៀនទី

# 1 តំបន់រៀបចំតាមលំដាប់និងតំបន់កំពុងកសាង

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីតំបន់រៀបចំតាមលំដាប់ តំបន់កំពុងកសាង និងមជ្ឈមណ្ឌលសម្រេចកិច្ចការងារ ។

## 1. តំបន់រៀបចំតាមលំដាប់

តំបន់ទាំងឡាយនៃសហភាពអឺរ៉ុប មានថាមភាពខុសៗគ្នា ។ នានាភាពនេះ បង្ហាញច្បាស់ពីវិសមភាពនៃការអភិវឌ្ឍរវាងតំបន់នីមួយៗ ។

### 1.1. មេកាឡូប៉ូលអឺរ៉ុប

ពហុកោណអឺរ៉ុប (Europolygone) ដែលមានកំពូលគឺ ទីក្រុងឡុង រ៉ង់ស្តាត រួ មីឡង់ និងប៉ារីស ស្ថិតនៅចំកណ្តាលនៃសហភាពអឺរ៉ុប មានប្រជុំក្រុងធំៗជាប់គ្នានិងមានដង់ស៊ីតេប្រជាជនខ្ពស់បំផុត ។ មេកាឡូប៉ូលនេះមានប្រជាជនចំនួន 40% រស់នៅលើផ្ទៃដី 20% សម្រេចបាន 2/3 នៃផលិតផលឧស្សាហកម្មរបស់សហភាព ។ សមិទ្ធផលនេះបានមកពីការរួមបញ្ចូលគ្នាដ៏ពិសេសមួយនៃឧស្សាហកម្មគ្រប់ប្រភេទ ទាំងឧស្សាហកម្មដែលមានលក្ខណៈប្រពៃណីបំផុតនៃស្រុកផ្សែងធ្យូង(តំបន់រួ) ទាំងឧស្សាហកម្មទំនើប បំផុត(សំណង់អេឡិចត្រូនិចនិងមេកានិច) នៅឡុំបាឌី ឡុង ប៉ារីស ។ ប្រង់ផត ប៉ារីស និងឡុង មាននាទីបញ្ជាភ្នាក់ហិរញ្ញវត្ថុនិងពាណិជ្ជកម្មដោយសារវត្តមានទីផ្សារតម្លៃដែលទទួលបានចំណាត់ថ្នាក់ពិភពលោកក្នុងចំណោមលេខ 5 ដំបូងគេ និងដោយសារបណ្តាញព័ត៌មានពិសេសៗបំផុតក្នុងលោក ។

### 1.2. មុខឆ្នេរនៃមហាសមុទ្រ

មុខឆ្នេរនៃសមុទ្រឧត្តរបានទទួលផលចំណេញពីចំណងទាក់ទង ដែលមានរវាងតំបន់ទាំងឡាយនៃអាឡឺម៉ង់ ហូឡង់ ស្កង់ឌីណាវី និងអង់គ្លេស ។ សកម្មភាពតាមសមុទ្រដូចជា ការដ្ឋានសំណង់នាវាក៏ទទួលបានភាពអនុគ្រោះច្រើន ដោយសារវត្តមានកំណប់រ៉ែធ្យូងថ្មនៅភាគខាងជើងប្រទេសអង់គ្លេសនិងដោយសារអាជីវកម្មប្រេងកាតនៅសមុទ្រឧត្តរ ដែលបានធ្វើឱ្យទីក្រុងឧស្សាហកម្មនៅអង់គ្លេសនិងអេកូសមានសកម្មភាពឡើងវិញ ។ ដង់ស៊ីតេនិងជីវភាពប្រជាជននៅតែមានកម្រិតខ្ពស់ ។

មុខឆ្នេរអាត្លង់ទិកបានជួបប្រទះនឹងឧបសគ្គមួយចំនួន៖

- នៅប៉ែកខាងជើង បញ្ហានៅអៀរឡង់និងនៅខាងលិចហ្វ្រង់ប្រីតាញ(ការធ្លាក់ចុះនៃផលិតកម្មត្បូងថ្ម វាយនភ័ណ្ឌ និងដែកថែប) ។
- នៅភាគខាងត្បូង ប្រទេសអេស្ប៉ាញនិងព័រទុយហ្កាល់បានខិតខំបំពេញភាពយឺតយ៉ាវរបស់ខ្លួន (តំបន់ជនបទស្រែចម្ការ ទទួលបានការផ្គត់ផ្គង់គ្រឿងបរិក្ខារមិនគ្រប់គ្រាន់) ។

## 1.3. មុខឆ្នេរមេឌីទែរ៉ាណេ

អតីតកាលមួយ វប្បធម៌មួយ និងរបៀបរស់នៅមួយ ជាលក្ខណៈរួមរបស់ប្រជាជននៅតាមមុខឆ្នេរមេឌីទែរ៉ាណេ ។ តំបន់នេះប្រមូលផ្តុំប្រជាជនជិត 70 លាននាក់(ស្មើនឹង 20% នៃសហភាព) និងតាងបានតែ 16% នៃ GDP សហភាព ។

ក្រិកជាប្រទេសដែលក្រីក្រជាងគេនិងស្ថិតនៅដាច់ឆ្ងាយពីគេ ក្នុងលំហទឹកដីអឺរ៉ុប ។ ប្រទេសអ៊ីតាលី តំបន់មេឌីទែរ៉ាណេមានការផ្លាស់ប្តូរ ប្រែប្រួលយ៉ាងច្រើនជាមួយនឹងកិច្ចអភិវឌ្ឍនៅភាគកណ្តាលអ៊ីតាលីនិងនៅមេស្សូជោណូ(Mezzogiono) ។ នៅប្រទេសអេស្ប៉ាញ តំបន់កាតាឡូញ (Catalogne) បានទទួលផលចំណេញច្រើនពីថាមពលនៃរាជធានីបាសឺឡូន(Barcelone) និងពីវិស័យទេសចរ ។ ឆ្នេរទេសចរមួយដ៏សំបូរសប្បាយ មានមនុស្សរស់នៅច្រើននិងមានអាកាសធាតុគួរជាទីមនោរម្យ បានរីកចម្រើនចាប់ពីទីក្រុងសេវីល ទៅដល់កោះក្រែត និងបង្កើតបានជាតំបន់ទេសចរលេខមួយក្នុងពិភពលោក ។

## 1.4. តំបន់ខាងក្នុង

អាកាសធាតុ(ភាពស្ងួតហែងនៃភាគកណ្តាលប្រទេសអេស្ប៉ាញ) និងសណ្ឋានដី(ប្រជុំភ្នំកណ្តាលជួរភ្នំពីរេនេ) បានបណ្តាលឱ្យមានការរំខាននានា ដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមិនទាន់បំបាត់បាននៅឡើយ ។ តំបន់ខាងក្នុងដែលភ្ជាប់ទំនាក់ទំនងមិនល្អត្រូវស្ថិតនៅឯកោនិងមានការថយចុះសកម្មភាពយ៉ាងយឺតៗផងដែរ ។ តំបន់ឡាន់ដរ (Lander) នៃអតីតសាធារណរដ្ឋប្រជាធិបតេយ្យ អាឡឺម៉ង់ជួបប្រទះនូវភាពលំបាកដូចគ្នានឹងតំបន់ខាងក្នុងទាំងនោះដែរ ។ ធាតុភាពនេះបានបង្ហាញពីឥទ្ធិពលនៃរបបប្រជាធិបតេយ្យប្រជាមានិតក្នុងពេលកន្លងមក ។

និយាយរួម សហភាពអឺរ៉ុបជាលំហមួយចម្រុះទៅដោយតំបន់នានា ដែលមានមណ្ឌលកណ្តាលដ៏សំបូរសប្បាយនិងប្រកបដោយថាមភាព គឺជាពហុកោណអឺរ៉ុប ឬមេកាឡូប៉ូលអឺរ៉ុប និងបរិមណ្ឌលជាច្រើនមានលក្ខណៈខុសប្លែកៗគ្នាណាស់ ។ បរិមណ្ឌលទាំងនោះមាន តំបន់មុខឆ្នេរសមុទ្រឧត្តរ តំបន់មុខឆ្នេរអាត្លង់ទិក តំបន់មុខឆ្នេរមេឌីទែរ៉ាណេ និងតំបន់កំពុងរៀបចំ ។ នៅឆ្នាំ 2007 សហភាពអឺរ៉ុបមានរដ្ឋទាំងអស់ចំនួន 27 ជាសមាជិក ដែលកាលពីឆ្នាំ 2004 មាន 25 ប្រទេស និងនៅឆ្នាំ 1995 មាន 15 ប្រទេសប៉ុណ្ណោះ ។




*ផែនទីតំបន់នានានៃសហភាពអឺរ៉ុប*

## 2. លំហមួយកំពុងកសាង

ប្រទេសនៅអឺរ៉ុបខាងលិចស្ទើរតែទាំងអស់ បានចូលរួមទៅក្នុងសហភាពអឺរ៉ុបជាបន្តបន្ទាប់ ។ សំណុំទិកដីនេះត្រូវបានកសាងឡើងអស់រយៈពេលជាងកន្លះសតវត្សមកហើយ ។

### 2.1. ការដ្ឋានមួយមានដំណើរការជាប់រដឹក

នៅឆ្នាំ 1957 មានប្រទេសចំនួន 6 បានចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងរ៉ូម ។ ប្រទេសអាល្លឺម៉ង់ បារាំង អ៊ីតាលី ជាមួយគ្នានេះមានប្រទេសបែលហ្ស៊ិក ហូឡង់ និងលុចសំបួ បានបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប(CEE) ។ នៅឆ្នាំ 1973 រាជាណាចក្ររួម អៀរឡង់ និងដាណឺម៉ាក ក៏បានចូលរួមទៅក្នុង CEE ។ បន្ទាប់មកមានប្រទេសក្រិក(ឆ្នាំ 1981) អេស្ប៉ាញនិងព័រទុយហ្គាល់នៅឆ្នាំ 1986 ប្រទេសអូទ្រីស ហ្វាំងឡង់ និងស៊ុយអែតនៅឆ្នាំ 1995 ប្រទេសស៊ីប អេស្តូនី ហុងគ្រី ឡេតូនី លីទុយអានី ម៉ាល់ ប៉ូឡូញ សាធារណរដ្ឋឆែក ស្លូវ៉ាគី និងស្លូវេនីនៅឆ្នាំ 2004 ប្រទេសប៊ុលហ្គារីនិងរូម៉ានីនៅឆ្នាំ 2007 ។ នៅឆ្នាំ 2007 សហភាពអឺរ៉ុបមានប្រទេសទាំងអស់ចំនួន 27 ជាសមាជិក ។ ក្រៅពីនេះ នៅមានប្រទេសផ្សេងខ្លះ

ទៀតដូចជាប្រទេសតួកគីគឺស្ថិតនៅក្នុងបេក្ខភាព ។ តែក្នុងរយៈពេលប្រមាណជាកន្លះសតវត្សប៉ុណ្ណោះ សហភាពអឺរ៉ុបបានរីកចម្រើនទាំងទំហំទឹកដី ទាំងចំនួនប្រជាជនពី 1 276 956 $km^2$ មក 4 324 782$km^2$ ពី 180 លាននាក់ មកជាង 491 លាននាក់ គឺផ្ទៃដីកើនជាង 3 ដងនិងប្រជាជនកើនជិត 3 ដង ។

## 2.2. ការរៀបចំមួយដ៏សាំញ៉ាំ

សហភាពអឺរ៉ុប(EU)ជាលំហសេរីមួយដែលកសាងឡើងលើគោលការណ៍ "សេរីភាពសំខាន់ៗបួន" មានចរាចរសេរីនៃទំនិញ សេវា មនុស្ស និងមូលធន ។ EU មានស្ថាប័នធំៗចាំបាច់បី សម្រាប់ដឹកនាំដែលត្រូវបានបង្កើតឡើងដោយមានការចូលរួមពីប្រទេសសមាជិកទាំងអស់ ។ ជារៀងរាល់ឆ្នាំក្រុមប្រឹក្សាអឺរ៉ុបបានកោះប្រជុំប្រមុខរដ្ឋ ឬរដ្ឋាភិបាលចំនួន 15 ប្រទេស ។ ប៉ុន្តែសេចក្ដីសម្រេចសំខាន់ៗប្រព្រឹត្តទៅដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសមាជិកដែលត្រូវពិភាក្សាលើសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍នៃសហគមន៍ ។ នយោបាយកសិកម្មរួមបានបញ្ជាក់ច្បាស់ពីភាពសាំញ៉ាំនៃសេចក្ដីសម្រេចទាំងឡាយនិងការអនុវត្ត ។ គ្មានប្រទេសណាមួយអាចធ្វើឱ្យខូចខាតផលប្រយោជន៍បានឡើយ ។ នីតិប្រតិបត្តិនេះ មានទីស្នាក់ការនៅទីក្រុងព្រុចសែល រ៉ាប់រងនូវសម្ព័ន្ធភាពនៃអឺរ៉ុប 15 ។

## 2.3. ការពុះពារជាបន្តបន្ទាប់

សន្ធិសញ្ញាម៉ាសទ្រិច (Maastricht) បានកំណត់ពលរដ្ឋសហភាពអឺរ៉ុបតាមរយៈសិទ្ធិនានា គឺសិទ្ធិស្នាក់នៅ សិទ្ធិធ្វើចរាចរណ៍សេរី សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានកិច្ចការពារផ្នែកសង្គម ។ សន្ធិសញ្ញានេះបានកំណត់ផងដែរពីសហភាពសេដ្ឋកិច្ចនិងរូបិយវត្ថុ ដែលនាំទៅរកការប្រើប្រាស់រូបិយវត្ថុរួមគឺអឺរ៉ូ (Euro) ។ ក្នុងបណ្ដាបញ្ហាដែលចោទ បញ្ហាសំខាន់គឺអធិបតេយ្យភាពរដ្ឋ ។ ប្រទេសប៉ូឡូញ ហុងគ្រី សាធារណរដ្ឋឆែក និងប្រទេសស្លូវេនី បានសុំចូលរួមក្នុងសហភាព ។ ការទទួលយករដ្ឋទាំងនោះត្រូវបានព្យួរទុកដោយរង់ចាំមើលសមត្ថភាពកសាងសេដ្ឋកិច្ចទីផ្សារមួយប្រកបដោយស្ថិរភាពសិន ។ បន្ទាប់មកនៅឆ្នាំ 2004 អតីតរដ្ឋប្រជាមានិតទាំងនោះត្រូវបានទទួលឱ្យចូលជាសមាជិកនៃ EU ។ "មហាអឺរ៉ុប" តែងនឹកគិតជានិច្ចពីអនាគតរបស់ខ្លួននិងសមាជិកមួយចំនួនទៀតក្នុងការសហការគ្នាដោះស្រាយបញ្ហាដែលចោទឡើងដូចជា បញ្ហាវិបត្តិហិរញ្ញវត្ថុនៅអ៊ីតាលីក្នុងពេលថ្មីៗកន្លងមក (2010) ជាដើម ។

## 2.4. លំហមួយទទួលបានការគាំទ្រ

ប្រទេសចំនួន 15 នៃ EU បានចូលរួមទៅក្នុងអង្គការអន្តរជាតិផ្សេងៗ ដែលប្រមូលផ្ដុំប្រទេសអឺរ៉ុបដទៃទៀតនិងប្រទេសលោកខាងលិច ។ ទំនាក់ទំនងមានយ៉ាងស្អិតរមួតជាមួយអង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច OCDE និងជាមួយសម្ព័ន្ធអាត្លង់ទិក ។ EU ជាដៃគូរបស់បណ្ដាប្រទេស

នៃសមាគមសេដ្ឋកិច្ចបណ្តូរសេរី AELE ក្នុងក្របខ័ណ្ឌលំហសេដ្ឋកិច្ចអឺរ៉ុប ។ នៅពេលចុងក្រោយនេះ ជាមួយ ប្រទេសអឺរ៉ុបកណ្តាលនិងខាងកើត EU បានបង្កើតធនាគារអឺរ៉ុប សម្រាប់ការកសាងឡើងវិញ និងអភិវឌ្ឍន៍ BERD និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្តូរសេរីជាមួយប្រទេសហុងគ្រី ប៉ូឡូញ សាធារណរដ្ឋឆែក និងស្លូវ៉ាគី ។ បណ្តាញសមាគមសេដ្ឋកិច្ចយ៉ាងញឹកធានារ៉ាប់រងបាននូវសន្តិភាព និងស្ថិរភាពសម្រាប់លំហនេះនៅទ្វីបអឺរ៉ុប ។ អនុសញ្ញាឡូមេ ឆ្នាំ 1975 បានរៀបចំឱ្យមានកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍជាមួយបណ្តារដ្ឋអាហ្វ្រិក ការ៉ាអ៊ីប និងប៉ាស៊ីហ្វិក(ACP)ចំនួន 69 ។ ឡូមេ ផ្តោតលើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងបច្ចេកទេសឧស្សាហកម្មនិងកសិកម្ម ។




*អឺរ៉ុប : សម្ព័ន្ធភាពនិងការបែងចែក*

## 3. មជ្ឈមណ្ឌលសម្រេចកិច្ចការងារ

សហភាពអឺរ៉ុប ដែលជា " អង្គការពហុជាតិ " គ្មានរដ្ឋធានីមួយទេ តែមានដល់ទៅបីគឺ ធានី ព្រុចសែល លុចសំបួ និងស្ត្រាសបួ ត្រូវបានជ្រើសរើសធ្វើជាទីស្នាក់ការនៃអំណាចទាំងបី ដោយ យោលទៅតាមលក្ខណៈភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ឬជានិមិត្តរូប ។

### 3.1. អំណាចនីតិប្រតិបត្តិ EU នៅព្រុចសែល

តាំងពីឆ្នាំ 1958 ជានីព្រុចសែលក្លាយជាទីស្នាក់ការសំខាន់ៗរបស់សហគមន៍សេដ្ឋកិច្ចអឺរ៉ុប CEE ។ ក្រុមប្រឹក្សារដ្ឋមន្ត្រី EU គណៈកម្មាធិការ និងរដ្ឋបាលមានមន្ត្រីទាំងអស់ជាង 14 000 នាក់ បានរួមប្រជុំ និងបំពេញការងារនៅទីនោះ ។

សំណើរបស់គណៈកម្មាធិការទៅក្រុមប្រឹក្សារដ្ឋមន្ត្រីនិងប្រមុខរដ្ឋនានា ត្រូវបានពិនិត្យនិងយល់ព្រម ឬក៏ធ្វើការសម្រួល ។ គណៈកម្មាធិការនេះមានភារកិច្ចពិនិត្យ ផ្ទៀងផ្ទាត់ការងារ អនុវត្តសេចក្ដីសម្រេច ដោយបញ្ជូនមន្ត្រីរបស់ខ្លួនទៅដល់ទីកន្លែង បើសិនជាចាំបាច់ ។

### 3.2. អំណាចនីតិប្បញ្ញត្តិ EU នៅស្ត្រាសបួ

តាំងពីឆ្នាំ 1979 ដោយការបោះឆ្នោតជាសកលនិងដោយផ្ទាល់ សភាសហភាពអឺរ៉ុបក៏ត្រូវបានជ្រើសតាំងអំណាចនិតិប្បញ្ញត្តិឡើងដែលជាស្ថាប័នដ៏សំខាន់មួយរបស់ EU ។ សន្ធិសញ្ញាម៉ាសទ្រិចឆ្នាំ 1992 បានកំណត់យកជានីស្ត្រាសបួជាទីស្នាក់ការរបស់សភា EU ដែលមានសមាជិកទាំងអស់ចំនួន 626 រូប បើកការរួមប្រជុំនៅទីនោះទៅតាមអាណត្តិ ។ ស្ថាប័ននេះធ្វើអន្តរាគមន៍ផ្ទាល់ ក្នុងដំណើរការរបស់សហភាព ដោយថ្លែងការលើសេចក្ដីសម្រេចផ្នែកហិរញ្ញវត្ថុនិងលើការចង្អុលបង្ហាញរបស់ប្រធានគណៈកម្មាធិការ EU ។

### 3.3. អំណាចតុលាការ EU នៅធានីលុចសំបួ

អង្គការតុលាការ EU មានចៅក្រមឯករាជ្យចំនួន 15 រូប មានទីស្នាក់ការនៅធានីលុចសំបួ ។ តុលាការនេះមានតួនាទីធានារ៉ាប់រងការគោរពសិទ្ធិក្នុងការធ្វើការបកស្រាយ និងការអនុវត្តសន្ធិសញ្ញាម៉ាសទ្រិច ។ សកម្មភាពរបស់តុលាការនេះមានការកើនឡើងជាលំដាប់ ដោយសម្រេចការកាត់ក្ដីបានជាង 3 000 សាលដីកា ទាំងករណីបង្ខំដោយច្បាប់ និងទាំងករណីអនុវត្តច្បាប់ ។

### ? សំណួរ

1. តើសហភាពអឺរ៉ុបជាអ្វី ? មានកំណាកំណើតដូចម្ដេច ?
2. តើគេអាចចែកសហភាពអឺរ៉ុបជាប៉ុន្មានតំបន់ ? អ្វីខ្លះ ?
3. តើគោលការណ៍សំខាន់ 4 របស់សហភាពអឺរ៉ុបមានអ្វីខ្លះ ?
4. តើស្ថាប័នសំខាន់ 3 របស់សហភាពអឺរ៉ុបមានអ្វីខ្លះ ? មានទីស្នាក់ការនៅទីណាខ្លះ ?
5. តើ EU 27 មានទំហំទឹកដីនិងប្រជាជនប៉ុន្មាន ?

# 2 អានុភាពសេដ្ឋកិច្ចសហភាពអឺរ៉ុប

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីអានុភាពសេដ្ឋកិច្ចសហភាពអឺរ៉ុបមាន សំណុំសេដ្ឋកិច្ចពិភពលោក មហាអំណាចហិរញ្ញវត្ថុ-ពាណិជ្ជកម្ម និងលំហសេដ្ឋកិច្ចថ្មីៗ ។

កម្លាំងសេដ្ឋកិច្ចសហភាពអឺរ៉ុបជាផ្លែផ្កាដែលបានមកពីសមាហរណកម្មសេដ្ឋកិច្ចជាបន្តបន្ទាប់ពីសំណាក់ប្រទេសសមាជិក ពិសេសប្រទេសអតីតមហាអំណាចមាន បារាំង អង់គ្លេស បែលហ្ស៊ិក ហូឡង់ លុចសំបួ... ។ សូម្បីប្រទេសសមាជិកថ្មី ដែលជាអតីតរដ្ឋសង្គមនិយមនៃអឺរ៉ុបខាងកើតមួយចំនួន ក៏បានខិតខំរៀបចំសេដ្ឋកិច្ចផែនការរបស់ខ្លួនឱ្យមកជាសេដ្ឋកិច្ចទីផ្សារ ប្រកបដោយស្ថិរភាពនិងសមស្របទៅតាមប្រព័ន្ធមូលធននិយមពិភពលោកដែរ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏គេឃើញថាពហុកោណអឺរ៉ុបមួយដ៏សំបូរសប្បាយ ដែលជាបេះដូងនៃសហភាពអឺរ៉ុប (EU) និងបរិមណ្ឌលជាច្រើននោះមានការអភិវឌ្ឍនៅក្នុងកម្រិតទាបនៅឡើយ ។

## 1. សំណុំសេដ្ឋកិច្ចពិភពលោកលេខមួយ

### 1.1. ឥទ្ធិពលសហភាពអឺរ៉ុបកើនឡើង

ចាប់ពីឆ្នាំ 2007 មក EU ត្រូវបានពង្រីកដល់ទៅ 27 រដ្ឋ ជារួមមានប្រជាជនដល់ទៅជិត 500 លាននាក់ និងទំហំទឹកដីដល់ទៅជាង 4 លាន $km^2$ ។ EU មានប្រព័ន្ធផលិតកម្មមួយយ៉ាងធំសម្បើម កំពុងតែទទួលបានការផ្លាស់ប្តូរ ដែលជាលទ្ធផលនៃការប្រមូលផ្តុំមូលធននិងធនធានបញ្ញាតាំងពីយូរមកហើយ និងពីសកម្មភាពចូលរួមយ៉ាងសកម្មពីបណ្តាសហគ្រាសនិងរដ្ឋនានា ។

ជាមួយផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ប្រចាំឆ្នាំចំនួន 14.8 លានដុល្លារ សហភាពអឺរ៉ុបបាននាំមុខសហរដ្ឋអាមេរិកនិងក្លាយទៅជាលំហសេដ្ឋកិច្ចមួយខ្លាំងក្លាបំផុតក្នុងលោក ។ ប៉ុន្តែស្ថានភាពសេដ្ឋកិច្ច EU មានភាពស្មុគស្មាញជាងប៉ូលទាំងពីរទៀតនៃទ្រីយ៉ាត (Triade) គឺសហរដ្ឋអាមេរិកនិងជប៉ុន ដោយហេតុថា EU មានវិសមភាពអភិវឌ្ឍន៍ផ្ទៃក្នុងយ៉ាងស៊ីជម្រៅនិងស្ថិតក្នុងស្ថាន

ភាពកំពុងកសាងសង្គម-សេដ្ឋកិច្ចតទៅមុខទៀត ។ ភាពខុសប្លែកគ្នានៃសេដ្ឋកិច្ចកើតមានស្របគ្នានិង-ការកាត់ផ្តាច់ចេញពីគ្នាពីមុនមកនៃប្រវត្តិសាស្ត្រ នយោបាយ និងវប្បធម៌ ។ EU បានខិតខំការពារផលប្រយោជន៍របស់ខ្លួនក្នុងកិច្ចចរចាសេដ្ឋកិច្ចជាអន្តរជាតិតាមរយៈសំណើជាច្រើន ។ តែផលប្រយោជន៍ជាតិតែងមានប្រៀបខ្លាំងជារឿយៗ ដែលនាំឱ្យវិវាទនដល់យុទ្ធសាស្ត្រសហគមន៍ ។

## 1.2. មហាអំណាចឧស្សាហកម្ម

អាជីវកម្មធនធានរ៉ែនិងថាមពលនៅសហភាពអឺរ៉ុបមានព្រំដែនកំណត់ លើកលែងតែក្នុងករណីពិសេសៗខ្លះចេញ ។ ជាទូទៅ សកម្មភាពជីកយករ៉ែមានការថយចុះ ដូចជារ៉ែដែកនិងធ្យូងថ្មជាដើម ។ ផ្ទុយទៅវិញ ការទាញយកថាមពលវារីអគ្គិសនីមានលក្ខណៈធំសម្បើមណាស់ ។ អាជីវកម្មអ៊ីដ្រូកាបួនៅក្នុងសមុទ្រខត្តរ អាចជួយកាត់បន្ថយភាពចំណុះគេខាងថាមពលរបស់ EU បានយ៉ាងជាក់ស្តែង ។

EU បានស្ថិតនៅពីមុខគេលើផ្នែកតម្លៃផលិតផលឧស្សាហកម្ម ។ ផលិតកម្មនេះទទួលបានការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងពេលតែមួយ ទាំងលើផ្នែកនីមួយៗនៃផលិតកម្មនិងទាំងលើផ្នែកដែនដី ។ វិបត្តិបានស្តែងចេញតាមការបាត់បង់ការងារយ៉ាងច្រើនសម្បើម ។ ហេតុការណ៍នេះមិនមែនមានន័យថាឧស្សាហូបនីយកម្មមានការថយចុះនោះទេ ។ ឧស្សាហកម្មនៅតែដើរតួនាទីចម្បងជានិច្ច នេះបើយោលទៅតាមផលសម្រេចបាននៅក្នុងសេដ្ឋកិច្ចរបស់ EU ។ ការកាត់បន្ថយចំនួនការងារត្រូវជំនួសវិញដោយផលចំណេញពីផលិតភាពដែលបានមកពីស្វ័យប្រវត្តិកម្ម ។ អ្នកបម្រើការងារក្នុងឧស្សាហកម្មជាច្រើនត្រូវបានផ្ទេរទៅកាន់ផ្នែកទទួលការងារបន្ត ដែលបង្កើតបានជាសកម្មភាពការងារផ្នែកសេវាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសកម្មភាពឧស្សាហកម្មណាមួយ ។ ហេតុដូច្នេះហើយ បានជាការងារផ្នែកទីបី(សេវា) ចំនួនមួយភាគបី តែងទាក់ទិនទៅនឹងវិស័យឧស្សាហកម្មយ៉ាងពិតប្រាកដ ។

## 1.3. មហាអំណាចកសិកម្ម

EU ជាមហាអំណាចកសិកម្មលេខពីរក្នុងពិភពលោក ។ ដោយបាននាំចេញផលិតផលកសិកម្មលើសតម្រូវការរបស់ខ្លួនមួយភាគយ៉ាងសំខាន់ដែលអាចរក្សាជំហរប្រកួតប្រជែងជាមួយសហរដ្ឋអាមេរិកបាន ។ ប៉ុន្តែក្នុងពេលកន្លងមកថ្មីៗនេះ បញ្ហាចោទកើតមានកាន់តែច្រើន ដូចជាបញ្ហាបរិស្ថាននិងបញ្ហាសុខភាពអនាម័យ(ជំងឺគោឆ្កួត) ដែលបណ្តាលឱ្យកសិកម្មមហាផល (L'agriculture Productiviste) ជួបការលំបាក ។

កសិកម្មអឺរ៉ុបមានលក្ខណៈឱ្យកនិយម ។ នៅក្បែរកសិដ្ឋានធំៗនាភាគពាយ័ព្យអឺរ៉ុបដែលកសិកម្មមានកម្រិតយន្តកម្មខ្ពស់បំផុតដោយសារការអនុវត្តគំរូកសិកម្មមហាផលនិងកសិកម្មបែបពាណិជ្ជកម្ម គេឃើញមានកសិកម្មរបស់ប្រជាជនតូចតាច ជាពិសេសនៅតំបន់ភ្នំត្រង់រយៈកម្ពស់មធ្យម ។ កសិកម្មនេះតែងតែជួបការលំបាកសំខាន់ៗជារឿយៗ ។ គេអាចរាប់បញ្ចូលផងដែរនូវករណីពិសេសនៃកសិកម្មអឺរ៉ុបខាងកើត ដែលទើបតែចេញពីប្រព័ន្ធសមូហកម្មសង្គមនិយមដ៏ទូលំទូលាយនោះ ។

នៅត្រង់ទំនាបនៃភាគខាងជើងអឺរ៉ុប ដំណាំធញ្ញជាតិនិងការចិញ្ចឹមសត្វមានលក្ខណៈអតិផលប្រដាប់ដោយគ្រឿងយន្ត គឺជាកសិ-ឧស្សាហកម្ម ។ កសិករមានចំនួនតិច តែផលិតផលមានច្រើនសម្បើម ។ នៅត្រង់តំបន់មួយចំនួននៃអឺរ៉ុបខាងត្បូងនិងនៅក្នុងប្រទេសដែលជាសមាជិកថ្មីនៃ EU ទិន្នផលមានកម្រិតទាប ហើយកសិករអនុវត្តពហុវប្បកម្មបែបប្រពៃណីនៅឡើយ ប្រដាប់ដោយគ្រឿងយន្តតិចតួច ។ នៅអឺរ៉ុបខាងកើត ចំនួនកសិករក៏មានច្រើនដែរ ។



*ដំណាំផ្សេងៗនិងប្រព័ន្ធផលិតកម្មកសិកម្មនៅសហភាពអឺរ៉ុប*

# 2. មហាអំណាចហិរញ្ញវត្ថុនិងពាណិជ្ជកម្ម

## 2.1. ការឡើងជាមហាអំណាចពាណិជ្ជកម្ម

EU ជាប៉ូលពាណិជ្ជកម្មទីមួយក្នុងពិភពលោក ។ កំណើនពាណិជ្ជកម្មផ្ទៃក្នុងអឺរ៉ុបកើតមានរហ័សជាងនៅក្រៅទ្វីបអឺរ៉ុប ។ ទំនាក់ទំនងរវាងបណ្តាប្រទេសឧស្សាហកម្មមានលក្ខណៈគួរឱ្យកត់សម្គាល់យ៉ាងខ្លាំង ។ បរិមាណផលិតផលនៅក្នុងបណ្តូរសរុបរបស់អឺរ៉ុបមានការថយចុះ រីឯបរិមាណផលិតផលឧស្សាហកម្មវិញ មានការកើនឡើងយ៉ាងច្រើនសម្បើម ។

បន្ទុកនៃការដោះដូរ បានបង្ហាញឱ្យឃើញតាមការរៀបចំដៃគូជំនួញឡើងវិញ ។ បរិមាណការដោះដូររបស់បណ្តាប្រទេសអាហ្វ្រិក ការ៉ាអ៊ីប និងប៉ាស៊ីហ្វិក (ACP) មានការថយចុះ ។ ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ EU មានសហរដ្ឋអាមេរិកដែលការនាំចេញបានបង្ហាញតុល្យភាពសមស្របចំពោះអឺរ៉ុប នាពេលនេះ ។ ផ្ទុយទៅវិញ ជញ្ជីងពាណិជ្ជកម្មស្ថិតក្នុងឱនភាពជាមួយតំបន់អាស៊ី ជប៉ុន ចិន និងប្រទេសឧស្សាហកម្មថ្មីនៃអាស៊ី ។

## 2.2. ភ្នាក់វិនិយោគផ្ទាល់នៅឯបរទេស

EU ជាប៉ូលផ្សាយវិនិយោគផ្ទាល់នៅឯបរទេស (IDE) លេខមួយក្នុងពិភពលោក ។ វិនិយោគរបស់អឺរ៉ុបបានកើនឡើងយ៉ាងសម្បើមនៅតាមបណ្តាលប្រទេសសមាជិក NAFTA "តំបន់ពាណិជ្ជកម្មសេរីនៃអាមេរិកខាងជើង" នៅបណ្តាប្រទេសឧស្សាហកម្មនៃអាស៊ី ឬប្រទេសដែលទើបតែផុសឡើងផ្នែកឧស្សាហកម្មនិងនៅតាមបណ្តាប្រទេសអឺរ៉ុបខាងកើត តែក្នុងទំហំតិចជាង ។

EU ក៏ជាប៉ូលទទួលវិនិយោគផ្ទាល់ពីបរទេសលេខមួយផងដែរក្នុងពិភពលោក ។ ទោះបីផ្សាររួមមួយនេះជាទីទាក់ទាញទុនពីសហរដ្ឋអាមេរិកនិងជប៉ុនក៏ដោយ ក៏ IDE ភាគច្រើនរបស់បណ្តាប្រទេសអឺរ៉ុប ជាវិនិយោគក្នុងផ្ទៃអឺរ៉ុបដែរ ។

ភូមិវិទ្យាតំបន់នៃ IDE មានទំនោរទៅរកការបង្កើនវិសមភាពលំហដែនដី ដែលមានពីមុនមក ។ IDE តែងប្រមូលផ្តុំក្នុងលំហទាំងឡាយនៃមេត្រូប៉ូល ។ *ឧទាហរណ៍* ដូចជានៅប្រទេសអេស្ប៉ាញ ធានីម៉ាឌ្រីត និងបាសឺឡូន បានច្បាមយកអស់ 80% នៃ IDE របស់ប្រទេស ។ កត្តាដៅទីសម្រាប់ IDE មានច្រើនដូចជា ការស្វែងរកសេដ្ឋកិច្ចមាត្រដ្ឋាន ទីកន្លែងដែលនៅជិតៗផ្សារអឺរ៉ុបសំខាន់ៗ តម្លៃពលកម្មមានកម្រិតទាប លទ្ធភាពខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ និងភាពសំបូរក្រុមហត្ថពលករ ឧស្សាហកម្មជំនាញ ។

## 2.3. លំហហិរញ្ញវត្ថុអឺរ៉ុប

តំបន់ប្រើប្រាស់រូបិយវត្ថុអឺរ៉ូរួមមាន 13 ប្រទេសក្នុងបណ្តាប្រទេសសមាជិកទាំង 27 នៃ EU ។ ក្រៅពីនេះរដ្ឋជាសមាជិកដទៃទៀតនៅមិនទាន់បានប្រុងប្រៀបទទួលប្រើប្រាស់លុយអឺរ៉ូនៅឡើយទេ មានដូចជា រាជាណាចក្ររួម ស៊ុយអែត ដាណឺម៉ាកជាដើម ។




*ប្រទេសប្រើប្រាស់ប្រាក់អឺរ៉ូ (€)*

ភូមិវិទ្យាដែនដីនៃហិរញ្ញវត្ថុអឺរ៉ុប មានលក្ខណៈប្រមូលផ្តុំកាន់តែខ្លាំងឡើងទាំងក្នុងក្របខ័ណ្ឌជាតិនិងលើផ្ទៃរាបអឺរ៉ុប ដើម្បីជាគុណប្រយោជន៍ចំពោះមេត្រូប៉ូលដែលមានអានុភាពខ្លាំងក្លាបំផុត ។ ដូច្នេះហើយ បានជាទីក្រុងឡុង ក្លាយទៅជាទីផ្សារហាងឆេងដ៏សំខាន់របស់ EU ។

ពហុមណ្ឌលតម្រង់ទិសនិងធ្វើសេចក្ដីសម្រេចនៅប្រទេសអាល្លឺម៉ង់មានមេត្រូប៉ូលបួនគឺ ប្រង់ផត បែឡាំង មុយនិច និងឌុយសែលដហ្វ នៅតែជាករណីពិសេសដោយសារមានទីស្នាក់ការធនាគារសំខាន់ៗមួយចំនួនធំ ។ ប្រង់ផតបានបង្ហាញឧត្ដមភាពរបស់ខ្លួនកាន់តែច្បាស់ឡើងៗ តាមរយៈវត្តមាននៃទីស្នាក់ការធនាគារ ប៊ុនដេសបង់ (Bundes Bank)និងធនាគារកណ្ដាលអឺរ៉ុប (BCE) រួមទាំងទីផ្សារហាងឆេងអាល្លឺម៉ង់និងទីស្នាក់ការធនាគារជាច្រើនទៀត ។

# 3. លំហសេដ្ឋកិច្ចថ្មីៗ

## 3.1. កត្តានៃការរៀបចំសេដ្ឋកិច្ចឡើងវិញ

លំហសេដ្ឋកិច្ចមានកម្លាំងទំនាញជាច្រើនដែលបង្កើតបានជាកត្តាសម្រេចក្នុងការដៅទីតាំង ។ កត្តាទាំងនោះមានការត្រៀមក្រុមកម្មករជំនាញ ទំនាក់ទំនងរវាងសហគ្រាសធំនិងសហគ្រាសតូចនិងមធ្យម (PME) ភាពបំពេញឱ្យគ្នាទៅវិញទៅមករវាងឧស្សាហកម្មនិងសេវាកម្ម និងលទ្ធភាពចូលដល់ទីតាំងដ៏ល្អមួយ ។ តំបន់ក្រុងធំៗរមែងមានគ្រប់កត្តាទាំងអស់នេះ ។ តំបន់ទាំងនោះមាននៅក្នុងមេត្រូប៉ូល ព្រមទាំងមាននៅខាងក្រៅមេត្រូប៉ូលផងដែរ ហើយតែងទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័ស ដូចជានៅតំបន់កាតាឡូញ (Catalogne) នៃប្រទេសអេស្ប៉ាញជាដើម ។ ទន្ទឹមនឹងនេះ ក៏បានបង្កើតឱ្យមានភាពខុសគ្នាជាមួយតំបន់ដែលនគរូបនីយកម្មមានកម្រិតទាប ។

មេត្រូប៉ូលមានមុខងារបញ្ជាសេដ្ឋកិច្ចកាន់តែខ្លាំងឡើងៗ ដោយបានប្រមូលផ្ដុំទីស្នាក់ការសង្គមនៃសហគ្រាសធនាគារនិងក្រុមហ៊ុនសំខាន់ៗ រួមទាំងសកលវិទ្យាល័យនិងសាលាធំៗផងដែរ ។ នៅក្នុងមេត្រូប៉ូល សកម្មភាពសិក្សាស្រាវជ្រាវក៏មានលក្ខណៈទូលំទូលាយណាស់ដែរ ។

## 3.2. លំហអភិវឌ្ឍន៍សេដ្ឋកិច្ច

ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចបានផ្ដល់ផលប្រយោជន៍ជាបឋមដល់តំបន់នានានៃមេត្រូប៉ូលពិសេសធានីធំៗរបស់ជាតិ (*ឧទាហរណ៍* រដ្ឋធានីប៉ារីសនិងរាជធានីឡុង) ។ ទីក្រុងទាំងឡាយរបស់ EU បានទាញយកផលកំរៃពីសមិទ្ធផលណាមួយ ដូចជាទីក្រុងប្រង់ផតដែលទទួលផលចំណេញពីការតាំងទីនៃធនាគារកណ្ដាលអឺរ៉ុប (BCE) យ៉ាងដូច្នេះដែរ រីឯទីក្រុងព្រុចសែលវិញក៏បានផលប្រយោជន៍ពីវត្តមាននៃគណៈកម្មាធិការអឺរ៉ុបនិងពីស្ថាប័នរដ្ឋបាលជាច្រើនរបស់សហភាព ។

តំបន់ដែលស្ថិតនៅតាមបណ្ដោយព្រំដែនអាចជួយបង្កើនថាមពលសេដ្ឋកិច្ច ។ ព្រំដែនសមាហរណទាំងឡាយដូចជា នៅក្នុងតំបន់ទន្លេរ៉ាំងនិងតំបន់ភ្នំអាល់បង្កើតបានជាទីពិសោធផ្នែកអន្តរទំនាក់ទំនងបែបពហុសណ្ឋាន រួមមានបណ្ដូរវិនិយោគ ការងារឆ្លងកាត់ព្រំដែន យុទ្ធសាស្ត្ររួមនៃការផ្គត់ផ្គង់គ្រឿងបរិក្ខារ និងការផ្សព្វផ្សាយពាណិជ្ជកម្ម ។ នៅទីនេះ គេបានធ្វើការរួមប្រជុំលើបញ្ហាបង្កើតតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូ ជាច្រើនកន្លែង ដូចជាតំបន់សាឡូលុច Sarlolux(Sarre, Loraine, Luxambourg) ។

ភាគពាយ័ព្យអឺរ៉ុបបង្កើតបានជាតំបន់កសិកម្មស្នូលរបស់សហភាពអឺរ៉ុប ។ មធ្យោបាយបច្ចេកវិទ្យានិងពាណិជ្ជកម្មកម្រិតខ្ពស់ ត្រូវបានយកមកអនុវត្តក្នុងកសិកម្មមហាផលមួយ ។ តំបន់មេឌីទែរ៉ាណេ ក៏មានលំហកសិកម្មដែលផ្តល់ទិន្នផលខ្ពស់ផងដែរ(ដំណាំឯកទេស ដំណាំបញ្ចូលទឹកនៅតាមទំនាបឆ្នេរ នៃប្រទេសអេស្ប៉ាញ ឬអ៊ីតាលី) ។ កសិកម្មអតិផល(ទំពាំងបាយជូរ ដំណាំអូលីវ ដំណាំក្រូច) អាច បំពេញតម្រូវការកាន់តែច្រើន ដែលបណ្តាលមកពីកំណើនកម្រិតជីវភាព ។

## ៣.៣. តំបន់ងាយប្រេះស្រាំនិងត្រូវប្តូរសកម្មភាព

តំបន់ឧស្សាហកម្មដែលជួបប្រទះនឹងខិនភាពតែងបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីលក្ខណៈសង្គមសេដ្ឋកិច្ច ដោយផ្អែកតឹងង់ស៊ីតេប្រជាជនញឹក អត្រាភាពឥតការងារធ្វើខ្ពស់ ។ តំបន់ទាំងនោះទទួលបានផលចំណេញពីជំនួយសំខាន់ៗរបស់ EU ដើម្បីធ្វើការផ្លាស់ប្តូរសកម្មភាពដែលក្នុងនោះឧស្សាហកម្មរថយន្តនៅតែរក្សាតួនាទីមួយសំខាន់ដដែល ។ សេដ្ឋកិច្ចតាមឆ្នេរក៏តែងជួបវិបត្តិជាញឹកញយដែលស្តែងឡើងតាមរយៈការលំបាកទាំងឡាយក្នុងការនេសាទ សំណង់នាវា និងតាមរយៈភាពងាយប្រេះស្រាំក្នុងការតាំងទីឧស្សាហកម្មតាមកំពង់ផែ ។



*ទីក្រុងនិងកំពង់ផែ ជែន ប្រទេសអ៊ីតាលី*

កសិកម្មយថាផល ត្រូវបានរាប់បញ្ចូលផងដែរទៅក្នុងបណ្តាលំហសេដ្ឋកិច្ចងាយប្រេះស្រាំ ។ កសិកម្មប្រភេទនេះបានគ្របដណ្តប់លើផ្ទៃដីយ៉ាងធំធេងនៃតំបន់ខាងក្នុងនិងតំបន់ភ្នំ ហើយតែងរងការគំរាមកំហែងពីបាតុភូតវាលលំហកម្មជារឿយៗ ។ នៅតាមបរិមណ្ឌលនៃតំបន់កសិកម្មស្នូលអឺរ៉ុប គេឃើញមានពហុវប្បកម្មបែបប្រពៃណីប្រកបដោយទិន្នផលទាប នៅលើទីដីកសិកម្មតូចៗ ។ នៅលើទីដីទាំងនេះ ប្រជាកសិករនៅតែមានចំនួនច្រើន(15%នៃប្រជាជនសកម្ម នៅអឺរ៉ុបខាងកើត) និងអនុវត្តកសិកម្មយថាផល ដែលប្រើប្រាស់គ្រឿងយន្តកសិកម្មតិចតួច ។

ជាបញ្ចប់ ព្រំដែនបញ្ញាសទិសខ្លះ គឺជាខ្សែបន្ទាត់នៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ដូចជានៅប្រទេសស៊ីបនិងនៅតំបន់អ៊ុលស្ទែ ជាពិសេសដែលបានរាំងខ្ទប់គ្រប់សហប្រតិបត្តិការសេដ្ឋកិច្ច។ នៅពេលនេះ ការបង្រួបបង្រួមប្រទេសស៊ីប កំពុងស្ថិតនៅលើមាគ៌ាមួយដ៏ល្អ។

## សំណួរ

1. តើ "សហភាពអឺរ៉ុប" ជាអ្វី ? មានកំណាក់កំណើតដូចម្តេច ?
2. តើមានចំណុចណាខ្លះ ដែលបង្ហាញឱ្យឃើញថា ឥទ្ធិពល EU មានការកើនឡើង ?
3. តើមានចំណុចណាខ្លះ ដែលបង្ហាញឱ្យឃើញថា ស្ថានភាពអានុភាពសេដ្ឋកិច្ច EU មានភាពសាំញ៉ាំ ?
4. ចូរបង្ហាញឱ្យឃើញថា "សហភាពអឺរ៉ុបជាមហាអំណាចឧស្សាហកម្មពិភពលោកមួយ"។
5. ចូរបង្ហាញពីលក្ខណៈទំនិយមនៃកសិកម្មអឺរ៉ុប ។
6. ចូរនិយាយពីស្ថានភាពអានុភាពពាណិជ្ជកម្មសហភាពអឺរ៉ុប ។
7. តើ IDE មានន័យពេញលេញជាភាសាជាតិយើងដូចម្តេច ? តើការដៅទីតាំងសម្រាប់ IDE ប្រព្រឹត្តទៅដោយផ្អែកលើកត្តាអ្វីខ្លះ ?
8. តើការដៅទីតាំងសម្រាប់ការរៀបចំលំហសេដ្ឋកិច្ចថ្មី ប្រព្រឹត្តទៅដោយផ្អែកលើកត្តាអ្វីខ្លះ ?
9. ចូរកំណត់ន័យនៃពាក្យ "ព្រំដែនសមាហរ័ណ" និង "ព្រំដែនបញ្ញាសទិស"។

មេរៀនទី

# 3 នានាភាពនៃលំហសេដ្ឋកិច្ចសហភាពអឺរ៉ុប

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីមជ្ឈមណ្ឌលនៃសហភាពអឺរ៉ុប លំហបរិមណ្ឌលអឺរ៉ុបខាងលិច អឺរ៉ុបខាងកើត និងការដ្ឋានដ៏ធំនៃសហភាពអឺរ៉ុប ។

លំហសេដ្ឋកិច្ចអឺរ៉ុបមានទិដ្ឋភាពខុសប្លែកៗគ្នា ។ នានាភាពនេះកើតមានឡើង ដោយសារការអភិវឌ្ឍតាមតំបន់មានកម្រិតមិនស្មើគ្នា ។ វិសមភាពនៃការអភិវឌ្ឍបានបង្កើតឱ្យមានលំហសេដ្ឋកិច្ចផ្សេងៗដូចជា មជ្ឈមណ្ឌលដែលជាបេះដូងអឺរ៉ុប បរិមណ្ឌលនៃអឺរ៉ុបខាងលិច និងលំហដែលកំពុងស្ថិតក្នុងការកសាង(អឺរ៉ុបខាងកើត) ។

## 1. មជ្ឈមណ្ឌលនៃសហភាពអឺរ៉ុប

### 1.1. លំហសេដ្ឋកិច្ចមួយមានភាពផ្ទុយគ្នា

ទោះបីមានកំណើនសមាហរណកម្ម ក៏លំហសេដ្ឋកិច្ចអឺរ៉ុបមានភាពផ្ទុយគ្នាយ៉ាងខ្លាំង ។ លំហទាំងឡាយនៃភាគកណ្តាលសហភាពអឺរ៉ុបទទួលបាននគរូបនីយកម្មខ្លាំងក្លានិងជាតំបន់សំបូរសប្បាយបំផុត ។ តំបន់ដែលទទួលបានភាពអនុគ្រោះខ្សោយស្ថិតនៅមួយផ្នែកតាមបរិមណ្ឌលស្រែចម្ការនៃពិភពអាត្លង់ទិកនិងមេឌីទែរ៉ាណេ និងមួយផ្នែកទៀតនៅតាមបណ្តោយខ្សែកណ្តាលនៃទ្វីបអឺរ៉ុប ។

បន្ទាប់ពីការពង្រីកខ្លួនដ៏ធំមួយកាលពីឆ្នាំ 2004 សហភាពអឺរ៉ុបត្រូវប្រឈមមុខជាថ្មីទៅនឹងបញ្ហាវិសមភាពនៃការអភិវឌ្ឍនៃរដ្ឋសមាជិក ។ នយោបាយសហគមន៍ គឺតម្រង់ទិសទៅរកសមាហរណកម្មប្រកបដោយលំនឹងសេដ្ឋកិច្ចនិងសំដៅកាត់បន្ថយវិសមភាពតំបន់ ។ ប្រវត្តិសាស្ត្រសហភាពអឺរ៉ុបបានបង្ហាញឱ្យឃើញថា រាល់ការពង្រីកខ្លួន តែងមានការខិតខំជំរុញការអភិវឌ្ឍរដ្ឋជាសមាជិកថ្មីៗដែរ ។




*សំណុំសេដ្ឋកិច្ចតំបន់ថ្មីៗនៃសហភាពអឺរ៉ុប*

## 1.2. បេះដូងនៃទ្វីបអឺរ៉ុប

បេះដូង ឬមជ្ឈមណ្ឌលអឺរ៉ុបស្ថិតនៅស្ទើរតែទាំងស្រុងក្នុងសហភាពអឺរ៉ុប លើកលែងតែប្រទេសស្វីសមួយចេញដែលស្ថិតនៅក្រៅ EU ទោះបីប្រទេសនេះជាផ្នែកមួយនៃលំហភូមិសាស្ត្រសេដ្ឋកិច្ចនេះក៏ដោយ ។ បេះដូងនេះផ្អែកលើមេត្រូប៉ូលកម្មយ៉ាងសកម្មមួយនៅក្នុងបណ្ដារដ្ឋអ្នកមានបំផុត មានបេនេលុចនិង អាល្លឺម៉ង់ ។ មជ្ឈមណ្ឌលនេះស្ថិតនៅស្របទៅនឹងភាគខាងជើងនៃទ្រនង់កណ្ដាលអឺរ៉ុប ប៉ុន្តែមិនកំណត់ព្រំប្រទល់ត្រឹមនេះទេ ។ វាបានបន្តជាបណ្ដាញឆ្ពោះទៅតំបន់ក្រុងដូចជា អាងនៃទីក្រុងឡុង ប៉ារីស និងអ៊ីលដឺហ្វ្រង់ ប៊ែឡាំង វីយែន មុយនិក និងភាគខាងជើងប្រទេសអ៊ីតាលី ។

នៅទីនោះរបាយទីក្រុងមានភាពញឹកចម្លែកបង្កើតបានជាប្រព័ន្ធមួយដែលលក្ខណៈសម្បត្តិដ៏ចម្បង គឺលទ្ធភាពចូលទៅដល់ ។ ទីក្រុងប៉ារីស ព្រុចសែល និងអាំស្ទែដាំ សុទ្ធតែជាមេត្រូប៉ូលអឺរ៉ុបដែលមានទីក្រុងមួយចំនួនធំអាចឱ្យគេធ្វើដំណើរត្រឡប់ទៅមកបានក្នុងរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ។

បេះដូងនេះគឺជាមជ្ឈមណ្ឌលផ្សព្វផ្សាយឬទទួលមួយ មានទម្រង់ជាបណ្ដាញទីផ្សារហិរញ្ញវត្ថុដ៏មានអានុភាព។ បណ្ដាញធនាគារនិងទីផ្សារហាងឆេងដ៏ធម្ភែកនេះបានទាក់ទាញទីស្នាក់ការសហគ្រាសអឺរ៉ុបធំៗ។ នៅទីនោះ ពហុជាតិអាចរកបានសេវាហិរញ្ញវត្ថុនិងសេវាគ្រប់គ្រងកម្រិតខ្ពស់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធនៃលទ្ធភាពចូលទៅដល់តាមសេចក្ដីត្រូវការរបស់ខ្លួន។

ទោះបីស្ថិតនៅឆ្ងាយពីគេឯង ក៏តំបន់ទាំងឡាយដូចជា កាតាឡូញ(អេស្ប៉ាញ) ខ្សែកណ្ដាលនៃប្រទេសអ៊ីតាលី និងភូមិភាគខាងត្បូងនៃរដ្ឋប៉ែកឧត្តរបានក្លាយទៅជាតំបន់ដ៏មានអានុភាព។ លំហសេដ្ឋកិច្ចអឺរ៉ុបក៏កាន់តែមានលក្ខណៈពហុប៉ូលខ្លាំងឡើងៗ។

## 1.3. ការពង្រីកចលករនៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចថ្មីមួយ

ការពង្រីកចំនួនសមាជិកកំពុងតែធ្វើឱ្យលំហសេដ្ឋកិច្ចអឺរ៉ុបទទួលបានការផ្លាស់ប្ដូរ ដែលរហូតមកទល់ពេលនេះ បានបែរមករកតំបន់ត្រីកោណ ឡុង-ប៉ារីស-ប្រង់ផត ក្លាយទៅជាលំហាពហុសណ្ឋាន (សំណុំមួយដែលមានតំបន់សេដ្ឋកិច្ចធំៗជាច្រើន)។

ដោយសារសមាហរណកម្មនៃបណ្ដាប្រទេសបាល់ (Pays Baltes) និងមុខឆ្នេរនៃប្រទេសប៉ូឡូញទៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសហ្វាំងឡង់ ស៊ុយអែត និងដាណឺម៉ាក តំបន់ឧត្តរមួយក៏លេចរូបរាងឡើងនៅជុំវិញសមុទ្របាល់ទិក។ រីឯតំបន់កណ្ដាលអឺរ៉ុបមួយក៏ត្រូវបានបង្កើតឡើងនៅជុំវិញប្រទេសអាល្លឺម៉ង់និងអូទ្រីស រួមមានប្រទេសប៉ូឡូញ សាធារណរដ្ឋឆែក ស្លូវ៉ាគី ហុងគ្រី និងស្លូវេនីដោយផ្នែក។ នៅទីនោះគេសង្កេតឃើញមានទ្វេអ័ក្សអភិវឌ្ឍមួយ ដែលមួយផ្នែកឆ្ពោះទៅតំបន់បាល់កង់ (Balkans) តាមទិសដៅប្រទេសតួកគី និងមួយផ្នែកទៀតឆ្ពោះទៅប្រទេសរុស្ស៊ី កាត់តាមប្រទេសប៉ូឡូញ។ អ័ក្សទាំងពីរនេះបែកចេញពីគ្នានៅក្នុងប្រទេសអាល្លឺម៉ង់ ត្រង់រយៈទទឹងនៃទីក្រុងប្រង់ផត។

# 2. លំហបរិមណ្ឌលនៃអឺរ៉ុបខាងលិច

## 2.1. បរិមណ្ឌលដែលធ្វើសមាហរណកម្ម

បរិមណ្ឌលដែលធ្វើសមាហរណកម្ម រួមមានមួយភាគធំនៃទឹកដីរបស់រដ្ឋទាំងឡាយដែលមានចំណងរឹងមាំមួយនៅក្នុងមជ្ឈមណ្ឌល ឬបេះដូងអឺរ៉ុប។ បន្ថែមពីលើនេះ មានមជ្ឈមណ្ឌលសំខាន់ៗរបស់រដ្ឋដែលមានការអភិវឌ្ឍខ្សោយ ជាពិសេសគឺជាធានីនៃរដ្ឋ។ តំបន់ទាំងនោះស្ថិតនៅក្នុងស្ថានភាពរណបមួយ ដែលជាសំខាន់ភាពរណបទៅលើផ្នែកនៃការធ្វើសេចក្ដីសម្រេចនិងការធ្វើវិនិយោគ។

មុខឆ្នេរមេឌីទែរ៉ាណេមួយភាគធំស្ថិតក្នុងស្ថានភាពមួយប្រហាក់ប្រហែលគ្នានិងប៉ូលកម្មដ៏សកម្មដែលមាននៅជុំវិញទីក្រុងម៉ាឌ្រីត បាសឺឡូន ឬរ៉ូម។ សព្វថ្ងៃអង់ដាលូស៊ី(អេស្ប៉ាញ) ជាតំបន់មួយកំពុងមានសន្ទុះដោយសារផលិតកម្មកសិកម្មបែបឯកទេសកម្ម(ដំណាំបន្លែបែបអតិផល) ត្រូវបាននាំ

ចេញទៅពាសពេញទ្វីបអឺរ៉ុប ។ អៀរឡង់ជាករណីមួយទៀតនៃបរិមណ្ឌល ដែលបញ្ចូលជាឧបសម្ព័ន្ធ ទទួលបានការរីកចម្រើនយ៉ាងពិសេស ។ សេដ្ឋកិច្ចអៀរឡង់បានក្លាយទៅជាសេដ្ឋកិច្ចបើកចំហខ្លាំងបំផុតមួយទៅរកពិភពលោក ដោយសារតែការខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការទាក់ទាញមូលធនពីបរទេសនិងដោយសារជម្រើសអភិវឌ្ឍន៍មួយដែលផ្តល់អាទិភាពខ្ពស់ទៅលើផ្នែកដំឡើងឧបករណ៍អេឡិចត្រូនិក ។

## 2.2. បរិមណ្ឌលដាច់ស្រយាល ឬនៅតាមចន្លោះៗ

លំហដែលជួបការលំបាកក្នុងការអភិវឌ្ឍ មានច្រើនករណីដូចតទៅនេះ

- ភាគខាងកើតប្រទេសអាល្លឺម៉ង់ ស្ថិតនៅក្នុងអន្តរភាពនៅឡើយ ហើយបានរៀបចំរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញទាំងស្រុងតាមរយៈការបន្ថយទម្ងន់កសិកម្ម ការកាត់បន្ថយឧស្សាហូបនីយកម្ម(សមាមាត្រការងារ GDP ឬឧស្សាហកម្ម)និងការបង្កើនសកម្មភាពផ្នែកទីបី(សេវា) ។
- តំបន់មេសូ្សជោណូ(អ៊ីតាលី) ក្លាយទៅជាកម្មវត្ថុនៃនយោបាយរៀបចំដែនដីមុនកាលកំណត់និងប្រកបដោយឆន្ទនិយមមួយ ដែលប្រើប្រាស់ជាបឋមនូវវិនិយោគទុនរបស់ជាតិ បន្ទាប់មករបស់សហគមន៍ ។ ការផុសឡើងនៃប៉ូលកំណើនក៏កើតមានឡើងជាបន្ត ដោយយកជា គោល គឺការតាំងទីឧស្សាហកម្មរថយន្តនៅកន្លែងថ្មីនិងឧស្សាហកម្មដែកនៅតាមតំបន់ឆ្នេរ ជាពិសេសនៅតារ៉ង់(Tarente) ។ បច្ចុប្បន្នភាពខុសគ្នារវាងភាគខាងជើងនិងភាគខាងត្បូងត្រូវបានកាត់បន្ថយតែមិនទាន់បំបាត់បានទាំងស្រុងនៅឡើយទេ ។
- លើកលែងតែរាជធានីម៉ាឌ្រីតចេញ ប៉ែកខាងក្នុងប្រទេសអេស្ប៉ាញមានការថយចុះចំនួនប្រជាជន ជាពិសេសនៅអេសត្រេម៉ាឌួនិងនៅខ្ពង់រាបខ្ពស់នៃតំបន់កាស្ទីល ។ ស្ថានភាពបែបនេះគេឃើញមាននៅតាមកោះមួយចំនួនធំនៃសមុទ្រមេឌីទែរ៉ាណេ នៅភាគខ្លះនៃប្រទេសក្រិកនិងភាគខាងក្នុងប្រទេសព័រទុយហ្កាល់ ។ តំបន់ទាំងនោះបានរក្សាទុកមូលដ្ឋានកសិកម្មសំខាន់ៗទោះបីនៅគ្រប់ទីកន្លែងសាខាកសិកម្មមានការថយចុះសកម្មភាពក៏ដោយ ។
- តំបន់ឧស្សាហកម្មចាស់ៗដែលផ្អែកលើសកម្មភាពរ៉ែនិងឧស្សាហកម្មស្ទើរតែទាំងស្រុងនោះជួបការលំបាកក្នុងការរៀបចំសេដ្ឋកិច្ចខ្លួនឡើងវិញ ។ អាងធ្យូងថ្មដែលរួមបញ្ចូលជាមួយឧស្សាហកម្មដែក ឬលោហៈកម្មធុនធ្ងន់អាចយកជាឧទាហរណ៍គំរូដូចជា ឡេនខេសាយ(Lan cashire)នាភាគកណ្តាលអង់គ្លេស ។

- បរិមណ្ឌលភាគខាងជើងអឺរ៉ុប(ភូមិភាគខាងជើងប្រទេសស៊ុយអែតនិងតំបន់ឡាប៉ូនី ហ្វាំងឡង់) ដែលមានលក្ខខណ្ឌជីវសាស្ត្រអាកាសធាតុហួសហេតុ អាចរាប់បញ្ចូលបានថា ជាបរិមណ្ឌលដាច់ស្រយាលដោយសារវត្តមាននៃលំហដ៏ធំធេង ឱ្យត់មនុស្សរស់នៅ ។
- ជារួមគម្លាតសំខាន់ៗនៅតែមានអត្ថិភាពនៅឡើយ ប៉ុន្តែភាពខុសគ្នាផ្នែកសេដ្ឋកិច្ចរវាងរដ្ឋអឺរ៉ុបទាំងឡាយនៅប៉ែកខាងលិច មានទំនោរដូចៗគ្នាទៅរកការថយចុះ ដោយសារមានមូលនិធិគម្រោងរបស់សហភាពអឺរ៉ុបជាឃ្លាស់ដ៏មានប្រសិទ្ធភាព ។

# ៣. ភាគខាងកើត ការដ្ឋានដ៏ធំរបស់សហភាពអឺរ៉ុប

## ៣.១. សហភាពអឺរ៉ុបរីកកាន់តែធំ

កាលពីខែឧសភាឆ្នាំ 2004 ប្រទេសចំនួនដប់នៃអឺរ៉ុបកណ្តាលនិងខាងកើត(PECO) បានចូលជាសមាជិករបស់ EU ។ ការបញ្ចូលនេះបានបើកការដ្ឋានភូមិសាស្ត្រសេដ្ឋកិច្ចមួយដ៏ធំចំឡែក ។ ខុសគ្នាពីការពង្រីកមុនៗ ដោយហេតុថាសមាជិកថ្មីទាំងនោះ ភាគច្រើនជាប្រទេសដែលស្ថិតក្នុងអន្តរភាពសេដ្ឋកិច្ចនៅឡើយ ។ គម្លាតនៃការអភិវឌ្ឍរវាងរដ្ឋដែលជាសមាជិកចាស់និងថ្មីមានធំធេងណាស់ ។

រចនាសម្ព័ន្ធសេដ្ឋកិច្ចនៃលំហថ្មីនេះខុសគ្នាយ៉ាងច្បាស់ពីតំបន់ដទៃទៀតរបស់សហភាព ព្រោះថាផ្នែកទីមួយប្រើប្រាស់កម្លាំងពលកម្មដល់ទៅ 22%នៃប្រជាជនសកម្ម ផ្នែកទីពីរ 33%និងផ្នែកទីបី 47% (មិនច្បាស់លាស់) ។ កសិកររបស់រដ្ឋសមាជិកថ្មីៗទាំងនោះ ស្ថិតនៅឆ្ងាយពីសមិទ្ធផលដែលសម្រេចបានដោយកសិករនៅទីជនបទនៃអឺរ៉ុបខាងលិច ។ ជារឿយៗ កសិកម្មមានលក្ខណៈជាអាជីវកម្មចុនតូចតាចដែលផ្តល់ផលិតផលតិច ប្រើប្រាស់កម្លាំងពលកម្មច្រើន ដូចជានៅប្រទេសប៉ូឡូញជាដើម ។

## ៣.២. ផលប៉ះពាល់បែបភូមិសាស្ត្រនៃអន្តរភាពសេដ្ឋកិច្ច

នៅបណ្តាប្រទេសអឺរ៉ុបកណ្តាលនិងខាងកើត អន្តរភាពសេដ្ឋកិច្ចយ៉ាងស៊ីជម្រៅមួយកំពុងតែប្រព្រឹត្តទៅ ហើយតម្រង់ទិសទៅរកការអនុវត្តសេដ្ឋកិច្ចទីផ្សារ ការរៀបចំឡើងវិញនូវទម្រង់ប្រព័ន្ធផលិតកម្មការបើកចំហផ្នែកពាណិជ្ជកម្មនិងហិរញ្ញវត្ថុ ។

យថាទស្សន៍សម្រាប់មនុស្ស 100 លាននាក់ ជាបន្ថែមនិងការគិតទុកថា ធ្វើយ៉ាងណាតាមឱ្យទាន់កម្រិតជីវភាពនៅអឺរ៉ុបខាងលិច បានបំផុសក្រុមហ៊ុនធំៗក្នុងពិភពលោកឱ្យមានការចាប់អារម្មណ៍ក្នុងការធ្វើវិនិយោគ ។ ជាបឋមនៅអឺរ៉ុបខាងលិច រួមទាំងសហគ្រាសតូចនិងមធ្យមជាច្រើនផងដែរ ឱ្យចូលមករកស៊ីនៅ PECO ។ អ្នកទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចរបស់ PECO បានខិតខំទាក់ទាញវិនិយោគពីខាងក្រៅមកក្នុងទឹកដីរបស់ខ្លួន ។

រដ្ឋទាំងនោះមានកម្រិតរីកចម្រើនខុសៗគ្នា ហើយបើគិតតាមក្របខ័ណ្ឌតំបន់វិញ ភាពខុសប្លែកគ្នាមានទំនោរទៅរកការកើនឡើង ។ ធានីជាតិនិងតំបន់ក្បែរបេះដូងនៃ EU បានបង្វិលវិនិយោគទៅកាន់ប្រទេសនានា ពិសេសទៅតំបន់ជួបវិបត្តិ ។ ផ្នែកដែលទទួលបាននវកម្មមានលក្ខណៈផ្ទុយពីផ្នែកដែលមិនទាន់ទទួលបានការផ្សាំខ្លួន ដូចជាឧស្សាហកម្មធុនធ្ងន់ ឬក៏កសិកម្ម ។ វិធីជ្រើសរើសត្រឹមត្រូវបំផុតនៃ IDE បានបែងចែកលំហសេដ្ឋកិច្ចអឺរ៉ុប ។

## ៣.៣. សមាហរណកម្មសេដ្ឋកិច្ចនៃសហភាពអឺរ៉ុប

ទិសដៅរួមនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់រដ្ឋសមាជិកថ្មីទាំងឡាយនិងត្រូវការពេលវេលាពីរ ឬបីទសវត្សរ៍ ។ ផលអវិជ្ជមានក៏កើតមានពីការដាក់ឱ្យប្រទេសទាំងនោះស្ថិតក្នុងភាពរណបផ្នែកសេដ្ឋកិច្ចយូរពេលពេកនិងពីការដែលទុកឱ្យសហភាពអឺរ៉ុបស្ថិតក្នុងការបែងចែកជាបីតំបន់ គឺអឺរ៉ុបមួយដ៏សំបូរសប្បាយ (មជ្ឈមណ្ឌលដើមដំបូងនៃអឺរ៉ុបដប់ពីរ) អឺរ៉ុបមួយរីកចម្រើនជាមធ្យម និងអឺរ៉ុបមួយនៅក្រីក្រនៅឡើយ ។

ចាប់ពីពេលមានការធ្លាក់ចុះនៃប្លុកកុម្មុយនិស្តនិងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ 1990 សហគមន៍អឺរ៉ុបបានផ្ដល់មូលនិធិថវិកាយ៉ាងច្រើនជួយដល់អន្តរភាពសេដ្ឋកិច្ច ។ បណ្ដាញដឹកជញ្ជូនថ្មីៗដែលភ្ជាប់ទំនាក់ទំនងភាគខាងលិចទៅភាគខាងកើតអឺរ៉ុប ត្រូវបានផ្ដល់ហិរញ្ញវត្ថុដោយសហភាពអឺរ៉ុប ។ ចំណែកលំហរដ្ឋសមាជិកថ្មីៗក៏បង្កើតបានជា "ព្រំដែនថ្មី" របស់សហភាពអឺរ៉ុបដែរ ។

## ? សំណួរ

1. តើលំហសេដ្ឋកិច្ចអឺរ៉ុបមានភាពផ្ទុយគ្នាយ៉ាងដូចម្ដេចខ្លះ ?
2. ចូរកំណត់ន័យនៃពាក្យ "បេះដូងនៃទ្វីបអឺរ៉ុប" ។ តើពាក្យនេះមានលក្ខណៈដូចម្ដេចខ្លះ ?
3. តើ "តំបន់ត្រីកោណអឺរ៉ុប" រួមមានទីក្រុងណាខ្លះ ?
4. តើ "តំបន់ឧត្តរមួយ" នៃលំហសេដ្ឋកិច្ចអឺរ៉ុប កកើតឡើងយ៉ាងដូចម្ដេច ?
5. តើ "តំបន់កណ្ដាលមួយ" នៃលំហសេដ្ឋកិច្ចអឺរ៉ុបរួមមានប្រទេសណាខ្លះ ?
6. តើតំបន់ណាខ្លះនៃទ្វីបអឺរ៉ុប ដែលត្រូវបានចាត់ទុកថាជា "បរិមណ្ឌល" ?
7. តើតំបន់ណាខ្លះនៃទ្វីបអឺរ៉ុប ដែលអាចចាត់ទុកថាជាតំបន់ដាច់ស្រយាល ឬតំបន់ជាចន្លោះៗ ?

## ? សំណួរបញ្ចប់ជំពូកទី៨

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. សហភាពអឺរ៉ុបមានប្រភពកំណើតចេញពីអង្គការ

☐ក. CECA ☐ខ. CEE ☐គ. BERD ☐ឃ. AELE

2. អង្គការនីតិប្បញ្ញត្តិរបស់សហភាពអឺរ៉ុបមានទីតាំងនៅ

☐ក. លុចសំបួ ☐ខ. ឡុង ☐គ. ស្ត្រាសបួ ☐ឃ. ព្រុចសែល

3. ប្រទេសមួយដែលប្រើប្រាស់ប្រាក់អឺរ៉ូគឺ

☐ក. រាជាណាចក្ររួម ☐ខ. ស្វីស ☐គ. អេស្ប៉ាញ ☐ឃ. ន័រវែស

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ពហុកោណអឺរ៉ុបជាតំបន់មួយនៃសហភាពអឺរ៉ុប ដែលសម្រេចបាន 2/3 នៃ .......................... របស់សហភាព ។

2. ទ្រីយ៉ាតជាប៉ូលសេដ្ឋកិច្ចពិភពលោកទាំងបី មានសហរដ្ឋអាមេរិក ......................និងជប៉ុន ។

3. តំបន់កសិកម្មគ្រឹះរបស់សហភាពអឺរ៉ុប ស្ថិតនៅ ............................... ។

4. អនុសញ្ញាឡូមេឆ្នាំ 1975 ផ្ដោតទៅលើ ..........................ជាមួយបណ្ដាប្រទេស ACP ។

III. ចូរឆ្លើយសំណួរខាងក្រោម

1. តើ "សហភាពអឺរ៉ុប" ជាអ្វី ? ចូររៀបរាប់អំពីគោលការណ៍សំខាន់ទាំងបួនរបស់សហភាពអឺរ៉ុប ។

2. ស្ថានភាពអានុភាពសេដ្ឋកិច្ច EU មានភាពសាំញ៉ាំជាងប៉ូលទាំងពីរទៀតនៃ "ទ្រីយ៉ាត" ។ ចូរពន្យល់អំណះអំណាងនេះ ។

3. តើអង្គការសេដ្ឋកិច្ចសំខាន់នៅទ្វីបអឺរ៉ុបមានអ្វីខ្លះ ? ចូររៀបរាប់ ។

4. តើសហភាពអឺរ៉ុបជាមហាអំណាចលើផ្នែកអ្វីខ្លះ ?

5. តើ "ពហុកោណអឺរ៉ុប" មានទីក្រុងសំខាន់ៗអ្វីខ្លះ ? ចុះ "តំបន់ត្រីកោណអឺរ៉ុប" មានទីក្រុងណាខ្លះដែរ ?